# បដិច្ចសមុប្បាទ




ប្រែសម្រួលដោយ

ភិក្ខុសីលសំវរោ ស៊ុំ សាមុត

សម្រាប់ជាធម្មទាន

# បដិច្ចសមុប្បាទទីបនី
# និង
# បច្ច័យ ២៤ ដោយសង្ខេប

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អភិធម្មត្ថសង្គហបាលី និង ពាក្យប្រែ

## ពាក្យបដិញ្ញារបស់ព្រះអនុរុទ្ធាចារ្យ

១. យេសំ សង្ខតធម្មានំ យេ ធម្មា បច្ចយា យថា
តំ វិភាគមិហេទានិ បវក្ខាមិ យថារហំ។

ឥឡូវនេះ ខ្ញុំព្រះអង្គនឹងពោលនូវការចែកធមិទាំងឡាយ ដែលជាបច្ច័យដល់ធមិដែលជាសង្ខតៈទាំងឡាយ ដោយអាការដែលប្រព្រឹត្តទៅបាន ក្នុងបច្ច័យសង្គហៈនេះ តាមសមគួរ ។

## បច្ច័យសង្គហៈមាន ២ ន័យ

## និងភាពផ្សេងគ្នារបស់ន័យទាំងពីរ

២. បដិច្ចសមុប្បាទនយោ បដ្ឋាននយោ ចេតិ បច្ចយសង្គហោ ទុវិធោ វេទិតព្វោ ។ តត្ថ តព្ភាវភាវីភាវាការមត្តោបលក្ខិតោ បដិច្ចសមុប្បាទនយោ បដ្ឋាននយោ បន អាហច្ចបច្ចយឋិតិមារព្ភ-បវុច្ចតិ, ឧភយំ បន វោមិស្សិត្វា បបញ្ចេន្តិ អាចរិយា។

អ្នកសិក្សាទាំងឡាយគប្បីជ្រាបថា បច្ច័យសង្គហៈនេះ មានន័យពីរយ៉ាងគឺ បដិច្ចសមុប្បាទន័យ ១ និងបដ្ឋានន័យ ១ ។

បណ្ដាន័យទាំងពីរនោះ ន័យដែលព្រះមានព្រះភាគកំណត់ទុកដោយអាការៈប្រព្រឹត្តទៅរបស់បច្ចយុប្បន្នធម៌ មានសង្ខារជាដើម ដែលមានសភាពកើតឡើងជាធម្មតា ព្រោះអាស្រ័យការកើតឡើងរបស់បច្ច័យធម៌នោះៗ មានអវិជ្ជាជាដើម ឈ្មោះថា **បដិច្ចសមុប្បាទន័យ** ។

ឯបដ្ឋានន័យនោះ ព្រះមានព្រះភាគទ្រង់ប្រារព្ធនូវអំណាចរបស់បច្ច័យដែលពិសេស ។

ចំណែកព្រះអដ្ឋកថាចារ្យទាំងឡាយ បានរួបរួមន័យទាំងពីរនេះបញ្ចូលគ្នា ហើយក៏សម្ដែងដោយពិស្ដារ ។

## បច្ច័យ និង បច្ចយុប្បន្នធម៌

**៣.អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ (កើតមាន) ព្រោះបច្ច័យ គឺ អវិជ្ជា ពោលគឺសេចក្ដីល្ងង់ ។

## តាមបដិច្ចសមុប្បាទន័យ

**សង្ខារប្បច្ចយា វិញ្ញាណំ** វិញ្ញាណ (កើតមាន) ព្រោះបច្ច័យ គឺ សង្ខារ ។

**វិញ្ញាណប្បច្ចយា នាមរូបំ** នាមនិងរូប (កើតមាន) ព្រោះបច្ច័យ គឺ វិញ្ញាណ ។

**នាមរូបប្បច្ចយា សឡាយតនំ** អាយតនៈ (កើតមាន) ព្រោះបច្ច័យ គឺ នាមនិងរូប ។

**សឡាយតនប្បច្ចយា ផស្សោ** សម្ផស្ស (កើតមាន) ព្រោះ បច្ច័យ គឺ អាយតនៈ ៦ ។

**ផស្សប្បច្ចយា វេទនា** វេទនា (កើតមាន) ព្រោះបច្ច័យ គឺ សម្ផស្ស ។

**វេទនាបច្ចយា តណ្ហា** តណ្ហា (កើតមាន) ព្រោះបច្ច័យ គឺ វេទនា ។

**តណ្ហាប្បច្ចយា ឧបាទានំ** ឧបាទាន (កើតមាន) ព្រោះបច្ច័យ គឺ តណ្ហា ។

**ឧបាទានប្បច្ចយា ភវោ** ភព (កើតមាន) ព្រោះបច្ច័យ គឺ ឧបាទាន ។

**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យ គឺ ភព ។

**ជាតិប្បច្ចយា ជរាមរណំ** ជរានិងមរណៈ (កើតមាន) ព្រោះ បច្ច័យ គឺ ជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** កិរិយាកើតមាននៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ ។

## ន័យរបស់បដិច្ចសមុប្បាទ ៧ យ៉ាង

**៤. តត្ថ តយោ អទ្ធា ទ្វាទសង្គានិ វីសតាការា តិសន្ធិ ចតុសង្ខេបា តីណិ វដ្តានិ ទ្វេ មូលានិ ច វេទិតព្វានិ។**

ក្នុងបដិច្ចសមុប្បាទធម៌នោះ អ្នកសិក្សាទាំងឡាយគប្បីជ្រាបនូវ អទ្ធា ៣ អង្គ ១២ អាការៈ ២០ សន្ធិ ៣ សង្ខេប ៤ វដ្តៈ ៣ មូល ២ ។

## អទ្ធា (កាល) ៣

**៥. កថំ អវិជ្ជា សង្ខារា អតីតោ អទ្ធា, ជាតិ ជរាមរណំ អនាគតោ អទ្ធា, មជ្ឈេ អដ្ឋ បច្ចុប្បន្នោ អទ្ធាតិ តយោ អទ្ធា។**

តើគប្បីជ្រាបយ៉ាងណា? គប្បីជ្រាបនូវកាល ៣ យ៉ាងនេះ គឺៈ

អវិជ្ជា និងសង្ខារ (ទាំងពីរនេះ) ជាអតីតអទ្ធា (គឺជាធម៌ដែលកើតក្នុងភពមុនៗ) ។

ជាតិ ជរា និងមរណៈ (ទាំងបីនេះ) ជាអនាគតអទ្ធា (គឺជាធម៌ដែលកើតក្នុងភពខាងមុខ) ។

អង្គធម៌ ៨ នៅត្រង់កណ្តាល (មានវិញ្ញាណជាដើម) មានភពជាទីបំផុត ជាបច្ចុប្បន្នអទ្ធា (គឺជាធម៌ដែលកើតក្នុងភពនេះឯង) ។

## អង្គ ១២

**៦. អវិជ្ជា សង្ខារា វិញ្ញាណំ នាមរូបំ សឡាយតនំ ផស្សោ វេទនា តណ្ហា ឧបាទានំ ភវោ ជាតិ ជរាមរណន្តិ ទ្វាទសង្គានិ ។**

គប្បីជ្រាបអង្គ ១២ ដូច្នេះ គឺៈ

អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ និងជរាមរណៈ ។

**៧. សោកាទិវចនំ បនេត្ថ និស្សន្ទផលនិទស្សនំ ។**

ក្នុងព្រះបាលីនេះ ពាក្យថា សោកៈ ជាដើម ជាការសម្តែងឱ្យដឹងដល់ផលដែលជានិស្សន្ទផល គឺជាផលដែលជាប់ទាក់ទងអំពីជាតិតែប៉ុណ្ណោះ មិនមែនជាអង្គដោយចំពោះ ។

**អាការៈ ២០ សន្ធិ ៣ សង្ខេប ៤**

៨. អវិជ្ជាសង្ខារគ្គហណេន បនេត្ថ តណ្ហុបាទានភវាបិ គហិតា ភវន្តិ តថា តណ្ហុបាទានភវគ្គហណេន ច អវិជ្ជាសង្ខារា ជាតិជរាមរណគ្គហណេន ច វិញ្ញាណាទិផលបញ្ចកមេវ គហិតន្តិ កត្វា ។

អតីតេ ហេតវោ បញ្ច　　ឥទានិ ផលបញ្ចកំ
ឥទានិ ហេតវោ បញ្ច　　អាយតឹ ផលបញ្ចកន្តិ
វីសតាការា តិសន្ធិ　　ចតុសង្ខេបា ច ភវន្តិ ។

ក្នុងអទ្ធា ៣ នោះ ដោយលើកយក អវិជ្ជា និងសង្ខារឡើងមកសម្តែងហើយ សូម្បីតណ្ហា ឧបាទាន កម្មភព ទាំង ៣ នេះ ក៏គប្បីរាប់បញ្ចូលក្នុងអតីតអទ្ធាផងដែរ ។

ដោយការលើកយកតណ្ហា ឧបាទាន កម្មភព ឡើងមកសម្តែង ហើយអវិជ្ជា សង្ខារ ទាំងពីរនេះ ក៏គប្បីរាប់បញ្ចូលក្នុងបច្ចុប្បន្នអទ្ធាផងដែរ ។

ដោយលើកយក ជាតិ ជរា មរណៈ ឡើងមកសម្តែងហើយ ផលទាំង ៥ យ៉ាង គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ក៏គប្បីរាប់បញ្ចូលក្នុងអនាគតអទ្ធាផងដែរ ។

ធម៌ទាំងនោះប្រព្រឹត្តទៅដូច្នេះ គឺៈ

ហេតុក្នុងអតីតភពមាន ៥ គឺ អវិជ្ជា សង្ខារ តណ្ហា ឧបាទាន និងកម្មភព ។

ផលក្នុងបច្ចុប្បន្នភពមាន ៥ គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ។

ហេតុក្នុងបច្ចុប្បន្នភពមាន ៥ គឺ តណ្ហា ឧបាទាន កម្មភព អវិជ្ជា និងសង្ខារ ។

ផលក្នុងអនាគតភពមាន ៥ គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ។

## វដ្ដៈ ៣ មូល ២

៩. អវិជ្ជាតណ្ហុបាទានា ច កិលេសវដ្ដំ កម្មភវសង្ខាតោ ភវេកទេសោ សង្ខារា ច កម្មវដ្ដំ ឧប្បត្តិភវសង្ខាតោ ភវេកទេសោ អវសេសា ច វិបាកវដ្ដន្តិ តីណិ វដ្ដានិ ។

អវិជ្ជាតណ្ហាវសេន ទ្វេ មូលានិ ច វេទិតព្វានិ ។

វដ្ដៈ ៣ គប្បីជ្រាបដូច្នេះ

អវិជ្ជា តណ្ហា ឧបាទាន ទាំងបីនេះជាកិលេសវដ្ដៈ ចំណែកភវៈមួយ គឺកម្មភវៈនិងសង្ខារទាំងនេះជាកម្មវដ្ដៈ ចំណែកភវៈមួយទៀតគឺ ឧប្បត្តិ-ភវៈ និងវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជរាមរណៈទាំងនេះជាវិបាកវដ្ដៈ ។

ចំណែកមូល២នោះសំដៅយកអវិជ្ជានិងតណ្ហានោះឯង

### ការសង្គ្រោះក្នុងវដ្ដៈ ៣ និងសមុដ្ឋានរបស់អវិជ្ជា

១០_តេសមេវ ច មូលានំ និរោធេន និរុជ្ឈតិ

ជរាមរណមុច្ឆាយ បីឡិតានមភិណ្ហសោ

អាសវានំ សមុប្បាទា អវិជ្ជា ច បវត្តតិ។

កាលវដ្ដមូលទាំង២នោះ រលត់ឥតមានសេសសល់ដោយអំណាចនៃអរហត្តមគ្គហើយ ការវិលវល់នៃបដិច្ចសមុប្បាទគឺវដ្ដៈ ទាំង៣

ក៏រលត់មួយរំពេចនោះ អវិជ្ជាកើតឡើងបានក៏ព្រោះ អាស្រ័យការកើតឡើងនៃអាសវៈធម៌ ដែលមានក្នុងសន្តានរបស់សត្វទាំងឡាយ អ្នកត្រូវបៀតបៀនដោយការចាស់ព្រមទាំងសេចក្តីស្លាប់ និងធម៌ដែលជាហេតុនៃសេចក្តីវង្វេងគឺសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈជារឿយ ៗ នោះឯង។

## គាថាចុងក្រោយ

វដ្តមាពន្ធមិច្ចេវំ តេភូមកមនាទិកំ

បដិច្ចសមុប្បាទោតិ បដ្ឋបេសិ មហាមុនិ ។

ការវិលវល់នៃវដ្តៈទាំង៣នេះ បើញែកចេញពីគ្នាមិនបានឡើយនៅក្នុងភូមិ៣ ជាធម្មជាតិរកខាងដើមមិនបាន ព្រះអង្គជាមហាមុនីរមែងត្រាស់ទុកថា **បដិច្ចសមុប្បាទ** ដូច្នោះ។

## អធិប្បាយឧបការៈរវាងបច្ច័យ និង បច្ចយុប្បន្ន តាមន័យនៃបដិច្ចសមុប្បាទដោយពិស្តារ

១-អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ ។

សង្ខារទាំង ៣ រមែងប្រាកដកើតឡើង ព្រោះអាស្រ័យអវិជ្ជាជាហេតុ ពាក្យថា **អវិជ្ជា** មកពី **អ+វិជ្ជា**

**អ** ប្រែថា មិន ឬ ផ្ទុយគ្នា

**វិជ្ជា** ប្រែថា ដឹង ឬ បញ្ញា

បើរួមចូលគ្នាប្រែថា មិនដឹង ឬ ធម្មជាតិដែលប្រព្រឹត្តទៅផ្ទុយគ្នាជាមួយនឹងបញ្ញា បានដល់ មោហចេតសិក មានវចនត្ថៈថា

**ចតុសច្ចធម្មំ វិទតិ បាកដំ ករោតីតិ = វិជ្ជា**

ធម្មជាតិណាជាអ្នកដឹងច្បាស់នូវអរិយសច្ចៈ ៤ និងជាអ្នកធ្វើឱ្យអរិយសច្ចៈ ៤ ប្រាកដឡើង ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា វិជ្ជា បានដល់ បញ្ញាចេតសិក ។

**វិជ្ជា បដិបក្ខាតិ = អវិជ្ជា**

ធម្មជាតិណាដែលប្រព្រឹត្តទៅផ្ទុយគ្នាជាមួយនឹងបញ្ញា ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា អវិជ្ជា ឬ **អវិន្ទិយំ វិន្ទតីតិ = អវិជ្ជា** ធម្មជាតិណារមែងបាននូវទុច្ចរិតធម៌ដែលមិនគួរបាន ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា អវិជ្ជា ឬ **វិន្ទិយំ ន វិន្ទតិ=អវិជ្ជា** ធម្មជាតិណាដែលរមែងមិនឱ្យបាននូវសុចរិតធម៌ដែលគួរបាន ព្រោះហេតុនោះធម្មជាតិនោះឈ្មោះថា អវិជ្ជា ឬ **អវិជ្ជមានេ ជវាបេតីតិ = អវិជ្ជា** ធម្មជាតិណាដែលជាអ្នកដឹងខុសក្នុងបញ្ញត្តិធម៌ មានប្រុស ស្រី ជាដើម ដែលមិនមានប្រាកដដោយសភាវៈ ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា អវិជ្ជា ឬ **វិជ្ជមានេ ន ជវាបេតីតិ = អវិជ្ជា**

ធម្មជាតិណាដែលជាអ្នកមិនឱ្យដឹងក្នុងបរមត្ថធម៌ មានខន្ធជាដើម ដែលប្រាកដដោយសភាវៈ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ឬ **វិទិតព្វំ អវិទិតំ ករោតីតិ = អវិជ្ជា** ធម្មជាតិណាដែលមិនឱ្យដឹងនូវធម៌ដែលគួរដឹង មានអរិយសច្ចៈ ៤ ជាដើម ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា អវិជ្ជា ។ អវិជ្ជាទាំងអស់នេះ បានដល់ មោហ-ចេតសិក ។

សម្រុបសេចក្តីថាការមិនដឹងតាមសេចក្តីពិតដែលគួរដឹង ដឹងតែវត្ថុដែលមិនប្រព្រឹត្តទៅតាមសេចក្តីពិតដែលមិនគួរដឹង នេះឯង ឈ្មោះថា **អវិជ្ជា**។

## ការមិនដឹងតាមសេចក្តីពិតរបស់អវិជ្ជាមាន ៨ ប្រការ

**១.ទុក្ខេ អញ្ញាណំ** មិនដឹងក្នុងទុក្ខ

**២.ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងហេតុដែលនាំឱ្យកើតទុក្ខ

**៣.ទុក្ខនិរោធេ អញ្ញាណំ** មិនដឹងធម៌ដែលជាទីរលត់នៃទុក្ខ

**៤.ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** មិនដឹងផ្លូវដែលជាទីឱ្យចូលដល់ការរលត់ទុក្ខ ។

**៥.បុព្វន្តេ អញ្ញាណំ** ការមិនដឹងក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអតីតៈ ។

**៦.អបរន្តេ អញ្ញាណំ** ការមិនដឹងក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអនាគត ។

**៧.បុព្វន្តាបរន្តេ អញ្ញាណំ** ការមិនដឹងក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអតីតៈ និងអនាគត ។

**៨.ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** ការមិនដឹងក្នុងនាមរូបដែលកើតឡើង ដោយអាស្រ័យមានហេតុនាំឱ្យកើតឡើងក្នុងបដិច្ចសមុប្បាទ ។

## ១.ការមិនដឹងក្នុងទុក្ខ (ទុក្ខេ អញ្ញាណំ)

តាមធម្មតាសត្វទាំងឡាយដែលកើតនៅក្នុងលោកនេះ មិនថាអ្នកណាៗ ត្រូវបានប្រសព្វនឹងការចាស់ ការឈឺ ការស្លាប់ សេចក្ដីសោកសៅខ្លួចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ការព្រាត់ប្រាសចាកវត្ថុដែលជាទីស្រលាញ់ ការបានជួបប្រសព្វនឹងវត្ថុដែលមិនជាទីស្រលាញ់ពេញចិត្ត ការមិនសម្រេចតាមសេចក្ដីប្រាថ្នា ការចង្អៀតចង្អល់ចិត្តជាដើមទាំងនេះ សុទ្ធតែជាសេចក្ដីទុក្ខទាំងអស់ មិនងាយនឹងអ្នកណាជៀសឱ្យផុតបានទេ ត្រូវបានទទួលតិចច្រើនតាមសមគួរដល់ឋានៈរបស់ខ្លួន ប៉ុន្តែបណ្ដាទុក្ខផ្សេងៗ ទាំងឡាយនេះ ការកើតនិងការស្លាប់ទាំង ២ នេះជាទុក្ខយ៉ាងពិតប្រាកដ មិនមានការលើកលែង

ដល់បុគ្គលណាមួយឡើយ ។ សូម្បីកើតជាអ្នកខ្ពង់ខ្ពស់ ថោកទាប ឬ កើតជាទេវតា មារ ព្រហ្មក៏ដោយ ត្រូវបានជួបដូចគ្នាទាំងអស់ ។ ចំពោះការចាស់ ការឈឺ សេចក្ដីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស ការព្រាត់ប្រាស់ចាកវត្ថុដែលជាទីស្រលាញ់ ការបានជួបនូវវត្ថុដែលមិនជាទីស្រលាញ់ ការមិនបានសម្រេចតាមសេចក្ដីប្រាថ្នា សេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយនេះ ជាទុក្ខដែលកើតឡើងជាមួយនឹងបុគ្គលមិនទូទៅ ដូចជា ក្នុងពួកទេវតាទាំងឡាយ (វៀរចាតុម្មហារាជិ-កាទេវតាជាន់ទាប) ការចាស់ ការឈឺ ទាំង២នេះ មិនប្រាកដតែសេចក្ដីទុក្ខផ្សេង ៗ រមែងទទួលតិច ឬច្រើនដូចគ្នា ។ សម្រាប់ពួកព្រហ្មសូម្បីផុតចាកសេចក្ដីទុក្ខផ្សេង ៗ ក៏ពិត តែសេចក្ដីទុក្ខដែលសំខាន់គឺ ការកើត ការស្លាប់ក៏គេចមិនផុត ។

សេចក្ដីទុក្ខផ្សេងៗ ដូចដែលបានពោលមកហើយនេះ សូម្បីសត្វទាំងឡាយធ្លាប់បានទទួលហើយក្នុងអតីតៈក៏ដោយ កំពុងទទួលក្នុងបច្ចុប្បន្នក៏ដោយ និងទទួលនាកាលអនាគតក៏ដោយ ប៉ុន្តែសត្វទាំងនោះពុំបានដឹង មិនមានការតក់ស្លុតក្នុងសេចក្ដីទុក្ខទាំងនេះទេ ហើយភ្លើតភ្លើនត្រេកអរនៅក្នុងលោកិយារម្មណ៍ទាំង៦ ពោលគឺសេចក្ដីវង្វេងក្នុង កូន ចៅ ស្វាមី ភរិយា ឪពុក ម្ដាយ ញាតិមិត្តបងប្អូន និង

វង្វេងក្នុងលាភ យស ដែលកំពុងមាន មានការជាប់ជំពាក់ក្នុងគ្រឿងបរិភោគ និងឧបភោគផ្សេង ៗ ដូចជា សត្វទា សត្វមាន់ ដែលម្ចាស់យកមកឃាំងទុកក្នុងទ្រុង កាលបើនាំយកទៅសម្លាប់ ទា មាន់ ទាំងនោះ ក៏មិនបានដឹងខ្លួនថា នឹងត្រូវស្លាប់ដែរ ។ កាលនៅក្នុងទ្រុងនោះនាំគ្នាសប្បាយរីករាយពេលដែលបានចំណីអាហារ ការសប្បាយនោះឯង ព្រោះតែវង្វេងមិនដឹងសេចក្តីទុក្ខ យ៉ាងណាមិញ សត្វទាំងឡាយដែលភ្លើតភ្លើនក្នុងលោកិយអារម្មណ៍ផ្សេងៗ ក៏ព្រោះមិនដឹងសេចក្តីទុក្ខផ្សេង ៗ ថាទុក្ខយ៉ាងនោះមែន ។

ឥឡូវនេះ ពួកវិទ្យាសាស្ត្រីកចម្រើនយ៉ាងណាក៏ដោយ នៅតែមិនអាចរកឧបាយមិនឱ្យកើត ចាស់ ឈឺ ស្លាប់បានឡើយ ហើយគ្មានសង្ឃឹមនឹងធ្វើបាន ។

ឧបាយដែលធ្វើឱ្យផុតពីការកើត ចាស់ ឈឺ ស្លាប់បាននោះមានតែក្នុងព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ដូច្នោះអ្នកមានបញ្ញាទាំងឡាយទើបព្យាយាមរកផ្លូវបដិបត្តិ ដើម្បីឱ្យផុតអំពីសេចក្តីទុក្ខទាំងនោះ ។ ដូចមានព្រះគាថាយ៉ាងនេះថា **បត្ថេន្តិ មុច្ចិតុំ សន្តា សំសារា ភយភេរវា ទុជ្ជនា មោទមានាវ វដ្ដន្តិ ភវសាគរេ** ។ សប្បុរសអ្នកឃើញទោសក្នុងរាងកាយនេះហើយ មិនមានសេចក្តីប្រកាន់មាំ និង

មានបញ្ញា មើលឃើញកាលខាងមុខ ហើយជាអ្នកមានសេចក្តីតក់ស្លុតប្រាថ្នាដើម្បីឱ្យផុតអំពីការកើតស្លាប់នៅក្នុងភូមិទាំង ៣១ ជាន់មិនមានទីបំផុត ។ ការកើត ចាស់ ឈឺ ស្លាប់នេះ ជាភ័យគួរឱ្យខ្លាច។ ចំណែកអសប្បុរស អ្នកមិនឃើញច្បាស់ក្នុងការកើត ចាស់ ឈឺ ស្លាប់ មានសេចក្តីប្រកាន់មាំក្នុងកាមគុណារម្មណ៍ទាំងនេះ មានសេចក្តីភ្លើតភ្លើនទៅដោយអារម្មណ៍ផ្សេងៗ មានរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ក្នុងភពផ្សេង ៗ ដែលប្រៀបដូចជាមហាសមុទ្រ រមែងវិលវល់ស្លាប់កើតក្នុងភូមិ ៣១ ហើយអន្ទោលពីភូមិមួយ ទៅភូមិមួយទៀត ។

នេះឈ្មោះថា **ទុក្ខេ អញ្ញាណំ** ការមិនដឹងក្នុងសេចក្តីទុក្ខ ។

## ២. ការមិនដឹងហេតុនាំឱ្យកើតទុក្ខ (សមុទយេ អញ្ញាណំ)

សេចក្តីទុក្ខផ្សេង ៗ មានការកើត ចាស់ ឈឺ ស្លាប់ សេចក្តីមិនសប្បាយចិត្តជាដើមនេះ កាលបើចូលទៅរកមូលហេតុដែលធ្វើឱ្យកើតទុក្ខហើយក៏នឹងជ្រាបបានថា លោភៈ គឺសេចក្តីចង់បាន សេចក្តីត្រេកអរពេញចិត្តនោះឯង ជាតួហេតុ ព្រោះធម្មតាមនុស្សទាំងឡាយ ក្នុងលោកនេះ មានសេចក្តីខ្វល់ខ្វាយព្យាយាមធ្វើកិច្ចការងារផ្សេង ៗ ទាំងអំពើល្អទាំងអំពើអាក្រក់ ដើម្បីស្វែងរកឱ្យបាននូវអារម្មណ៍ដែលជាទីពេញចិត្ត

គួរប្រាថ្នាផ្សេង ៗ ដូចគ្នាទាំងអស់ សូម្បីនឿយកាយ នឿយចិត្ត យ៉ាងណាក៏ដោយ ក៏មិនរាថយ ចង់ឱ្យតែបានសម្រេចក្នុងកិច្ចការដែលខ្លួនបានធ្វើនោះ ហើយក៏បាននូវវត្ថុដែលខ្លួនប្រាថ្នា សមដូចបំណង តែមនុស្សទាំងឡាយ មិនដឹងខ្លួនថា ធ្លាក់ទៅក្នុងអំណាចរបស់លោភៈដែលជាអ្នកចាត់ចែងឱ្យខ្លួននឿយហត់ លំបាកកាយ លំបាកចិត្ត ដោយអំណាចនៃរូបតណ្ហា គឺសេចក្តីត្រេកអរពេញចិត្ត ក្នុងរូបខ្លះ សទ្ទតណ្ហា គឺសេចក្តីត្រេកអរពេញចិត្ត ក្នុងសម្លេងខ្លះ គន្ធតណ្ហា គឺសេចក្តីត្រេកអរពេញចិត្ត ក្នុងក្លិនខ្លះ រសតណ្ហា គឺសេចក្តីត្រេកអរពេញចិត្តក្នុងរសខ្លះ ផោដ្ឋព្វតណ្ហា គឺសេចក្តីត្រេកអរពេញចិត្ត ក្នុងផោដ្ឋព្វៈខ្លះ ធម្មតណ្ហា គឺសេចក្តីត្រេកអរពេញចិត្ត ក្នុងការនឹកគិតខ្លះ។

លោភៈ គឺការប្រាថ្នាត្រេកអរពេញចិត្តក្នុងរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ជាដើមដែលខ្លួនគិតថា នឹងនាំនូវសេចក្តីសុខមកឱ្យ ជាហេតុនៃការខ្វល់ខ្វាយព្យាយាមដើម្បីឱ្យបានមកនូវវត្ថុទាំងនោះ ដោយកាយខ្លះដោយវាចាខ្លះ ក្នុងខណៈដែលខ្វល់ខ្វាយព្យាយាមនោះ រមែងទទួលបាននូវសេចក្តីលំបាកកាយ លំបាកចិត្ត សុទ្ធតែជាសេចក្តីទុក្ខដែលជាផលបានទទួលអំពីការព្យាយាមជាហេតុ ។

ម្យ៉ាងទៀត បើសេចក្តីព្យាយាមល្មមប្រមាណ សេចក្តីទុក្ខផ្សេង ៗ ដែលទទួលបាននោះ ក៏ល្មមប្រមាណ បើមានសេចក្តីព្យាយាមច្រើនប៉ុណ្ណា ការទទួលសេចក្តីទុក្ខក៏ច្រើនប៉ុណ្ណោះ។

ន័យម្យ៉ាងទៀត បើការព្យាយាមនោះប្រព្រឹត្តទៅក្នុងអំពើល្អ ដូចព្យាយាមធ្វើកុសលផ្សេងៗ មានទាន សីល ភាវនា ដើម្បីប្រាថ្នាសេចក្តីសុខ ឱ្យក្រៃលែងឡើងក្នុងភពនេះនិងភពខាងមុខ។ ការធ្វើកុសលដែលមានសេចក្តីប្រាថ្នា ដូច្នេះ ក៏រាប់ថាធ្វើទៅដោយអំណាចលោភៈដែរ ជាហេតុឱ្យបានទទួលសេចក្តីទុក្ខកើតឡើង គឺសេចក្តីលំបាកកាយ លំបាកចិត្ត ក្នុងខណៈដែលកំពុងធ្វើ និងកាលស្លាប់អំពីភពនេះ ហើយក៏ត្រូវបានទទួលសេចក្តីទុក្ខក្នុងភពខាងមុខតទៅទៀត គឺ ការកើត ចាស់ ឈឺ ស្លាប់នោះឯង តែអ្នកដែលទទួលសេចក្តីទុក្ខនេះ រមែងមានសេចក្តីអត់ធន់បាន ដោយឃើញថា ជារបស់ធម្មតា តែមិនបានដឹងថា ការកើត ចាស់ ឈឺ ស្លាប់ ទុក្ខកាយទុក្ខចិត្តជាដើម ដែលខ្លួនកំពុងបានទទួល នឹងបានទទួលតទៅទៀតក្នុងពេលខាងមុខនោះ ថាជាផលដែលកើតអំពីលោភៈ ជាហេតុនោះទេ ។

ប្រសិនបើការខ្វល់ខ្វាយព្យាយាមនោះ ប្រព្រឹត្តទៅក្នុងផ្លូវមិនល្អ ដូចជា សម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយព្រះពង្រ់ និយាយស៊កសៀត និយាយឥតប្រយោជន៍ សេពសុរា ជាដើមនេះ ដើម្បីឱ្យបានទ្រព្យសម្បត្តិ មាសប្រាក់ យកមកទំនុកបម្រុងសេចក្តីសុខផ្ទាល់ខ្លួន ការធ្វើទុច្ចរិតផ្សេង ៗ ដូចដែលបានពោលមកហើយនេះ ក៏

រាប់ថា ធ្វើដោយអំណាចនៃលោភៈ ជាហេតុឱ្យទទួលសេចក្ដីទុក្ខក្នុងជាតិនេះនិងជាតិមុខ ពោលគឺក្នុងជាតិនេះ រមែងទទួលសេចក្ដីទុក្ខកាយទុក្ខចិត្ត យ៉ាងធ្ងន់ធ្ងរ បានដល់ ការតិះដៀលមាក់ងាយអំពីសប្បុរសទាំងឡាយខ្លះ ត្រូវគេចាប់បានក៏ត្រូវទទួលទោសតាមច្បាប់ អាចនឹងទទួលទោសដល់ការប្រហារជីវិតបាន ទាំងនេះសុទ្ធតែជាសេចក្ដីទុក្ខដែលបានទទួលដោយការឃើញច្បាស់នឹងភ្នែក បើអ្នកនោះស្លាប់នឹងត្រូវទទួលសេចក្ដីទុក្ខយ៉ាងធ្ងន់ធ្ងរ ក្នុងលោកខាងមុខ គឺទៅកើតក្នុងនរកខ្លះតិរច្ឆានខ្លះ ប្រេតខ្លះ នឹងទៅកើតក្នុងពួកអបាយសត្វណាមួយ រមែងសេសសល់ផលកម្មតិចតួច និងទៅកើតជាមនុស្ស ឬទេវតាដែលជាវត្ថុគួរខ្លាចដោយច្រើន ការប្រព្រឹត្តធ្វើរបស់សត្វទាំងឡាយនោះ ក៏នាំឱ្យវង្វេងក្នុងអំណាចលោភៈ មិនដឹងខ្លួនថាលោភៈជាហេតុ នាំឱ្យកើតទុក្ខផ្សេងៗ ឡើយ ។

ឧបមាដូចជាត្រីបានឃើញនុយបិទដោយផ្លែសន្ទូច មានសេចក្ដីដឹងថាត្រឹមតែនុយប៉ុណ្ណោះ មិនដឹងថាត្រូវទទួលភ័យទេ កាលលេបចូលទៅហើយ ត្រូវផ្លែសង្ទូចមុតមាត់ មានសេចក្ដីទុក្ខយ៉ាងខ្លាំងក្លាក្រៃលែងជាងនេះទៅទៀត ត្រូវមនុស្សយកទៅសម្លាប់ធ្វើជាអាហារ សេចក្ដីនេះយ៉ាងណា សត្វទាំងឡាយដែលទទួលសេចក្ដីលំបាកកាយ លំបាកចិត្ត

ផ្សេង១ ច្រើនខ្លះ តិចខ្លះ មកអំពីខ្វល់ខ្វាយរកសេចក្ដីសុខ ឱ្យដល់ខ្លួន ដោយអំណាចលោភៈដូចគ្នា ។

ម្យ៉ាងទៀត សត្វទាំងឡាយ សូម្បីនឹងវៀរចាកការកើតស្លាប់ រាប់ចំនួនមិនអស់ក៏ដោយ តែសត្វទាំងនោះមិនមានសេចក្ដីនឿយណាយ សូម្បីតែបន្តិចបន្តួច នៅត្រេកអរពេញចិត្តក្នុងភពជាតិរបស់ខ្លួន ព្រមទាំងវត្ថុនានា កុំថាឡើយតែនឹងកើតជាមនុស្ស ទេវតា ព្រហ្ម សូម្បីនឹងបានកើតជាសត្វតិរច្ឆាន រហូតដល់សត្វដង្កូវ នៅក្នុងឧច្ចារៈក៏ដោយ នៅតែត្រេកអរក្នុងអត្តភាពនៃការរស់នៅរបស់ខ្លួន ព្រោះហេតុនោះ សត្វទាំងឡាយ នៅមានតណ្ហាជាមិត្តយ៉ាងជិតស្និត ជួយទំនុកបម្រុងជារឿយ ៗ នោះឯង ទើបធ្វើឱ្យសត្វទាំងឡាយនោះមិននឿយណាយ ចំពោះការកើតក្នុងភពផ្សេង ៗ ដែលជាឫសគល់នៃកងទុក្ខទាំងពួង ថែមទាំង មើលមិនឃើញកងទុក្ខដទៃទៀត ដែលខ្លួនបានប្រសព្វ ក៏មកអំពីតណ្ហានោះជាតួហេតុ ដូចសត្វសុនខមួយក្បាល ដែលភ្លើតភ្លើនជាមួយនឹងឆ្អឹងគោមិនមានសាច់ ដោយអាស្រ័យទឹកមាត់របស់ខ្លួនយ៉ាងណា សត្វទាំងឡាយ ដែលកំពុងសោយកាមគុណារម្មណ៍ នឹងអត់ធន់ចំពោះសេចក្ដីទុក្ខផ្សេង ៗ ដែលខ្លួនបានប្រសព្វ ដោយមិនមានសេចក្ដីនឿយនាយនោះ ក៏ព្រោះដោយអំណាចនៃតណ្ហា ដែលមាននៅក្នុងសន្ដានរបស់ខ្លួននោះឯង ចំណែកវត្ថុទាំងឡាយ ដែលជាគ្រឿងបង្ក

ឱ្យកើតសេចក្ដីត្រេកអរពេញចិត្តនោះ គ្រាន់តែជាអារម្មណ៍នាំឱ្យតណ្ហាកើតឡើង ដោយហេតុនេះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថាៈ

**តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសារំ**

**ឥត្ថម្ភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ។**

អ្នកមានតណ្ហាជាមិត្ត រមែងអន្ទោលទៅកាន់ភពដទៃទៀត ការរស់នៅពីភពមួយទៅកាន់ភពមួយ ហើយមិនអាចឈានផុតអំពីសង្សារវដ្តដ៏យូរ ព្រោះតែមានតណ្ហាជាមិត្ត។

សម្រាប់អ្នកដែលរួចផុតអំពីលោភៈបានក្ដី ឬ អ្នកដែលធ្វើការងារផ្សេងៗ ដែលមិនប្រព្រឹត្តទៅដោយអំណាចរបស់លោភៈក្ដី រមែងរួចផុតអំពីសេចក្ដីទុក្ខទាំងពួង ឬ បើនៅមិនទាន់រួចចាកផុតទុក្ខទេ ក៏នៅតែជួបប្រសព្វគ្នានឹងសេចក្ដីទុក្ខ ដែលប្រព្រឹត្តទៅជាធម្មតា គឺ កើត ចាស់ ឈឺ ស្លាប់ប៉ុណ្ណោះ ហើយមិនយូរទេនឹងអាចរួចផុតអំពីសេចក្ដីទុក្ខបាន ដោយហេតុនេះ សមដូចសម្ដេចព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា

**តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ**

**តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ។**

សេចក្ដីសោកកើតឡើងព្រោះតណ្ហាជាហេតុ ភ័យក៏រមែងកើតឡើងព្រោះតណ្ហាជាហេតុដែរ សេចក្ដីសោករមែងមិនមានដល់បុគ្គល

អ្នកផុតអំពីតណ្ហាហើយ សេចក្តីសោកមិនមាន តើភ័យនឹងមានមកពីណា ។

## ៣.ការមិនដឹងធម៌ដែលជាទីរលត់ទុក្ខ (ទុក្ខនិរោធេ អញ្ញាណំ)

ការកើតរបស់សត្វទាំងឡាយ ដែលវិលវល់កើតស្លាប់នៅក្នុងភូមិ ៣១ជាន់ ទាំងនេះសុទ្ធតែធ្លាក់នៅក្នុងកងទុក្ខ មិនថាអ្នកនោះកើតជាមនុស្ស ថ្នាក់ទាប ថ្នាក់ខ្ពស់ ឬកើតក្នុងទុគតិភូមិ សុគតិភូមិក៏ដោយ ក៏ត្រូវបានជួបនឹងទុក្ខផ្សេងៗ មានការកើត ចាស់ ឈឺ ស្លាប់ ដោយហេតុនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់មិនសរសើរក្នុងការដែលសត្វទាំងឡាយកើត ចាស់ ឈឺ ស្លាប់ នៅក្នុងភូមិផ្សេងៗ ឬបុគ្គលថ្នាក់ទាប ថ្នាក់ខ្ពស់ក៏ដោយ មានតែទ្រង់ចង្អុលបង្ហាញផ្លូវឱ្យសត្វទាំងឡាយ បានឆ្លងផុតចាកភពផ្សេងៗ ដូចគ្នាទាំងអស់ ។

ឧច្ចារៈជាវត្ថុគួរខ្ពើមដល់មនុស្សទាំងឡាយទូទៅ មិនថាឧច្ចារៈនោះ កើតពីអាហារដែលល្អប្រណីត សាច់ជ្រូក សាច់មាន់ សាច់ទាជាដើម ឬនឹងកើតពីអាហារដែលមិនប្រណីតដូចជា ក្តាមប្រៃ ត្រីប្រៃជាដើមក៏ដោយ ក៏ជាវត្ថុដែលគួរខ្ពើមទាំងនេះ មិនមានអ្នកណាសរសើរថាល្អឡើយ ។ សត្វទាំងឡាយដែលកើតនៅក្នុងភូមិផ្សេងៗក៏ដូចគ្នា បណ្ឌិតទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម មិនបាន

សរសើរថាល្អទេ ព្រោះត្រូវបន្តនៅក្នុងទុក្ខផ្សេង ៗ ដូចដែល បានពោល មកហើយ នោះឯង។

វត្ថុដែលបណ្ឌិតទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម រមែង យល់ថា ជារបស់ប្រសើរមានតែព្រះនិព្វានម្យ៉ាងប៉ុណ្ណោះ ព្រោះនិព្វាន នេះមានសភាពជាសន្តិសុខ គឺសេចក្តីសុខដែលស្ងប់ចាក ខន្ធ ៥ មិន ទាក់ទងជាមួយការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវ ការនឹកគិតទាំងពួង ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែល មាននៅក្នុងបិដកទាំង ៣ មាន ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធនោះ គោល ដៅដែលព្រះអង្គប៉ងប្រាថ្នាក៏គឺវិមុត្តិរស បានដល់ ព្រះនិព្វានតែម្យ៉ាង ដោយហេតុនេះ ទើបព្រះអង្គពណ៌នាសរសើរព្រះនិព្វានយ៉ាងច្រើន ដូច មានប្រាកដថា ៖

**និព្វានំ បរមំ សុខំ**

ព្រះនិព្វានមានសេចក្តីសុខយ៉ាងក្រៃលែង

**នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃក្រៅអំពីព្រះនិព្វានឡើយ

**និព្វានំ បរមំ វទន្តិ ពុទ្ធា**

ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គទ្រង់ត្រាស់ថា ព្រះនិព្វាន ជា ធម៌ដ៏ប្រសើរ ។

សូម្បីព្រះអង្គទ្រង់បានប្រកាសគុណនៃព្រះនិព្វានជានិច្ច មិនថាទ្រង់សម្ដែងធម៌រឿងណា ក្នុងទីណា ព្រះអង្គទ្រង់លើកព្រះនិព្វានមកសម្ដែងឡើង ក្នុងពេលចុងក្រោយគ្រប់ៗពេល តែជនទាំងឡាយដែលព្យាយាម បដិបត្តិតាមបំណងរបស់ព្រះអង្គនោះ រកបានដោយកម្រណាស់ ចំណែកបុគ្គល ដែលមានការប្រព្រឹត្តបដិបត្តិ ធ្វើឱ្យខ្លួនវិលវល់នៅក្នុងជាតិកំណើត ព្រមទាំងខ្លួនក៏ត្រេកអរពេញចិត្ត មានចំនួនច្រើនដូចជាដីខ្សាច់ ដែលនៅក្នុងមហាសមុទ្រ កាលបើចាប់ខ្សាច់នោះឡើងមកមួយក្ដាប់ ចំនួនដីខ្សាច់ដែលនៅក្នុងដៃនោះ ប្រៀបដូចអ្នកដែលបដិបត្តិខ្លួនដើម្បីឱ្យដល់ព្រះនិព្វាន ចំនួនដីខ្សាច់ ដែលនៅក្នុងសមុទ្រនោះ ប្រៀបដូចអ្នកដែលនៅមានការត្រេកអរ វិលវល់នៅក្នុងភពផ្សេងៗ ដូច្នោះទើប ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងថា ៖

**អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ**

**អថាយំ ឥតរា បជា តីរមេវានុធាវតិ។**

បណ្ដាជនទាំងឡាយ ជនណាដែលជាអ្នកដល់ត្រើយនាយ គឺព្រះនិព្វាននោះមានចំនួនតិច ចំណែកពួកជនដែលក្រៅពីនោះរមែងនៅក្នុងត្រើយអាយនេះ គឺវិលវល់នៅក្នុងសង្សារវដ្ដ ដែលជាប់ជាមួយសក្កាយទិដ្ឋិ។

មួយប្រការទៀត ប្រៀបដូចសត្វត្មាត តាមធម្មតាសត្វត្មាត នោះ ប្រសិនបើមានមនុស្សស្រែកប្រកាសថា ត្រើយខាងនុ៎ះមានអាហារ ដែលមានឱជារស មានក្លិនឈ្ងុយផ្សេងៗ សូមឱ្យពួកត្មាតទាំងឡាយ ចូលនាំគ្នាទៅស៊ីឱ្យជាទីសប្បាយចុះ ពួកសត្វត្មាតបានស្ដាប់ឮដំណឹងនេះ ហើយ នឹងមិនមានសត្វត្មាតណាមួយ មានសេចក្ដីត្រេកអរឡើយ តែបើមានមនុស្សទៅប្រាប់ថា ទីនោះមានឆ្កែងាប់ ឬគោក្របីងាប់ មាន ក្លិនស្អុយ សូមនាំគ្នាទៅស៊ីឱ្យឆ្អែតចុះ ពួកសត្វត្មាត មានសេចក្ដីត្រេកអរ ប្រញាប់នាំគ្នាទៅឯទីនោះភ្លាម ចំណុចនេះ ប្រៀបដូចបណ្ឌិតទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម មានសេចក្ដីព្យាយាម ប្រៀនប្រដៅចង្អុល បង្ហាញដល់ជនទាំងឡាយឱ្យឃើញទោស នៃការវិលវល់ ស្លាប់ កើត នៅក្នុងសង្សារវដ្ដ ដែលសុទ្ធតែធ្លាក់នៅក្នុងកងទុក្ខទាំងអស់ ហើយ បានណែនាំផ្លូវ ឱ្យរួចផុតចាកកងទុក្ខទាំងនេះ ឱ្យជនទាំងឡាយ បាន ប្រព្រឹត្តបដិបត្តិតាម ហើយជនទាំងឡាយដែលមាន សេចក្ដីជ្រះថ្លា នឹងពាក្យណែនាំប្រៀនប្រដៅ ដែលជាសារៈនេះ បានដោយលំបាក ប៉ុន្តែប្រសិនបើមានអ្នកពណ៌នាសរសើរ ដល់សេចក្ដីសុខផ្សេងៗ ដែល ប្រព្រឹត្តទៅក្នុងលោក ជនពួកនោះ នឹងត្រេកអរណាស់ ហើយណែនាំ យ៉ាងណា ក៏នាំគ្នាធ្វើតាមទាំងអស់ ដើម្បីសង្ឃឹមសេចក្ដីសុខដែលកើត

ទូទៅក្នុងលោកជារបស់ ដែលរកបានដោយលំបាក នឹងរកសារៈមិនបាន ដោយហេតុនេះហើយ អ្នកនោះរមែងមិនបានទទួល សេចក្តីសុខដ៏ប្រសើរគឺ ព្រះនិព្វាន មានន័យថា អ្នកនោះមិនមានថ្ងៃឆ្លងផុតពីការកើត ចាស់ ឈឺ ស្លាប់ នឹងត្រូវវិលវល់នៅក្នុងសង្សារវដ្ត សមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងទុកថាៈ

**អសារេ សារមតិនោ សារេ ចាសារទស្សិនោ**

**តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា។**

ជនទាំងឡាយណា មានការឃើញប្រកាន់មាំក្នុងវត្ថុដែលគ្មានសារៈថាជាសារៈ ក្នុងវត្ថុដែលជាសារៈថាមិនជាសារៈ ជនទាំងឡាយនោះជាអ្នកមានសេចក្តីត្រិះរិះខុស ពេញចិត្តក្នុងអារម្មណ៍ដែលខុសរមែងជាអ្នកមិនបាននូវសីលគុណ សមាធិគុណ បញ្ញាគុណ ដែលជាសារៈដែលអាចនាំទៅកាន់ព្រះនិព្វានបាន ។

សេចក្តីសុខក្នុងព្រះនិព្វាន ដែលហៅថា សន្តិសុខ ជាមួយសេចក្តីសុខក្នុងលោកនេះ ដែលហៅថា **វេទយិតសុខ** នោះ មានសភាពផ្ទុយគ្នា ពោលគឺ សេចក្តីស្ងប់ចាក ខន្ធ ៥ នោះឯង ឈ្មោះថា សន្តិសុខ ចំណែកវេទយិតសុខនោះ ជាសេចក្តីសុខដែលទាក់ទងជាមួយការសោយអារម្មណ៍ មានរូប សម្លេង ក្លិន រស ជាដើម សេចក្តីសុខប្រភេទនេះ

មនុស្សទាំងឡាយមិនថា ក្មេង ចាស់ ទេវតា ព្រហ្ម រហូតដល់អបាយសត្វគប្បីពេញចិត្តឃើញប្រយោជន៍ និងមានសេចក្តីប្រាថ្នា ដូចគ្នាទាំងអស់ សម្រាប់សន្តិសុខនោះ សត្វទាំងឡាយមើលមិនឃើញប្រយោជន៍ មិនមានការពេញចិត្តសូម្បីពុទ្ធសាសនិកជនពួកខ្លះ ដែលប្រាថ្នាព្រះនិព្វាន ក៏រមែងតែងតែប្រព្រឹត្តទៅត្រឹមតែវាចា ចំណែកចិត្តមិនបានបង្អោនចូលដល់ព្រះនិព្វានយ៉ាងពិតទេ ដោយច្រើនយល់ថា ព្រះនិព្វាននោះជាស្ថានទីមួយកន្លែងដែលក្រៅពីលោកយើងនេះ ក្នុងស្ថានទីនោះបរិបូណ៌ដោយសេចក្តីសុខនានា រកសេចក្តីទុក្ខមិនមាន អ្នកដែលបានទៅកាន់ព្រះនិព្វាននោះក៏សម្គាល់ថា កាលស្លាប់ពីលោកនេះហើយក៏ទៅកើតឯទីនោះ នឹងមិនមានការចាស់ ឈឺ ស្លាប់ មិនមានសេចក្តីសោកផ្សេងៗ សុទ្ធតែសេចក្តីសុខ ឬពួកខ្លះក៏យល់ថា អ្នកដែលទៅកើតក្នុងព្រះនិព្វាននោះ មិនមានរាងកាយតួខ្លួន មានតែការដឹងតែប៉ុណ្ណោះ ដែលមានការដឹងនោះក៏ឆ្អែតឆ្អល់ទៅដោយសេចក្តីសុខមិនមានសេចក្តីទុក្ខមកលាយឡំឡើយ ។

តែបើអ្នកមានសេចក្តីប្រាថ្នាព្រះនិព្វាន ដោយអាស្រ័យការយល់ក្នុងព្រះនិព្វាន ដូចពោលមកហើយនេះ ដោយបានការសិក្សាយ៉ាងត្រឹមត្រូវហើយ ថាអ្នកដែលបានចូលដល់ព្រះនិព្វាន បានដល់ព្រះអរហន្ត

ទាំងឡាយ កាលដែលនឹងលះលោកនេះហើយខន្ធ៥របស់ព្រះអរហន្ត ទាំងនោះ រមែងរលត់អស់មិនមានសេសសល់ ការដឹងផ្សេង ៗ ក៏ មិនមាន ដូច្នេះហើយអ្នកនោះអាចកើតសេចក្ដីសង្ស័យថា ការចូល ដល់ព្រះនិព្វាននោះ នឹងមានសេចក្ដីសុខយ៉ាងក្រៃលែង បានយ៉ាងណា បើមិនមានអ្វីសេសសល់ ដោយហេតុនេះ បណ្ឌិតទាំងឡាយអ្នកឃើញ ភ័យទាំង ៤ ដែលមាននៅក្នុងសង្សារវដ្ដ ដោយអាស្រ័យការកើត ការស្លាប់ប៉ុណ្ណោះ ដែលសមចូលទៅកាន់ព្រះនិព្វានដោយពិត បុគ្គល ក្រៅពីនោះ នៅមិនទាន់ពេញចិត្តទៅកាន់ព្រះនិព្វាន ដោយឃើញថា មិនមានសេចក្ដីសុខ ព្រោះហេតុដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ ត្រាស់ទេសនាទុកថា:

**សទេវកស្ស លោកស្ស ឯតេ វោ សុខសម្មតា**
**យត្ថ ចេតេ និរុជ្ឈន្តិ តំ តេសំ ទុក្ខសម្មតំ**

សត្វលោកទាំងឡាយព្រមទាំងទេវតា សន្មតិគ្នាថា លោកិយ-អារម្មណ៍ផ្សេងៗ មានរូប សម្លេង ក្លិន រស ជាដើមទាំងនោះរលត់សូន្យ អស់ហើយ សត្វលោកព្រមទាំងទេវតានោះ សម្មតិគ្នាថា ធម៌នោះគឺ ព្រះនិព្វាន ជាធម៌មិនល្អ ជាទុក្ខ។

# ភ័យ ៤ យ៉ាង

**១.នានាសត្ថុឧលលោកនភ័យ** គឺនៅមិនទាន់ឆ្លងផុតពីការគោរពរាប់អានសាស្ដាផ្សេងៗ មានន័យថា ក្នុងភពនេះគោរពរាប់អានព្រះសម្មាសម្ពុទ្ធក៏ពិតមែន តែក្នុងភពតៗ ទៅមិនគោរពសាសនាព្រះសម្មាសម្ពុទ្ធ ប្ដូរទៅគោរពសាសនាផ្សេងៗ រហូតគោរពទេវតាព្រហ្ម ខ្មោច ជាដើម នេះក៏ជាភ័យគួរខ្លាចប្រការទីមួយ ។

**២.វិនិបាតភ័យ** គឺការទៅកើតក្នុងកន្លែងមិនពិតប្រាកដ មានន័យថា កាលស្លាប់ចាកលោកនេះហើយ ទៅកើតកន្លែងណាក៏មិនបានដឹង កើតជាមនុស្ស ទេវតា ព្រហ្ម ឬ ទៅកើតជាសត្វនរកសត្វតិរច្ឆាន ប្រេត អាសុរ ក៏មិនដឹងទាំងអស់ ស្រេចតែកម្មរបស់ខ្លួនដែលធ្វើទុក ឬ ក្នុងជាតិនេះកើតជាមនុស្សអាក្រក់ ស្អាត ឆ្លាតត្រកូលខ្ពស់ មានសតិសម្បជញ្ញៈល្អ មានអវយវៈគ្រប់គ្រាន់ មានសុខភាពល្អ តទៅជាតិមុខអាចនឹងទៅកើតជាមនុស្សក្រខ្សត់ មិនស្អាតល្ងង់ ត្រកូលថោកទាប មានសតិមិនល្អ មានអវយវៈមិនគ្រប់គ្រាន់ជាដើម ទាំងនេះក៏ជាភ័យគួរខ្លាចប្រការទីពីរ ។

**៣.អបាយភ័យ** គឺនៅមិនទាន់ឆ្លងផុតអំពីអបាយភូមិ មានន័យថាក្នុងជាតិនេះបានទៅកើតជាមនុស្ស ឬទេវតា ជាតិខាងមុខអាចទៅកើតក្នុងអបាយភូមិ ជាសត្វនរក សត្វតិរច្ឆាន ប្រេត អសុរកាយ ក៏បាន អ្នក

ដែលទៅកើតជាព្រហ្មស្រាប់ហើយនោះ ក៏មិនប្រាកដថា មិនទៅកើតក្នុងអបាយ ព្រោះនៅជាបុថុជ្ជន សូម្បីក្នុងជាតិទី ២ នឹងមិនទៅកើតជាអបាយ តែជាតិទី ៣ ជាដើម ក៏នឹងអាចទៅកើតបាន នេះជាភ័យគួរខ្លាច ប្រការទីបី ។

**៤.ទុច្ចរិតភ័យ** គឺនៅមិនទាន់ឆ្លងផុតពីការធ្វើទុច្ចរិតផ្សេងៗ មានន័យថា ក្នុងជាតិនេះមិនបានធ្វើទុច្ចរិត គឺមិនចូលចិត្តសម្លាប់សត្វ បៀតបៀនសត្វ មិនជាចោរ មិនជាអ្នកនិយាយឡេះឡោះ មិនជាអ្នកសេពសុរា មិនមានមិច្ឆាទិដ្ឋិ តែជាតិត ៗ ទៅមុខ អាចកើតជាមនុស្ស ដែលមានសេចក្តីពេញចិត្តក្នុងការធ្វើទុច្ចរិត គឺចូលចិត្ត សម្លាប់សត្វ ជាចោរ ជាមនុស្សនិយាយឡេះឡោះ ចូលចិត្តសេពសុរា មានមិច្ឆាទិដ្ឋិ ទាំងនេះក៏ជាវត្ថុដែលគួរខ្លាចប្រការទីបួន ។

ពាក្យអធិប្បាយដូចពោលមកនេះ ជាការអធិប្បាយក្នុងសេចក្តីដឹងនូវធម៌ដែលជាទីរលត់នៃសេចក្តីទុក្ខ ។

## ៤.ការមិនដឹងផ្លូវដែលជាទីរលត់ទុក្ខ
## (ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ)

តាមធម្មតាមនុស្សទាំងឡាយក្នុងលោកនេះ មិនមានអ្នកណាមួយឡើយចង់ជួបសេចក្តីទុក្ខ នឹងអ្នកដែលជួបសេចក្តីទុក្ខស្រាប់ហើយក៏ព្យាយាមរើបម្រាស់រកផ្លូវឱ្យផុតពីសេចក្តីទុក្ខនោះ ៗ ដោយអាស្រ័យ

ហេតុនេះហើយ មនុស្សម្នាក់ៗ ក៏ព្យាយាមប្រព្រឹត្តបដិបត្តិផ្សេងៗ ទាំងផ្លូវលោក និងផ្លូវធម៌ ដើម្បីតែសេចក្តីសុខ និងឱ្យឆ្លងផុតសេចក្តីទុក្ខនោះឯង។

## ទុក្ខ ២ យ៉ាង

**១.ទុក្ខសាមញ្ញ** បានដល់ ការកើត ចាស់ ឈឺ ស្លាប់ របស់សត្វទាំងឡាយក្នុងលោក ដែលប្រព្រឹត្តទៅតាមធម្មតា មិនមានអ្នកណាចៀសវាងបាន។

**២.ទុក្ខពិសេស** បានដល់ សេចក្តីទុក្ខដែលកើតឡើងដោយអាស្រ័យព្យសនៈ ៥ យ៉ាងគឺ

**ញាតិព្យសនៈ** ការវិនាសញាតិ

**ភោគព្យសនៈ** ការវិនាសទ្រព្យសម្បត្តិ

**រោគព្យសនៈ** ការវិនាសព្រោះមានរោគ

**សីលព្យសនៈ** ការវិនាសព្រោះសីល

**ទិដ្ឋិព្យសនៈ** ការវិនាសព្រោះមានមិច្ឆាទិដ្ឋិ

ព្រមទាំងសេចក្តីទុក្ខ ដែលកើតឡើងដោយជួបជាមួយអគ្គិភ័យខ្លះ ចោរភ័យខ្លះ រាជភ័យខ្លះ អសប្បុរសភ័យខ្លះ ទាំងនេះជាដើម។

ការបដិបត្តិ ដែលមនុស្សទាំងឡាយប្រព្រឹត្តឱ្យផុតអំពីសេចក្តីទុក្ខមាន ២ យ៉ាងគឺ៖

**១.ការបដិបត្តិខាងផ្លូវលោក** បានដល់ការព្យាយាមប្រកបអាជីពផ្សេងៗ ដូចជាធ្វើស្រែចំការ លក់ដូរ ជំនួញ ជាដើម ជនពួកខ្លះក៏ប្រកបអាជីពដែលប្រព្រឹត្តទៅក្នុងផ្លូវទុច្ចរិត ដូចជាលួចទ្រព្យគេ ធ្វើការនេសាទ និងការបោកបញ្ឆោតជាដើម ហើយជនពួកខ្លះកាលបានជួបជាមួយនឹងសេចក្តីទុក្ខកាយ ទុក្ខចិត្តហើយ ក៏ទៅរកគ្រូទាយដើម្បីបំបាត់អន្តរាយឱ្យផុតពីសេចក្តីទុក្ខទាំងនេះទៅខ្លះ ដូច្នេះជាដើម ។

**២.ការបដិបត្តិក្នុងផ្លូវធម៌** បានដល់ ការបំពេញទានខ្លះ រក្សាសីលខ្លះ ធ្វើសមថៈខ្លះ បដិបត្តិដោយអត្តកិលមថានុយោគ គឺ ធ្វើបាបរាងកាយដោយប្រការផ្សេងៗ មានការបដិបត្តិដូចសត្វគោខ្លះ ដូចសត្វឆ្កែខ្លះ បដិបត្តិដោយកាមសុខល្លិកានុយោគ គឺ បំរើខ្លួនឱ្យបានទទួលសេចក្តីសុខផ្សេងៗ តាមសេចក្តីពេញចិត្តរបស់ខ្លួន មិនឱ្យមានវត្ថុណាមួយមករារាំងបានឡើយ ។

ការបដិបត្តិចពោលមកនេះការប្រព្រឹត្តក្នុងផ្លូវលោក ដែលមិនទាក់ទងជាមួយទុច្ចរិតទាំងនោះ រមែងធ្វើឱ្យផុតអំពីសេចក្តីទុក្ខទៅបានត្រឹមតែមួយគ្រាប៉ុណ្ណោះ ការបដិបត្តិដែលមិនប្រកបដោយទុច្ចរិតនោះក្នុងចន្លោះនៃការប្រព្រឹត្តនៅមិនទាន់ឱ្យផល ក៏សម្គាល់ថាមានសេចក្តីសុខ ប៉ុន្តែការប្រព្រឹត្តអាក្រក់នោះឱ្យផលហើយអ្នកនោះ រមែងបានទទួលសេចក្តីទុក្ខយ៉ាងក្រៃលែង សមដូចព្រះបរមសាស្តាទ្រង់ត្រាស់សម្តែងទុកថា :

**មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**

**យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ។**

បាបមិនទាន់ឱ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថាដូចទឹកឃ្មុំ លុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្ដីទុក្ខក្នុងកាលនោះ។

ចំណែកការបដិបត្តិក្នុងផ្លូវធម៌ ដែលទាក់ទងជាមួយនឹងទាន សីល សមថភាវនា រមែងរួចផុតចាកសេចក្ដីទុក្ខបានមួយគ្រាខ្លះ ឬផុតទៅបានរហូតអស់ថ្ងៃ ខែ ឆ្នាំខ្លះ ឬ ទៅបាន ១ ជាតិ ២ជាតិ ៣ ជាតិខ្លះ ឱ្យរួចផុតទៅដោយដាច់ខាតមិនមាន ហើយទុក្ខដែលផុតទៅមួយគ្រានេះ ផុតបានតែទុក្ខពិសេស គឺការចាស់ និង ឈឺ ប៉ុណ្ណោះសម្រាប់ទុក្ខដែលទាក់ទងជាមួយការកើត ស្លាប់ នោះមិនអាចរួចផុតបាន។

អ្នកដែលបដិបត្តិ**អត្តកិលមថានុយោគ** ដោយសង្ឃឹមថាកាលជម្រះកិលេសឱ្យអស់រលីងទៅហើយ ក្នុងជាតិខាងមុខនឹងត្រូវបានទទួលសេចក្ដីសុខ សោយទិព្វសម្បត្តិក្នុងទេវលោក ផុតពីសេចក្ដីទុក្ខផ្សេងៗដែលមនុស្សទាំងឡាយបានជួប សេចក្ដីសង្ឃឹមរបស់បុគ្គលពួកនេះ ត្រូវអស់សង្ឃឹម ព្រោះមិនត្រឹមតែបានទទួលសេចក្ដីទុក្ខ ដែលកើតអំពីការ

ធ្វើបាបរាងកាយក្នុងភពនេះប៉ុណ្ណោះទេ កាលស្លាប់ពីភពនេះទៅហើយ រមែងបានទទួលសេចក្តីទុក្ខដ៏ធ្ងន់ក្រៃលែងថែមទៀត ក្នុងនិរយភូមិយ៉ាងពិតប្រាកដ ព្រោះអាស្រ័យការយល់ខុសរបស់ខ្លួននោះឯង ។

អ្នកដែលបដិបត្តិកាមសុខល្លិកានុយោគដោយយល់ថា ជីវិតគឺការប្រព្រឹត្តទៅនៃមនុស្សយើងនេះ ប្រសិនបើមានវត្ថុណាមួយមកជាឧបសគ្គរារាំងពីការស្វែងរកសេចក្តីសុខការភ្លើតភ្លើនផ្សេងៗ តាមដែលខ្លួនពេញចិត្តហើយ រមែងធ្វើឱ្យកើតសេចក្តីសៅហ្មងក្នុងចិត្ត មិនផុតអំពីសេចក្តីទុក្ខទៅបាន ព្រោះហេតុដូច្នោះ ទើបត្រូវព្យាយាមរកវិធីផ្សេងៗ ដែលនាំសេចក្តីសប្បាយរីករាយភ្លើតភ្លើនមកដល់ខ្លួន ដើម្បីមិនឱ្យកើតសេចក្តីទោមនស្ស កាលបើចិត្តរីករាយហើយក្នុងជាតិនេះ ក៏រួចផុតពីសេចក្តីទុក្ខកាយទុក្ខចិត្ត ជាតិខាងមុខនឹងបានទទួលសេចក្តីសុខ ក្នុងមនុស្សលោក ឬទេវលោកតទៅទៀត កាលមានការយល់ដូច្នេះ ក៏ព្យាយាមស្វែងរកវត្ថុកាមផ្សេងៗ មកបម្រើខ្លួនតាមសេចក្តីពេញចិត្ត ការបដិបត្តិដូច្នេះ បុគ្គលខ្លះក៏បានសម្រេច គឺមានសេចក្តីភ្លើតភ្លើនក្នុងកាមគុណារម្មណ៍ផ្សេងៗ មិនមានវត្ថុណាមួយមកជាឧបសគ្គរារាំងបានឡើយ ប៉ុន្តែបុគ្គលខ្លះក៏ធ្វើមិនបាន ដោយមានអ្នកដទៃមករារាំខ្លះ ទាក់ទងជាមួយទ្រព្យសម្បត្តិមាសប្រាក់ខ្លះ ទាក់ទងជាមួយរោគភ័យ

មកបៀតបៀនខ្លះ ទាំងនេះធ្វើឱ្យចិត្តរបស់អ្នកនោះត្រឡប់ជាមានសេចក្តីក្តៅក្រហាយថែមទៀត ទីបំផុតកាលបើរកផ្លូវកែខៃមិនបាន អាចហ៊ានប្រហារជីវិតរបស់ខ្លួន ឬអ្នកមករារាំខ្លួននោះទៀតផង។ តែយ៉ាងណាការបដិបត្តិខ្លួនបែបកាមសុខល្លិកានុយោគនេះ នឹងធ្វើឱ្យសម្រេចទៅបានឬមិនបាន ផលទីបំផុតនោះ កាលស្លាប់អំពីភពនេះ ហើយត្រូវបានទទួលសេចក្តីទុក្ខក្នុងអបាយភូមិ ដោយអាស្រ័យ សេចក្តីលោភ សេចក្តីវង្វេង និង សេចក្តីយល់ខុសនោះឯង។

សរុបសេចក្តីមកថា ការបដិបត្តិប្រាថ្នាដើម្បីឱ្យរួចផុតសេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងលោក ការបដិបត្តិបែបអត្តកិលមថានុយោគ និងកាមសុខល្លិកានុយោគ ទាំងនេះជាការបដិបត្តិរបស់ពួកអន្ធបុថុជ្ជន ជាចំណែកច្រើន ចំណែកការបដិបត្តិជារបៀបបំពេញ ទាន សីល សមថ-ភាវនាទាំងនេះ ជាការបដិបត្តិរបស់ពួកកល្យាណបុថុជ្ជនជាចំណែកច្រើន ប៉ុន្តែការបដិបត្តិទាំងនេះ ក៏មិនមែនជាផ្លូវដែលជម្រះកិលេស ឱ្យអស់ហើយឱ្យចូលដល់សេចក្តីរលត់ទុក្ខពិតប្រាកដបានទេ ព្រោះថាបុគ្គលទាំងនេះមិនយល់ក្នុងការបដិបត្តិ ជាផ្លូវដែលនាំឱ្យចូលដល់ការ រលត់ទុក្ខដោយសមុច្ឆេទនោះឯង។

ការបដិបត្តិ ដែលជាផ្លូវឱ្យដល់នូវសេចក្ដីរលត់ទុក្ខបាននោះគឺ ការចម្រើនមគ្គ ៨ ដែលទាក់ទងជាមួយសតិប្បដ្ឋាន ៤ប៉ុណ្ណោះ ឯការបដិបត្តិដែលក្រៅពីនេះ មិនថាការបដិបត្តិនោះ ប្រព្រឹត្តទៅយ៉ាងលំបាកលំបិន ឬប្រតិបត្តិអស់រយៈពេលយូរប៉ុណ្ណាក៏ដោយ មិនមែនជាផ្លូវដែលជម្រះកិលេសឱ្យអស់រលីង ហើយចូលដល់សេចក្ដីរលត់ទុក្ខទាំងពួងបានទេ មានន័យថា មានការប្រតិបត្តិនិងមានសេចក្ដីខិតខំ ព្យាយាមបន្តការប្រតិបត្តិនោះហើយ កុំគប្បីជឿថា ការប្រតិបត្តិ របស់ខ្លួននោះជាផ្លូវដែលត្រឹមត្រូវជានិច្ច ដោយហេតុនេះ ទើបព្រះពុទ្ធឃោសាចារ្យសម្ដែងទុកក្នុងវិសុទ្ធិមគ្គអដ្ឋកថា ថា:

**យថាភូតំ អជានន្តា សុទ្ធិកាមាបិ យេ ឥធ**

**វិសុទ្ធឹ នាធិគច្ឆន្តិ វាយមន្តាបិ យោគិនោ ។**

ព្រះយោគី គឺ អ្នកប្រកបដោយសេចក្ដីព្យាយាមក្នុងការចម្រើនភាវនាទាំងឡាយ សូម្បីមានការប្រាថ្នាសេចក្ដីបរិសុទ្ធក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយមានសេចក្ដីព្យាយាមប្រតិបត្តិ ប៉ុន្តែមិនយល់ក្នុងផ្លូវដែលត្រឹមត្រូវតាមសេចក្ដីពិតព្រះយោគីទាំងនោះ រមែងមិនអាចសម្រេចដល់សេចក្ដីបរិសុទ្ធបាន ។

ប៉ុន្តែទោះជាយ៉ាងណា បុគ្គលទាំងឡាយដែលនាំគ្នាប្រតិបត្តិតាមលទ្ធិ ផ្សេងៗ របស់ខ្លួនក៏មានការប្រាថ្នានឹងឱ្យចូលដល់នូវសេចក្តីរលត់ទុក្ខដូចគ្នាទាំងអស់ ប៉ុន្តែសេចក្តីទុក្ខផ្សេងៗ នោះ ក៏មិនរលត់តាមសេចក្តីប្រាថ្នា ត្រឡប់ជាធ្ងន់ក្រៃលែងឡើង ឬមិនដូច្នោះ ក៏មានការកើត ចាស់ ឈឺ ស្លាប់ នៅក្នុងសង្សារវដ្ត យឺតយូរដោយមិនមានទីបំផុត ទាំងនេះ ក៏ព្រោះថា បុគ្គលពួកខ្លះ ក្នុងលទ្ធិពុទ្ធសាសនាដែលមិនមានសេចក្តីប្រាថ្នា សម្មាសម្ពោធិញ្ញាណ បច្ចេកពោធិញ្ញាណ អគ្គសាវ័កពោធិញ្ញាណ មហាសាវ័កពោធិញ្ញាណណាមួយ ប្រាថ្នាឱ្យផុតទុក្ខចូលដល់ព្រះនិព្វាន ដោយត្រង់តែម្តង ដូចពោលពាក្យប្រាថ្នាថា **ឥទំមេបុញ្ញំ អាសវក្ខយំ វហំ ហោតុ** អ្នកនោះនៅមានសេចក្តីពេញចិត្តបដិបត្តិត្រឹមតែទាន សីល សមថៈ ភាវនា មិនបានបដិបត្តិឱ្យចូលដល់មគ្គក្នុងផ្លូវនៃសតិប្បដ្ឋាន ៤ ព្រោះហេតុនោះ ការបដិបត្តិដូច្នេះ ក៏រាប់ថានៅប្រព្រឹត្តទៅដោយ អំណាចលោភៈនៅឡើយ ដោយហេតុនេះ អ្នកបដិបត្តិទាំងនេះ ត្រូវនៅកើត ចាស់ ឈឺ ស្លាប់ នៅក្នុងវដ្តសង្សារយូរទៀត ផ្ទុយ គ្នាជាមួយសេចក្តីប្រាថ្នារបស់ខ្លួន។

អ្នកដែលបដិបត្តិអត្តកិលមថានុយោគនោះ ការបដិបត្តិដែលប្រព្រឹត្តទៅដោយអំណាចនៃទិដ្ឋិ និង មោហៈ ដូច្នោះ ទើបឱ្យផលទៅ

កើតក្នុងនិរយភូមិ ហើយអ្នកនោះថែមទាំងដឹងខ្លួនថា ការបដិបត្តិដូច្នេះ មិនមែនជាផ្លូវដែលជម្រះកិលេសឱ្យចូលដល់សេចក្តីរលត់ទុក្ខទេ។

ចំណែកអ្នកដែលបដិបត្តិ តាមបែបកាមសុខល្លិកានុយោគនោះ មិនមែនតែអ្នកកាន់លទ្ធិផ្សេងៗ បដិបត្តិដូច្នេះទេ សូម្បីអ្នកដែលកាន់លទ្ធិពុទ្ធសាសនាក៏បដិបត្តិដែរ ដូចអ្នកដែលមិនឃើញប្រយោជន៍ ក្នុងការបំពេញទាន សីល ភាវនា មានការយល់ឃើញថាសេចក្តីសុខដែលទាក់ទិននឹងព្រះនិព្វាននោះមិនមានដោយចំពោះ សេចក្តីពិត គឺក្នុងចន្លោះដែលមានជីវិតរស់នៅនេះ យើងមានសេចក្តីប្រាថ្នាយ៉ាងណាពេញចិត្តយ៉ាងណា ក៏បដិបត្តិទៅតាមសេចក្តីពេញចិត្តរបស់ខ្លួន យ៉ាងនោះ ដូចជា ចង់មើលអ្វីក៏មើល ចង់ស្តាប់អ្វីក៏ស្តាប់ ចង់ស៊ីអ្វីក៏ស៊ី ចង់ដេកក៏ដេក ចង់ទៅណាក៏ទៅ ចង់ធ្វើអ្វីក៏ធ្វើ ចង់និយាយអ្វីក៏និយាយជាដើម អ្នកទូន្មានយ៉ាងណាក៏គ្មាន ការបដិបត្តិខ្លួនយ៉ាងនេះឯង ហៅថាបដិបត្តិឱ្យផុតចាកទុក្ខ បានទទួលសេចក្តីសុខដូច្នេះ ការបដិបត្តិយ៉ាងនេះទើបប្រព្រឹត្តទៅដោយអំណាចលោភៈ ទិដ្ឋិ និង មោហៈ រមែងផ្តល់ផលឱ្យអ្នកនោះ ទៅកើតក្នុងអបាយភូមិណាមួយ ហើយអ្នកនោះថែមទាំងមិនមានសេចក្តីដឹងខ្លួនថា ការបដិបត្តិដូច្នេះ មិនមែនជាផ្លូវដែលជម្រះកិលេសឱ្យដល់ទីរលត់ទុក្ខ។

ពាក្យអធិប្បាយដូចពោលមកនេះ ជាការអធិប្បាយក្នុងសេចក្តីមិនដឹងក្នុងផ្លូវដែលនាំឱ្យដល់ទីរលត់ទុក្ខ។

## ៥.ការមិនដឹងក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអតីតៈ (បុព្វន្តេ អញ្ញាណំ)

ពាក្យថា **ខន្ធ ធាតុ អាយតនៈ** ដែលជាអតីតៈនោះ ជាការ - ពោលដោយធម្មាធិដ្ឋាន ប៉ុន្តែបើពោលដោយបុគ្គលាធិដ្ឋាន បានដល់សត្វទាំងឡាយដែលធ្លាប់កើត និងស្លាប់ទៅហើយនោះឯង ដូច្នោះក្នុងចំណុចដែលថា **បុព្វន្តេ អញ្ញាណំ** នេះ សំដៅដល់ ការមិនដឹងថា ខ្លួនឯងក្តី ឬអ្នកដទៃក្តី ធ្លាប់កើតជាមនុស្សខ្លះ ទេវតាខ្លះ ព្រហ្មខ្លះ អបាយសត្វខ្លះនោះឯង ។

## ៦.ការមិនដឹងក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអនាគត (អបរន្តេ អញ្ញាណំ)

ខន្ធ ធាតុ អាយតនៈ ដែលជាអនាគតនោះ បានដល់ សភាពជាមនុស្ស ទេវតា មារ ព្រហ្ម និង អបាយសត្វដែលតអំពីជាតិនេះ ដូច្នោះក្នុងចំណុចដែលថា **អបរន្តេ អញ្ញាណំ** នេះ សំដៅដល់អ្នកដែលមានសេចក្តីយល់ឃើញថា ខ្លួនឯងក្តី អ្នកដទៃក្តី កាលបើស្លាប់អំពីជាតិនេះហើយ ក៏មិនមានការកើតបន្តទៅទៀត។ ប៉ុន្តែមានសេចក្តីជឿថា សត្វទាំងឡាយរមែងធ្លាប់កើតមកពីជាតិមុន បុគ្គលដែលមានការយល់

ឃើញដូច្នេះ មានច្រើនលទ្ធិ កាលបើអ្នកកាន់លទ្ធិព្រះពុទ្ធសាសនា មានការយល់ឃើញដូច្នេះក៏នៅមាន បុគ្គលទាំងនេះមិនជឿថា បើស្លាប់ ហើយនឹងកើតតទៅទៀតទេ តែជឿថាធ្លាប់កើតមកហើយ ពីជាតិមុន ព្រោះអាស្រ័យបានជួបអ្នកដែលរលឹកជាតិនោះឯង ។

## ៧.ការមិនដឹងក្នុង ខន្ធ ធាតុ អាយតនៈ ដែលជា អតីតៈ និងអនាគត (បុព្វន្តាបរន្តេ អញ្ញាណំ)

ភាពជាមនុស្ស ទេវតា មារ ព្រហ្ម និងអបាយសត្វដែលធ្លាប់កើតមកហើយក្នុងអតីតៈ និងដែលកើតតទៅខាងមុខទៀត ដូច្នោះ ក្នុងចំណុចដែលថា **បុព្វន្តា បរន្តេ អញ្ញាណំ** នេះ សំដៅដល់អ្នកដែលមិនដឹងថា ខ្លួនយើងក្តី អ្នកដទៃក្តី ធ្លាប់កើតមកហើយ និងកើតតទៅខាងមុខទៀត ចំពោះបុគ្គលដែលមានសេចក្តីយល់ឃើញដូច្នេះ ក៏មានច្រើនលទ្ធិដូចគ្នា ព្រោះថា បុគ្គលពួកនេះ មិនធ្លាប់បានទទួលការសិក្សាក្នុងព្រះសូត្រ ព្រះអភិធម្ម ព្រះវិន័យ និងមិនធ្លាប់បាន បដិបត្តិវិបស្សនា ទាំងនៅមិនទាន់ធ្លាប់បានឃើញបានជួបអ្នកដែល រលឹកជាតិបាន ។

# ៨.ការមិនដឹងក្នុងនាមរូប ដែលកើតឡើងដោយអាស្រ័យមានហេតុឱ្យកើតឡើង តាមន័យបដិច្ចសមុប្បាទ (ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ)

សរីររាងកាយរបស់សត្វទាំងឡាយមានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយជាដើម ព្រមទាំងការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវទាំងនេះ សុទ្ធតែជាផលដែលកើតអំពីហេតុ គឺការប្រព្រឹត្តធ្វើដោយកាយ វាចា ចិត្ត ទាំងល្អនិងអាក្រក់ ដែលជាហេតុចាស់ មានអវិជ្ជា តណ្ហាជាមូល នឹងដោយអាស្រ័យ មានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ជាដើម ព្រមទាំងការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវផងនោះ ក៏នាំឱ្យមានការប្រព្រឹត្តធ្វើដោយកាយ វាចា ចិត្ត ទាំងល្អទាំងអាក្រក់ បន្ថែមទៀត ដែលជាហេតុថ្មី មានតណ្ហា អវិជ្ជា ជាមូល ធ្វើឱ្យមានការឃើញ និងការឮជាដើម ដែលហៅថា អ្នកនោះ អ្នកនេះ ដែលជាផលតទៅទៀត ហេតុ និង ផល ដូចដែលពោលមកនេះ បើសម្ដែងតាមន័យនៃបដិច្ចសមុប្បាទ គឺការប្រព្រឹត្តផ្សេងៗ ដែលជាហេតុចាស់នោះ បានដល់ អវិជ្ជា សង្ខារ តណ្ហា ឧបាទាន កម្មភវៈ របស់សត្វទាំងឡាយ ហើយការឃើញ ការឮជាដើម ដែលផលកើតឡើងនោះ បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និង

វេទនា ការប្រព្រឹត្តដោយកាយ វាចា ចិត្ត របស់សត្វទាំងឡាយ ដែលជាហេតុថ្មីនោះ បានដល់តណ្ហា ឧបាទាន កម្មភវៈ អវិជ្ជា និងសង្ខារ សត្វទាំងឡាយ និងការឃើញ ការឮជាដើម ដែលជាផលកើតតទៅទៀតនោះ បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ។

ការប្រព្រឹត្តរបស់សត្វទាំងឡាយ ដូចដែលបានពោលមកនេះ កាលបើពិចារណាក៏ឃើញបានថា មិនមានអ្វីផ្សេងក្រៅអំពីធម៌ដែលជាហេតុផល ដែលអាស្រ័យគ្នានិងគ្នាកើតឡើងប៉ុណ្ណោះ ប៉ុន្តែអន្ធបុថុជ្ជន គឺអ្នកដែលមិនមានបញ្ញានោះ រមែងមិនដឹងដល់ការប្រព្រឹត្តទៅរបស់សត្វទាំងឡាយតាមបដិច្ចសមុប្បាទដូចពោលមកនេះ យល់ថាសត្វលោកដែលប្រាកដនៅក្នុងលោករាល់ថ្ងៃនេះ កើតឡើងព្រោះមានព្រះជាអ្នកសាង បុគ្គលពួកខ្លះក៏យល់ថាមិនមានហេតុផល សត្វទាំងឡាយកើតមកបានក៏ព្រោះមានមាតាបិតានោះឯង ។

សភាពមិនដឹងក្នុងហេតុផល នៃការប្រព្រឹត្តទៅរបស់សត្វទាំងឡាយក្នុងបដិច្ចសមុប្បាទនេះឯង ឈ្មោះថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** ។

ម្យ៉ាងទៀត អវិជ្ជា ដែលមានសភាពបិទបាំងសេចក្ដីពិត មិនឱ្យកើតសេចក្ដីដឹងនោះ ចែកចេញជាច្រើនប្រភេទ គឺៈ

១.បុគ្គលពួកខ្លះ មិនដឹងថា ការប្រព្រឹត្តយ៉ាងនេះល្អជាកុសល ការប្រព្រឹត្តយ៉ាងនេះអាក្រក់ជាអកុសល ដោយអំណាចនៃអវិជ្ជា ដែលបិទបាំងទុកមិនឱ្យដឹង ព្រោះហេតុដូច្នោះ បុគ្គលពួកនេះទើបក្លាហានក្នុងការធ្វើទុច្ចរិតផ្សេងៗ ដោយមិនញញើត អវិជ្ជាប្រភេទនេះ ជាអវិជ្ជាដែលក្រាស់ណាស់ ។

២.បុគ្គលពួកខ្លះ ដឹងថាការប្រព្រឹត្តយ៉ាងនេះល្អជាកុសល យ៉ាងនេះមិនល្អជាអកុសល ព្រោះហេតុដូច្នោះ បុគ្គលជំពូកនេះ បើខណៈដែលមានអកុសលកើតឡើង ក៏អាចរំងាប់បានមិនបណ្តោយឱ្យកន្លងដល់កាយ ឬ វាចា ហើយផ្លាស់ប្តូរចិត្តនិងការប្រព្រឹត្តនោះឱ្យជាកុសលកើតឡើងវិញ អវិជ្ជារបស់បុគ្គលជំពូកនេះចាត់ថា ជាអវិជ្ជាដែលស្តើងហើយ ។

៣.បុគ្គលដែលបានសម្រេចជា សោតាបន្ន សកទាគាមី អនាគាមីនោះ បានឈ្មោះថាជាអ្នកដែលឃើញច្បាស់ក្នុងអរិយសច្ចៈ៤ហើយ ប៉ុន្តែនៅមិនទាន់បានទម្លាយអវិជ្ជាឱ្យអស់រលីងនៅឡើយ អវិជ្ជារបស់ព្រះអរិយបុគ្គលទាំងនេះ ជាអវិជ្ជាដែលស្រាលស្តើងជាទី បំផុត ។

បុគ្គលដែលអស់អវិជ្ជាបាននោះមានតែព្រះអរហន្តមួយ ប៉ុណ្ណោះ ដូច្នោះ ការបិទបាំងមិនឱ្យដឹងនូវអវិជ្ជាតាមសេចក្តីពិត ទើបមិនដល់ព្រះអរហន្តទាំងឡាយ តែប្រសិនបើសួរថា ព្រះអរហន្តបើមិនមានអវិជ្ជាហើយ ក៏អាចដឹងអ្វី ៗ ទូទៅបានទាំងអស់ឬ ? មិនជាដូច្នោះទេ ការឆ្លើយយ៉ាងនេះត្រូវហើយ តែកម្លាំងបញ្ញា ប្រសិនបើជា បញ្ញារបស់ព្រះសម្មាសម្ពុទ្ធ ក៏ដឹងបានទូទៅទាំងអស់មិនមានសល់ ហើយបើជាបញ្ញារបស់ព្រះបច្ចេកពុទ្ធ ក៏ដឹងបានត្រឹមតែសភាវៈ គឺការប្រព្រឹត្តទៅរបស់នាមរូបដែលជាអត្ថរស សម្រាប់ការដឹងក្នុងសភាពនៃការប្រព្រឹត្តទៅរបស់នាមរូបតាមបរិយត្តិ ដែលជាធម្មរសនោះ ក៏ដឹងមិនបាន បើជាបញ្ញារបស់អគ្គសាវ័ក មហាសាវ័ក ក៏ដឹងបាន ក្នុងអត្ថរសធម្មរសបានទាំងពីរ តែមិនអាចដឹងស្មើនឹងបញ្ញារបស់ព្រះសម្មាសម្ពុទ្ធបានឡើយ ។

សរុបសេចក្តីមកថា សូម្បីអ្នកដែលបានសម្រេចជាព្រះអរហន្តប្រាស់ចាកអវិជ្ជាហើយក៏ដោយ បើមិនមែនជា បដិសម្ភិទាបត្តៈ ហើយមិនបានសិក្សាក្នុងព្រះត្រៃបិដកអដ្ឋកថាទេ ក៏មិនអាចយល់ ក្នុងព្រះបរិយត្តិធមិបានឡើយ សូម្បីថាបានសិក្សាយល់ក្នុងព្រះបរិយត្តិធមិយ៉ាងល្អហើយក៏ដោយ នៅមិនទាន់អាចដឹងទៅដល់អាធ្យាស្រ័យរបស់

វេនេយ្យសត្វទាំងអស់ដោយហ្មត់ចត់ពិតប្រាកដបានឡើយ។ ព្រោះការដឹងដូច្នេះ មិនមែនជាវិស័យរបស់ព្រះសាវ័កទាំងឡាយទេ ជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ ហើយក្នុងកាលដែលព្រះអរហន្តទាំងឡាយ ដឹងទូទៅមិនបាននោះ ក៏មិនមែនព្រោះអវិជ្ជាបិទបាំងមិនឱ្យដឹងនោះទេ តែព្រោះកំលាំងនៃបញ្ញាមិនពេញគ្រប់គ្រាន់ប៉ុណ្ណោះ ឧបមាដូចលេខាម្នាក់ដែលមើលមិនឃើញនូវវត្ថុដែលឆ្ងាយក្នុងវេលាថ្ងៃត្រង់ ការមើលមិនឃើញនេះ មិនមែនកើតព្រោះ ងងឹតបិទបាំងទេ តែកើតព្រោះកម្លាំងនៃខ្សែភ្នែកមិនបរិបូរណ៍ ចំនុចនេះយ៉ាងណា ព្រះអរហន្តដែលមិនអាចដឹងទូទៅបាន ក៏ព្រោះកម្លាំងនៃបញ្ញាមិនបរិបូរណ៍ដូចដែលបានពោលមកហើយដូច្នោះ។

ការបិទបាំងដែលមិនឱ្យដឹងតាមសេចក្តីពិតនោះ មាន ៨ យ៉ាង គឺ សច្ចៈ ៤ បុព្វន្តៈ អបរន្តៈ បុព្វន្តាបរន្តៈ និង បដិច្ចសមុប្បាទប៉ុណ្ណោះ។ ចំណែកការមិនយល់ក្នុងរឿងផ្សេងៗ នោះមិនទាក់ទងជាមួយអវិជ្ជាទេ ដូចមានឧទាហរណ៍ដូច្នេះថា ព្រះសារីបុត្រជាអ្នកមានបញ្ញាលើសសាវ័ក-ទាំងឡាយ វៀរលែងតែព្រះសម្មាសម្ពុទ្ធចេញហើយ ក៏មិនមានអ្នកណានឹងមានបញ្ញាស្មើឡើយ ក៏ធ្លាប់ភ្លាំងភ្លាត់ខុសក្នុងការឱ្យកម្មដ្ឋានដល់ភិក្ខុកំលោះដែលជាសិស្សរបស់លោក ពោលគឺលោកយល់ថាភិក្ខុ

កំលោះរូបនេះនៅអាយុតិច ព្រោះហេតុដូច្នោះ ចិត្តនឹងត្រូវបង្អោនទៅក្នុងកាមអារម្មណ៍ បើដូច្នេះ លោកក៏ឱ្យពិចារណាអសុភកម្មដ្ឋាន ភិក្ខុកំលោះក៏ព្យាយាមពិចារណាអសុភកម្មដ្ឋានរហូតដល់៤ ខែ មិនបានផលណាមួយឡើយ សូម្បីតែនិមិត្តក៏មិនប្រាកដ ព្រោះកម្មដ្ឋាននេះមិនត្រូវជាមួយចិត្តរបស់ខ្លួន ព្រះសេនាសារីបុត្រទើបនាំសេចក្តីនោះទៅទូលថ្វាយព្រះដ៏មានព្រះភាគជាម្ចាស់ឱ្យទ្រង់ជ្រាប ។

ព្រះដ៏មានព្រះភាគ ទើបទ្រង់និមិត្តផ្កាឈូកក្រហមឱ្យភិក្ខុកំលោះនោះមើល ព្រោះទ្រង់ជ្រាបអាធ្យាស្រ័យរបស់ភិក្ខុកំលោះនោះ ធ្លាប់កើតជាជាងមាសជាប់បន្តគ្នាមក ៥០០ជាតិហើយ ព្រោះហេតុដូច្នោះផ្កាឈូកមាសនេះទើបជាកម្មដ្ឋាន ដែលសមរម្យដល់អាធ្យាស្រ័យ កាលបើភិក្ខុកំពុងមើលផ្កាឈូកនោះ ព្រះអង្គក៏ទ្រង់និមិត្តឱ្យត្របកផ្កាឈូកនោះស្រពោនបន្តិចម្តង១ ដើម្បីឱ្យសភាវៈដែលជាអនិច្ចៈប្រាកដ ក្នុងថ្ងៃនោះឯង ភិក្ខុកំលោះនោះ ក៏បានសម្រេចជាព្រះអរហន្តខីណាស្រព

រឿងដែលលើកមកនេះ ជាចំណុចដែលសម្តែងឱ្យយើងឃើញថា ជាអ្នកដែលអស់អវិជ្ជាហើយ ប៉ុន្តែដែលនៅមិនទាន់ដឹងនូវវត្ថុខ្លះនោះ មិនមែនព្រោះអវិជ្ជាបិទបាំងទេ គឺព្រោះតែកម្លាំងបញ្ញាមិនគ្រប់គ្រាន់ ដូចដែលពោលមកហើយនោះឯង ។

## លក្ខណាទិចតុក្កៈរបស់ អវិជ្ជា

**១.អញ្ញាណលក្ខណា** មានការមិនដឹងជាលក្ខណៈ ។

**២.សម្មោហនរសា** ធ្វើឱ្យធម៌ដែលប្រកបជាមួយខ្លួនមានសេចក្ដីវង្វេងជាកិច្ច ។

**៣.ឆាទនបច្ចុប្បដ្ឋានា** ជាធម្មជាតិដែលបិទបាំងសភាវៈក្នុងអារម្មណ៍នោះៗ ជាអាការៈប្រាកដ ។

**៤.អាសវបទដ្ឋានា** មានអាសវៈ ៣ ជាហេតុជិត (វៀរខ្លួនឯង) ។

## សង្ខារ

ពាក្យថា **សង្ខារ** នេះមានន័យថា ធម៌ដែលតាក់តែងឱ្យផលធម៌កើតឡើង ដូចមានវចនត្ថៈថាៈ

**សង្ខតំ សង្ខរោតិ អភិសង្ខរោន្តីតិ = សង្ខារា**

ធម៌ទាំងឡាយណា រមែងតាក់តែងសង្ខតធម៌ដែលជាផលដោយត្រង់ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **សង្ខារ** បានដល់ ចេតនានៅក្នុងអកុសល និងលោកិយកុសល ។

## ន័យម្យ៉ាងទៀត

**សង្ខតំ កាយវចីមនោកម្មំ អភិសង្ខរោន្តិ ឯតេហីតិ = សង្ខារា**

សត្វទាំងឡាយរមែងតាក់តែងកាយកម្ម វចីកម្ម មនោកម្ម ដែលជាសង្ខតធម៌ដោយចេតនាទាំងនោះ ព្រោះហេតុនោះ ចេតនាដែលជា

ហេតុនៃការតាក់តែងទាំងនោះ ឈ្មោះថា **សង្ខារ** បានដល់ ចេតនានៅក្នុងអកុសល និងលោកិយកុសល ។

## សង្ខារដែលជាផលរបស់អវិជ្ជា ៦ យ៉ាង

**១.បុញ្ញាភិសង្ខារ** កុសលចេតនាជាអ្នកតាក់តែង លោកិយ-កុសលវិបាក និងកុសលកម្មជរូបដោយត្រង់ បានដល់ មហាកុសលចេតនា ៨ រូបាវចរកុសលចេតនា ៥ ។

**២.អបុញ្ញាភិសង្ខារ** អកុសលចេតនាជាអ្នកតាក់តែងអកុសលវិបាក និងអកុសលកម្មជរូបដោយត្រង់ បានដល់ អកុសលចេតនា ១២ ។

**៣.អនេញ្ជាភិសង្ខារ** បានដល់ កុសលជាអ្នកតាក់តែងដោយត្រង់ បានដល់អរូបាវចរកុសល ៤ ។

**៤.កាយសង្ខារ** ចេតនាដែលជាអ្នកតាក់តែងកាយទុច្ចរិត និងកាយសុចរិតឱ្យសម្រេច បានដល់អកុសលចេតនា ១២ មហាកុសលចេតនា ៨ ដែលទាក់ទងនឹងផ្លូវកាយ ។

**៥.វចីសង្ខារ** ចេតនាដែលជាអ្នកតាក់តែងវចីទុច្ចរិត និងវចី-សុចរិតឱ្យសម្រេច បានដល់អកុសលចេតនា ១២ មហាកុសលចេតនា ៨ ដែលទាក់ទងនឹងផ្លូវវាចា ។

**៦.ចិត្តសង្ខារ** ចេតនាដែលជាអ្នកតាក់តែងមនោទុច្ចរិត និងមនោសុចរិតឱ្យសម្រេច បានដល់អកុសលចេតនា ១២ និង លោកិយ-កុសលចេតនា ១៧ ដែលទាក់ទងនឹងផ្លូវចិត្ត ។

សម្រាប់លោកុត្តរកុសលចេតនានោះ មានឈ្មោះថា **បុញ្ញ** ក៏ពិត តែមិនឈ្មោះថា **បុញ្ញាភិសង្ខារ** ទេ ព្រោះមិនមានតួនាទីធ្វើឱ្យកើតភពជាតិដែលជាវដ្តសង្សារ តែមានតួនាទីទម្លាយភព ជាតិ ប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបមិននាំមកសម្តែងក្នុងទីនេះ ។

វិចនត្ថៈរបស់ពាក្យថា **បុញ្ញាភិសង្ខារ** ជាដើម

**អត្តនោ សន្តានំ បុនាតិ សោធេតីតិ = បុញ្ញំ**

ធម្មជាតិណាវមែងជម្រះខន្ធសន្តាន របស់ខ្លួនឱ្យស្អាតព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **បុណ្យ** ។

**ន បុញ្ញំ = អបុញ្ញំ**

ធម្មជាតិណាជាបដិបក្ខចំពោះបុណ្យ ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **បាប** ។

**ន ឥញ្ជតីតិ = អនិញ្ជំ, អនិញ្ជំយេវ = អានេញ្ជំ:**

ធម្មជាតិណាជាអ្នកតម្កល់មាំមិនរិបរិត ព្រោះហេតុនោះ ធម្ម-ជាតិនោះ ឈ្មោះថា **អនិញ្ជៈ** ធម្មជាតិដែលមិនរិបរិតនោះឯងឈ្មោះថា **អានេញ្ជៈ** ។

**បុញ្ញញ្ច តំ អភិសង្ខរោ ចាតិ = បុញ្ញាភិសង្ខារោ**

ធម្មជាតិណាជាបុណ្យផង ជាអ្នកតាក់តែងដោយត្រង់ផង ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **បុញ្ញាភិសង្ខារ** ។

**អបុញ្ញញ្ច តំ អភិសង្ខរោ ចាតិ = អបុញ្ញាភិសង្ខារោ**

ធម្មជាតិណាជាបាបផង ជាអ្នកតាក់តែងដោយត្រង់ផង ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **អបុញ្ញាភិសង្ខារ** ។

**អានេញ្ជញ្ច តំ អភិសង្ខរោ ចាតិ = អានេញ្ជាភិសង្ខារោ**

ធម្មជាតិណាតាំងមាំមិនញាប់ញ័រផង ជាអ្នកតាក់តែងដោយត្រង់ផង ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **អានេញ្ជាភិសង្ខារ**

**កាយំ សង្ខរោតីតិ = កាយសង្ខារោ**

ធម្មជាតិណាជាអ្នកតាក់តែងនូវកាយ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **កាយសង្ខារ** ។

**វាចំ សង្ខរោតីតិ = វចីសង្ខារោ**

ធម្មជាតិណាជាអ្នកតាក់តែងនូវវាចា ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **វចីសង្ខារ** ។

**ចិត្តំ សង្ខារោតីតិ = ចិត្តសង្ខារោ**

ធម្មជាតិណាជាអ្នកតាក់តែងនូវចិត្ត ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **ចិត្តសង្ខារ** ។

ក្នុងសង្ខារដែលជាផលរបស់អវិជ្ជាទាំងនោះ បុញ្ញាភិសង្ខារដែលទាក់ទង់ជាមួយមហាកុសល និងអបុញ្ញាភិសង្ខារទាំងនេះ សម្រេចបានដោយ កាយកម្ម វចីកម្ម និង មនោកម្ម ។

បុញ្ញាភិសង្ខារដែលទាក់ទងជាមួយរូបាវចរកុសល និងអានេញ្ជាភិសង្ខារទាំងនេះ សម្រេចបានដោយមនោកម្មតែម្យ៉ាង ។

**បុញ្ញាភិសង្ខារ** សម្រេចបានដោយអំណាច ទាន សីល ភាវនា

**អបុញ្ញាភិសង្ខារ** សម្រេចបាដោយអំណាច ទុច្ចរិត ១០

**អានេញ្ជាភិសង្ខារ** សម្រេចបានដោយអំណាចភាវនា

**ធម៌ឈ្មោះថាសង្ខារដែលមិនមែនជាផលរបស់អវិជ្ជា ៧ យ៉ាង**

**១.សង្ខតសង្ខារ** ធម៌ដែលត្រូវបច្ច័យទាំង ៤ តាក់តែងបានដល់ ចិត្ត ចេតសិក រូប ទាំងអស់ ដូចជា **អនិច្ចា វត សង្ខារា ។**

**២.អភិសង្ខតសង្ខារ** នាមរូបដែលត្រូវកម្មជាអ្នកតាក់តែងដោយត្រង់ បានដល់លោកិយវិបាក និងកម្មជរូប ហើយអភិសង្ខតសង្ខារនោះក៏សង្គ្រោះចូលក្នុងសង្ខតសង្ខារ ដូចគ្នា ។

**៣.អភិសង្ខរណកសង្ខារ** ធម៌ដែលជាអ្នកតាក់តែងលោកិយវិបាក និងកម្មជរូបដោយត្រង់ បានដល់ អកុសលចេតនា ១២ និងលោកិយកុសលចេតនា ១៧ ។

**៤.បយោគាភិសង្ខារ** សេចក្ដីព្យាយាមផ្លូវកាយនិងផ្លូវចិត្ត បានដល់វីរិយចេតសិក ដែលទាក់ទងជាមួយកាយកម្ម និង មនោកម្ម ។

**៥.កាយសង្ខារ** ធម្មជាតិដែលតាក់តែងរាងកាយ បានដល់ខ្យល់ដកដង្ហើមចេញចូល ។

**៦.វចីសង្ខារ** ធម្មជាតិដែលតាក់តែងវាចា បានដល់ វិតក្ក និងវិចារ ។

**៧.ចិត្តសង្ខារ** ធម្មជាតិតាក់តែងចិត្ត បានដល់សញ្ញា វេទនា ឬចេតសិក ៥០ (វៀរវិតក្កនិងវិចារ) ។

**ចំណាំ** ក្នុងចំណុចទី ៤ គឺ បយោគាភិសង្ខារនោះ មិនយកវីរិយចេតសិកដែលទាក់ទងជាមួយវចីកម្មទេ ព្រោះផ្លូវវាចានោះ វីរិយ-ចេតសិកមិនបានជាប្រធាន ទាក់ទងតែជាមួយវិតក្កនិងវិចារប៉ុណ្ណោះ ។

**បុញ្ញាភិសង្ខារប្រាកដឡើង ព្រោះអាស្រ័យវិជ្ជាជាហេតុនោះគឺៈ**

អ្នកដែលមានសេចក្ដីជ្រះថ្លា ពេញចិត្តក្នុងការធ្វើបុណ្យផ្សេងៗ មានការបំពេញទាន រក្សាសីល ចម្រើនភាវនានោះ ដោយច្រើនចង់បានសេចក្ដីសុខសប្បាយតទៅក្នុងជាតិខាងមុខ ឱ្យច្រើនជាងខ្លួនដែលបានទទួលក្នុងបច្ចុប្បន្ននេះ នឹងឃើញបានថា បើបានស្ដាប់ បានអាន រឿងរ៉ាវដែលពោលដល់អ្នកដែលបានកើតជាសេដ្ឋី គហបតី ព្រះរាជា ព្រះរាជានីជាមនុស្សល្អ មានអំណាច មានសេចក្ដីឆ្លៀវឆ្លាត ឬបានកើតជាទេវបុត្រ

ទេវធីតា មានទិព្វសម្បត្តិច្រើនមហិមា មានអាយុវែង មិនមានសេចក្តីលំបាកដោយប្រការណាមួយ ទាំងនេះសុទ្ធតែជាផល ដែលបានមកពីការឱ្យទាន រក្សាសីល ចម្រើនភាវនាទាំងអស់ ដូច្នោះហើយ អ្នកនោះក៏មានការសរសើរត្រេកអរចង់បានសេចក្តីសុខ ទាំងនេះហើយ ក៏ព្យាយាមបំពេញកុសល មានការឱ្យទានខ្លះ រក្សាសីលខ្លះ ស្តាប់ធម៌ទេសនាខ្លះ ធ្វើសមថៈខ្លះ វិបស្សនាខ្លះ ហើយតាំងប្រាថ្នាថា **ឥទំមេបុញ្ញំ និព្វានស្ស បច្ចយោ ហោតុ** ពាក្យប្រាថ្នានេះជាពាក្យប្រាថ្នាដោយវាចាប៉ុណ្ណោះ ចំណែកចិត្តនោះរមែងបង្អោន ចូលកាន់សេចក្តីសុខផ្សេងៗ ដូចដែលបានពោលមកហើយ ដូច្នេះ ព្រោះថា អ្នកនោះមើលមិនឃើញទោសនៃសមុទយៈ ហើយមើល មិនឃើញគុណរបស់និរោធ និងមគ្គ ការមើលមិនឃើញគុណ និងទោសនេះ ក៏ព្រោះមោហៈនោះឯង ។

បុគ្គលខ្លះយល់ឃើញថា ការបានកើតជាមនុស្ស ឬទេវតានោះ សូម្បីថាមានសេចក្តីសុខក៏ពិត ប៉ុន្តែសេចក្តីសុខនោះនៅមិនទាន់ប្រណិតស្មើនឹងសេចក្តីសុខរបស់រូបព្រហ្មទេ ព្រោះរូបព្រហ្មនោះ មាន អាយុវែង មានអំណាចច្រើនជាង ភាពស្រស់ស្អាតរបស់រាងកាយ និងវិមានក៏ប្រណីតជាង សេចក្តីទុក្ខកាយទុក្ខចិត្ត សូម្បីតែបន្តិចបន្តួច ក៏មិន

មានឡើយ ព្រោះហេតុដូច្នោះ ទើបព្យាយាមធ្វើសមថកម្មដ្ឋាន រហូតបានរូបឈាន អ្នកដែលមានការយល់ដូច្នោះ ក៏ព្រោះ មើលមិនឃើញទោសនិងគុណរបស់អរិយសច្ចៈ៤ ដោយអំណាច នៃមោហៈនោះឯង ព្រោះហេតុនោះទើបពោលថា អវិជ្ជាជាហេតុ បុញ្ញាភិ-សង្ខារជាផល ។

**អបុញ្ញាភិសង្ខារប្រាកដឡើងព្រោះអាស្រ័យអវិជ្ជាជាហេតុនោះគឺ:**

បុគ្គលខ្លះមិនជឿថាការធ្វើល្អនោះជាបុណ្យ ការធ្វើអាក្រក់ជាបាប ព្រោះហេតុនោះបុគ្គលជំពូកនោះ ទើបមានសេចក្ដីពេញចិត្តធ្វើទុច្ចរិតផ្សេងៗ មានការសម្លាប់សត្វ លួចទ្រព្យគេ បោកបញ្ឆោត សេពសុរាជាដើម ឬបុគ្គលខ្លះក៏ដឹងថា ការធ្វើអាក្រក់ផ្សេងៗនោះ មិនល្អជាបាបតែខ្លួនលះមិនបាន ព្រោះហេតុនោះ បុគ្គលជំពូកនោះក៏ពេញចិត្តធ្វើទុច្ចរិតផ្សេងៗ ដូចគ្នា ឬបុគ្គលដែលរាប់អានកាន់លទ្ធិព្រះជាម្ចាស់ផ្សេងៗ យល់ថា ប្រសិនបើសម្លាប់សត្វយកទៅ បូជាព្រះហើយ ព្រះនោះនឹងបណ្ដាលឱ្យសម្រេចតាមសេចក្ដី ប្រាថ្នារបស់ខ្លួន និងគ្រប់គ្រងឱ្យត្រជាក់ត្រជុំ សុខសប្បាយរហូត អស់មួយជីវិត បើស្លាប់ពីលោកនេះហើយ ព្រះនោះក៏នឹងចាត់ បញ្ជូនឱ្យវិញ្ញាណរបស់ខ្លួនឡើងទៅកាន់ស្ថានសួគ៌ព្រោះហេតុនោះបុគ្គលជំពូកនេះទើបសម្លាប់សត្វផ្សេងៗ ដើម្បីយកទៅបូជាវត្ថុដែលខ្លួន គោរពនោះ ។

ការធ្វើទុច្ចរិតផ្សេងៗ របស់បុគ្គលដូចពោលមកនេះ ក៏ព្រោះមើលមិនឃើញទោសរបស់សមុទយៈ ហើយនឹកទៅមិនដល់គុណរបស់និរោធ និងមគ្គ ដោយអំណាចនៃមោហៈ បិទបាំងទុកនោះឯង ព្រោះហេតុនោះ ទើបនិយាយបានថា អវិជ្ជាជាហេតុ អបុញ្ញាភិសង្ខារជាផល ។

## អានេញ្ជាភិសង្ខារប្រាកដឡើង ព្រោះអាស្រ័យអវិជ្ជាជាហេតុនោះគឺ:

បុគ្គលពួកខ្លះក៏មានការយល់ឃើញថា សេចក្ដីទុក្ខ សេចក្ដីក្ដៅក្រហាយផ្សេងៗ ដែលសត្វទាំងឡាយកំពុងបានទទួលនោះ ដោយសារមកពីរូបធម៌នោះជាហេតុ ព្រោះបើមានភ្នែក ត្រចៀក ច្រមុះ អណ្ដាតកាយ ហើយក៏ត្រូវការចង់ឃើញ ចង់ឮ ចង់ដឹងក្លិន ចង់ដឹងរស ចង់ពាល់ត្រូវទាំងនេះ បើមិនបានទៅតាមសេចក្ដីប្រាថ្នាហើយ ក៏រមែងកើតសេចក្ដីក្ដៅក្រហាយ ឬការឈឺចាប់មិនសប្បាយផ្សេងៗ ក៏ព្រោះអាស្រ័យ មានរូបរាងកាយនោះឯង ប្រសិនបើមិនមានរូបរាងកាយសេចក្ដីទុក្ខផ្សេងៗ ក៏មិនមាន មានតែសេចក្ដីសុខម្យ៉ាង ព្រោះហេតុនោះ បុគ្គលជំពូកនោះ ទើបព្យាយាមរកផ្លូវដែលមិនឱ្យមានរូបកើត

ឡើងដោយព្យាយាមធ្វើសមថកម្មដ្ឋាន បានឈានតាមលំដាប់ រហូតដល់អរូបឈាន ។

ឬអ្នកដែលបានរូបឈានហើយ និងពួកអរូបព្រហ្មទាំងឡាយ មានការយល់ឃើញថា រូបឈានដែលខ្លួនបាននេះ បើប្រៀបធៀប ជាមួយអរូបឈាននៅមិនទាន់មានសេចក្ដីប្រណីតទេ ព្រោះនៅញាប់ញ័រ ដោយអំណាចនៃអង្គឈាននិងអារម្មណ៍ សម្រាប់អរូបឈាននោះថា ដោយអង្គឈានមានតែឧបេក្ខា និងឯកគ្គតាដែលជាសភាវៈ តាំងមាំ មិនញាប់ញ័រ ពោលដោយអារម្មណ៍ មានសេចក្ដីល្អិតច្រើនជាង-អារម្មណ៍របស់រូបឈាន ព្រោះហេតុនោះ អ្នកដែលបានអរូបឈាន ទើបមានសេចក្ដីសុខច្រើន ហើយបើស្លាប់ពីលោកនេះ ក៏បានទៅកើត ក្នុងអរូបព្រហ្ម មានតែនាមធម៌ ផុតពីទុក្ខទាំងពួង ដូច្នោះអ្នកទាំងនោះ ទើបព្យាយាមធ្វើឈានតទៅរហូតបានដល់ អរូបឈាន ។

បុគ្គលដែលមានការយល់ឃើញដូចពោលមកនេះ ក៏ព្រោះថា នៅមានសេចក្ដីល្ងង់បិទបាំងមិនឱ្យឃើញក្នុងអរិយសច្ចៈ ៤ សូម្បីពួក អរូបព្រហ្មទាំងឡាយមិនមានសេចក្ដីទុក្ខកាយទុក្ខចិត្ត ព្រោះមិនមាន វត្ថុ នៅជុំវិញដែលនឹងឱ្យកើតសេចក្ដីក្ដៅក្រហាយផ្សេងៗ ក៏ដោយ ក៏ នៅតែគេចមិនផុតពីសេចក្ដីស្លាប់ដែលជាមរណៈទុក្ខបានឡើយ ។

ម្យ៉ាងទៀត បើអំណាចនៃអរូបឈានអស់ហើយ ត្រូវច្យុតិមកកើតជាមនុស្ស ឬ ទេវតា បានជួបជាមួយសេចក្តីទុក្ខសេចក្តីលំបាកផ្សេងៗ ដែលមាននៅក្នុងមនុស្សលោក និងទេវលោកនោះ ហើយបើស្លាប់ពីមនុស្សនិងទេវតាហើយ អាចនឹងទៅកើតក្នុងអបាយភូមិ ជួបជាមួយមហាទុក្ខក៏ថាបាន ការដែលមិនឃើញទោសនៃអរូបឈាន និងអរូបព្រហ្មនេះឯង ទើបបានឈ្មោះថា **ទុក្ខេ អញ្ញាណំ** ។

ក្នុងការដែលមានសេចក្តីត្រេកអរ ពេញចិត្តចង់បានអរូបឈាន ចង់ជាអរូបព្រហ្មនោះ ក៏ដោយអំណាចនៃតណ្ហាដែលជាតួហេតុឱ្យកើតសេចក្តីទុក្ខ តែអ្នកនោះក៏មិនឃើញទោសនៃការត្រេកអរពេញចិត្តក្នុងអរូបឈាន ដូច្នេះហើយទើបឈ្មោះថា **ទុក្ខសមុទយេ អញ្ញាណំ** ។

អ្នកដែលកើតជាអរូបព្រហ្មនោះ សង្កត់សង្កិនសេចក្តីទុក្ខបានដោយវិក្ខម្ភនៈប៉ុណ្ណោះ ព្រោះហេតុនោះ សេចក្តីសុខដែលពួកអរូប-ព្រហ្មបានទទួលនោះ ទើបមិនមែនជាសេចក្តីសុខយ៉ាងពិតប្រាកដ ជាសេចក្តីសុខដែលទាក់ទងដោយសង្ខារទុក្ខ និង វិបរិណាមទុក្ខ ការលះទុក្ខបានដោយសមុច្ឆេទ នឹងមានសេចក្តីសុខយ៉ាងពិតប្រាកដ មានតែព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ តែអ្នកនោះរកមិនឃើញ គិតថាសេចក្តីសុខក្នុងអរូបឈាន និង អរូបព្រហ្មនោះ ជាសេចក្តីសុខយ៉ាងពិសេស ដូច្នេះហើយទើបបានឈ្មោះថា **ទុក្ខនិរោធេ អញ្ញាណំ** ។

ពិតណាស់ ចំណុចបដិបត្តិដែលជាផ្លូវអាចកាត់ផ្តាច់កិលេសជាសមុច្ឆេទ និងនាំឱ្យចូលដល់សេចក្តីរលត់ទុក្ខបាននោះ គឺអរិយមគ្គអង្គ ៨ ដែលទាក់ទងជាមួយការចម្រើនវិបស្សនា តែអ្នកនោះដឹងមិនដល់យល់ថាការចម្រើនសមថកម្មដ្ឋាននេះឯង អាចនាំឱ្យចូលដល់សេចក្តីសុខផុតពីទុក្ខបាន ដូច្នេះទើបបានឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទាយ-អញ្ញាណំ** ។

## ពោលថាអ្នកដែលប្រាសចាកអវិជ្ជាហើយ មិនបំពេញទាន សីល ភាវនា ឬ ?

អ្នកខ្លះអាចយល់ខុសថា អ្នកដែលសម្រេចជាព្រះអរហន្តហើយនោះបុណ្យក៏មិនកើត បាបក៏មិនកើត ដោយសារតែពាក្យដែលពោលថាអ្នកដែល ទម្លាយមោហៈបានហើយ ដូចជាថា សង្ខារទាំង ៣ ដែលជាបាប ជាបុណ្យនោះ រមែងត្រូវទម្លាយផងដែរ បើជាដូច្នេះ ក៏សំដៅថាព្រះអរហន្តនោះ មិនមែនតែមិនធ្វើបាបមានសម្លាប់សត្វ លួចទ្រព្យជាដើមប៉ុណ្ណោះទេ សូម្បីតែបុណ្យផ្សេងៗមាន ទាន សីល ភាវនាជាដើមក៏មិនធ្វើដែរ ចំណុចនេះអធិប្បាយថា ដូច្នោះមិនមែនទេ ព្រោះសេចក្តីពិត ព្រះអរហន្តទាំងឡាយក៏នៅបំពេញទាន សីល និងភាវនាដែរ តែថា ទាន សីល ភាវនា ដែលព្រះអរហន្តធ្វើនោះ

មិនចាត់ជាបុញ្ញាភិសង្ខារ ឬ អានេញ្ជាភិសង្ខារដែលជាផលរបស់អវិជ្ជា ទេ ការធ្វើនោះចាត់ជាកិរិយាដែលជាសង្ខារសាមញ្ញ ហើយមិនមានការឱ្យផលក្នុងបដិសន្ធិកាលតទៅទៀតឡើយ ។

ការប្រព្រឹត្តដោយកាយ វាចា ចិត្ត របស់ព្រះអរហន្តដែលហៅថា សង្ខារសាមញ្ញនោះ ក៏សំដៅដល់ការតាក់តែងឱ្យការងារដែលទាក់ទងជាមួយ កាយ វាចា ចិត្ត សម្រេចប៉ុណ្ណោះ ត្រូវគ្នានឹងពាក្យដែលពោលថា **ន ហិ កោចិ បដិច្ចសមុប្បាទរហិតោ សង្ខតធម្មោ នាម អត្ថិ** ធម៌ណាមួយដែលឈ្មោះថា សង្ខត ប៉ុន្តែផុតពីបដិច្ចសមុ-ប្បាទនោះ រមែងមិនមានឡើយ មានន័យថា កិរិយាចិត្តរបស់ព្រះអរ-ហន្ត ក៏នៅបានឈ្មោះថា សង្ខារ ដែលសង្គ្រោះចូលជាអង្គរបស់បដិច្ចស-មុប្បាទផងដែរ ។

## លក្ខណាទិចតុក្កៈរបស់ សង្ខារ

**១.អភិសង្ខរណលក្ខណា** មានការតាក់តែងជាលក្ខណៈ

**២.អាយុហនរសា** មានការព្យាយាមឱ្យបដិសន្ធិវិញ្ញាណកើតឡើង

**៣.ចេតនាបច្ចុប្បដ្ឋានា** ជាធម្មជាតិដែលដឹកនាំជំរុញ ជាអាការប្រាកដក ។

**៤.អវិជ្ជាបទដ្ឋានា** មានអវិជ្ជា ជាហេតុជិត ។

សរុបសេចក្តីមកថា ការប្រព្រឹត្តផ្សេងៗ ដោយកាយ វាចា ចិត្ត របស់សត្វទាំងឡាយនោះ រមែងគេចមិនផុតពីសង្ខារទាំង ៣ គឺ បុញ្ញា-ភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារព្រមទាំងមានសេចក្តីត្រេក-អរក្នុងសង្ខារទាំង ៣ នេះទៀតផង ទាំងនេះក៏ដោយសារអវិជ្ជា គឺការមិនស្គាល់ទោសនៃទុក្ខនិងសមុទយៈ ហើយមិនដឹងគុណរបស់និរោធ និងមគ្គនោះឯង ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យសម្តែងទុកក្នុងសម្មោហវិនោទនីអដ្ឋកថា ថាៈ

**មរុបបាតំ ទីបច្ចី មធុលិត្តស្ស លេហនំ**

**គូថកីឡំ វិសំ ខាទំ បិសាចនគរំ យថា។**

**ពាលោ ករោតិ សង្ខារេ តិវិធេ ទុក្ខហេតវោ**

**តស្មា សតិ អវិជ្ជាយ ភាវតោ ហោតិ បច្ចយោ។**

អ្នកដែលត្រូវគ្របដោយអវិជ្ជា រមែងព្យាយាមសាងសង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម ដែលជាហេតុនៃទុក្ខទាំងពួង ដូចអ្នកដែលលោតចុះក្នុងជ្រោះអាស្រ័យសេចក្តីចង់បានទេពធីតា ឬដូចមេភ្លៀងដែលហើរចូលភ្លើងដោយមានសេចក្តីត្រេកអរក្នុងពន្លឺភ្លើងនោះ ឬដូចទារកដែលវង្វេងលេងឧច្ចារៈរបស់ខ្លួនឯង ឬដូចអ្នកដែលផឹកថ្នាំពិសដោយអាស្រ័យសេចក្តីខូចចិត្តចង់ស្លាប់ ឬដូចអ្នកដែលវង្វេងផ្លូវចូលទៅក្នុងនគរបិសាច

ព្រោះហេតុនោះ សាធុជនទាំងឡាយគប្បីជ្រាបថា អវិជ្ជា ជាបច្ច័យរបស់សង្ខារ ព្រោះបើមានអវិជ្ជា សង្ខារទាំង៣ ក៏រមែងកើតឡើងយ៉ាងពិតប្រាកដ ។

ម្យ៉ាងទៀត អ្នកដែលដើរផ្លូវទៅក្នុងកណ្ដាលនៃសេចក្ដីងងឹត រមែងមើលមិនឃើញផ្លូវ ព្រោះហេតុនោះ អ្នកដែលត្រូវដើរស្ទានព្រាវទៅតាមបុណ្យតាមកម្មត្រូវខ្លះ ខុសខ្លះ បើខណៈដែលដើរមិនត្រូវផ្លូវនោះ សូម្បីពោលថា ព្រោះងងឹតទើបដើរមិនត្រូវផ្លូវក៏ពិត តែខណៈដែលដើរត្រូវផ្លូវនោះ ក៏ពោលបានថា ព្រោះភ្លឺទើបដើរត្រូវផ្លូវ ចំណុចនេះគួរពិចារណាឱ្យដឹងថា ដូច្នោះបុថុជ្ជនទាំងឡាយ ដែលកំពុងដើរផ្លូវវិលវល់នៅក្នុងវដ្ដសង្សារ ទើបពោលបានថា ជាអ្នកដើរទៅកាន់ផ្លូវនៃសេចក្ដីងងឹតដូចគ្នាទាំងអស់ ហើយខ្វះអ្នកអូសទាញគឺ សច្ចបដិវេធញ្ញាណ ដោយហេតុនេះហើយ ការប្រព្រឹត្តរបស់បុគ្គល ទាំងនេះខ្លះក៏ជាបុណ្យហៅថា បុញ្ញាភិសង្ខារ និង អានេញ្ជាភិសង្ខារ ខ្លះក៏ជាបាបហៅថា អបុញ្ញាភិសង្ខារ ដូច្នោះ ទើបព្រះអដ្ឋកថាចារ្យសម្ដែងតទៅថា :

**យថាបិ នាម ជច្ចន្ធោ នរោ អបរិណាយកោ**

**ឯកទា យាតិ មគ្គេន កុម្មគ្គេនាបិ ឯកទា។**

**សំសារេ សំសរំ ពាលោ តថា អបរិណាយកោ**

**ករោតិ ឯកទា បុញ្ញំ អបុញ្ញម្បិ ឯកទា។**

អន្ធបុថុជ្ជនដែលកំពុងដើរផ្លូវនៅក្នុងវដ្ដសង្សារ ហើយខ្វះអ្នកអូសទាញ គឺ សច្ចបដិវេធញ្ញាណ គ្រាខ្លះក៏រមែងធ្វើបុណ្យ គ្រាខ្លះក៏រមែងធ្វើបាប ប្រៀបដូចអ្នកខ្វាក់ភ្នែកពីកំណើត គ្រាខ្លះក៏ដើរត្រូវផ្លូវ គ្រាខ្លះក៏ដើរខុសផ្លូវ ។

## សង្គ្រោះបច្ច័យ ២៤

## ចូលក្នុងបទថា អវិជ្ជាបច្ចយា សង្ខារា

អវិជ្ជា ជាបច្ច័យជួយឧបការៈ ដល់បុញ្ញាភិសង្ខារនោះ បានដោយអំណាចបច្ច័យ ២ គឺ:

១.អារម្មណប្បច្ច័យ ២.បកតូបនិស្សយប្បច្ច័យ

អវិជ្ជា ជាបច្ច័យជួយឧបការៈ ដល់អបុញ្ញាភិសង្ខារនោះ បានដោយអំណាចបច្ច័យ ១៥ គឺ:

១.ហេតុប្បច្ច័យ ២.អារម្មណប្បច្ច័យ ៣.អធិបតិប្បច្ច័យ
៤.អនន្តរប្បច្ច័យ ៥.សមនន្តរប្បច្ច័យ ៦.សហជាតប្បច្ច័យ
៧.អញ្ញមញ្ញប្បច្ច័យ ៨.និស្សយប្បច្ច័យ ៩.ឧបនិស្សយប្បច្ច័យ
១០.អាសេវនប្បច្ច័យ ១១.សម្បយុត្តប្បច្ច័យ ១២.អត្ថិប្បច្ច័យ
១៣.នត្ថិប្បច្ច័យ ១៤.វិគតប្បច្ច័យ ១៥.អវិគតប្បច្ច័យ ។

អវិជ្ជា ជាបច្ច័យជួយឧបការៈដល់អានេញ្ជាភិសង្ខារនោះ បានដោយអំណាចបច្ច័យ ១ គឺ បកតូបនិស្សយប្បច្ច័យ ។

## ចប់ អវិជ្ជាបច្ចយា សង្ខារា

## ២.សង្ខារប្បច្ចយា វិញ្ញាណំ សម្ភវតិ

លោកិយវិបាកវិញ្ញាណ ៣២ រមែងប្រាកដកើតឡើង ព្រោះអាស្រ័យសង្ខារ ៣ ជាហេតុ សង្ខារមាន ២ យ៉ាងគឺ សង្ខារដែលជាផលរបស់អវិជ្ជា ១ និង សង្ខារដែលជាហេតុឱ្យកើតវិញ្ញាណ ១។

សម្រាប់សង្ខារដែលជាផលរបស់អវិជ្ជានោះ រមែងបានទាំងអស់មិនវៀរមួយណាឡើយ ចំណែកសង្ខារដែលជាហេតុឱ្យកើតវិញ្ញាណនោះ លើកលែងតែចេតនាដែលនៅក្នុងឧទ្ធច្ចសម្បយុត្តចិត្ត ក្នុងខណៈដែលអកុសលបដិសន្ធិវិញ្ញាណកើតឡើងដោយអាស្រ័យអបុញ្ញាភិសង្ខារជាហេតុ ព្រោះឧទ្ធច្ចចេតនានេះមិនមានកម្លាំងល្មមនឹងឱ្យផលក្នុងបដិសន្ធិកាលឱ្យកើតក្នុងពួកអបាយសត្វបានទេ ប៉ុន្តែក្នុងបវត្តិកាលនោះអាចឱ្យផលកើតជាអកុសលវិបាកបាន ព្រោះហេតុនោះ ក្នុងពាក្យថា **សង្ខារប្បច្ចយា វិញ្ញាណំ** នោះ រវាងអបុញ្ញាភិសង្ខារជា ហេតុបដិសន្ធិវិញ្ញាណជាផល ទើបវៀរឧទ្ធច្ចចេតនាចេញ នៅអកុសលចេតនា ១១ ប៉ុន្តែរវាងអបុញ្ញាភិសង្ខារជាហេតុ បវត្តិវិញ្ញាណ ជាផលនោះ បានដល់ អកុសលចេតនា ១២ ។

ចំណែក ក្នុងបុញ្ញាភិសង្ខារនោះ វៀរចេតនាដែលនៅក្នុងកុសលអភិញ្ញាចេញដោយពិតប្រាកដ ព្រោះអភិញ្ញាកុសលចេតនានោះ មិនមានតួនាទីឱ្យផល គឺ វិបាកវិញ្ញាណ ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល តែយ៉ាងណា អភិញ្ញាផ្សេងៗ មានឥទ្ធិវិធអភិញ្ញាជាដើម ដែលកើតឡើងក៏ជាផលមកពីកុសលអភិញ្ញា ជាផលដែលកើតឡើងដោយបច្ចុប្បន្នប្រចក្សច្បាស់នោះឯង ប៉ុន្តែសូម្បីថា នឹងវៀរចេតនាដែលនៅក្នុងកុសលអភិញ្ញាក៏ដោយ ចំនួនចេតនាដែលជា បុញ្ញាភិសង្ខារក៏គង់បាន១៣ ដូចដើម ព្រោះរូបាវចរកុសលបញ្ចមជ្ឈាន ដែលមិនទាក់ទងជាមួយអភិញ្ញាក៏មាន។

សម្រាប់អានេញ្ជាភិសង្ខារនោះ បានដល់ចេតនាទាំងអស់មិនមានវៀរ ដូច្នោះបើសរុបចំនួនសង្ខារដែលជាហេតុឱ្យកើតវិញ្ញាណ គង់បានដូច្នេះ

-បុញ្ញាភិសង្ខារ ១៣ ( វៀរចេតនាដែលនៅក្នុងកុសលអភិញ្ញា)

-អបុញ្ញាភិសង្ខារ ១២ ( វៀរឧទ្ធច្ចចេតនាដែលឱ្យផល ក្នុងបដិសន្ធិកាល)

-អានេញ្ជាភិសង្ខារ ៤ រួមជាចេតនា ២៩

ម្យ៉ាងទៀត អកុសលចេតនាដែលត្រូវប្រហារដោយមគ្គទាំង ៤ និងកុសលអកុសលចេតនាដែលជាអហោសិកម្ម សូម្បីថា ជាសង្ខារដែលកើតមកពីអវិជ្ជាជាហេតុក៏ពិត តែមិនចាត់ចូលក្នុងសង្ខារដែលជាហេតុរបស់វិញ្ញាណទេ។

## វចនត្ថៈរបស់ពាក្យថា វិញ្ញាណ

**វិជានាតីតិ = វិញ្ញាណំ**

ធម្មជាតិណាដឹងអារម្មណ៍ជាពិសេស ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **វិញ្ញាណ** ( សំដៅយកលោកិយវិបាក ៣២ ) ។

##ម្យ៉ាងទៀត

**វិជានន្តិ ឯតេនាតិ = វិញ្ញាណំ**

បុគ្គលទាំងឡាយរមែងបានដឹងអារម្មណ៍ជាពិសេស ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិដែលជាហេតុឱ្យបុគ្គលទាំងឡាយបានដឹងអារម្មណ៍ជាពិសេសនោះ ឈ្មោះថា វិញ្ញាណ (សំដៅយកលោកិយវិបាកចិត្ត ៣២ ព្រមដោយចេតសិកដែលប្រកប) ។

អង្គធមិរបស់វិញ្ញាណនេះ សម្តែងជា២ន័យ គឺ ដោយអភិធម្មភាជនីយន័យ និង ដោយសុត្តន្តភាជនីយន័យ ។

ពោលដោយអភិធម្មភាជនីយន័យ បានដល់ចិត្ត ៨៩ ព្រោះពាក្យថាវិញ្ញាណនោះ មានការដឹងអារម្មណ៍ជាពិសេសជាងការដឹងរបស់សញ្ញានិង បញ្ញា ព្រោះហេតុនោះ ទើបរាប់យកចិត្តទាំងអស់បាន ហើយប្រការមួយទៀតចិត្តទាំងអស់ដែលកើតឡើងបានក៏ត្រូវអាស្រ័យសង្ខារ គឺការតាក់តែង ព្រោះហេតុនោះទើបរាប់យកចិត្តទាំងអស់ ។

ពោលដោយសុត្តន្តភាជនីយន័យ បានដល់លោកិយវិបាកចិត្ត ៣២ ព្រោះការសម្ដែងបដិច្ចសមុប្បាទ ដោយសុត្តន្តភាជនីយន័យនេះ មានការចែកដោយកាល គឺ ភពដែលជាអតីត បច្ចុប្បន្ន អនាគត ចែក ដោយ ហេតុ ផល វដ្ដៈទាំង ៣ នេះ ជាដើម ព្រោះហេតុនោះវិញ្ញាណ បើពោលដោយកាល ក៏ចាត់ចូលក្នុងបច្ចុប្បន្នភព ដូចដែលសម្ដែងថា **មជ្ឈេ អដ្ឋ បច្ចុប្បន្នាទ្ធោ អទ្ធា** បើពោលក្នុងហេតុផលក៏ចាត់ចូលក្នុងផល ដូចដែលបានសម្ដែងថា **ឥទានិ ផលបញ្ចកំ** បើពោលដោយវដ្ដៈទាំង ៣ ក៏ចាត់ចូលក្នុងវិបាកវដ្ដៈ ដូចដែលបានសម្ដែងថា **អវសេសា ច វិបាកវដ្ដំ** ព្រោះហេតុនោះ ពាក្យថា **វិញ្ញាណ** ដែលជាផលរបស់សង្ខារនោះ ទើបបានដល់លោកិយវិបាកចិត្ត ៣២ នោះឯង ។

ចំណែកការសម្ដែងដោយអភិធម្មភាជនីយន័យនោះ អង្គធម៌មិនកំណត់ គឺ ពាក្យថា វិញ្ញាណ បានដល់ចិត្តទាំងអស់ ពាក្យថា នាម ក៏បានដល់ចិត្តទាំងអស់ ពាក្យថា រូប ក៏បានដល់រូបទាំងអស់ ពាក្យថា ផស្សៈ ក៏បានដល់ផស្សៈទាំងអស់ ដូច្នោះជាដើម ព្រោះមិនមានការចែកដោយ កាល ហេតុ ផល ជាដើម ។

ការសម្តែងបដិច្ចសមុប្បាទដោយន័យទាំង ២ ដូចពោលមកនេះ ព្រះពុទ្ធអង្គទ្រង់បានសម្តែងទុកក្នុងវិភង្គបករណ៍ក្នុងអភិធម្មបិដក ។

**អធិប្បាយវចនត្ថៈត្រង់ចំណុចទី ១ គឺ វិជានាតីតិ = វិញ្ញាណំ**

ធម្មជាតិរបស់ចិត្តនោះរមែងបានទទួលអារម្មណ៍ជានិច្ច មិនថាពេលណា ការបានទទួលអារម្មណ៍ជានិច្ចនេះឯងឈ្មោះថា រមែងដឹងអារម្មណ៍ជាពិសេស ។

ប្រការមួយទៀត ក្នុងចំនួនលោកិយវិបាកចិត្តទាំងនោះ មានការដឹងអារម្មណ៍កំណត់ ដោយចំពោះជាចំណែកច្រើន ផ្សេងគ្នានឹងការដឹងអារម្មណ៍របស់កុសលកិរិយា ដែលមានការដឹងអារម្មណ៍ ដោយមិនកំណត់ ជាចំណែកច្រើនដូចជាចក្ខុវិញ្ញាណចិត្ត ក៏មានការដឹងចំពោះរូបារម្មណ៍ ។ល។ កាយវិញ្ញាណចិត្ត ក៏មានការដឹងតែចំពោះផោដ្ឋព្វារម្មណ៍ សម្បដិច្ឆន្នចិត្ត ក៏មានការដឹងតែចំពោះបញ្ចារម្មណ៍ ឧបេក្ខាសន្តីរណចិត្ត មហាវិបាកចិត្ត និងមហគ្គតវិបាកចិត្ត បើខណៈដែលធ្វើ បដិសន្ធិ ភវង្គ ចុតិ ក៏មានការដឹងចំពោះអារម្មណ៍ ដែលទាក់ទងជាមួយអតីតភព ដូច្នេះហើយទើបបានឈ្មោះថា ដឹងអារម្មណ៍ជាពិសេស គឺ ដឹងមិនទូទៅ ។

## អធិប្បាយវចនត្ថៈត្រង់ចំណុចទី ២

## វិជានន្តិ ឯតេនាតិ = វិញ្ញាណំ

សត្វទាំងឡាយក្តី ចេតសិកក្តី ដែលមានការដឹងអារម្មណ៍បានផ្សេងៗ ទាំងបរមត្ថ និងបញ្ញត្តិនោះ ក៏ដោយអាស្រ័យវិបាកវិញ្ញាណជាហេតុ ពោលគឺ ប្រសិនបើចក្ខុវិញ្ញាណចិត្តមិនកើត ក៏ដូចជាថាអ្នកនោះ មិនមានការឃើញ ។ល ។បើកាយវិញ្ញាណចិត្តមិនកើត ក៏ដូចជាថាអ្នកនោះមិនមានការដឹងតាមកាយទ្វារ ប្រសិនបើដកភវង្គចិត្តចេញអ្នកនោះក៏មិនមានសេចក្តីដឹងអារម្មណ៍ណាៗ ឡើយ ដោយហេតុនេះឯង វិបាកវិញ្ញាណទាំងនេះ ទើបជាធមិដែលជាហេតុឱ្យសត្វទាំងឡាយដឹងអារម្មណ៍ជាពិសេស ។

**វិញ្ញាណដែលជាផលរបស់សង្ខារចែកចេញជា ២ ពួក គឺៈ**

-វិញ្ញាណដែលកើតក្នុងបដិសន្ធិកាល ឈ្មោះថា **បដិសន្ធិវិញ្ញាណ** បានដល់បដិសន្ធិចិត្ត ១៩ រាប់ជាមួយពួក ។

-វិញ្ញាណដែលកើតក្នុងបវត្តិកាល ឈ្មោះថា **បវត្តិវិញ្ញាណ** បានដល់លោកិយវិបាកចិត្ត ៣២ រាប់ជាមួយពួក ។

## ចែកបដិសន្ធិវិញ្ញាណ ១៩ ដោយសង្ខារ ៣

**១.អបុញ្ញាភិសង្ខារ ១១** (វៀរឧទ្ធច្ចចេតនា) ជាហេតុ ឧបេក្ខាសន្តីរណអកុសលវិបាក ១ ជាផល ឱ្យបដិសន្ធិក្នុងអបាយភូមិទាំង ៤ ជាពួកទុគតិអហេតុកបុគ្គល គឺ ពួកអបាយសត្វ ។

**២.បុញ្ញាភិសង្ខារ** ដែលបានដល់ មហាកុសលទ្វិហេតុកឱមកចេតនា ៤ ជាហេតុ ឧបេក្ខាសន្តីរណកុសលវិបាក ១ ជាផល ឱ្យបដិសន្ធិក្នុងមនុស្សភូមិ ១ ចាតុម្មហារាជិកាភូមិ ១ ជាពួកសុគតិអហេតុកបុគ្គល គឺ មនុស្ស និងទេវតាជាន់ទាបដែលពិកលពិការ មិនចេះនិយាយ ឆ្កួត ខ្វាក់ ខ្វិន ជាដើម ។

**៣.បុញ្ញាភិសង្ខារ** បានដល់ មហាកុសលទ្វិហេតុកឧក្កដ្ឋចេតនា ៤ និង តិហេតុកឱមកចេតនា ៤ ជាហេតុ ។

មហាវិបាកញ្ញាណវិប្បយុត្ត ៤ ជាផល ឱ្យបដិសន្ធិក្នុងមនុស្សភូមិ ១ ទេវភូមិ ៦ ជាពួកទ្វិហេតុកបុគ្គល គឺ មនុស្ស និងទេវតាជាន់កណ្តាល.

**៤.បុញ្ញាភិសង្ខារ** បានដល់ មហាកុសលតិហេតុកឧក្កដ្ឋចេតនា ៤ ជាហេតុ មហាវិបាកញ្ញាណសម្បយុត្ត ៤ជាផល ឱ្យបដិសន្ធិក្នុងមនុស្សភូមិ ១ ទេវភូមិ ៦ ជាពួកទ្វិហេតុកបុគ្គល គឺ មនុស្ស និងទេវតាជាន់ខ្ពស់ ។

**៥.បុញ្ញាភិសង្ខារ** បានដល់ រូបាវចរកុសលចេតនា ៥ ជាហេតុ រូបាវចរវិបាក ៥ ជាផល ឱ្យបដិសន្ធិក្នុងភូមិ ១៥ (វៀរអសញ្ញសត្តភូមិ) ជាពួករូបព្រហ្ម ។

៦.អានេញ្ជាភិសង្ខារ ដែលបានដល់ អរូបាវចរកុសលចេតនា ៤ ជាហេតុ អរូបាវចរវិបាក ៤ ជាផល ឱ្យបដិសន្ធិក្នុងអរូបភូមិ ៤ ជាពួកអរូបព្រហ្ម។

## ចែកបវត្តិវិញ្ញាណ ៣២ ដោយសង្ខារ ៣

១.អបុញ្ញាភិសង្ខារ ១២ ជាហេតុ អកុសលវិបាក ៧ បានដល់ ការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវ ការទទួលអារម្មណ៍ ការពិចារណាអារម្មណ៍ និង ការទទួលអារម្មណ៍បន្តពីជវនៈដែលមិនល្អជាផល ក្នុងកាមភូមិ ១១។

២.អបុញ្ញាភិសង្ខារ ១២ ជាហេតុ អកុសលវិបាក ៤ បានដល់ ការឃើញ ការឮ ការទទួលអារម្មណ៍ និង ការពិចារណាអារម្មណ៍ ដែលមិនល្អជាផល ក្នុងរូបភូមិ ១៥។

៣.បុញ្ញាភិសង្ខារ ដែលបានដល់ មហាកុសលចេតនា ៨ ជាហេតុ អហេតុកកុសលវិបាក ៨ បានដល់ ការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវ ការទទួលអារម្មណ៍ ការពិចារណាអារម្មណ៍ និង ការទទួលអារម្មណ៍បន្តពីជវនៈដែលល្អជាផលក្នុងកាមភូមិ ១១។

៤.បុញ្ញាភិសង្ខារ ដែលបានដល់ មហាកុសលចេតនា ៨ ជាហេតុ មហាវិបាក ៨ បានដល់ ការទទួលអារម្មណ៍បន្តពីជវនៈ ដែលល្អជាផល ក្នុងកាមសុគតិភូមិ ៧ ។

**៥.បុញ្ញាភិសង្ខារ** ដែលបានដល់ មហាកុសលចេតនា ៨ ជាហេតុ អហេតុកកុសលវិបាក ៥ បានដល់ ការឃើញ ការឮ ការទទួលអារម្មណ៍ ការពិចារណាអារម្មណ៍ដែលល្អជាផល ក្នុងរូបភូមិ ១៥។

**៦.បុញ្ញាភិសង្ខារ** បានដល់ រូបាវចរកុសលចេតនា ៥ ជាហេតុ រូបាវចរវិបាក ៥ បានដល់ ការរក្សាភពជាផលក្នុងរូបភូមិ ១៥។

**៧.អានេញ្ជាភិសង្ខារ** ដែលបានដល់ អរូបាវចរកុសលចេតនា ៤ ជាហេតុ អរូបាវចរវិបាក ៤ បានដល់ ការរក្សាភពជាផល ក្នុងអរូបភូមិ ៤ ។

## ការចែកបដិសន្ធិវិញ្ញាណ ១៩ ដោយន័យផ្សេង ៗ

បដិសន្ធិវិញ្ញាណ ១៩ ទាំងនេះ បើចែកដោយមិស្សកៈ និង សុទ្ធៈ ចែកចេញជា ២ គឺៈ

**១.រូបមិស្សកវិញ្ញាណ** វិញ្ញាណដែលលាយដោយរូប មាន ១៥

**២.រូបអមិស្សកវិញ្ញាណ** វិញ្ញាណដែលមិនលាយដោយរូបមាន ១៥

**បើចំណែកដោយភូមិ ចែកចេញជា ៣ គឺៈ**

| | |
|---|---|
| ១.កាមវិញ្ញាណ | មាន ១០ |
| ២.រូបវិញ្ញាណ | មាន ៥ |
| ៣.អរូបវិញ្ញាណ | មាន ៤ |

បើចំណែកដោយកំណើត ចែកចេញជា ៤ គឺ:

១-អណ្ឌជវិញ្ញាណ មាន ១០

២-ជលាពុជវិញ្ញាណ មាន ១០

៣-សំសេទជវិញ្ញាណ មាន ១០

៤-ឱបបាតិកវិញ្ញាណ មាន ១៩

បើចំណែកដោយគតិ ចែកចេញជា ៥ គឺ:

១.ទេវគតិវិញ្ញាណ មាន ១៨

២.មនុស្សគតិវិញ្ញាណ មាន ៩

៣.និរយគតិវិញ្ញាណ មាន ១

៤.តិរច្ឆានគតិវិញ្ញាណ មាន ១

៥.បេតគតិវិញ្ញាណ មាន ១

បើចែកដោយវិញ្ញាណឋិតិ មាន ៧ គឺ:

១-នានត្តកាយនានត្តសញ្ញីវិញ្ញាណ មាន ៩

២-នានត្តកាយឯកត្តសញ្ញីវិញ្ញាណ មាន ២

៣-ឯកត្តកាយនានត្តសញ្ញីវិញ្ញាណ មាន ២

៤-ឯកត្តកាយឯកត្តសញ្ញីវិញ្ញាណ មាន ២

៥-អាកាសានញ្ចាយតនវិញ្ញាណ មាន ១

៦-វិញ្ញាណញ្ចាយតនវិញ្ញាណ មាន ១

៧-អាកិញ្ចញ្ញាយតនវិញ្ញាណ មាន ១

បើចែកដោយសត្តាវាស (ភូមិដែលជាទីអាស្រ័យរបស់សត្វ) មាន ៨ (វៀរសត្តាវាស ១ គឺអសញ្ញសត្តា ព្រោះមិនមានវិញ្ញាណ) គឺ ចំណុច ១ ដល់ ៧ ដូចវិញ្ញាណឋិតិ ៧ ។

៨.នេវសញ្ញានាសញ្ញាយតនវិញ្ញាណ មាន ១ ។

<u>ចំណាំ</u> ការដែលចែកបដិសន្ធិវិញ្ញាណដោយវិញ្ញាណឋិតិ និង សត្តាវាស ក្នុងទីនេះសម្តែងទុកត្រឹមតែចំនួនប៉ុណ្ណោះ ចំណែកឈ្មោះ របស់វិញ្ញាណនោះប្រាកដស្រាប់ហើយក្នុងបរមត្ថជោតិកៈបរិច្ឆេទទី ៥ ភាគ ២ ។

## លក្ខណាទិចតុក្កៈរបស់ វិញ្ញាណ

**១-វិជាននលក្ខណំ** មានការដឹងអារម្មណ៍ជាពិសេសពីសញ្ញា និងបញ្ញាជាលក្ខណៈ ។

**២-បុព្វង្គមរសំ** ជាប្រធាននៃចេតសិកនិងកម្មជរូប ជាកិច្ច ។

**៣-បដិសន្ធិបច្ចុប្បដ្ឋានំ** មានការជាប់តគ្នារវាងភពចាស់ និងភពថ្មី ជាអាការប្រាកដ ។

**៤-សង្ខារបទដ្ឋានំ (វា) វត្ថារម្មណបទដ្ឋានំ** មានសង្ខារ ៣ ជាហេតុជិត ឬ មានវត្ថុ ៦ និង អារម្មណ៍ ៦ ជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា

## សង្ខារប្បច្ចយា វិញ្ញាណំ

សង្ខារទាំង ៣ ជាបច្ច័យជួយឧបការៈដល់វិបាកវិញ្ញាណនេះ បានដោយអំណាចបច្ច័យ ២ គឺ :

១.បកតូបនិស្សយប្បច្ច័យ ២.នានក្ខណិកកម្មប្បច្ច័យ

**ចប់ សង្ខារប្បបច្ចយា វិញ្ញាណំ**

## ៣.វិញ្ញាណប្បច្ចយា នាមរូបំ សម្ភវតិ

ចេតសិកដែលប្រកបជាមួយនឹងលោកិយវិបាកចិត្ត និង កម្មជរូប រមែងប្រាកដកើតឡើង ព្រោះអាស្រ័យកម្មវិញ្ញាណ និង វិបាកវិញ្ញាណ ជាដើម ។

វិញ្ញាណដែលជាហេតុឱ្យកើតនាមរូបនេះ មាន ២ យ៉ាងគឺ

វិបាកវិញ្ញាណ និងកម្មវិញ្ញាណ

**វិបាកវិញ្ញាណ** បានដល់ លោកិយវិបាកចិត្ត ៣២

**កម្មវិញ្ញាណ** បានដល់ អកុសលចិត្ត មហាកុសលចិត្ត រូបាវចរកុសលចិត ដែលប្រកបជាមួយកុសលអកុសលចេតនាដែលនៅក្នុងអតីតភព ។

**នាម** បានដល់ ចេតសិក ៣៥ ដែលប្រកបជាមួយលោកិយ-វិបាកចិត្ត ៣២ ។

**រូប** បានដល់ បដិសន្ធិកម្មជរូប បវត្តិកម្មជរូប ចិត្តជរូប (សម្រាប់បវត្តិកម្មជរូប និង ចិត្តជរូបដែលចូលក្នុងបទថា **រូបំ** បាននោះក៏ដោយអាស្រ័យកម្មវិញ្ញាណ និង បវត្តិវិបាកវិញ្ញាណនោះឯង រាប់ចូលដោយអនុលោម) ។

បើចែកវិបាកវិញ្ញាណ និង នាមរូបទាំងនេះដោយបដិសន្ធិកាល និងបវត្តិកាល រមែងប្រព្រឹត្តទៅបានដូច្នេះ គឺៈ

**បដិសន្ធិវិបាកវិញ្ញាណ** បានដល់ បដិសន្ធិចិត្ត ១៩

**បវត្តិវិបាកវិញ្ញាណ** បានដល់ លោកិយវិបាកចិត្ត ៣២

**បដិសន្ធិនាម** បានដល់ ចេតសិក ៣៥ ដែលប្រកបជាមួយនឹងបដិសន្ធិវិញ្ញាណ ១៩ ។

**បវត្តិនាម** បានដល់ ចេតសិក៣៥ ដែលប្រកបជាមួយបវត្តិ-វិបាកវិញ្ញាណ ៣២ ។

**បដិសន្ធិរូប** បានដល់ កម្មជរូបដែលកើតឡើងព្រមជាមួយបដិសន្ធិវិញ្ញាណ ។

**បវត្តិរូប** បានដល់ ចិត្តជរូបដែលកើតពីបវត្តិវិបាកវិញ្ញាណ ១៨ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ អរូបវិបាក ៤) និង បវត្តិកម្មជរូប ដែលកើតពីកម្មវិញ្ញាណ ២៥ ។

## វចនត្ថៈរបស់ពាក្យថា នាម

**អារម្មណេ នមតីតិ = នាមំ**

ធម្មជាតិណាបង្អោនទៅក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **នាម** បានដល់ ចេតសិក ដែលប្រកបជាមួយលោកិយ-វិបាកចិត្ត ៣២ ។

## វចនត្ថៈរបស់ពាក្យថា រូប

**សីតុណ្ហាទិវិរោធិបច្ចយេហិ រុប្បតីតិ = រូបំ**

ធម្មជាតិណារមែងបែកធ្លាយ ព្រោះបច្ច័យដែលជាបដិបក្ខ មានសភាពត្រជាក់ ក្តៅ ជាដើម ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **រូប** បានដល់ កម្មជរូប និងចិត្តជរូប ។

## វចនត្ថៈរបស់ពាក្យថា នាមរូប

**នាមញ្ច រូបញ្ច នាមរូបញ្ច = នាមរូបំ**

នាមផង រូបផង នាមរូបផង ឈ្មោះថា **នាមរូប**

## អធិប្បាយវចនត្ថៈរបស់ នាមរូប

ពាក្យថា **នាមរូបំ** នេះ ប្រសិនបើសម្តែងការប្រព្រឹត្តទៅរបស់នាម និង រូប ដែលកើតពីវិញ្ញាណ ត្រូវសម្តែងថា **វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបំ** តែក្នុងទីនេះ កាត់យកនាមរូបចេញមួយបទ នៅសល់តែ **នាមរូបំ** មួយបទ ការសម្តែងដូច្នេះហៅថា **ឯកសេសន័យ** ។

អធិប្បាយថា វិញ្ញាណជាបច្ច័យជួយឧបការៈដល់នាមរូបនេះ មាន ៣ យ៉ាង គឺៈ

១.វិញ្ញាណជាបច្ច័យជួយឧបការៈដល់នាមក្នុងអរូបភូមិ និង បញ្ចវោការភូមិ ម្យ៉ាងទៀត ក្នុងទីនេះពាក្យថា វិញ្ញាណ បានដល់ អរូបវិបាកចិត្ត ៤ ជាបច្ច័យជួយឧបការៈដល់ចេតសិក ៣០ ទាំងក្នុង បដិសន្ធិកាល និង បវត្តិកាល ក្នុងអរូបភូមិ ៤ ។

ហើយទ្វិបញ្ចវិញ្ញាណ ១០ ជាបច្ច័យជួយឧបការៈដល់សព្វចិត្ត-សាធារណចេតសិក៧ ក្នុងបវត្តិកាល និងក្នុងបញ្ចវោការភូមិ ២៦ តាមសមគួរ ។

២.វិញ្ញាណជាបច្ច័យជួយឧបការៈដល់រូប ក្នុងអសញ្ញីសត្តភូមិ និង ក្នុងបញ្ចវោការភព ម្យ៉ាងទៀតក្នុងទីនេះ ពាក្យថា **វិញ្ញាណ** សំដៅ យកកម្មវិញ្ញាណ ដែលបានដល់រូបាវចរបញ្ចមជ្ឈានកុសលចិត្ត ដែល

ប្រកបជាមួយសញ្ញាវិរាគភាវនាចេតនានៅក្នុងអតីតភព ជាបច្ច័យជួយឧបការៈដល់កម្មជរូប ទាំងក្នុងបដិសន្ធិកាល និង បវត្តិកាលរបស់ពួកអសញ្ញសត្តព្រហ្ម ហើយអកុសលចិត្ត ១២ មហាកុសល ៨ ដែលប្រកបជាមួយកុសលអកុសលចេតនាក្នុងអតីតភព ជាបច្ច័យជួយឧបការៈដល់បវត្តិកម្មជរូបក្នុងកាមភូមិ ១១។

ហើយមហាកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ ដែលប្រកបជាមួយកុសលចេតនាក្នុងអតីតភព ជាបច្ច័យជួយឧបការៈដល់បវត្តិកម្មជរូបក្នុងរូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ) ។

៣.វិញ្ញាណជាបច្ច័យជួយឧបការៈដល់នាមរូប ក្នុងបញ្ចវោការភូមិ ក្នុងទីនេះ ពាក្យថា វិញ្ញាណ បានដល់ បញ្ចវោការបដិសន្ធិ វិញ្ញាណ ១៩ ជាបច្ច័យជួយឧបការៈដល់ចេតសិក ៣៥ និងបដិសន្ធិកម្មជរូបក្នុងបញ្ចវោការភូមិ ២៦ ហើយបញ្ចវោការបវត្តិវិបាកវិញ្ញាណ ១៨ (វៀរ ទ្វិបញ្ចវិញ្ញាណ ១០)ជាបច្ច័យជួយឧបការៈដល់ចេតសិក ៣៥ និង ចិត្តជរូបក្នុងបញ្ចវោការភូមិ ២៦ ។

## លក្ខណាទិចតុក្កៈរបស់ នាម

**១.នមលក្ខណំ** មានការបង្អោនទៅកាន់អារម្មណ៍ជាលក្ខណៈ ។

**២.សម្បយោគរសំ** មានការប្រកបជាមួយវិញ្ញាណ សហជាតធម៌ដែលកើតជាមួយខ្លួន ជាកិច្ច។

**៣.អវិនិព្ភោគបច្ចុប្បដ្ឋានំ** មានការមិនបែកគ្នាជាមួយចិត្ត ជាអាការប្រាកដ។

**៤.វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់ រូប

**១.រុប្បនលក្ខណំ** មានការបែកធ្លាយប្រែប្រួលជាលក្ខណៈ

**២.វិកិរណរសំ** មានការបែកចេញពីគ្នា ជាកិច្ច

**៣.អព្យាកតបច្ចុប្បដ្ឋានំ** មានភាពជាអព្យាកតធម៌ ឬមានភាពមិនដឹងអារម្មណ៍ជាអាការប្រាកដ

**៤.វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាហេតុជិត ។

## សង្រ្គោះបច្ច័យ ២៤ ចូលក្នុងបទថា

## វិញ្ញាណប្បច្ចយា នាមរូបំ

វិបាកវិញ្ញាណ ជាបច្ច័យជួយឧបការៈដល់ នាម គឺ ចេតសិកដែលប្រកបនោះបានអំណាចបច្ច័យ ៩ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ ៤.វិបាកបច្ច័យ ៥.អាហារប្បច្ច័យ ៦.ឥន្ទ្រិយប្បច្ច័យ ៧.សម្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ ។

បដិសន្ធិវិញ្ញាណ ជាបច្ច័យជួយឧបការៈដល់ ហទយវត្ថុរូបនោះ បានដោយអំណាចបច្ច័យ ៩ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ ៤.វិបាកប្បច្ច័យ ៥.អាហារប្បច្ច័យ ៦.ឥន្ទ្រិយប្បច្ច័យ ៧.វិប្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ ។

បដិសន្ធិវិញ្ញាណ ជាបច្ច័យជួយឧបការៈដល់បដិសន្ធិកម្មជរូប (វៀរហទយវត្ថុ) នោះ បានដោយអំណាចបច្ច័យ ៨ គឺៈ

១.សហជាតប្បច្ច័យ ២.និស្សយប្បច្ច័យ ៣.វិបាកប្បច្ច័យ ៤.អាហារប្បច្ច័យ ៥.ឥន្ទ្រិយប្បច្ច័យ ៦.វិប្បយុត្តប្បច្ច័យ ៧.អត្ថិប្បច្ច័យ ៨.អវិគតប្បច្ច័យ ។

កម្មវិញ្ញាណ ជាបច្ច័យជួយឧបការដល់បដិសន្ធិកម្មជរូប ក្នុងអសញ្ញីសត្តភូមិ និង បវត្តិកម្មជរូបក្នុងបញ្ចវោការភូមិ និងឯកវោ-ការភូមិនោះ ដោយអំណាចបច្ច័យ ១ គឺ បកតូបនិស្សយប្បច្ច័យ ។

**៤.នាមរូបប្បច្ចយា សឡាយតនំ សម្ភវតិ**

អជ្ឈត្តកាយតនៈ ៦ មានចក្ខាយតនៈជាដើម រមែងប្រាកដកើតឡើង ព្រោះអាស្រ័យនាមរូបជាហេតុ ។

ក្នុងទីនេះ **នាម** បានដល់ចេតសិត ៣៥ ដែលប្រកបជាមួយលោកិយវិបាកចិត្ត ៣២ ។

**រូប** បានដល់ កម្មជរូប ១៦ អវិនិព្ភោគរូប ៨ បសាទរូប ៥ ភាវរូប ១ ហទយរូប ១ ជីវិតរូប ១ ។

**សឡាយតនៈ** បានដល់ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ និង មនាយតនៈ គឺលោកិយ-វិបាកចិត្ត ៣២ ។

**វចនត្ថៈរបស់ពាក្យថា សឡាយតនៈ**

**អាយតំ សង្ខារវដ្ដំ នយតីតិ=អាយតនំ**

ធម្មជាតិណាទ្រទ្រង់ទុកនូវវដ្ដសង្សារដ៏យឺតយូរ ព្រោះហេតុ-នោះ ធម្មជាតិនោះឈ្មោះថា **អាយតនៈ** បានដល់ អាយតនៈ ១២ ។

**ឆ អាយតនានិ=សឡាយតនំ**

អាយតនៈទាំង ៦ ឈ្មោះថា សឡាយតនៈ បានដល់ អជ្ឈត្តិកាយតន : ៦ ។

**សឡាយតនញ្ច ឆត្ថាយតនញ្ច =សឡាយតនំ**

អាយតនៈទាំង ៦ ឈ្មោះថា **សឡាយតនៈ**

អធិប្បាយថា ពាក្យថា **អាយតនៈ** ក្នុងបទថា **នាមរូបប្បច្ចយា សឡាយតនំ** នេះ ជាបទដែលធ្វើឱ្យសល់ ២ បទ គឺ **សឡាយតនំ ឆត្ថាយតនំ** ការធ្វើឱ្យប្រព្រឹត្តទូទៅដូច្នេះ ហៅថា **ឯកសេសន័យ** គឺលុបបទ **ឆត្ថាយតនំ** ចេញ សល់ត្រឹមតែ **អាយតនំ** ម្យ៉ាងទៀត

មានន័យថា អជ្ឈត្តិកាយតនៈ ៦ ដែលជាផលរបស់នាមរូបនេះ កាលចែកដោយភូមិ រមែងប្រព្រឹត្តទូទៅដូច្នេះគឺ :

ក្នុងបញ្ចវោការភូមិ នាមរូបជាហេតុ អជ្ឈត្តិកាយតនៈ ៦ ឈ្មោះថា **សឡាយតនៈ** ជាផលតាមសមគួរ ។

ក្នុងអរូបភូមិ នាមជាហេតុ មនាយតនៈឈ្មោះថា **ឆដ្ឋាយតនៈ** ជាផល ។

ការសម្ដែងហេតុផលរវាង នាម និង មនាយតនៈនោះ កើតព្រមគ្នា និងជាហេតុជាផលដល់គ្នានឹងគ្នាក៏បាន ចំណែកការដែលជាហេតុជាផលរវាង នាម និង បញ្ចាយតនៈនោះ កើតព្រមគ្នាក៏មាន ហើយកាលជាហេតុផលដូចគ្នារវាង រូប និង អាយតនៈ រូប និង បញ្ចាយតនៈនោះកើតព្រមគ្នាក៏មាន មិនកើតព្រមគ្នាក៏មានស្រេចតែកំណើត ។

## លក្ខណាទិចតុក្កៈរបស់ សឡាយតនៈ

**១.អាយតនលក្ខណំ** មានការប៉ះខ្ទប់ ឬ មានការធ្វើឱ្យវដ្ដសង្សារយឺតយូរ ជាលក្ខណៈ ។

**២.ទស្សនាទិរសំ** មានការឃើញជាដើមជាកិច្ច

**៣.វត្ថុទ្វារភាវបច្ចុប្បដ្ឋានំ** មានសភាពជាវត្ថុនិងទ្វាររបស់បញ្ចវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ តាមសមគួរជាអាការប្រាកដ ។

**៤.នាមរូបទដ្ឋានំ** មានចេតសិក និងកម្មជរូប ជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា
## នាមរូបបច្ចយា សឡាយតនំ

**១.នាម** គឺ ចេតសិកខន្ធ ៣ ដែលប្រកបជាមួយលោកិយវិបាកចិត្ត ជាបច្ច័យជួយឧបការដល់ មនាយតនៈ បានដល់ លោកិយវិបាកចិត្ត ដែលកើតព្រមជាមួយខ្លួនឯងនោះ ដោយអំណាចបច្ច័យ ៧ គឺ :

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.សហជាតនិស្សយ-ប្បច្ច័យ ៤.វិបាកប្បច្ច័យ ៥.សម្បយុត្តបច្ច័យ ៦.អត្ថិប្បច្ច័យ ៧.អវិគតប្បច្ច័យ ។

**២.នាម** គឺអលោភៈ អទោសៈ អមោហៈ ដែលប្រកបជាមួយលោកិយវិបាកចិត្ត ជាបច្ច័យជួយឧបការៈដល់មនាយតនៈ បានដល់ លោកិយសហេតុកវិបាក ដែលកើតព្រមគ្នាជាមួយខ្លួនឯង បានដោយអំណាចបច្ច័យ ៨ គឺ :

១.ហេតុប្បច្ច័យ ២.សហជាតប្បច្ច័យ ៣.អញ្ញមញ្ញប្បច្ច័យ
៤.និស្សយប្បច្ច័យ ៥.វិបាកប្បច្ច័យ ៦.សម្បយុត្តប្បច្ច័យ
៧.អត្ថិប្បច្ច័យ ៨.អវិគតប្បច្ច័យ ។

**៣.នាម** គឺចេតនាចេតសិក ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈ ដល់មនាយតនៈ បានដល់ លោកិយវិបាក ដែលកើតព្រមគ្នាជាមួយខ្លួនឯងនោះ ដោយអំណាចបច្ច័យ ៩ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ ៤.សហជាតប្បច្ច័យ ៥. វិបាកប្បច្ច័យ ៦. និស្សយប្បច្ច័យ ៧.សម្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ ។

**៤.នាម** គឺ ផស្សៈ ចេតនា ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈ ដល់មនាយតនៈ បានដល់ លោកិយវិបាក ដែលកើតព្រមគ្នាជាមួយខ្លួនឯងនោះ ដោយអំណាចបច្ច័យ៨ គឺ :

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ ៤.វិបាកប្បច្ច័យ ៥.នាមអាហារប្បច្ច័យ ៦.សម្បយុត្តប្បច្ច័យ ៧.អត្ថិប្បច្ច័យ ៨.អវិគតប្បច្ច័យ ។

**៥.នាម** គឺ វិតក្កៈ វិចារៈ បីតិ ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈ ដល់មនាយតនៈ បានដល់ លោកិយវិបាក (វៀរទ្វិបញ្ចវិញ្ញាណ) ដែលប្រកបព្រមជាមួយខ្លួនឯង ដោយអំណាច បច្ច័យ ៨ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ ៤.វិបាកប្បច្ច័យ ៥.ឈានប្បច្ច័យ ៦.សម្បយុត្តប្បច្ច័យ ៧.អត្ថិប្បច្ច័យ ៨.អវិគតប្បច្ច័យ ។

**៦.នាម** គឺជីវិតិន្ទ្រិយ៍ វេទនា សទ្ធា ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈដល់មនាយតនៈ ដែលបានដល់លោកិយវិបាក ដែលកើតព្រមគ្នាជាមួយខ្លួននោះ បានដោយអំណាចបច្ច័យ ៨ គឺ :

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ
៤.វិបាកប្បច្ច័យ ៥.សហជាតិន្ទ្រិយប្បច្ច័យ ៦.សម្បយុត្តប្បច្ច័យ
៧.អត្ថិប្បច្ច័យ ៨.អវិគតប្បច្ច័យ ។

**៧.នាម** គឺ វីរិយៈ សតិ បញ្ញា ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈដល់ មនាយតនៈ ដែលបានដល់លោកិយវិបាក ដែលកើតព្រមគ្នាជាមួយខ្លួននោះ បានអំណាចបច្ច័យ ៩ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ
៤.វិបាកប្បច្ច័យ ៥.សហជាតិន្ទ្រិយប្បច្ច័យ ៦.មគ្គប្បច្ច័យ
៧.សម្បយុត្តប្បច្ច័យ ៨.អត្ថិប្បច្ច័យ ៩.អវិគតប្បច្ច័យ ។

**៨.នាម** គឺ ឯកគ្គតា ដែលប្រកបជាមួយលោកិយវិបាក ជាបច្ច័យជួយឧបការៈដល់មនាយតនៈ ដែលបានដល់លោកិយវិបាក ដែលកើតព្រមគ្នាជាមួយខ្លួននោះ បានអំណាចបច្ច័យ ១០ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.និស្សយប្បច្ច័យ

៤.វិបាកប្បច្ច័យ ៥.សហជាតិន្ទ្រិយប្បច្ច័យ ៦.ឈានប្បច្ច័យ
៧.មគ្គប្បច្ច័យ ៨.សម្បយុត្តប្បច្ច័យ ៩.អត្ថិប្បច្ច័យ
១០.អវិគតប្បច្ច័យ ។

ការចែកបច្ច័យ និងបច្ចយុប្បន្ន តាំងពីចំណុច ១-៨ ដូចពោលមកនេះ ជាបច្ច័យបានទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល ។

**៩.នាម** គឺ ចេតសិកខន្ធ ៣ ដែលប្រកបជាមួយបញ្ចវោការបដិសន្ធិចិត្ត ជាបច្ច័យជួយឧបការៈដល់បញ្ចាយតនៈក្នុង បដិសន្ធិកាល នៃបញ្ចវោការភូមិនោះ បានអំណាចបច្ច័យ ៦ គឺៈ

១.សហជាតប្បច្ច័យ ២.និស្សយប្បច្ច័យ ៣.វិបាកប្បច្ច័យ
៤.សហជាតវិប្បយុត្តប្បច្ច័យ ៥.អត្ថិប្បច្ច័យ ៦.អវិគតប្បច្ច័យ ។

ក្នុងទីនេះសម្រាប់ចក្ខុ សោតៈ ឃានៈ ជិវ្ហា អាយតនៈទាំង ៤ នេះបំណងយកសំសេទជៈ និង ឱបបាតិកកំណើត ចំណែក កាយាយតនៈនោះ បានកំណើតទាំងអស់ ។

**១០.នាម** គឺ ចេតសិកខន្ធ ៣ ដែលប្រកបជាមួយបញ្ចវោការវិបាក ជាបច្ច័យជួយឧបការៈដល់បញ្ចាយតនៈ ក្នុងបវត្តិកាល នៃបញ្ចវោការភូមិនោះ បានដោយអំណាចបច្ច័យ ៤ គឺៈ

១.បច្ឆាជាតប្បច្ច័យ ២.បច្ឆាជាតវិប្បយុត្តប្បច្ច័យ

៣.អត្ថិប្បច្ច័យ ៤.អវិគតប្បច្ច័យ

**១១. រូប** គឺ ហទយវត្ថុ ជាបច្ច័យជួយឧបការៈដល់ មនាយតនៈ ដែលបានដល់បញ្ចវោការបដិសន្ធិចិត្ត ១៥ ក្នុងបដិសន្ធិកាល នៃបញ្ចវោការភូមិនោះ បានដោយអំណាចបច្ច័យ ៦ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.សហជាតនិស្សយប្បច្ច័យ ៤.សហជាតវិប្បយុត្តប្បច្ច័យ ៥.អត្ថិប្បច្ច័យ ៦.អវិគតប្បច្ច័យ ។

**១២.រូប** គឺ ហទយវត្ថុ ដែលកើតមុន និងកំពុងតាំងនៅ ជាបច្ច័យជួយឧបការៈដល់មនាយតនៈដែលបានដល់បញ្ចវោការវិបាក ១៨ (វៀរទ្វិបញ្ចវិញ្ញាណ) ក្នុងបវត្តិកាល នៃបញ្ចវោការភូមិនោះ បាន អំណាចបច្ច័យ ៥ គឺៈ

១.វត្ថុបុរេជាតនិស្សយប្បច្ច័យ ២.វត្ថុបុរេជាតបច្ច័យ ៣.វត្ថុបុរេជាតប្បច្ច័យ ៤.អត្ថិប្បច្ច័យ ៥.អវិគតប្បច្ច័យ ។

**១៣.រូប** គឺ បញ្ចាយតនៈ ដែលកើតមុន និងតាំងនៅ ជាបច្ច័យជួយឧបការៈដល់មនាយតនៈ ដែលបានដល់ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ក្នុងបវត្តិកាលនៃបញ្ចវោការភូមិនោះ បានអំណាចបច្ច័យ ៦ គឺៈ

១.វត្ថុបុរេជាតនិស្សយប្បច្ច័យ ២.វត្ថុបុរេជាតប្បច្ច័យ ៣.បុរេជាតិន្ទ្រិយប្បច្ច័យ ៤.វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ ៥.អត្ថិប្បច្ច័យ ៦.អវិគតប្បច្ច័យ ។

**១៤.រូប** គឺ កម្មជមហាភូតរូប ៤ ជាបច្ច័យជួយឧបការៈដល់បញ្ចាយតនៈ ដែលតាំងនៅក្នុងកលាបៈដូចគ្នាជាមួយខ្លួនឯង ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាលនៃបញ្ចវោការភូមិនោះ បានអំណាចបច្ច័យ ៤ គឺៈ

១.សហជាតប្បច្ច័យ ២.សហជាតនិស្សយប្បច្ច័យ

៣.អត្ថិប្បច្ច័យ ៤.អវិគតប្បច្ច័យ

**១៥.រូប** គឺ រូបជីវិតិន្ទ្រិយប្បច្ច័យ ជាបច្ច័យជួយឧបការដល់បញ្ចាយតនៈ ដែលតាំងនៅកលាបៈដូចគ្នាជាមួយខ្លួនឯង ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាលនៃបញ្ចវោការភូមិនោះ បានអំណាចបច្ច័យ ៣ គឺៈ

១.រូបជីវិតិន្ទ្រិយប្បច្ច័យ ២.អត្ថិប្បច្ច័យ ៣.អវិគតប្បច្ច័យ

**១៦.រូប** កម្មជឱជា ជាបច្ច័យជួយឧបការៈដល់បញ្ចាយតនៈដែលតាំង-នៅក្នុងកលាបៈ ដូចគ្នាជាមួយខ្លួនឯងនិងក្នុងកលាបៈដទៃៗ ក្នុងបវត្តិ-កាលនៃកាមភូមិនោះ ដោយអំណាចបច្ច័យ ៣ គឺៈ

១.រូបអាហារប្បច្ច័យ ២.អត្ថិប្បច្ច័យ ៣.អវិគតប្បច្ច័យ

កាលរួមអំណាចបច្ច័យក្នុងការជួយសង្គ្រោះឧបការៈ របស់នាមរូបដល់សឡាយតនៈនោះបានបច្ច័យ ២២ គឺៈ

១.ហេតុប្បច្ច័យ ២.សហជាតប្បច្ច័យ ៣.អញ្ញមញ្ញប្បច្ច័យ

៤.សហជាតនិស្សយប្បច្ច័យ ៥.វត្ថុបុរេជាតនិស្សយប្បច្ច័យ

៦.វត្ថុបុរេជាតប្បច្ច័យ ៧.បច្ឆាជាតប្បច្ច័យ ៨.កម្មប្បច្ច័យ

៩.វិបាកប្បច្ច័យ១០.រូបអាហារប្បច្ច័យ១១.នាមអាហារប្បច្ច័យ

១២.សហជាតិន្ទ្រិយប្បច្ច័យ ១៣.បុរេជាតិន្ទ្រិយប្បច្ច័យ

១៤.រូបជីវិតិន្ទ្រិយប្បច្ច័យ ១៥.ឈានប្បច្ច័យ ១៦.មគ្គប្បច្ច័យ

១៧.សម្បយុត្តប្បច្ច័យ ១៨.សហជាតវិប្បយុត្តប្បច្ច័យ

១៩.វត្ថុបុរេជាតិប្បយុត្តប្បច្ច័យ ២០.បច្ឆាជាតវិប្បយុត្តប្បច្ច័យ

២១.អត្ថិប្បច្ច័យ( ទាំង ៥ បច្ច័យ) ២២.វិគតប្បច្ច័យ

( ទាំង ៥ បច្ច័យ ) ។

**ចប់ នាមរូបប្បច្ចយា សឡាយតនំ**

## ៥.សឡាយតនប្បច្ចយា ផស្សោ សម្ភវតិ

ផស្សៈ ៦ រមែងប្រាកដកើតឡើង ព្រោះអាស្រ័យអជ្ឈត្តិ-កាយតនៈ ៦ ជាហេតុ គឺ សឡាយតនៈដែលជាហេតុឱ្យកើតផស្សៈនេះ ក៏បានដល់ អជ្ឈត្តិកាយតនៈ ។

ផស្សៈ ៦ គឺ ជាផលរបស់នាមរូបនោះឯង ។

១.ចក្ខុសម្ផស្សៈ ២.សោតសម្ផស្សៈ ៣.ឃានសម្ផស្សៈ

៤.ជិវ្ហាសម្ផស្សៈ ៥.កាយសម្ផស្សៈ ៦.មនោសម្ផស្សៈ

ផស្សៈទាំង ៦ នេះ បានដល់ ផស្សចេតសិក ដែលប្រកបជាមួយ

លោកិយវិបាកចិត្ត ៣២ ។

## វចនត្ថៈរបស់ ផស្សៈ

អារម្មំ ផុសតីតិ = ផស្សោ

ធម្មជាតិដែលប៉ះខ្ទប់នូវអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ផស្សៈ ។

ម្យ៉ាងទៀត

ផុសន្តិ សម្បយុត្តធម្មា ឯតេនាតិ = សម្ផស្សោ

សម្បយុត្តធម៌ គឺ ចិត្ត និងចេតសិកទាំងឡាយ រមែងប៉ះខ្ទប់នូវអារម្មណ៍ ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ផស្សៈ ។

ន័យម្យ៉ាងទៀត

ផុសនំ =ផស្សោ (វា)សំផុសតេ = សម្ផស្សោ

ការប៉ះខ្ទប់នូវអារម្មណ៍ ឈ្មោះថា ផស្សៈ ឬ ឈ្មោះថា សម្ផស្សៈ

## វចនត្ថៈរបស់ ចក្ខុសម្ផស្សៈ ជាដើម

ចក្ខុវិញ្ញាណេន សម្បយុត្តោ សម្ផស្សោតិ=ចក្ខុសម្ផស្សោ

ផស្សៈ គឺការប៉ះខ្ទប់ជាមួយចក្ខុវិញ្ញាណ ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខុសម្ផស្សៈ បានដល់ ផស្សចេតសិកដែលប៉ះខ្ទប់ ជាមួយចក្ខុវិញ្ញាណ (សោតសម្ផស្សៈ ។ល។ កាយសម្ផស្សៈ ក៏មាន ទំនងយ៉ាងនេះដូចគ្នា) ។

**មនោវិញ្ញាណេន សម្បយុត្តោ សម្ផស្សោតិមនោសម្ផស្សោ**
**ផស្ស:** គឺ ការប៉ះខ្ទប់ជាមួយមនោវិញ្ញាណ ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្ស:** បានដល់ ផស្សចេតសិក ដែលប្រកបជាមួយលោកិយវិបាកចិត្ត ២២ (វៀរទ្វិបញ្ចវិញ្ញាណ) ។

**អធិប្បាយថា** មនុស្សដែលស្លាប់ហើយ សូម្បីមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ក៏ដោយ តែផស្ស:ផ្សេងៗ មានចក្ខុ-សម្ផស្សជាដើម រមែងកើតឡើងមិនបាន មានន័យថា ការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវ ការនឹកគិតផ្សេងៗ មិនមាន ដូច្នេះក៏ព្រោះបាត់បសាទរូបទាំង ៥ និង ភវង្គចិត្ត ដែលហៅថា សឡាយតន:នោះឯង ហើយអ្នកដែលមានជីវិតនោះ ប្រសិនបើខ្វាក់ភ្នែកហើយ ចក្ខុសម្ផស្សក៏កើតមិនបាន ឬប្រសិនបើត្រចៀកខូចហើយ សោតសម្ផស្ស: ក៏កើតមិនបានជាដើមដូចគ្នា ។

ម្យ៉ាងទៀត ផស្ស: ដែលជាផលរបស់សឡាយតន:នោះ បានដល់ ការប្រជុំព្រមគ្នា រវាងបសាទរូបទាំង ៥ ជាមួយបញ្ចារម្មណ៍ និងបញ្ចវិញ្ញាណ ឈ្មោះថា ចក្ខុផស្ស: សោតផស្ស: ឃានផស្ស: ជិវ្ហាផស្ស: កាយផស្ស: ព្រោះការដែលចក្ខុវិញ្ញាណជាដើម កើតឡើងបាននោះ ក៏អាស្រ័យប៉ះខ្ទប់គ្នារវាងចក្ខុបសាទ និងរូបារម្មណ៍

សោតបសាទ ជាមួយ សទ្ទារម្មណ៍ ឃានបសាទ ជាមួយ គន្ធារម្មណ៍ ជីវ្ហាបសាទ ជាមួយ រសារម្មណ៍ កាយបសាទ ជាមួយ ផោដ្ឋព្វារម្មណ៍ ហើយទើបធ្វើឱ្យចក្ខុវិញ្ញាណជាដើមកើតឡើង បើចក្ខុវិញ្ញាណជាដើមកើតឡើងហើយ ចក្ខុសម្ផស្សៈជាដើមក៏ប្រាកដ ចំណែកមនោសម្ផស្សនោះ បានដល់ ការប៉ះខ្ទប់គ្នារវាងភវង្គចិត្តជាមួយសភាវធម៌ផ្សេងៗ ទាំងបរមត្ថនិងបញ្ញត្តិ ដែលបានដល់ធម្មារម្មណ៍ ឬអារម្មណ៍ ៦ សំដៅយកក្នុងរវាងដែលវិថីចិត្តមិនទាន់កើត ព្រោះភវង្គចិត្តដែលកើតឡើងនោះ ក៏បានប៉ះខ្ទប់ជាមួយអារម្មណ៍ដែលជា កម្ម កម្មនិមិត្ត គតិនិមិត្ត ណានីមួយជានិច្ច ប៉ះខ្ទប់នេះឯង ឈ្មោះថា មនោសម្ផស្សៈ បានដល់ផស្សៈដែលប្រកបជាមួយភវង្គចិត្តនោះឯង។

**ន័យម្យ៉ាងទៀត** មនោសម្ផស្ស បានដល់ ការប្រជុំព្រមគ្នារវាងភវង្គចិត្ត ជាមួយ សភាវធម៌ផ្សេងៗ ទាំងបរមត្ថ បញ្ញត្តិ និងវិញ្ញាណ នេះសំដៅយក ក្នុងរវាងដែលវិថីចិត្តកើតឡើងហើយ ព្រោះវិថីចិត្តដែលកើតឡើងបាននោះ ក៏ត្រូវអាស្រ័យការប៉ះខ្ទប់គ្នារវាងភវង្គចិត្ត ជាមួយសភាវធម៌ផ្សេងៗ ជាហេតុ បើវិថីចិត្តកើតឡើងហើយ មនោសម្ផស្សៈក៏ប្រាកដឡើង តែផស្សៈដែលប្រកបនៅក្នុងកុសល អកុសល និងកិរិយានោះមិនយកទេ សំដៅយកតែចំពោះផស្សៈ

ដែលប្រកបនៅក្នុងវិបាកមនោវិញ្ញាណ មានសម្បដិច្ឆន្នៈ សន្តីរណៈ តទាលម្ពណៈប៉ុណ្ណោះ សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្ដែងទុកក្នុងនិទានវគ្គសំយុត្តព្រះបាលីថា

ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.
សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.
ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.
ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.
កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.
មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ.

ចក្ខុវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យចក្ខុបសាទ ជាមួយរូបារម្មណ៍ ការប្រជុំរួមគ្នារវាងចក្ខុបសាទ រូបារម្មណ៍ ចក្ខុវិញ្ញាណ ទាំង ៣ នេះឯងឈ្មោះថា ផស្សៈ ។

សោតវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យសោតបសាទ ជាមួយ សទ្ទារម្មណ៍ ការប្រជុំរួមគ្នារវាងសោតបសាទ សទ្ទារម្មណ៍ សោតវិញ្ញាណ ទាំង ៣ នេះឯងឈ្មោះថា ផស្សៈ ។

ឃានវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យឃានបសាទ ជាមួយ គន្ធារម្មណ៍ ការប្រជុំរួមគ្នារវាងឃានបសាទ គន្ធារម្មណ៍ ឃានវិញ្ញាណ ទាំង ៣ នេះឯងឈ្មោះថា ផស្សៈ ។

ជិវ្ហាវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យ ជិវ្ហាបសាទ ជាមួយ រសារម្មណ៍ ការប្រជុំរួមគ្នារវាងជិវ្ហាបសាទ រសារម្មណ៍ ជិវ្ហាវិញ្ញាណ ទាំង ៣ នេះឯងឈ្មោះថា ផស្សៈ ។

កាយវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យ កាយបសាទ ជាមួយផោដ្ឋព្វារម្មណ៍ ការប្រជុំរួមគ្នារវាងកាយបសាទ ផោដ្ឋព្វារម្មណ៍ កាយវិញ្ញាណ ទាំង ៣ នេះឯងឈ្មោះថា ផស្សៈ ។

មនោវិញ្ញាណ រមែងប្រាកដកើតឡើងបាន ព្រោះអាស្រ័យ ភវង្គចិត្ត ជាមួយ សភាវធម៌ផ្សេងៗ ទាំងបរមត្ថ និងបញ្ញត្តិ ការប្រជុំរួម គ្នារវាងភវង្គចិត្ត សភាវធម៌ផ្សេងៗ មនោវិញ្ញាណទាំង ៣ នោះឯង ឈ្មោះថា ផស្សៈ ។

**ម្យ៉ាងទៀត** ការប៉ះខ្ទប់អារម្មណ៍របស់ផស្សៈនេះ មិនដូចគ្នា ជាមួយការប៉ះខ្ទប់គ្នារវាង រូប និង រូប ដូចដៃ ២ ខាងប៉ះខ្ទប់គ្នា ឬ វត្ថុ ២ ប៉ះខ្ទប់គ្នា ជាការប៉ះខ្ទប់គ្នាក្នុងអារម្មណ៍ណាមួយតាមសភាវៈ តែគ្រា ខ្លះការប៉ះខ្ទប់អារម្មណ៍តាមសភាវៈដែលឈ្មោះថា ផស្សៈនេះ ក៏ប្រាកដ ជាក់ច្បាស់ដូចជាមានវត្ថុណាមួយមកប៉ះខ្ទប់ជាមួយកាយ ដូចជា ក្នុង ខណៈដែលឃើញបុគ្គលដទៃ កំពុងបរិភោគរបស់ជូរៗអ្នកឃើញក៏ ស្រក់ទឹកមាត់ ឬបុគ្គលណាមួយកំពុងសំលៀងកាំបិតនៅលើថ្មដែលមាន

ដីខ្សាច់ បុគ្គលដែលបានឮសម្លេងនោះ ក៏ស្រៀវធ្មេញ ឬបុគ្គលដែលមានចិត្តខ្សោយ ឃើញអ្នកឡើងទៅកាន់ទីខ្ពស់ៗ ក៏ញ័រតក់ស្លុត ខ្លាច ឬបុគ្គលកំសាកបានឃើញគេកំពុងដំធ្មេញមានលោហិតស្រក់ ឃើញហើយចិត្តក៏ញ័រដូចខ្យល់ ឬម្រឹគកាលបើឃើញខ្លា នឹងឈានជើងមិនរួចឈរធ្មឹង នៅមួយកន្លែង ឬអ្នកដែលបានចូលទៅក្នុងស្ថានទីស្ងប់ស្ងាត់មានសប្បុរសទាំងឡាយកំពុងបំពេញកម្មដ្ឋាន កាលបើឃើញបុគ្គល និងស្ថានទីដូច្នេះហើយ ក៏ដឹងថាចិត្តសប្បាយត្រជាក់ជ្រះថ្លាឡើងភ្លាម ការប្រព្រឹត្តទៅដូចពោលមកនេះ ក៏គឺការប៉ះខ្ទប់គ្នារវាងចិត្ត ជាមួយអារម្មណ៍ដែលហៅថា ផស្សៈនោះឯង ហើយផស្សៈទាំង ៦ កើតឡើងបានក៏ព្រោះមានអជ្ឈត្តិកាយតនៈ ៦ ដែលកើតពីអតីតកម្មជាហេតុ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងថា៖ **សឡាយតនប្បច្ចយា ផស្សោ ។**

**បើចែកផស្សៈ ៦ ដោយភូមិបានដូច្នេះ គឺ៖**

ក្នុងកាមភូមិ ១១ ផស្សៈ ៦ រមែងកើតឡើងបាន

ក្នុងរូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ) ផស្សៈរមែងកើតបាន ៣ គឺ ចក្ខុសម្ផស្សៈ សោតសម្ផស្សៈ មនោសម្ផស្សៈ

ក្នុងអរូបភូមិ ៤ ផស្សៈរមែងកើតបាន ១ គឺ មនោសម្ផស្សៈ

ចំណែក ក្នុងអសញ្ញីសត្តភូមិនោះ ផស្សៈទាំងអស់រមែងកើតមិនបាន ព្រោះមិនមានអជ្ឈត្តិកាយតនៈ ៦ កើតក្នុងភូមិនោះ ។

## លក្ខណាទិចតុក្កៈរបស់ ផស្សៈ

១.**ផុសនលក្ខណោ** មានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈ

២.**សំឃដ្ដនរសោ** មានការធ្វើឱ្យចិត្តជាមួយអារម្មណ៍ ជាកិច្ច

៣.**សង្គតិបច្ចុប្បដ្ឋានោ** មានការប្រជុំរួមគ្នារវាងវត្ថុ អារម្មណ៍ និងវិញ្ញាណ ជាអាការប្រាកដ

៤.**សឡាយតនបទដ្ឋានោ** មានអជ្ឈត្តិកាយតនៈ ៦ ជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា
## សឡាយតនប្បច្ចយា ផស្សោ

**១.ចក្ខាយតនៈ** ជាបច្ច័យជួយឧបការៈដល់ចក្ខុសម្ផស្សៈនោះ បានដោយអំណាចបច្ច័យ ៦ គឺៈ

| | |
|---|---|
| ១.វត្ថុបុរេជាតនិស្សយប្បច្ច័យ | ២.វត្ថុបុរេជាតប្បច្ច័យ |
| ៣.បុរេជាតិន្ទ្រិយប្បច្ច័យ | ៤.វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ |
| ៥.វត្ថុបុរេជាតត្ថិប្បច្ច័យ | ៦.វត្ថុបុរេជាតអវិគតប្បច្ច័យ |

**២.សោតាយតនៈ** ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ ជាបច្ច័យ ជួយឧបការៈដល់ សោតសម្ផស្សៈ ឃានសម្ផស្សៈ ជិវ្ហាសម្ផស្សៈ កាយសម្ផស្សៈនោះ បានដោយអំណាចបច្ច័យ៦ ដូចគ្នានឹងជាមួយ ចក្ខាយតនៈជាបច្ច័យ ចក្ខុសម្ផស្សៈ ជាបច្ចយុប្បន្នៈ។

**៣.មនាយតនៈ** គឺ លោកិយវិបាកចិត្ត ២២ (វៀរទ្វិបញ្ចវិញ្ញាណ) ជាបច្ច័យ ជួយឧបការៈដល់មនោសម្ផស្សៈ ដែលប្រកបនឹងខ្លួននោះ បានដោយអំណាចបច្ច័យ ៩ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.សហជាតនិស្សយបច្ច័យ ៤.វិបាកប្បច្ច័យ ៥.នាមអាហារប្បច្ច័យ ៦.សហជាតិន្ទ្រិយប្បច្ច័យ ៧.សម្បយុត្តប្បច្ច័យ ៨.សហជាតត្ថិប្បច្ច័យ ៩.សហជាតអវិគតប្បច្ច័យ។

**ចប់ សឡាយតនប្បច្ចយា ផស្សោ**

## ៦.ផស្សប្បច្ចយា វេទនា សម្ពុទតិ

វេទនា ៦ រមែងប្រាកដកើតឡើង ព្រោះអាស្រ័យផស្សៈ ៦ ជាហេតុ វេទនាដែលកើតឡើងដោយអាស្រ័យសម្ផស្សៈនោះគឺៈ

**១.ចក្ខុសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងចក្ខុវិញ្ញាណ ជាមួយ រូបារម្មណ៍បានដល់ វេទនាដែលនៅក្នុងចក្ខុវិញ្ញាណចិត្ត។

**២.សោតសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងសោតវិញ្ញាណ ជាមួយ សទ្ទា-រម្មណ៍ បានដល់ វេទនាដែលនៅក្នុងសោតវិញ្ញាណចិត្ត។

**៣.ឃានសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាង ឃានវិញ្ញាណ ជាមួយ គន្ធា-រម្មណ៍ បានដល់ វេទនាដែលនៅក្នុងឃានវិញ្ញាណចិត្ត។

**៤.ជិវ្ហាសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងជិវ្ហាវិញ្ញាណ ជាមួយ រសារម្មណ៍បានដល់ វេទនាដែលនៅក្នុងជិវ្ហាវិញ្ញាណចិត្ត។

**៥.កាយសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងកាយវិញ្ញាណ ជាមួយផោដ្ឋព្វារម្មណ៍ បានដល់ វេទនាដែលនៅក្នុងកាយវិញ្ញាណចិត្ត ។

**៦.មនោសម្ផស្សជ្ជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងមនោវិញ្ញាណជាមួយធម្មារម្មណ៍ ឬអារម្មណ៍ ៦ បានដល់ វេទនាដែលនៅក្នុងលោកិយវិបាកចិត្ត ២២ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត) ។

## វចនត្ថៈរបស់ពាក្យថា វេទនា

**វេទយតីតិ = វេទនា**

ធម្មជាតិណារមែងសោយអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **វេទនា** ។

ចក្ខុសម្ផស្សតោ ជាតា វេទនាតិ = ចក្ខុសម្ផស្សជ្ជា វេទនា

សោតសម្ផស្សតោ ជាតា វេទនាតិ = សោតសម្ផស្សជ្ជា វេទនា

ឃានសម្ផស្សតោ ជាតា វេទនាតិ = ឃានសម្ផស្សជ្ជា វេទនា

ជិវ្ហាសម្ផស្សតោ ជាតា វេទនាតិ = ជិវ្ហាសម្ផស្សជ្ជា វេទនា

កាយសម្ផស្សតោ ជាតា វេទនាតិ = កាយសម្ផស្សជ្ជា វេទនា

មនោសម្ផស្សតោ ជាតា វេទនាតិ = មនោសម្ផស្សជ្ជា វេទនា

វេទនាដែលកើតឡើងព្រោះអាស្រ័យចក្ខុសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **ចក្ខុសម្ផស្សជ្ជាវេទនា** ។

វេទនាដែលកើតឡើង ព្រោះអាស្រ័យសោតសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **សោតសម្ផស្សជ្ជាវេទនា** ។

វេទនាដែលកើតឡើងព្រោះអាស្រ័យឃានសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **ឃានសម្ផស្សជ្ជាវេទនា** ។

វេទនាដែលកើតឡើងព្រោះអាស្រ័យជិវ្ហាសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **ជិវ្ហាសម្ផស្សជ្ជាវេទនា** ។

វេទនាដែលកើតឡើងព្រោះអាស្រ័យកាយសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **កាយសម្ផស្សជ្ជាវេទនា** ។

វេទនាដែលកើតឡើងព្រោះអាស្រ័យមនោសម្ផស្សជាហេតុ ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្សជ្ជាវេទនា** ។

វេទនាទាំង ៦ នេះ កាលពោលដោយចំណែក សុខ ទុក្ខ និងឧបេក្ខាបានហើយដូចនេះ គឺៈ

ចក្ខុសម្ផស្សជ្ជាវេនា រហូតដល់ ជិវ្ហាសម្ផស្សជ្ជាវេទនាទាំង ៤ នេះជាការសោយអាម្មណ៏ប្រភេទឧបេក្ខាវេទនា។

កាយសម្ផស្សជ្ជាវេទនា ជាការសោយអារម្មណ៏ប្រភេទសុខ ១ ទុក្ខ ១

មនោសម្ផស្សជ្ជាវេទនា ជាការសោយអារម្មណ៍ប្រភេទសុខ ១ ទុក្ខ ១ ឧបេក្ខា ១

កាលបើពោលដោយធម្មជាតិ ដែលប្រព្រឹត្តទៅនៅក្នុងលោកនេះ ការសោយអារម្មណ៍មាន ៣ យ៉ាងគឺ:

១.ភាពដឹងសប្បាយកាយសប្បាយចិត្ត ក្នុងកាលបានប្រសព្វជាមួយអារម្មណ៍ដែលត្រូវចិត្ត ហៅថា សុខវេទនា តែម្យ៉ាង។

២.ភាពដឹងមិនសប្បាយកាយ មិនសប្បាយចិត្ត ក្នុងកាលបានជួបប្រសព្វជាមួយអារម្មណ៍ដែលមិនត្រូវចិត្តហៅថា ទុក្ខវេទនា តែម្យ៉ាង។

៣.ភាពដឹងព្រងើយៗក្នុងកាលបានជួបប្រសព្វជាមួយអារម្មណ៍កណ្តាល ហៅថា ឧបេក្ខាវេទនាតែម្យ៉ាង។

កាលបើពោលដោយបុគ្គលាធិដ្ឋាន ការសោយអារម្មណ៍ រមែងមាន ២ គឺ សុខ១ ទុក្ខ ១ ។

សុខបានដល់ សុខសហគតកាយសម្ផស្សជ្ជាវេទនាសោមនស្ស-ហគតមនោសម្ផស្សជ្ជាវេទនា ឧបេក្ខាវេទនាដែលទាក់ទង ជាមួយនឹងកុសល កិរិយា និង កុសលវិបាក ។

ទុក្ខបានដល់ ទុក្ខសហគតកាយសម្ផស្សជ្ជាវេទនា ទោមនស្សហគតមនោសម្ផស្សជ្ជាវេទនា ឧបេក្ខាវេទនាដែលទាក់ទងជាមួយនឹងអកុសល និង កុសលវិបាក ។

សេចក្ដីសុខ និង សេចក្ដីទុក្ខដូចពោលមកហើយនេះ កើតឡើងបាននោះ ដោយអាស្រ័យសម្ផស្សៈ ដែលបានដល់ការប៉ះខ្ទប់រវាងចិត្ត ជាមួយនិងអារម្មណ៍នោះឯងជាហេតុ ដូច្នេះ សេចក្ដីសុខក្ដី សេចក្ដីទុក្ខក្ដី ដែលមានច្រើន ឬ មានតិចនោះ ក៏ស្រេចតែនឹងកម្លាំងរបស់សម្ផស្សៈ គឺប្រសិនបើការប៉ះខ្ទប់ជាមួយចិត្តរវាងអារម្មណ៍ មានកម្លាំងច្រើន សភាពយល់ដឹងសុខ ទុក្ខ ក៏ប្រាកដច្រើន ប្រសិនបើ ការប៉ះខ្ទប់ ជាមួយចិត្តរវាងអារម្មណ៍មានកម្លាំងតិច ការយល់ដឹងសុខ សភាពយល់ដឹងទុក្ខ ក៏ប្រាកដតិច ឧបមាដូចជាខណៈដែលបរិភោគអាហារ ធ្មេញមានតួនាទីទំពារអាហារ អណ្ដាតមានតួនាទីដឹងរស ប្រសិនបើធ្មេញ ធ្វើតួនាទីទំពារម៉ដ្ឋហើយ អណ្ដាតក៏ដឹងរសបានយ៉ាងច្បាស់ ប្រសិនបើធ្មេញមិនបានធ្វើតួនាទី ទំពារឱ្យម៉ដ្ឋហើយ អណ្ដាតក៏ដឹងរសបានតិច សេចក្ដីនេះយ៉ាងណា ផស្សៈក៏ប្រៀបដូចធ្មេញ វេទនាប្រៀបដូចជាក្លិនអារម្មណ៍ប្រៀបដូចអាហារ ការប៉ះខ្ទប់រវាងចិត្តជាមួយអារម្មណ៍ប្រៀបដូចការទំពារអាហារ ការប៉ះខ្ទប់ដែលមានកម្លាំងច្រើន ឬមានកម្លាំងតិចនោះ ប្រៀបដូចជាការទំពារបានល្អិត និងមិនល្អិតនោះឯង ។

ការប៉ះខ្ទប់រវាងចិត្តជាមួយអារម្មណ៍ដែលហៅថា ផស្សៈដូចពោលមកនេះ នឹងឃើញបានក្នុងការប្រព្រឹត្តទៅដែលកើតឡើងជាមួយមនុស្សទាំងឡាយ ដូចក្នុងខណៈដែលមើលល្ខោន ឬភាពយន្ត ប្រសិន

បើឃើញមិនច្បាស់ បានឮមិនច្បាស់ដោយនៅឆ្ងាយពេក ឬមានពន្លឺតិច បើពោលដោយធម្មាធិដ្ឋាន គឺផស្សៈ មានកម្លាំងតិច ដោយហេតុនេះ អ្នកដែលមើលនោះទើបព្យាយាមរំកិលឱ្យចូលទៅជិតៗ ដើម្បីឃើញ និងឮបានជាក់ច្បាស់ ឬបើមានពន្លឺ តិចក៏ព្យាយាមឱ្យមានពន្លឺច្រើនឡើង ប្រសិនបើឃើញ ឬឮជាក់ច្បាស់ល្អហើយ ក៏សំដៅថា ផស្សៈនោះមានកម្លាំងខ្លាំងឡើង បើផស្សៈមានកម្លាំងខ្លាំងឡើងហើយ វេទនា គឺការសោយអារម្មណ៍នោះ ក៏ប្រាកដជាក់ច្បាស់ក្រៃលែងឡើង គឺឃើញជាក់ច្បាស់ ឬបានឮជាក់ច្បាស់នោះឡើង បើមានការឃើញច្បាស់ ឮច្បាស់ហើយ ឥដ្ឋរស ឬអនិដ្ឋរសដែលមាននៅក្នុងអារម្មណ៍នោះៗ ក៏រមែងប្រាកដច្បាស់ ទាំងនេះក៏ព្រោះថា ចក្ខុវិញ្ញាណ គឺការឃើញជាដើមនោះ មាននាទីត្រឹមតែប៉ះខ្ទប់ រូប សម្លេង ក្លិន រស ជាដើម ឱ្យជាអារម្មណ៍ប៉ុណ្ណោះ ធ្វើឱ្យឥដ្ឋរស ឬ អនិដ្ឋរស ដែលមាននៅក្នុងអារម្មណ៍នោះៗ ឱ្យប្រាកដឡើងមិនបាន ធម៌ដែលអាចធ្វើឱ្យឥដ្ឋរស ឬ អនិដ្ឋរសប្រាកដឡើងបាននោះ បានដល់ ផស្សៈ ដូច្នោះ ក្នុងពេលណាដែលបានទទួលអារម្មណ៍ល្អ សំដៅដល់ ផស្សៈបានប៉ះខ្ទប់ ធ្វើនាទីច្របាច់ឱ្យឥដ្ឋរសប្រាកដឡើងហើយ ក្នុងវេលាណា ដែលបាន ទទួលអារម្មណ៍មិនល្អ សំដៅដល់ ផស្សៈបានធ្វើនាទី ដែល ច្របាច់ឱ្យអនិដ្ឋរសប្រាកដឡើង កាលបើឥដ្ឋរស និងអនិដ្ឋរស

ប្រាកដឡើងហើយ វេទនាក៏ចូល ទៅធ្វើនាទីសោយ គឺដឹងអារម្មណ៍សប្បាយ ឬមិនសប្បាយក្នុងអារម្មណ៍នោះៗ ដោយហេតុនេះ ខណៈណាដែលវេទនាកំពុងសោយសេចក្ដីសុខក្នុងអារម្មណ៍ វេទនានោះរមែងសម្ដែងអាការៈឱ្យប្រាកដឡើងដល់បុគ្គលនោះ គឺ ធ្វើឱ្យមានមុខមាត់ស្រស់បស់ សប្បាយរីករាយ ដែលក្នុងលោកសម្មតិគ្នាថា បុគ្គលនោះបុគ្គលនេះកំពុងមានសេចក្ដីសុខ ហើយក្នុងខណៈណាដែល វេទនាកំពុងសោយសេចក្ដីទុក្ខនៅក្នុងអារម្មណ៍ វេលានោះក៏សម្ដែងអាការៈឱ្យប្រាកដឡើងដល់បុគ្គលនោះដូចគ្នា គឺធ្វើឱ្យមានការសៅហ្មង ពិបាកដែលសម្មតិគ្នាថាអ្នកនោះ អ្នកនេះកំពុងមានទុក្ខអាស្រ័យ នៅនោះឯង ។

## លក្ខណាទិចតុក្កៈរបស់ វេទនា

**១.អនុភវនលក្ខណា** មានការសោយអារម្មណ៍ជាលក្ខណៈ។

**២.វិសយរសសម្ភោគរសា** មានការសោយរសរបស់អារម្មណ៍ជាកិច្ច។

**៣.សុខទុក្ខបច្ចុប្បដ្ឋានា** មានសេចក្ដីសុខនិងទុក្ខ ជាអាការប្រាដក។

**៤.ផស្សបទដ្ឋានា** មានផស្សៈជាហេតុជិត។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា ផស្សប្បច្ចយា វេទនា

ផស្សៈទាំង ៦ ជាបច្ច័យជួយឧបការៈដល់វេទនា ៦ នោះ ដោយអំណាចបច្ច័យ ៨ គឺៈ

១.សហជាតប្បច្ច័យ ២.អញ្ញមញ្ញប្បច្ច័យ ៣.សហជាតនិស្សយប្បច្ច័យ

៤.វិបាកប្បច្ច័យ ៥.នាមអាហារប្បច្ច័យ ៦. សម្បយុត្តប្បច្ច័យ

៧.សហជាតត្ថិប្បច្ច័យ ៨.សហជាតអវិគ្គតប្បច្ច័យ

ចប់ ផស្សបច្ចយា វេទនា

## ៧.វេទនាបច្ចយា តណ្ហា សម្ភវតិ

តណ្ហា រមែងប្រាកដកើតឡើង ព្រោះអាស្រ័យវេទនា ៦ ជាហេតុ ។

### វចនត្ថៈរបស់ពាក្យថា តណ្ហា

**វត្ថុកាមំ បរិតស្សតីតិ = តណ្ហា**

ធម្មជាតិណារមែងជាប់ចិត្តក្នុងវត្ថុកាម ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា តណ្ហា ។

**ម្យ៉ាងទៀត :វត្ថុកាមំ បរិតស្សន្តិ សត្តា ឯតាយាតិ = តណ្ហា**

សត្វទាំងឡាយរមែងត្រេកអរនូវវត្ថុកាម ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា តណ្ហា បានដល់លោភ-ចេតសិកដែលនៅក្នុងលោភមូលចិត្ត ៨ ។

**អធិប្បាយថា** កាលរូប សំឡេង ក្លិន រស សម្ផស្ស និងសភាវៈធម៌ផ្សេង ៗ មកប្រាកដក្នុងផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហើយ តណ្ហាគឺសភាពត្រេកអរក្នុងអារម្មណ៍នោះៗ ក៏រមែងកើតឡើង

ជាធម្មតាដល់មនុស្សទូទៅ វៀរតែព្រះអរហន្ត ហើយប្រសិនបើអារម្មណ៍នោះ ទទួលកាមគុណហើយក៏វៀរព្រះអនាគាបាន ដូច្នេះក៏ព្រោះអាស្រ័យមានវេទនា គឺសភាពដឹងក្នុងការឃើញជាដើមនោះឯង ធម្មតាមនុស្សទាំងឡាយដែលកើតសេចក្ដីពេញចិត្តក្នុង អារម្មណ៍ណាមួយក៏ដោយ ត្រូវជាអារម្មណ៍ដែលខ្លួនបានជួបប្រសព្វមកហើយ ឬកំពុងបានទទួលនូវអារម្មណ៍ ដែលខ្លួនមិនបានជួបប្រទះនោះ តណ្ហារមែងកើតបានលំបាក ព្រោះវេទនាគឺការសោយអារម្មណ៍ ដែលខ្លួននៅមិនទាន់ជួបប្រទះនោះ រមែងកើតបានលំបាក តណ្ហា គឺសេចក្ដីពេញចិត្តក្នុងអារម្មណ៍មានរូប សំឡេង ក្លិន រស ជាដើមនេះ គឺសេចក្ដីពេញចិត្ត ចំពោះសុខវេទនាដែលបានទទួល អំពីអារម្មណ៍នោះៗ កាលពេញចិត្តចំពោះសុខវេទនាហើយ ក៏ត្រូវមានសេចក្ដីពេញចិត្ត ក្នុងអារម្មណ៍ ដែលធ្វើឱ្យសុខវេទនាកើតដូចគ្នា អ្នកដែលកំពុងបានទទួលសេចក្ដីសុខហើយ តណ្ហានោះរមែងពេញក្នុងសេចក្ដីសុខដែលខ្លួនកំពុងធ្វើនោះ ហើយក៏មានសេចក្ដីប្រាថ្នាឱ្យ បានទទួលសេចក្ដីសុខក្រៃលែងឡើងតទៅទៀត ដូច្នេះ ទើបព្រះអង្គទ្រង់សម្ដែងថា **វេទនា-បច្ចយា តណ្ហា** គឺ សុខវេទនាជាហេតុឱ្យ កើតតណ្ហា។

អ្នកដែលបានទទួលសេចក្ដីទុក្ខសេចក្ដីសុខលំបាកផ្សេងៗ ឬកំពុងមិនសប្បាយក៏រមែងគិតដល់សេចក្ដីសុខ និងអារម្មណ៍ដែលធ្វើឱ្យសេចក្ដីសុខកើត ហើយព្យាយាមខ្វល់ខ្វាយ រកផ្លូវដែលនឹងឱ្យឆ្លងចាកសេចក្ដីទុក្ខ សេចក្ដីលំបាកនោះ ៗ ដោយវិធីការផ្សេង ៗ អ្នកដែលឈឺមិនសប្បាយចិត្ត ក៏ព្យាយាមរកពេទ្យឱ្យមករក្សាឱ្យផុតអំពីជំងឺ កាលនៅមិនទាន់រួចពីសេចក្ដីទុក្ខទាំងឡាយ ក៏រំពឹងត្រិះរិះថា កាលណាទើបពេទ្យឱ្យខ្លួនផុតអំពីសេចក្ដីទុក្ខលំបាកនេះបាន ក៏ព្រោះដោយអំណាចនៃតណ្ហាដែលកើតមកពីទុក្ខវេទនាជាហេតុ សម្ដែងឱ្យឃើញថាទុក្ខវេទនាជាហេតុឱ្យកើតតណ្ហាបាន ។

អ្នកដែលមិនជួបទុក្ខប្រក្រតី នឹងមិនមានសេចក្ដីសុខជាពិសេស គឺ កំពុងសោយសេចក្ដីសុខទុក្ខយ៉ាងកណ្ដាល សភាវៈរបស់ឧបេក្ខាវេទនា មានសភាពយ៉ាងស្ងប់ ស្រដៀងនឹងសុខវេទនា អ្នកដែលនៅក្នុងសភាពយ៉ាងនេះ រមែងមានសេចក្ដីត្រេកអរពេញចិត្ត ចំពោះឧបេក្ខាវេទនានេះ ហើយគិតថាសូម្បីមិនបានសេចក្ដីសុខយ៉ាងពិសេស ក៏ចំណុចនេះឱ្យប្រព្រឹត្តទៅជារឿយៗ កុំឱ្យសេចក្ដីទុក្ខកើតឡើង នេះក៏ព្រោះអំណាចតណ្ហាដែលកើតមកពីឧបេក្ខាវេទនាជាហេតុ នឹងសម្ដែងឱ្យឃើញថា ឧបេក្ខាវេទនាក៏ជាហេតុឱ្យកើតតណ្ហាបាន ។

## ចែកតណ្ហាដោយអារម្មណ៍មាន ៦ យ៉ាង គឺះ

**១.រូបតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងរូបារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **រូបេ តណ្ហា = រូបតណ្ហា**

**២.សទ្ទតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងសទ្ទារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **សទ្ទេ តណ្ហា = សទ្ទតណ្ហា**

**៣.គន្ធតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងគន្ធារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **គន្ធេ តណ្ហា = គន្ធតណ្ហា**

**៤.រសតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងរសារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **រសេ តណ្ហា = រសតណ្ហា**

**៥.ផោដ្ឋព្វតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងផោដ្ឋព្វារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **ផោដ្ឋព្វេ តណ្ហា = ផោដ្ឋព្វតណ្ហា**

**៦.ធម្មតណ្ហា** សេចក្តីត្រេកអរពេញចិត្តក្នុងធម្មារម្មណ៍ ដូច សម្តែងវិចនត្ថៈថា **ធម្មេ តណ្ហា = ធម្មតណ្ហា ។**

### អធិប្បាយថា

កាលរូបារម្មណ៍មកប៉ះខ្ទប់ជាមួយចក្ខុបសាទហើយ ចក្ខុវិញ្ញាណក៏កើត ហើយក្នុងខណៈជាមួយគ្នានោះ ផស្សៈ វេទនាក៏កើតឡើងបាន ហៅថា ឃើញ នេះពោលដោយធម្មាធិដ្ឋាន ប្រសិនបើពោលដោយបុគ្គលា-ធិដ្ឋាន ត្រង់នេះ នៅមិនមានសភាពដឹងយ៉ាងណានៅឡើយ វិថីចិត្ត

រហូតដល់ជវនៈជាមុន ទើបមានសេចក្ដីដឹងច្បាស់ក្នុងការឃើញនោះ ត្រឹមខណៈតូចៗ ជារឿយៗ នូវមិនទាន់ជាក់ច្បាស់ កាលដល់មនោទ្វារវិថីសព្វគ្រប់ហើយ ទើបមានសេចក្ដដឹងច្បាស់ក្នុងការឃើញនេះ បានយ៉ាងច្បាស់ តែតណ្ហាដែលកើតឡើងបាននោះ ក្នុងខណៈដែលដឹងច្បាស់ក្នុងការឃើញតិចតួចតណ្ហាក៏កើតបាន មានសេចក្ដថា តណ្ហាកើតឡើងក្នុងចក្ខុទ្វារវិថីនោះឯង ព្រោះថាអ្នកនោះនៅមានតណ្ហានុស័យ ដូច្នោះវេទនាទើបជាហេតុនាំឱ្យកើតតណ្ហាបាន សម្រាប់អ្នកដែលប្រាសចាកតណ្ហានុស័យ ឬអ្នកដែលមានសតិកំណត់ដឹងក្នុងការឃើញជាដើម ក៏ប្រព្រឹត្តទៅជាប់តគ្នាមិនដាច់ សូម្បីថានឹងកើតសេចក្ដីដឹងច្បាស់ ក្នុងការឃើញត្រឹមតែតិចតួច វេទនាក៏មិនអាចជា ហេតុនាំឱ្យកើតតណ្ហាបាន ដូច្នោះការឃើញ ព្រះពុទ្ធអង្គទ្រង់សម្ដែង ទុកក្នុងនិទានវគ្គសំយុត្តព្រះបាលីថា "**ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា**" ។ នេះជាការសម្ដែងសំដៅយកតែធម្មាធិដ្ឋានប៉ុណ្ណោះ បើសំដៅយកបុគ្គលាធិដ្ឋាន ក៏បានដោយចំណែកច្រើន មិនមែនទាំងអស់នោះទេ។

ក្នុងសទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ក៏ប្រព្រឹត្តទៅដូចគ្នា ជាមួយរូបតណ្ហាដែរ។ ចំពោះធម្មតណ្ហានោះមានសេចក្ដីថា ក្នុងខណៈនឹកដល់លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិជាដើមដែល

ជាផ្នែកអកុសល និងទឹកដល់ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ឈាន អភិញ្ញាជាដើម ជាផ្នែកលោកិយកុសល និង កិរិយា ឬទឹកដល់ ការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការពាល់ត្រូវ ការដេកលក់ ដែលជាផ្នែកខាងកាមវិបាក ឬ ទឹកដល់បសាទរូប សុខុមរូប និងបញ្ញត្តិផ្សេងៗ ទាំងនេះហើយ មានសេចក្តីត្រេកអរពេញចិត្តកើតឡើង ហៅថា **ធម្មតណ្ហា** ។

**ម្យ៉ាងទៀតក្នុងមជ្ឈិមបណ្ណាសកអដ្ឋកថាសម្តែងទុកថា** សេចក្តីត្រេកអរពេញចិត្តក្នុងការចម្រើនសមថៈ និងវិបស្សនាក៏ហៅថា ធម្មតណ្ហាបានដូចគ្នា ដូចមានបាលីសម្តែងទុកថាៈ

**ធម្មរាគេន ធម្មនន្ទិយាតិ បទ្ទ្វយេហិ សមថវិបស្សនាសុ ឆន្ទរាគោ វុត្តោ** ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ពោលដល់សេចក្តីត្រេកអរពេញចិត្ត ក្នុងការចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដោយបទទាំងពីរថា ធម្មរាគៈ ធម្មនន្ទិ ដែលមានសេចក្តីថា ឆន្ទរាគៈ កើតឡើង ក្នុងសមថភាវនា វិបស្សនាភាវនា ឈ្មោះថា **ធម្មតណ្ហា**។

**កាលបើពោលដោយអាការៈមាន ៣ គឺៈ**

**១_កាមតណ្ហា** បានដល់ សេចក្តីត្រេកអរពេញចិត្ត ក្នុងអារម្មណ៍ទាំង ៦ ដែលប្រកបជាមួយនឹងកាមគុណទាំង ៥ តែមិនប្រកបដោយសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ។

ដូចមានវចនត្ថៈថា

"កាមេតីតិ = កាមោ" "កាមោ ច សោ តណ្ហា ចាតិ = កាមតណ្ហា"

សភាវធម៌ណារមែងត្រេកអរក្នុងអារម្មណ៍ទាំង ៦ ព្រោះហេតុនោះ សភាវធម៌នោះឈ្មោះថា **កាម**។

សភាវធម៌ណា រមែងត្រេកអរចង់បានទូវអារម្មណ៍ទាំង ៦ ដោយជាប់នៅក្នុងអារម្មណ៍នោះ ដូច្នោះសភាវធម៌នោះ ឈ្មោះថា កាមតណ្ហា បានដល់ លោភចេតសិក ។

**២-តណ្ហា** បានដល់តណ្ហាដែលកើតព្រមជាមួយសស្សតទិដ្ឋិដោយអាស្រ័យរូប សំឡេង ក្លិន រស សម្ផស្សសំដៅដល់អ្នកដែលមាន ការយល់ឃើញថា រូប សំឡេង ក្លិន រស សម្ផស្ស ដែលខ្លួនកំពុងបានទទួលនេះ តាំងនៅជានិច្ច មិនយល់ថាមានការកើតរលត់ ដូចមានវចនត្ថៈថា **ភវតីតិ ភាវោ ភាវោ ច សោ តណ្ហា ចាតិ = ភវតណ្ហា**

សភាវធម៌ណា រមែងឃើញថាមានតួខ្លួនដែលនៅក្នុងអារម្មណ៍៦នោះប្រាកដមាននៅជានិច្ច មិនសាបសូន្យ ព្រោះហេតុនោះ សភាវធម៌នោះឈ្មោះថា **ភវៈ** បានដល់សស្សតទិដ្ឋិ។

## ន័យម្យ៉ាងទៀត ភវតណ្ហានេះ កាលបើ សម្តែងតាមសុត្តន្តមហាវគ្គអដ្ឋកថាមាន ៥ យ៉ាង គឺ៖

១-មានសេចក្តីត្រេកអរពេញចិត្តក្នុងកាមភពគឺការបានកើតជាមនុស្ស និងទេវតាណាមួយ ។

២-មានសេចក្តីត្រេកអរពេញចិត្តក្នុងរូបភព គឺការបានកើតជារូបព្រហ្ម ។

៣-មានសេចក្តីត្រេកអរពេញចិត្តក្នុងអរូបភព គឺការបានកើតជាអរូបព្រហ្ម។

៤-មានសេចក្តីត្រេកអរពេញចិត្តក្នុងឈានសមាបត្តិ គឺការបានកើតក្នុងរូបឈាន និងអរូបឈាន។

៥-មានសេចក្តីត្រេកអរពេញចិត្តក្នុងសស្សតទិដ្ឋិ យល់ឃើញថាសត្វទាំងឡាយមានតួខ្លួន ហើយតួខ្លួននេះក៏មិនសាបសូន្យ សូម្បីស្លាប់ ក៏ស្លាប់តែរូបរាងកាយប៉ុណ្ណោះ ម្យ៉ាងទៀត តួខ្លួនដែលមាននៅក្នុងរាងកាយរបស់មនុស្ស កាលមនុស្សស្លាប់ហើយ តួខ្លួននោះក៏កើតជាមនុស្សទៀត តួខ្លួនដែលមាននៅក្នុងរូបរាងកាយ របស់សត្វតិរច្ឆានក៏ដូចគ្នា កាលសត្វនោះ ៗ ស្លាប់ហើយតួខ្លួនក៏ទៅ កើតជាសត្វនោះ ៗ ទៀត មិនប្រែប្រួល ដូចមានបាលីសម្តែងថា៖

"ភវេ តណ្ហា = ភវតណ្ហា" ភវបត្ថនាវសេន ឧប្បន្នស្ស សស្សតទិដ្ឋិសហគតស្ស រូបារូបភវរាគស្ស ច ឈាននិកន្តិយា ចេតំ អធិវចនំ"

សេចក្តីត្រេកអរពេញចិត្តក្នុងភពផ្សេងៗ ឈ្មោះថា **ភវតណ្ហា** ពាក្យថា **ភវតណ្ហា** នេះ បានដល់ រាគៈដែលកើតឡើងដោយសេចក្តីប្រាថ្នាកាមភពម្យ៉ាង រាគៈដែលកើតព្រមគ្នាជាមួយសស្សតទិដ្ឋិម្យ៉ាង រាគៈដែលកើតឡើងក្នុងរូបភពអរូបភពម្យ៉ាង រាគៈដែលកើតឡើងក្នុងឈានសមាបត្តិម្យ៉ាង ។

**៣-វិភវតណ្ហា** បានដល់ តណ្ហាដែលកើតឡើងព្រមជាមួយនឹងឧច្ឆេទទិដ្ឋិ ដោយអាស្រ័យអារម្មណ៍៦ សំដៅដល់អ្នកដែលមានសេចក្តីយល់ឃើញថា ក្នុងអារម្មណ៍៦ ដែលបានដល់វត្ថុដែលមានជីវិត និងមិនមានជីវិតទាំងឡាយក្នុងលោកនេះ មានតួខ្លួននៅ ហើយតួខ្លួននេះមិនអាចតាំងនៅរហូតបានរមែងសូន្យទៅ ហើយមានសេចក្តីត្រេកអរពេញចិត្តក្នុងអារម្មណ៍នោះ ឬមានសេចក្តីយល់ឃើញថា មិនថានរណាៗទាំងអស់ កាលបើស្លាប់ហើយក៏សូន្យទៅមិនកើតទៀត ហើយមានសេចក្តីត្រេកអរពេញចិត្តក្នុងអារម្មណ៍នោះ អ្នកដែលមានសេចក្តីយល់ឃើញ ក្នុងព្រះនិព្វានថាមានតួខ្លួនហើយប្រាថ្នាព្រះនិព្វាន ការប្រាថ្នាព្រះនិព្វាន ការប្រាថ្នានេះ ក៏ឈ្មោះថា វិភវតណ្ហា ដូចមានវចនត្ថៈថា : "**ន ភវតីតិ = វិភវោ**"សភាវធម៌រមែងឃើញថាតួខ្លួននៅក្នុងអារម្មណ៍ទាំង ៦ នោះ មិនអាចតាំងនៅបានរហូតរមែងសាបសូន្យទៅ ព្រោះហេតុនោះសភាវៈនោះ ឈ្មោះថា **វិភវៈ**។

"*វិភវោ ច សោ តណ្ហា ចាតិ = វិភវតណ្ហា*" សភាវធម៌ណាមានសេចក្តីយល់ឃើញថា សត្វទាំងឡាយកាលស្លាប់ហើយរមែងសូន្យទៅមិនកើតទៀត ព្រោះហេតុនោះ សភាវធម៌នោះឈ្មោះថា **វិភវៈ** បានដល់ ឧច្ឆេទទិដ្ឋិ ។

ម្យ៉ាងទៀតសភាវធម៌មានតួខ្លួនក្នុងអារម្មណ៍ទាំង៦ នោះមិនអាចតាំងនៅរហូតបាន រមែងសូន្យទៅផង ត្រេកអរក្នុងអារម្មណ៍នោះផង សភាវធម៌នោះឈ្មោះថា **វិភវតណ្ហា ។**

ឬមានសេចក្តីត្រេកអរពេញចិត្តក្នុងឧច្ឆេទទិដ្ឋិឈ្មោះថា វិភវតណ្ហា បានដល់ លោភៈដែលប្រកបដោយឧច្ឆេទទិដ្ឋិ ។

## តណ្ហា ១០៨

យកតណ្ហាទាំង ៣ x អារម្មណ៍ ៦ = ១៨

អតីតៈ ១៨ បច្ចុប្បន្ន ១៨ អនាគត ១៨ = ៥៤

ខាងក្នុង ៥៤ ខាងក្រៅ ៥៤ = ១០៨

តណ្ហា ១០៨ ដូចដែលបានពោលមកនេះ កើតឡើងដល់សត្វទាំងឡាយក៏ព្រោះអាស្រ័យវេទនា គឺការសោយអារម្មណ៍ជាសុខ ជាទុក្ខ និងជាឧបេក្ខា កាលបើសោយអារម្មណ៍នោះហើយតណ្ហាផ្សេងៗក៏កើតឡើងបាន ដោយហេតុនេះទើបព្រះអង្គទ្រង់ត្រាស់ថា **វេទនាបច្ចយា តណ្ហា ។**

## លក្ខណាទិចតុក្កៈរបស់ តណ្ហា

**១-ហេតុលក្ខណា** ជាហេតុរបស់កងទុក្ខទាំងពួងជាលក្ខណៈ ។

**២-អភិនន្ទនរសា** មានការត្រេកអរពេញចិត្តក្នុងអារម្មណ៍ជាកិច្ច ។

**៣-អតិត្តភាវបច្ចុប្បដ្ឋានា** មានសេចក្ដីមិនឆ្អែតក្នុងអារម្មណ៍ផ្សេងៗ របស់ចិត្តជាអាការប្រាកដ ។

**៤-វេទនាបទដ្ឋានា** មានវេទនាជាហេតុជិត ។

ការសង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា **វេទនាបច្ចយា តណ្ហា** វេទនាជាបច្ច័យដល់តណ្ហានោះ បានដោយអំណាចបច្ច័យ១ គឺបកតូបនិ-ស្សយបច្ច័យ ។

**ចប់ វេទនាបច្ចយា តណ្ហា**

### ៨.តណ្ហាបច្ចយា ឧបាទានំ សម្ភវតិ

ឧបាទានប្រាកដឡើងព្រោះអាស្រ័យតណ្ហាជាហេតុ ពាក្យថា ឧបាទាន សំដៅដល់ការប្រកាន់មាំក្នុងវត្ថុដែលខុសដោយលោភៈ និង ទិដ្ឋិ ដូចមានវចនត្ថៈថា

**"ភុសំ អាទិយន្តិ អមុញ្ចគាហំ គយ្ហន្តីតិ = ឧបាទានានិ"**

ធម៌ទាំងឡាយដែលប្រកាន់យ៉ាងខ្លាំងក្លា គឺចាប់ទុកមិនលែង ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **ឧបាទាន** ។

ន័យម្យ៉ាងទៀត "**ឧបាទិយន្តីតិ = ឧបាទានានិ**"

ធម៌ទាំងឡាយណាចូលទៅប្រកាន់មាំ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា **ឧបាទាន** បានដល់ តណ្ហា និង ទិដ្ឋិដែលមានកម្លាំងច្រើន ។

វចនត្ថៈនេះបានសម្តែងឱ្យឃើញថា តណ្ហានិងទិដ្ឋិដូចធម្មតានៅមិនទាន់បានឈ្មោះថា ឧបាទាន បន្ទាប់ពីតណ្ហានិងទិដ្ឋិនោះមានកម្លាំងខ្លាំងឡើង ពោលគឺការត្រេកអរជាប់ចិត្តក្នុងអារម្មណ៍នោះៗ មិនព្រមលែង វេលានោះតណ្ហានោះបានឈ្មោះថា ឧបាទាន កាលបើវេលាដែលយល់ឃើញខុសនោះជាប់ណែនកែមិនបានហើយ វេលានោះ ទិដ្ឋិនោះក៏បានឈ្មោះថា ឧបាទាន ។

## ឧបាទាន ៤ យ៉ាង

**១.កាមុបាទាន** ការប្រកាន់មាំក្នុងវត្ថុកាមទាំង ៦ មានរូបារម្មណ៍ជាដើម បានដល់ លោភចេតសិកដែលប្រកាន់មាំក្នុងអារម្មណ៍ ៦ ដែលជាវត្ថុកាម ។

**២.ទិដ្ឋុបាទាន** ការប្រកាន់មាំក្នុងការយល់ខុស មាននិយតមិច្ឆាទិដ្ឋិ ៣ មិច្ឆាទិដ្ឋិ ៦២ និង អន្តគ្គាហិកទិដ្ឋិ ១០ បានដល់ ទិដ្ឋិចេតសិកដែលក្រៅពីសីលព្វតទិដ្ឋិ និង សក្កាយទិដ្ឋិ ។

**៣.សីលព្វតុបាទាន** ការប្រកាន់មាំក្នុងការបដិបត្តិខុស មានការបដិបត្តិដូចសត្វគោ និងសត្វឆ្កែជាដើម បានដល់ សីលព្វតទិដ្ឋិ ។

**៤.អត្តវាទុបាទាន** ការប្រកាន់មាំក្នុងខន្ធ ៥ របស់ខ្លួន និង របស់អ្នកដទៃ បានដល់ សក្កាយទិដ្ឋិ ។

## សម្តែងឧបាទាន ៤ ដោយពិស្តារ

**១.កាមុបាទានមាន ៦ គឺ:**

១-រូបកាមុបាទាន ២-សទ្ទកាមុបាទាន
៣-គន្ធកាមុបាទាន ៤-រសកាមុបាទាន
៥-ផោដ្ឋព្វកាមុបាទាន ៦-ធម្មកាមុបាទាន

**២.ទិដ្ឋុបាទាន** មាននិយតមិច្ឆាទិដ្ឋិ ៣ មិច្ឆាទិដ្ឋិ ៦២ អន្តគ្គាហិកទិដ្ឋិ ១០ រួម ៧៥ គឺ:

## និយតមិច្ឆាទិដ្ឋិ ៣

១. នត្ថិកទិដ្ឋុបាទាន ២. អហេតុកទិដ្ឋុបាទាន ៣. អកិរិយទិដ្ឋុបាទាន ទាំង ៣ នេះ ជាទិដ្ឋិធំ ។

# មិច្ឆាទិដ្ឋិ ៦២

**បុព្វន្តកប្បិកទិដ្ឋិ** គឺ ការយល់ឃើញខុសដោយការគិតនឹកយកខ្លួនឯងក្នុងរឿងប្រព្រឹត្តទៅរបស់ខន្ធ ៥ ដែលកន្លងមកហើយមាន ១៨។

**អបរន្តកប្បិកទិដ្ឋិ** គឺ ការយល់ឃើញខុសដោយការគិតនឹកយកខ្លួនឯង ក្នុងរឿងប្រព្រឹត្តទៅរបស់ខន្ធ ៥ ក្នុងអនាគត មាន ៤៤។

រួមជាមិច្ឆាទិដ្ឋិ ៦២

**បុព្វន្តកប្បិកទិដ្ឋិ ១៨ គឺៈ**

សស្សតទិដ្ឋិ ៤ ឯកច្ចសស្សតទិដ្ឋិ ៤ អន្តានន្តទិដ្ឋិ ៤

អមរាវិក្ខេបទិដ្ឋិ ៤ អធិច្ចសមុប្បន្នទិដ្ឋិ ២

**អបរន្តកប្បិកទិដ្ឋិ ៤៤ គឺៈ**

ឧទ្ធមាឃាតនិកសញ្ញីវាទទិដ្ឋិ ១៦

ឧទ្ធមាឃាតនិកអញ្ញីវាទទិដ្ឋិ ៨

ឧទ្ធមាឃាតនិកនេវសញ្ញីនាសញ្ញីវាទទិដ្ឋិ ៨

ឧច្ឆេទវាទទិដ្ឋិ ៧

ទិដ្ឋិធម្មនិព្វានវាទទិដ្ឋិ ៥

## អន្តគ្គាហិកទិដ្ឋិ ១០

១.សស្សតោ លោកោ យល់ឃើញថា លោកទៀង ។

២.អសស្សតោ លោកោ យល់ឃើញថា លោកមិនទៀង ។

៣.អន្តវា លោកោ យល់ឃើញថា លោកមានទីបំផុត ។

៤.អនន្តវា លោកោ យល់ឃើញថា លោកមិនមានទីបំផុត ។

៥.តំ ជីវំ តំ សរីរំ យល់ឃើញថា ជីវៈនិងសរីរៈ ជារបស់តែមួយ

៦.អញ្ញំ ជីវំ អញ្ញំ សរីរំ យល់ឃើញថា ជីវៈនិងសរីរៈផ្សេងពីគ្នា

៧.ហោតិ តថាគតោ បរំ មរណា យល់ឃើញថា សត្វនោះក្រោយពីស្លាប់ហើយនឹងទៅកើតទៀត ។

៨. ន ហោតិ តថាគតោ បរំ មរណា យល់ឃើញថា សត្វ-នោះ បន្ទាប់ពីស្លាប់ហើយមិនទៅកើតទៀត ។

៩.ហោតិ ច ន ហោតិ តថាគតោ បរំ មរណា យល់ឃើញថា សត្វនោះបន្ទាប់ពីស្លាប់ហើយ រមែងកើតទៀតក៏មានមិនកើតទៀត ក៏មាន ។

១០.នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណា យល់ឃើញថា សត្វនោះបន្ទាប់ពីស្លាប់ហើយ រមែងកើតទៀតក៏មិនមែន រមែងមិនកើតទៀតក៏មិនមែន ។

## ៣. សីលព្វតុបាទាន

ការបដិបត្តិខុសតាមផ្លូវដែលត្រឹមត្រូវ ដូចជា បដិបត្តិខ្លួនឱ្យដូចជាសត្វគោ ឬសត្វឆ្កែ ដោយអ្នកនោះត្រូវការឆ្លងពីសេចក្តីទុក្ខសេចក្តីលំបាកផ្សេងៗ ក្នុងសង្សារវដ្ត ឬត្រូវការទៅកើតក្នុងទេវលោក តែមិន

មានឱកាសបានសេពគប់ជាមួយសប្បុរសទាំងឡាយ មានព្រះសម្មា-សម្ពុទ្ធជាដើម នឹងមិនមានឱកាសបានសិក្សាព្រះបរិយត្តិធម៌ ដែលត្រឹមត្រូវ បុគ្គលជំពូកនេះគិតឃើញថា អកុសលផ្សេងៗ ដែលកើតមកហើយដល់ខ្លួននោះ មានចំនួនច្រើនរកប្រមាណមិនបាន នឹង ត្រូវរកផ្លូវកម្ចាត់អកុសលផ្សេងៗ ទាំងនេះឱ្យអស់ ព្រោះថាអកុសលទាំងនេះធ្វើឱ្យខ្លួនមិនអាចទៅសោយសេចក្តីសុខក្នុងស្ថានសួគ៌បាន កាលបើនឹកដូច្នេះហើយ ក៏កើតមានសេចក្តីគិតឃើញ ឡើងថាខ្លួននៅជាប់ជំពាក់ដោយអកុសល ត្រូវព្យាយាមលះបង់អកុសលចាស់ឱ្យអស់ និងអកុសលថ្មីក៏មិនធ្វើទៀតដូច្នេះ ទើប នឹងអាចលាងចេញឱ្យអស់ទៅបាន ហើយអកុសលចាស់ជាម្ចាស់នោះ ធ្វើឱ្យខ្លួនត្រូវលំបាកខ្លួន ចាំបាច់យកសេចក្តីលំបាកនោះប្រើជំនួសគ្នាវិញ ចំណុចនេះឧបមាដូចបុគ្គលម្នាក់ដែលជាកូនបំណុលរបស់គេ មិនអាចរកមាសប្រាក់សងគេបាន ក៏ចាំបាច់ត្រូវយកខ្លួនឯងទៅតស៊ូ ជាមួយសេចក្តីលំបាក គឺព្រមជាទាសៈរបស់គេ សេចក្តីលំបាកនោះឯង អាចនឹងជួយខ្លួនឱ្យផុតបាន ចំណុចនេះយ៉ាងណា ខ្លួនជាបំណុល អកុសលក៏យ៉ាងនោះដែរ ត្រូវមានសេចក្តីលំបាកដូចសត្វតិរច្ឆានមានគោនិងឆ្កែជាដើម ដែលកំពុងបានទទួលនោះ មកជាគ្រឿងជួយខ្លួនឱ្យផុតពីម្ចាស់អកុសល បើគិតឃើញផ្លូវដូច្នោះហើយ

ក៏នាំគ្នាប្រព្រឹត្ត ប្រតិបត្តិខ្លួនឱ្យដូចជា គោ និង ឆ្កែ មានការស៊ី កាដេក ដើរ ឈរ អង្គុយ ការបន្ទោរបង់ឧច្ចារៈ បស្សាវៈ រហូតដល់តុបតែង រូបរាងសណ្ឋាន ឱ្យដូច ជាគោឬឆ្កែនោះ ដែលជាការបដិបត្តិផ្ទុយគ្នា និង មនុស្សទាំងឡាយការបដិបត្តិដូច្នេះឯងឈ្មោះថា **សីលព្វតុបាទាន** ។

## ៤.អត្តវាទុបាទាន

បានដល់ អត្តទិដ្ឋិ ឬ សក្កាយទិដ្ឋិ ដែលប្រកាន់មាំក្នុងខន្ធ ៥ ថា ជាតួខ្លួន មាន ២០ យ៉ាង ឬដោយពិស្តារ ២៥៦ គឺ :

សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យរូបខន្ធ ជាអារម្មណ៍ មាន ៤ ឬ ១១២

សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យវេទនាខន្ធ ជាអារម្មណ៍ មាន ៤ ឬ៧២

សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យសញ្ញាខន្ធ ជាអារម្មណ៍ មាន ៤ឬ ២៤

សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យសង្ខារខន្ធ ជាអារម្មណ៍ មាន ៤ឬ ២៤

សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យ វិញ្ញាណខន្ធជាអារម្មណ៍ មាន ៤ឬ ២៤

### សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យរូបខន្ធជាអារម្មណ៍ មាន ៤ គឺៈ

១.រូបំ អត្តតោ សមនុបស្សតិ មានការយល់ឃើញថា រូបជាយើង យើងជារូប (យល់ថាយើងនិងរាងកាយដូចតែគ្នា ដូចជា ឃើញ អណ្តាតភ្លើង និងពន្លឺភ្លើងដូច្នោះ) ។

**២.រូបវន្តំ វា អត្តានំ** មានការយល់ឃើញថា យើងមានរូប (យល់ថាយើងនិងរាងកាយតែមួយ ដូចដើមឈើមួយដើម និងម្លប់ដូច្នោះ) ។

**៣.អត្តនិ វា រូបំ** មានការយល់ឃើញថា រូបនៅក្នុងយើង (យល់ថាយើងនិងរាងកាយតែមួយ ដូចក្លិនផ្កាដែលនៅក្នុងផ្កាដូច្នោះ)

**៤.រូបស្មឹ វា អត្តានំ** មានការយល់ឃើញថា យើងនៅក្នុងរូប (យល់ថាយើងនិងរាងកាយតែមួយ ដូចកែវមណីមួយដែលនៅក្នុងប្រអប់ដូច្នោះ) ។

### សម្រាប់ចំនួនពិស្តារ ១១២ នោះគឺៈ

សក្កាយទិដ្ឋិ ដែលមានរូបខន្ធជាអារម្មណ៍ ៤ យ៉ាងនេះ កើតឡើងដោយអាស្រ័យបឋវីក៏មាន កើតឡើងដោយអាស្រ័យអាបោជាដើមរហូតដល់ ជរតា អនិច្ចតា ក៏មាន ដូច្នោះសក្កាយទិដ្ឋិ ៤ គុណនឹងរូប ២៨ ទើបជា ១១២ ។

## សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យវេទនាខន្ធ ជាអារម្មណ៍មាន ៤

**១.វេទនំ អត្តតោ សមនុបស្សតិ** យល់ឃើញថា ការសោយអារម្មណ៍ជាយើង យើងគឺការសោយអារម្មណ៍ (យល់ថា យើងនិងការសោយអារម្មណ៍ដូចគ្នា) ។

**២.វេទនាវន្តំ វា អត្តានំ** យើងមានការសោយអារម្មណ៍ (យល់ថា យើងនិងការសោយអារម្មណ៍ជារបស់តែមួយ) ។

**៣.អត្តនិ វា វេទនំ** ការសោយអារម្មណ៍នៅក្នុងយើង (យល់ថា យើងនិងការសោយអារម្មណ៍ជារបស់តែមួយ) ។

**៤.វេទនាយ វា អត្តានំ** យើងនៅក្នុងការសោយអារម្មណ៍ (យល់ថា យើងនិងការសោយអារម្មណ៍ ជារបស់តែមួយ) ។

(សេចក្តីឧបមាដែលទាក់ទងនឹងវេទនាទាំង ៤ ចំណុចនេះដូចដែលសម្តែងក្នុងរូបខន្ធ)

**សម្រាប់ចំនួនពិស្តារ ៧២ នោះ គឺៈ**

វេទនាកាលបើពោលដោយទ្វារ មាន ៦ បានដល់ ចក្ខុសម្ផស្សជ្ជាវេទនា ជាដើម ក្នុងវេទនា ៦ យ៉ាងនេះ ចែកចេញជា ៣ គឺ សុខ ទុក្ខ ឧបេក្ខា រួមជាវេទនា ១៨ ។

សក្កាយទិដ្ឋិទាំង ៤ កើតឡើងដោយអាស្រ័យចក្ខុសម្ផស្សជ្ជាវេទនាក៏មាន កើតឡើងដោយអាស្រ័យចក្ខុសម្ផស្សជ្ជាទុក្ខវេទនាក៏មាន កើតឡើងដោយអាស្រ័យចក្ខុសម្ផស្សជ្ជាឧបេក្ខាក៏មាន និងសក្កាយទិដ្ឋិ ៤ កើតឡើងដោយអាស្រ័យ សុខ ទុក្ខ ឧបេក្ខា ដែលទាក់ទងជាមួយ និង សោតៈ ជាដើម រហូតដល់ មនៈ ក៏ដូចគ្នា ដូច្នេះ សក្កាយទិដ្ឋិ ៤ គុណនឹងវេទនា ១៨ ទើបជា ៧២ ។

## សក្កាយទិដ្ឋិកើតឡើងដោយអាស្រ័យសញ្ញាខន្ធ ជាអារម្មណ៍ មាន ៤

**១.សញ្ញំ អត្តតោ សមនុបស្សតិ** យល់ឃើញថា ការចាំអារម្មណ៍ ជាយើង យើងគឺការចាំអារម្មណ៍ (យល់ថា យើងនិង ការចាំអារម្មណ៍ ជារបស់ដូចគ្នា) ។

**២.សញ្ញាវន្តំ វា អត្តានំ** យល់ឃើញថា យើងមានការចាំអារម្មណ៍ ។

**៣.អត្តនិ វា សញ្ញំ** យល់ឃើញថា ការចាំអារម្មណ៍នៅក្នុងយើង ។

**៤.សញ្ញាយ វា អត្តានំ** យល់ឃើញថា យើងនៅក្នុងការចាំអារម្មណ៍ ។ (ចំណុច ២,៣,៤ យល់ថាយើងនិងការចាំអារម្មណ៍ ជារបស់តែមួយ រីឯចំណុចឧបមាសម្តែងក្នុងរូបខន្ធ) ។

### សម្រាប់ចំនួនពិស្តារ ២៤ នោះ គឺ:

ការចាំអារម្មណ៍នេះ កាលបើពោលដោយអារម្មណ៍ មាន៦ យ៉ាង បានដល់ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា និង ធម្មសញ្ញា ។

សក្កាយទិដ្ឋិទាំង ៤ កើតឡើងដោយអាស្រ័យរូបសញ្ញាក៏មាន អាស្រ័យគន្ធសញ្ញាជាដើមក៏មាន ដូច្នោះ សក្កាយទិដ្ឋិទាំង ៤ គុណនឹង សញ្ញា ៦ ទើបជា ២៤ ។

## សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យសង្ខារខន្ធ ជាអារម្មណ៍មាន ៤

**១.សង្ខារេ អត្តតោ សមនុបស្សតិ** យល់ឃើញថា ការតាក់តែង ក្នុងអារម្មណ៍ជាយើង យើងគឺការតាក់តែងក្នុងអារម្មណ៍ (យល់ថា យើងនិងការតាក់តែងក្នុងអារម្មណ៍ដូចគ្នា)។

**២.សង្ខារវន្តំ វា អត្តានំ** យល់ឃើញថា យើងមានការតាក់តែង ក្នុងអារម្មណ៍។

**៣.អត្តនិ វា សង្ខារា** យល់ឃើញថា ការតាក់តែងក្នុងអារម្មណ៍ នៅក្នុងយើង។

**៤.សង្ខារេសុ វា អត្តានំ** យល់ឃើញថា យើងនៅក្នុងការតាក់តែងអារម្មណ៍។

(ចំណុច ២,៣,៤ យល់ថា យើងនឹងតាក់តែងក្នុងអារម្មណ៍ ជាមនុស្សតែមួយ ហើយចំណុចឧបមាសម្ដែងដូចរូបខន្ធ)។

**សម្រាប់ចំនួនពិស្ដារ ២៤ នោះ គឺ:**

ការតាក់តែងក្នុងអារម្មណ៍នេះ បើពោលដោយអារម្មណ៍មាន ៦ យ៉ាង បានដល់ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា និង ធម្មសញ្ចេតនា។

សក្កាយទិដ្ឋិទាំង ៤ កើតឡើងដោយអាស្រ័យរូបសញ្ញាចេតនាក៏មាន អាស្រ័យសទ្ទសញ្ញាចេតនាជាដើមក៏មាន ដូច្នោះ សក្កាយទិដ្ឋិ ៤ គុណនឹងចេតនា ៦ ទើបបាន ២៤។

## សក្កាយទិដ្ឋិដែលកើតឡើងដោយអាស្រ័យវិញ្ញាណខន្ធ ជាអារម្មណ៍មាន ៦

**១.វិញ្ញាណំ អត្តតោ សមនុបស្សតិ** យល់ឃើញថាការដឹងអារម្មណ៍ជាយើង យើងគឺការដឹងអារម្មណ៍ (យល់ថា យើងនិងការដឹងអារម្មណ៍ជារបស់តែមួយ)។

**២.វិញ្ញាណវន្តំ វា អត្តានំ** យល់ឃើញថាយើងមានការដឹងអារម្មណ៍។

**៣.អត្តនិ វា វិញ្ញាណំ** យល់ឃើញថាការដឹងអារម្មណ៍នៅក្នុងយើង

**៤.វិញ្ញាណស្មឹ វា អត្តានំ**យល់ឃើញថានៅក្នុងការដឹងអារម្មណ៍

(ចំណុច ២,៣,៤ យល់ថាយើងនិងការដឹងអារម្មណ៍ជារបស់តែមួយ រីឯចំណុចឧបមាដូចដែលសម្តែងក្នុងរូប)

**សម្រាប់ចំនួនពិស្តារ ២៤ នោះ គឺ:**

ការដឹងអារម្មណ៍នេះ បើពោលដោយទ្វារមាន៦ យ៉ាង បានដល់ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ

និងមនោវិញ្ញាណ ។ សក្កាយទិដ្ឋិទាំង ៤ កើតឡើងដោយ អាស្រ័យចក្ខុវិញ្ញាណក៏មាន អាស្រ័យសោតវិញ្ញាណជាដើមក៏មាន ដូច្នេះសក្កាយទិដ្ឋិ ៤ គុណនឹងទ្វារ ៦ ទើបបាន ២៤។

**អធិប្បាយថា** អ្នកដែលមានអត្តវាទុបាទាននេះ មិនឃើញ មិនយល់ និងមិនជឿថា ខន្ធ ៥ នេះជាអនត្តា គឺជាសភាវៈដែលមិននៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណាមិនមានតួខ្លួន យល់ថា ខន្ធ ៥ នេះ ជាអត្តៈមានតួខ្លួន ហើយតួខ្លួននេះជាឥស្សរៈអាចបង្គាប់បញ្ជាខន្ធ ៥ បាន អត្តៈបញ្ជូនឱ្យរាងកាយ ដើរ ដេក ឈរ អង្គុយ និយាយ មើល ស្តាប់ ជាដើមទាំងនេះ រាងកាយក៏ធ្វើតាមអត្តៈជំរុញ។

## ការប្រកាន់មាំថាជាអត្តៈ ២ យ៉ាង

**១.បរមអត្តៈ**

**២.ជីវអត្តៈ**

ការប្រកាន់មាំថាអត្តៈនេះ ជាអ្នកសាងលោកឡើងបាន បណ្តាវត្ថុដែលមានជីវិតនិងមិនមានជីវិតទាំងឡាយដែលប្រាកដនៅក្នុងលោករាល់ថ្ងៃនេះ ក៏សុទ្ធតែកើតមកដោយអំណាចនៃអត្តៈទាំងអស់ ការប្រកាន់មាំដូច្នេះ បានឈ្មោះថា **បរមអត្តៈ** ។

ការប្រកាន់មាំថា បណ្តាសត្វទាំងឡាយដែលនៅក្នុងលោកនេះមានតួខ្លួន គឺមានជីវិតរក្សា ការប្រកាន់មាំដូច្នេះ បានឈ្មោះថា **ជីវអត្តៈ**។

**អធិប្បាយថា** បរមអត្ថៈនេះ មានប្រវត្តិមកថា នាកាលសម័យដែលត្រូវប្រល័យដោយភ្លើង ហើយផ្តើមសាងឡើងថ្មីនោះ បឋមឈាន ៣ បានសាងឡើងមុនភូមិផ្សេងៗ ក្នុងវេលាដែលសាងស្រេចថ្មីៗ នេះ នៅមិនទាន់មានព្រហ្មអង្គណាម្នាក់កើតឡើងឡើយ បន្ទាប់មកព្រហ្មដែលនៅខាងលើតាំងពីទុតិយជ្ឈានភូមិ អង្គណាមួយអស់បុណ្យចាកភូមិនោះហើយ ក៏ច្យុតមកកើតក្នុងបឋមឈានភូមិនេះ ប្រាកដជាមហាព្រហ្មអង្គដំបូង មហាព្រហ្មនេះមានរស្មីរុងរឿងច្រើន លុះកាលយូរមកមហាព្រហ្មអង្គនេះមានអារម្មណ៍ស្រងេះស្រងោចកើតឡើង ទើបនឹកប្រាថ្នាឱ្យមានព្រហ្មអង្គផ្សេងមកកើតនៅជាមួយ ជួនជាក្នុងវេលានោះព្រហ្មដែលនៅក្នុងភូមិខាងលើ អង្គខ្លះអស់បុណ្យអស់អាយុ ក៏នាំគ្នាច្យុតចុះមកកើតក្នុងបឋមឈានភូមិនេះក្នុងវេលានោះជាប់ៗ គ្នា ច្រើនអង្គតែពួកព្រហ្មដែលមកកើតជំនាន់ក្រោយនេះ មិនមែនជា មហាព្រហ្មទេតែជាព្រហ្មបរិស្សជ្ជាខ្លះ ជាព្រហ្មបរោហិតាខ្លះ ដែលសុទ្ធតែជាបរិវាររបស់ព្រះមហាព្រហ្មទាំងអស់ សេចក្តីរុងរឿងនៃរស្មីក្នុងកាយក៏មានតិចជាងព្រះមហាព្រហ្ម កាលបើមហាព្រហ្មបានឃើញពួកព្រហ្មទាំង-ឡាយមកកើតឡើងក្នុងវេលានោះ ក៏គិតថា កាលយើងមានសេចក្តីប្រាថ្នាចង់បានព្រហ្មមកកើតរួមជាមួយ សេចក្តីប្រាថ្នារបស់យើងក៏

សម្រេចសមដូចសេចក្ដីប្រាថ្នា ដូច្នោះយើងនេះហើយ ទើបជាអ្នកដែលសាងព្រហ្មទាំងឡាយឱ្យប្រាកដឡើងក្នុងលោក ។

ចំណែកពួកព្រហ្មទាំងឡាយដែលកើតថ្មីនោះ បានមើលឃើញមហាព្រហ្មមានរស្មីរុងរឿង មានគ្រឿងអាភរណៈដែលប្រដាប់កាយរហូតដល់ទាំងវិមានដែលនៅ សែនស្រស់ស្អាតទើបនាំគ្នាប្រារព្ធឡើងថា **អយំ ខោ ភវំ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មាតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ ឥមិនា មយំ ភោតា ព្រហ្មុនា និម្មិតា,**

(នៅក្នុងព្រហ្មជាលសូត្រព្រះបាលីនៃសីលខន្ធវគ្គ)

ប្រែសេចក្ដីថា "ព្រហ្មអង្គនេះជាព្រះមហាព្រហ្ម អាចគ្រប់គ្រងសត្វទាំងឡាយបាន មិនបាននៅក្រោមសេចក្ដីគ្រប់គ្រងរបស់អ្នកដទៃណាឡើយ ជាព្រះដែលអាចដឹងឃើញវត្ថុផ្សេងៗ បានដោយពិតប្រាកដ អាចធ្វើឱ្យសត្វទាំងឡាយបដិបត្តិ ឱ្យប្រព្រឹត្តទៅតាមសេចក្ដីពេញចិត្តរបស់ខ្លួនបាន ជាព្រះឥសូរដែលជាអ្នកគ្រប់គ្រងសត្វទាំងឡាយ ជាអ្នកសាងលោកនិងសត្វទាំងឡាយ ជាអ្នកប្រសើរបំផុតក្នុងលោក ជាអ្នកចាត់ចែងសត្វឱ្យជាក្សត្រ ជាព្រាហ្មណ៍ ជាសេដ្ឋី ជាអ្នកមាន ជាអ្នកក្រតាមសមគួរដល់ឋានៈ ជាបិតារបស់សត្វដែលប្រាកដឡើងហើយ នឹង

ប្រាកដតទៅខាងមុខ សូម្បីយើងទាំងឡាយដែលប្រាកដកើតឡើង ឯស្ថានទីនេះ ក៏ព្រោះព្រះមហាព្រហ្មអង្គនោះជាអ្នកសាងឡើង" កាលបើប្រារព្ធគ្នាដូច្នេះហើយ ក៏នាំគ្នាមកក្រាបប្រណិប័តន៏ទទួលបម្រើព្រះ-មហាព្រហ្មគ្រប់ប្រការ ។

តមកពួកព្រហ្មដែលជាបរិវារទាំងនេះ កាលអស់បុណ្យអស់អាយុពីព្រហ្មហើយ ក៏ច្យុតចុះមកកើតក្នុងមនុស្សលោក សម្រាប់ព្រះ-មហាព្រហ្មនោះក៏នៅមានជីវិត ព្រោះអាយុច្រើនជាងព្រហ្មពួកនោះ ចំណែកព្រហ្មទាំងឡាយដែលចុះមកកើតជាមនុស្សហើយនោះ ពួកខ្លះក៏ធ្វើសមថៈ បានឈានអភិញ្ញា អាចឃើញព្រះមហាព្រហ្មបាន កើតសេចក្តីប្រកាន់មាំ យ៉ាងក្រៃលែងឡើងថា លោកនិងសត្វទាំងឡាយដែលមាននៅក្នុងលោកនេះ ព្រះមហាព្រហ្មជាអ្នកសាងឡើង ទាំងអស់ ព្រោះហេតុនោះ ព្រះមហាព្រហ្មនោះជាព្រះដ៏ប្រសើរ បានឈ្មោះថា "**បរមអត្តៈ**"ជាអ្នកមិនស្លាប់មិនសូន្យបាត់ទៅណា ការឃើញប្រកាន់មាំដូច្នេះបានជាប់តមានប្រជាប្រិយទាក់ទងគ្នារហូតមកដល់បច្ចុប្បន្ននេះ ព្រោះហេតុនោះ ពួកដែលមានសេចក្តីឃើញថា បណ្តាវត្ថុផ្សេងៗ ដែលមានជីវិតនិងមិនមានជីវិតដែលប្រាកដនៅក្នុងលោក រាល់ថ្ងៃនេះ រហូតទាំងសេចក្តីសប្បាយ សេចក្តីលំបាក ការមានទ្រព្យ សម្បត្តិច្រើន ភាពក្រខ្សត់ ភាពស្អាត ភាពមិនស្អាត ត្រកូលខ្ពស់ ត្រកូលទាប

ជាដើមទាំងនេះ ក៏ព្រោះបរមអត្តៈជាអ្នកសាងឡើង នោះក៏កើតមក ពីមនុស្សក្នុងសម័យដើមកប្បដែលបានឈាន អភិញ្ញា អាច មើលឃើញ ព្រះមហាព្រហ្មបាននោះឯងជាដើមហេតុ មនុស្សដែលកើត ក្នុងសម័យ តៗមកក៏មានការឃើញដូច្នេះតំណតាមគ្នាមក តែមនុស្ស ក្នុងសម័យ ក្រោយៗមកនេះ មិនអាចមើលឃើញព្រះមហាព្រហ្ម ព្រោះមិន បានអភិញ្ញា កាលបើមានអ្នកសួរថា ព្រះអ្នកសាងលោកនោះនៅទីណា ក៏បានតែត្រឹមថា នៅខាងលើអាកាសប៉ុណ្ណោះ ។

បរមអត្តៈនេះ មានឈ្មោះហៅបានច្រើនយ៉ាង តាមឈ្មោះជាតិ និងភាសាអ្នកកាន់លទ្ធិប្រភេទនេះគឺៈ

តាមភាសាសំស្ក្រឹត និងឥឌូ ហៅថា ឥសូរ បរមេសួ បរមាតម័ន

| | | |
|---|---|---|
| តាមភាសាប្រើស៊ុល | ហៅថា | គោត្រ |
| តាមភាសាអារប៉ៀន | " | អាឡា |
| តាមភាសាអង់គ្លេស | " | កត |
| តាមភាសាភូមា | " | ថាវរះព្យា |
| តាមភាសាថៃ | " | ព្រះចៅ |

តាមភាសាវៀតណាម ហៅថា ដឹកចូវ ដែលសុទ្ធតែជា បរមអត្តៈទាំងអស់ ។

# ជីវអត្ត:

១.អ្នកដែលមានការយល់ឃើញថា ខាងក្នុងរាងកាយរបស់សត្វទាំងឡាយនេះមានអត្តៈដែលហៅថា ជីវអត្តៈនេះមានអំណាចធ្វើការងារផ្សេងៗបាន ដូចជាក្នុងវេលាដែលកំពុងដើរ អាការកិរិយាដែលឈានដើរនោះ មិនមែនប្រព្រឹត្តទៅតាមអំណាចរបស់ជើងទេ គឺប្រព្រឹត្តតាមអំណាចជីវអត្តៈនោះឯង ជាអ្នកជំរុញជើងឱ្យ ឈានដើរទៅ ឬ ក្នុងវេលាណាជីវអត្តៈមានបំណងនឹងធ្វើវត្ថុដែលមិនល្អ កាយវាចាក៏ឱ្យវត្ថុដែលមិនល្អនោះតាមសេចក្តីប្រាថ្នារបស់ជីវអត្តៈឬ ជីវអត្តៈចង់ធ្វើវត្ថុដែលល្អ ដោយកាយ វាចា ក៏ធ្វើវត្ថុដែលល្អតាមពាក្យជំរុញរបស់ជីវអត្តៈ ដូចជាក្នុងវេលាដែលកំពុងលើកដៃសំពះចំពោះព្រះភក្ត្រពុទ្ធរូបនោះ ការលើកដៃឡើងសំពះចំពោះព្រះភក្ត្រព្រះពុទ្ធរូបបាននោះក៏ដោយអំណាចរបស់ជីវអត្តៈ ឬពេលដែលកំពុងសូត្រមន្ត ការបញ្ចេញវាចាសូត្របាននោះ ក៏ដោយអំណាចរបស់ជីវអត្តៈ ហើយការសូត្របានត្រឹមត្រូវក៏ដោយអំណាចរបស់ជីវអត្តៈយ៉ាងនេះជាដើមព្រោះហេតុនោះជីវអត្តៈនេះទើបហៅថា **ការកៈ** (អ្នកធ្វើ) ប្រការមួយ ។

២.អ្នកដែលមានសេចក្តីយល់ឃើញថា ជីវអត្តៈនេះ ជាអ្នកសោយផលដែលកើតមកពីកម្មល្អ និង កម្មអាក្រក់ សេចក្តីសុខ

សេចក្តីទុក ឈឺចុកចាប់ និងការបរិភោគអាហារមានរសឆ្ងាញ់ រសមិនឆ្ងាញ់ទាំងនេះ ជីវអត្តៈក៏ជាអ្នកសោយ ការធ្វើល្អ ធ្វើអាក្រក់ ដែលនឹងបានទទួលផលក្នុងកាលខាងមុខនោះ ជីវអត្តៈក៏ជាអ្នកបានទទួល ព្រោះហេតុនោះ ជីវអត្តៈនេះ ទើបហៅថា **វេទកៈ** ( អ្នកសោយ) ។

៣.អ្នកមានការយល់ឃើញថា ជីវអត្តៈនេះ ជាម្ចាស់របស់រាងកាយនៃសត្វទាំងឡាយ ព្រោះអាចជាអ្នកគ្រប់គ្រងអាវយវៈទូទៅសព្វរាងកាយបាន ព្រោះហេតុនោះ ជីវអត្តៈទើបហៅថា **សាមី** ( ម្ចាស់របស់) ។

៤.អ្នកដែលមានសេចក្តីយល់ឃើញថា ជីវអត្តៈនេះ កាលរាងកាយរបស់សត្វទាំងឡាយបែកធ្លាយដោយហេតុណាមួយ ដែលជាឧប្បត្តិវហេតុក៏ដោយ ជីវអត្តៈនេះក៏ចាត់ចែងសាងរាងកាយឡើងថ្មី ហើយក៏ចូលទៅនៅក្នុងរាងកាយថ្មីនោះ ទាំងនេះសុទ្ធតែជីវអត្តៈជាអ្នកសាងរាងកាយថ្មីៗ ជានិច្ច ។

ឬអ្នកខ្លះក៏យល់ឃើញថា ជីវអត្តៈនេះជាចំណែកមួយរបស់បរមអត្តៈ កាលបើសត្វជិតស្លាប់រាងកាយក៏ត្រឡប់ទៅកាន់សំណាក់របស់បរមអត្តៈដែលនៅខាងលើភ្លាមមានន័យថា បរមអត្តៈជាអ្នកហៅត្រឡប់ទៅវិញដូចជាថាជីវអត្តៈនេះមិនមានការស្លាប់ ព្រោះហេតុនោះ ជីវអត្តៈនេះ ទើបហៅថា **និវាសី** ( នៅជានិច្ច) ១ ។

៥.អ្នកដែលមានការយល់ឃើញថា ជីវអត្តៈនេះមានអំណាចក្នុងរាងកាយរបស់សត្វទាំងឡាយ អាចបង្គាប់រាងកាយរបស់សត្វទាំង-ឡាយនោះ ធ្វើវត្ថុគ្រប់យ៉ាងតាមសេចក្ដីប្រាថ្នារបស់ខ្លួនបាន ព្រោះហេតុនោះ ទើបហៅថា **សយំវសី** ( អ្នកអាចបង្គាប់រាងកាយ បាន) ១។

បើរួមការយល់ឃើញ ២ យ៉ាង គឺ **និវាសី** និង **សយំវសី** ចូលគ្នា មានន័យថា អ្នកដែលមានការយល់ឃើញទាំង ២យ៉ាងនេះ យល់ថាជីវអត្តៈនេះជាខ្លឹមជាសារៈជាទីបំផុត មិនមានវត្ថុណាមួយអាចមកទម្លាយឱ្យសូន្យបានផង ហើយមានអំណាចពិសេសដែលអាចបង្គាប់រាងកាយរបស់សត្វទាំងឡាយ ឱ្យធ្វើតាមសេចក្ដីប្រាថ្នារបស់ខ្លួនបាន ព្រោះហេតុនោះ ហៅថា **វសវត្តនៈ** ( អ្នកមានអំណាចពិសេស) ១។

សេចក្ដីប្រកាន់ថាជាជីវអត្តៈ ៥ ប្រការ ដូចដែលបានពោលហើយនេះ ពួកខ្លះក៏ប្រកាន់យកវិញ្ញាណខន្ធជាតួជីវិត ពួកខ្លះប្រកាន់យករូបខន្ធជាតួជីវិត ហើយបុគ្គលពួកខ្លះក៏ប្រកាន់យកវេទនាខន្ធ សញ្ញាខន្ធ ឬសង្ខារខន្ធណាមួយជាតួជីវិតគឺជាតួខ្លួន ព្រោះហេតុនោះ ការយល់ឃើញដែលប្រកាន់ក្នុងខន្ធ ៥ ណាមួយថា ជាតួរបស់ខ្លួន ដូច្នេះឯង

ទើបហៅថា **សក្កាយទិដ្ឋិ** ហើយក៏ចូលនៅក្នុងពួកដែល ហៅថា **អត្តវាទុបាទាន**។

មិច្ឆាទិដ្ឋិផ្សេងៗ ប្រាកដកើតឡើងបានដោយអាស្រ័យសក្កាយ-ទិដ្ឋិនោះឯងជាមូល ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបទ្រង់សម្តែងទុកក្នុងចិត្តវគ្គនៃសឡាយតនសំយុត្តព្រះបាលីថា សក្កាយទិដ្ឋិនេះ ជាពូជពង្សរបស់មិច្ឆាទិដ្ឋិទាំងពួង ប្រសិនបើសម្តែងវចនត្ថៈរបស់សក្កាយ-ទិដ្ឋនេះ ក៏មានដូច្នេះគឺៈ "**សន្តោ កាយោ = សក្កាយោ**" "**សក្កាយេ បវត្តាទិដ្ឋិ = សក្កាយទិដ្ឋិ**" ខន្ធ ៥ ដែលប្រកប នៅតាមសភាវបរមត្ថ ឈ្មោះថា **សក្កាយៈ** បានដល់ខន្ធ ៥ ទិដ្ឋិ គឺ សេចក្តីប្រកាន់មាំ ដែលកើតឡើងក្នុងក្រុមខន្ធ ៥ ដែលមានប្រាកដនៅ តាមសភាវបរមត្ថ នោះ ឈ្មោះថា **សក្កាយទិដ្ឋិ** ។

ម្យ៉ាងទៀត ពុទ្ធសាសនិកជនដោយច្រើន មិនអាចនឹងចង្អុលបង្ហាញថា ពួកជីវអត្តៈណាមួយឡើយ តែតាមការយល់ឃើញថា ការដែលប្រកាន់មាំក្នុងនាមរូបថា ជាតួរបស់ខ្លួន នេះរមែងនៅមានដូចតែគ្នាទាំងអស់ វៀរលែងតែអរិយបុគ្គលប៉ុណ្ណោះ ការប្រកាន់ចំណែកច្រើននោះក៏គឺប្រកាន់ក្នុងវិញ្ញាណខន្ធ ដូចជាអ្នកណាម្នាក់ស្លាប់ អ្នកដែលនៅរមែងពោលថា អ្នកនោះ អ្នកនេះមានវិញ្ញាណរត់ចេញពីរាងកាយហើយ ឬ ក្មេងតូច ៗ ដែលភ្ញាក់ព្រើត អ្នករមែង និយាយថា ចិត្ត

ឬព្រលឹងរបស់ក្មេងនោះចាកចេញពីរាងកាទៅនោះឯង ឬ មនុស្សខ្លះ ដែលស្លាប់ទៅហើយវិញ្ញាណនៅអណ្តែតមិនទាន់បានទៅកើតក្នុងទីណា វិញ្ញាណរបស់អ្នកនោះក៏មកហៅ បងប្អូន កូនចៅ ស្វាមី ភរិយា ជាដើម ឱ្យទៅនៅជាមួយគ្នា ឬ ពេលខ្លះដែលវិញ្ញាណរបស់អ្នកស្លាប់នោះ ក៏ចូលមកស្ថិតនៅក្នុងរាង កាយរបស់ញាតិ បងប្អូន ភរិយា ស្វាមី ទាំងនោះ ធ្វើឱ្យត្រូវកើតមានការ ធ្វើពិធីបណ្តេញវិញ្ញាណ យ៉ាងនេះ ជាដើម ។

ការប្រកាន់ដែលជាអត្តទិដ្ឋិនេះ មានន័យធំទូលំទូលាយណាស់ មិនចំពោះតែប្រកាន់ត្រឹមតែខន្ធ ៥ គឺរាងកាយប៉ុណ្ណោះទេ សូម្បីវត្ថុ ដែលនៅខាងក្រៅដូចជា ភ្នំ ដើមឈើ ផែនដី ទឹក ទាំងនេះក៏ប្រកាន់ថា មានតួខ្លួន គឺជីវអត្តទិដ្ឋិទាំងនោះ ដោយហេតុនេះទើបព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់ទុកក្នុងភូតគាមសិក្ខាសេនាសនៈ នៃភិក្ខុបាតិមោក្ខ ព្រះបាលីថា "**ជីវសញ្ញិនោ ហិ មោឃបុរិសា មនុស្សា រុក្ខស្មឹ** ប្រែថា ម្នាលមោឃបុរស មនុស្សទាំងឡាយ មានសេចក្តីប្រកាន់ថា ដើមឈើនេះមានជីវិត ។

## គាថាសរុបសេចក្តីក្នុងជីវអត្តៈ

សត្តិយា យស្ស ជីវស្ស លោកោ វត្តតិ មញ្ញិតោ

ការកោ វេទកោ សាមិ   និវាសី សោ សយំវសី ។

បុថុជ្ជនទាំងឡាយមានការយល់ឃើញថា សត្វទាំងឡាយមិនថានរណា ដែលកំពុងធ្វើការងារផ្សេងៗរបស់ខ្លួនបាន ហើយតាំងនៅបាននោះ ក៏ព្រោះអាស្រ័យអំណាចរបស់តួជីវិតនោះឯង ហើយតួជីវិតនេះ ជាអ្នកអាចប្រព្រឹត្តការងារផ្សេងៗបាន ជាអ្នកសោយផលល្អ និងអាក្រក់ផ្សេងៗ បានជាម្ចាស់របស់រាងកាយនៃសត្វទាំងឡាយ អាចសាងរាងកាយឡើងថ្មី ឬមានអំណាចបញ្ជារាងកាយរបស់សត្វទាំងឡាយឱ្យធ្វើវត្តគ្រប់យ៉ាងតាមសេចក្តីប្រាថ្នារបស់ខ្លួនបាន ។

| | | |
|---|---|---|
| ជីវអត្តៈនេះក្នុងភាសាសំស្ក្រឹត | ហៅថា | អាត្មា អាត្មន |
| ជីវអត្តៈនេះក្នុងភាសា មគធ | ” | អាតុមា |
| ជីវអត្តៈនេះក្នុងភាសាព្រះត្រៃបិដកហៅថា ជីវៈ សរីរៈ បុគ្គល សត្តៈ | | |
| ជីវអត្តៈនេះក្នុងភាសាអារ៉ាប់បៀន | ” | រូហ៏ |
| ជីវអត្តៈនេះក្នុងភាសាអង់គ្លេស | ហៅថា | សោល (soul) |
| ជីវអត្តៈនេះក្នុងភាសាវៀតណាម | ” | ទ័ងហោង |
| ជីវអត្តៈនេះក្នុងភាសាថៃ | ” | ជីវិត |
| ជីវអត្តៈនេះក្នុងភាសាភូមា | ” | អតែក់ |

អត្តទិដ្ឋិដែលជាអត្តវាទុបាទានបាននោះ អ្នកនោះនឹងត្រូវប្រកាន់ថា ក្នុងរាងកាយរបស់សត្វទាំងឡាយ ប្រសិនបើក្នុងការសម្ដែងធម៌ ឬក្នុងការប្រើនិយាយគ្នាថា "**អត្តា ហិ អត្តនោ នាថោ**" ខ្លួននោះឯងជាទីពឹងរបស់ខ្លួន ឬពាក្យថា "ជឿខ្លួនឯង" ទាំងនេះមិនមែនជាអត្តវាទុបាទានទេ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងទុកក្នុងនិក្ខេបកណ្ឌនៃធម្មសង្គណីបករណ៍ថា "**ឋបេត្វា សីលព្វតុបាទានញ្ច អត្តវាទុបា-ទានញ្ច សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋុបាទានំ**" ប្រែថា វៀរសីលព្វតុ-បាទានទិដ្ឋិ និងអត្តវាទុបាទានទិដ្ឋិចេញហើយ មិច្ឆាទិដ្ឋិទាំងអស់ទាំងនោះជាទិដ្ឋុបាទានទាំងអស់ ។

## ការបែកផ្សេងគ្នារវាងតណ្ហា និង កាមុបាទាន

**តណ្ហា** បើពោលដោយអង្គធម៌ បានដល់ លោភៈ

**កាមុបាទាន** បើពោលដោយអង្គធម៌បានដល់ លោភៈដូចគ្នា

ព្រោះហេតុនោះ ក្នុងការដែលពោលថា តណ្ហាជាបច្ច័យឱ្យកាមុបាទានកើតឡើងនោះក៏មានន័យថា លោភៈជាបច្ច័យឱ្យកើតលោភៈនោះឯង បើដូច្នេះលោភៈដែលបានឈ្មោះថា តណ្ហា និងលោភៈដែលបានឈ្មោះថា **កាមុបាទាន** នោះ មានការបែកផ្សេងគ្នាយ៉ាងណា?

**អធិប្បាយ** ការជាប់ចិត្ត ចង់បានក្នុងអារម្មណ៍ផ្សេង១ មានរូប សំឡេង ក្លិន រស សម្ផស្ស ទាំងនេះបានឈ្មោះថា **តណ្ហា** ។

ការជាប់ចិត្ត ការចង់បាននេះឯង កាលបើមានកម្លាំងច្រើនឡើងហើយ រមែងមានចិត្តចងព័ន្ធនៅជាមួយអារម្មណ៍នោះ១ ជានិច្ចមិនបាត់ ឬកាលបានវត្ថុដែលខ្លួនប្រាថ្នាមកហើយ ក៏មានការហួងហែងថ្នាក់ថ្នមវត្ថុនោះទុកមិនព្រមលែង ដូច្នេះ ហៅថា **កាមុបាទាន** ដែលកើតឡើងដោយអាស្រ័យតណ្ហាជាបច្ច័យ ។

តណ្ហានេះ គឺការត្រេកអរពេញចិត្តដែលកើតឡើងជាគ្រាដំបូងក្នុងអារម្មណ៍ណាមួយ ។

កាមុបាទាន គឺការជាប់ចិត្តប្រកាន់នៅក្នុង អារម្មណ៍នោះ១ មិនព្រមលែង ។

តណ្ហា ប្រៀបដូច ជាដើមឈើដែលទើបចេញពន្លកមកថ្មី ១

កាមុបាទាន ប្រៀបដូចដើមឈើដែលដុះលូតលាស់ធំធាត់ហើយ ធម្មតាដើមឈើដែលដុះឡើងថ្មីនោះ ឫសនៅតូចនឹងកប់នៅក្នុងដីបានរាក់១ បើត្រូវការដកទៅដាំក្នុងទីដទៃ ក៏អាចដកបានងាយស្រួល នឹងមិនធ្វើឱ្យឫសនោះដាច់យ៉ាងណា ចំណែកដើមឈើ ដែលចម្រើនលូតលាស់ រមែងមានឫសវែងកប់នៅក្នុងដីជ្រៅហើយ លំបាក ដល់ការដកទៅទីដទៃ ព្រោះអាចធ្វើឱ្យឫសដាច់បាន សេចក្ដីនេះយ៉ាងណា ការប្រព្រឹត្តទៅនៃតណ្ហា និងកាមុបាទានដូចគ្នា តណ្ហាគឺការពេញ

ចិត្តក្នុងអារម្មណ៍ផ្សេងៗ ដែលមានកម្លាំងខ្សោយ នៅមិនប្រកាន់មាំក្នុងអារម្មណ៍ទាំងនោះ ចំណែកកាមុបាទាននោះ គឺសេចក្ដីពេញចិត្តក្នុងអារម្មណ៍ដែលមានកម្លាំងខ្លាំងឡើងហើយ នឹងប្រកាន់នៅក្នុងអារម្មណ៍នោះៗ ទុកមិនព្រមលែងយ៉ាងនេះឯង ។

តណ្ហានេះ ជាធម៌ដែលបដិបក្ខដល់អប្បិច្ឆតាគុណ គឺភាពជាអ្នកប្រាថ្នាតិច ។

កាមុបាទាន ជាធម៌ដែលបដិបក្ខដល់សន្តោសគុណ គឺភាពជាអ្នកពេញចិត្តក្នុងវត្ថុដែលខ្លួនមាន ។

តណ្ហា ជាហេតុនៃបរិយេសនទុក្ខ គឺសេចក្ដីទុក្ខដែលទាក់ទងជាមួយការខ្វល់ខ្វាយស្វែងរកក្នុងកាមគុណារម្មណ៍ផ្សេងៗ ។

កាមុបាទាន ជាហេតុនៃអារក្ខទុក្ខ គឺសេចក្ដីទុក្ខដែលទាក់ទងនឹងការប្រយ័ត្នរក្សាក្នុងកាមគុណារម្មណ៍ផ្សេងៗ ដែលខ្លួនបានមកនោះមិនឱ្យសាបសូន្យ ។

## ១.សម្ដែងតណ្ហាជាបច្ច័យឱ្យកើតកាមុបាទាន

តណ្ហាជាបច្ច័យឱ្យកើតកាមុបាទាននោះ លើកឧទាហរណ៍ដូចរឿងព្រះពោធិសត្វក្នុងជាតិដែលជាតាបស បានសម្រេចឈានអភិញ្ញាអាចហោះទៅក្នុងអាកាសបាន បានទៅសំរាកនៅក្នុងព្រះរាជឧទ្យានរបស់ព្រះបាទពារាណសី ហើយចូលទៅឆាន់អាហារក្នុងព្រះរាជវាំងរៀងរាល់

ថ្ងៃ តមកព្រះបាទពារាណសីមានកិច្ចត្រូវចេញទៅក្រៅក្រុង បានបញ្ជូនព្រះមហេសីព្រះនាម មុទុលក្ខណា ឱ្យចាត់ចែងអាហារជំនួសព្រះអង្គ ព្រះមហេសីក៏ធ្វើតាមពាក្យបញ្ជារបស់ព្រះរាជាដោយរៀបរយ ថ្ងៃមួយព្រះនាងបានត្រៀមអាហារសម្រាប់តាបសរៀបរយហើយ ក៏បានដេកសម្រាកកាយរង់ចាំតាបសលើក្រឡាបន្ទំឯព្រះរោង កាលបើដល់កំណត់វេលាតាបសក៏ហោះចូលមកជិតបង្អួច ព្រះនាងកាលបើបានឮសំឡេងតាបសមកក៏ប្រញាប់ក្រោកឡើងទទួល រំពេចនោះសំពត់របស់ព្រះនាងក៏របូតពីរកាយទាំងមិនដឹងខ្លួន តាបសបានឃើញរាងរបស់ព្រះនាងហើយបាត់ការសង្រួមឥន្ទ្រីយ៍ កើតសេចក្ដីត្រេកអរក្នុងរូបឆោមរបស់ព្រះនាង តណ្ហាដែលស្ងប់ខាងក្នុងនោះ ក៏កម្រើកឡើងដូចដើមឈើមួយដើមដែលមានដ៏រកាលដែលត្រូវកាំបិតឆ្មូតនោះឯង ឈានរបស់លោកក៏ដាច់ ឈរត្រឹងទទួលអាហារបិណ្ឌបាតចុះពីប្រាសាទ ដើរទៅកាន់ឧទ្យាន ចូលបណ្ណសាលាទុកបាត្រចោល ហើយដេករំពឹងដល់ព្រះនាងមិនឆាន់អាហារអស់ ៧ ថ្ងៃ ។

រឿងនេះសម្ដែងឱ្យឃើញថា តណ្ហាជាហេតុឱ្យកើតកាមុបាទាន គឺ ខណៈដែលតាបសបានឃើញរាងរបស់ព្រះនាងកើតសេចក្ដីត្រេកអរពេញចិត្តឡើងជាគ្រាដំបូងនោះ ជាពេលដែលតណ្ហាកើត បន្ទាប់មកសេចក្ដីពេញចិត្តនោះមានកម្លាំងខ្លាំងឡើង មិនស៊ីមិនដេករហូត ៧ ថ្ងៃនោះ ជាពេលដែលកាមុបាទានកើតឡើងហើយ ។

ក្នុងកាមជាតកនៃទ្វាទសនិបាត បានលើករឿងដែលសម្តែងឱ្យឃើញដល់សេចក្តីប្រព្រឹត្តទៅរបស់កាមុបាទាន ដែលកើតឡើងដោយអាស្រ័យតណ្ហាជាហេតុនោះ មានដូច្នេះគឺៈ

ព្រះបាទព្រហ្មទត្តនៃនគរពារាណសី មានឱរស ២ ព្រះអង្គ ឱរសបងបានតំណែងឧបរាជ ឱរសប្អូនបានតំណែងសេនាបតី បន្ទាប់មកកាលព្រះរាជបិតាអស់ព្រះជន្ម ពួកអាមាត្យព្រមគ្នាប្រគល់រាជសម្បត្តិឱ្យព្រះឱរសជាបងតែព្រះអង្គមិនត្រូវការ បានលះរាជសម្បត្តិឱ្យដល់ប្អូនឡើងគ្រងរាជជំនួស ហើយស្តេចចេញចាកព្រះនគរទៅកាន់ជនបទជាយដែន ទៅអាស្រ័យនៅជាមួយត្រកូលសេដ្ឋី ១ ទ្រង់ធ្វើការនៅទីនោះ បន្ទាប់មកអ្នកទាំងនោះ ដឹងថាលោកជាព្រះរាជកុមារ ក៏មិនព្រមឱ្យលោកធ្វើការ ហើយបានលើកលោកក្នុងឋានៈជាព្រះរាជកុមារ គ្រាយូរមកលោកសេដ្ឋីចូលទៅគាល់ព្រះរាជកុមារ ទូលសូមឱ្យជួយប្រាប់ទៅព្រះរាជាជាប្អូនឱ្យចុះសួយសារអាករឱ្យដល់ពួកគេ ព្រះអង្គក៏ទទួលហើយជួយចាត់ការឱ្យសមតាមសេចក្តីប្រាថ្នា គ្រានោះពួកអ្នកភូមិនោះនិងអ្នកភូមិផ្សេងៗ បាននាំគ្នាមកគាល់ព្រះអង្គ យំអង្វរសូមឱ្យព្រះរាជាទ្រង់លើកលែងសួយដល់ពួកគេ ហើយពួកគេនឹងថ្វាយសួយដល់ព្រះអង្គ ព្រះអង្គក៏ផ្ញើសារទៅឱ្យព្រះរាជាឱ្យទ្រង់លើកលែងប្រាក់

សួយដល់ពួកអ្នកស្រុកនោះ ព្រះរាជាក៏ទ្រង់អនុញ្ញាត តាំងពីនោះមក ពួកប្រជាជនក៏នាំគ្នាថ្វាយសួយដល់ព្រះអង្គ ធ្វើឱ្យកើតលាភសក្ការៈធំឡើង ដោយហេតុនេះភាពរីកចម្រើនរបស់ព្រះអង្គក៏ពង្រីកធំទៅៗទ្រង់បានទូលសុំជនបទនោះទាំងអស់ ហើយសុំរាជសម្បត្តិខ្លះ ព្រះរាជាប្អូនក៏ព្រះរាជទានឱ្យ បានទទួលហើយក៏នៅមិនពេញព្រះហឫទ័យ ការរីកចម្រើននោះមានកម្លាំងខ្លាំងឡើងជាលំដាប់ ទើបទ្រង់គិតនឹងដណ្ដើមរាជសម្បត្តិ ហើយរួបរួមលើកទ័ពទៅជិតព្រះនគរ បញ្ជូនសារឱ្យដល់ព្រះរាជាឱ្យយករាជសម្បត្តិឱ្យពុំដូច្នោះទេ នឹងត្រូវច្បាំងគ្នាមិនខាន ព្រះរាជាប្អូនទ្រង់ព្រះតម្រិះថា ព្រះជេដ្ឋានេះជាពាល កាលមុននេះមិនត្រេកអរក្នុងរាជសម្បត្តិ តែឥឡូវនេះ គិតមកដណ្ដើមយករាជសម្បត្តិវិញ ហើយព្រះរាជាទ្រង់ប្រាថ្នាសេចក្ដីសន្តិភាពហើយបានថ្វាយរាជសម្បត្តិឱ្យដល់ព្រះជេដ្ឋា គ្រងរាជសម្បត្តិ ធ្លាក់នៅក្នុងអំណាចនៃតណ្ហា មិនបានពេញព្រះទ័យ ក្នុងរាជសម្បត្តិត្រឹមតែមួយព្រះនគរ មានសេចក្ដីប្រាថ្នារាជសម្បត្តិនៃនគរដទៃៗទៀត មិនមានទីបញ្ចប់នៃសេចក្ដីប្រាថ្នាឡើយ ។

គ្រាដំបូងនោះ សក្កទេវរាជទ្រង់មើលសភាពទូទៅក្នុងមនុស្សលោក បានឃើញព្រះរាជាទ្រង់ធ្លាក់នៅក្នុងអំណាចនៃតណ្ហា ទើប

ទ្រង់ត្រិះរិះថាព្រះរាជាអង្គនេះជាពាល មិនមានសេចក្តីពេញចិត្តក្នុងរាជសម្បត្តិនៃខ្លួន យើងនឹងធ្វើឱ្យលោកដឹងខ្លួនខ្លះ ហើយក៏ក្លែងភេទជាមាណពចូលទៅក្នុងព្រះរាជវាំង ហើយចូលគាល់ព្រះរាជា ទូលថា ខ្ញុំព្រះអង្គម្ចាស់ឃើញព្រះនគរ ៣ កន្លែងដែលមានធនធានសម្បូរច្រើន ខ្ញុំព្រះអង្គម្ចាស់ត្រូវការព្រះនគនោះមកថ្វាយដល់ព្រះអង្គ សូមព្រះអង្គត្រៀមពលទាហានឱ្យស្រេចចុះ ។ ព្រះរាជាលោកធ្លាក់នៅក្នុងអំណាចនៃសេចក្តីលោភ ក៏សប្បាយព្រះទ័យ សក្កៈត្រាស់នឹងព្រះរាជាដូច្នោះហើយ ក៏ស្តេចត្រឡប់ទៅឋានរបស់ខ្លួនវិញ ។ ព្រះរាជាក៏ហៅពួកអាមាត្យមកហើយបានប្រាប់ថា មានមាណពម្នាក់ចង់ឱ្យរាជសម្បត្តិនៃនគរ ៣ មកឱ្យពួកយើង ដូច្នោះ សុំឱ្យពួកលោកត្រៀមពលទាហានឱ្យសព្វគ្រប់ហើយហៅមាណពមកឱ្យយើង ពួកអាមាត្យក៏នាំគ្នាទៅរកមាណពតែមិនបានជួប ទើបត្រឡប់មកក្រាបទូល ព្រះរាជាឱ្យទ្រង់ជ្រាបទ្រង់ក៏ទោមនស្ស ហើយក៏ត្រិះរិះថារាជសម្បត្តិ ក្នុងព្រះនគរទាំង ៣នោះនឹងត្រូវបាត់បង់ហើយ សភាពទោមនស្ស ដែលកើតឡើងដោយអាស្រ័យលោភៈ ជាហេតុមានកម្លាំងខ្លាំងធ្វើឱ្យ ព្រះរាជាប្រឈួនធ្ងន់ វេជ្ជបណ្ឌិតមិនអាចព្យាបាលបាន ។

ក្នុងកាលនោះ ព្រះពោធិសត្វសម្រេចការសិក្សាពីក្រុងតក្កសិលាក៏ត្រឡប់មកស្រុកឆ្ពោះទៅកាន់ព្រះនគរពារាណសីនោះ បានឮថា

ព្រះរាជាទ្រង់ប្រឈួនខ្លាំង ក៏ចូលទៅថែរក្សា តែបានសុំឱ្យព្រះរាជាទ្រង់ប្រាប់ដល់ហេតុដែលធ្វើឱ្យប្រឈួនឱ្យស្ដាប់សិន ព្រះរាជាទ្រង់ក៏ប្រាប់ឱ្យស្ដាប់គ្រប់ប្រការ ព្រះពោធិសត្វទើបក្រាបទូលឱ្យភ្ញាក់ រលឹកថា ធម្មតាសត្វទាំងឡាយ រមែងលះបង់ជីវិតរបស់ខ្លួនព្រោះតែសវិញ្ញាណកទ្រព្យ និង អវិញ្ញាណកទ្រព្យទាំងអស់ សូម្បីព្រះអង្គក៏គ្រប់គ្រងរាជសម្បត្តិក្នុងព្រះនគរទាំង៤ ព្រះអង្គក៏សោយអាហារក្នុងភាជនៈទាំង ៤ ផ្ទំលើស្ថានទីទាំង៤ ទ្រង់គ្រឿងប្រដាប់ទាំង៤ ព្រមជាមួយគ្នាក្នុងគ្រាតែមួយមិនបាន ដូច្នោះព្រះអង្គមិនគួរធ្លាក់ក្នុងអំណាចតណ្ហា ព្រោះតណ្ហានេះ កាលចម្រើនឡើងរមែងជាហេតុឱ្យកើតសេចក្ដីទុក្ខ និង ធ្លាក់ក្នុងអបាយភូមិទាំង៤បាន បន្ទាប់ពីនោះមកព្រះពោធិសត្វ ក៏សំដែងធម៌ដែលជាគតិដាស់តឿនចិត្តដោយច្រើន អាចធ្វើឱ្យព្រះរាជាធូរស្រាលសេចក្ដីសោកសៅ និងអាការប្រឈួនរហូតដល់ធូរស្រាលបាន ។

រឿងនេះបង្រៀនឱ្យដឹងថា តណ្ហាកាលកើតឡើងជាដំបូងនោះ ប្រសិនបើមិនព្យាយាមដោះស្រាយ ក៏នាំឱ្យរាលដាលកាន់តែច្រើនឡើង ហើយក៏ក្លាយទៅជាឧបាទាន នឹងលំបាកលះបង់។

## ២.សម្ដែងតណ្ហាជាបច្ច័យឱ្យកើតទិដ្ឋុបាទាន

សេចក្ដីត្រេកអរពេញចិត្តក្នុងអារម្មណ៍នោះៗ ជាហេតុឱ្យយល់ឃើញខុស ដែលមិនទាក់ទងជាមួយសីលព្វតទិដ្ឋិ និង អត្តទិដ្ឋិទាំង ២ កើតឡើងមុន ឈ្មោះថា ទិដ្ឋុបាទាន ។

អារម្មណ៍ដែលជាគ្រឿងឱ្យកើតសេចក្ដីពេញចិត្តនោះ បានដល់អារម្មណ៍ខាងក្នុង និង ខាងក្រៅ អារម្មណ៍ខាងក្នុងគឺជាតួរបស់ខ្លួននោះឯង សេចក្ដីពេញចិត្តរបស់ខ្លួនឯងជាហេតុធ្វើឱ្យទិដ្ឋិកើតឡើងបាន នឹងសេចក្ដីពេញចិត្តក្នុងអារម្មណ៍ខាងក្រៅគឺវត្ថុដែលមានជីវិត និងមិនមានជីវិតទាំងឡាយនោះ ក៏ជាហេតុឱ្យទិដ្ឋិកើតឡើងបាន តួយ៉ាងដូចជាព្រះអង្គតិអ្នកគ្រប់គ្រងក្រុងមិថិលា នៅក្នុងដែនវិទេហៈ ព្រះអង្គតិនេះមានសេចក្ដីជឿក្នុងពាក្យនិយាយរបស់សេនាបតីម្នាក់ ឈ្មោះថា**អលាតៈ** សេនាបតីអលាតៈម្នាក់នេះ បានណែនាំឱ្យព្រះអង្គតិទៅកាន់សំណាក់របស់អាចារ្យមិច្ឆាទិដ្ឋិម្នាក់ឈ្មោះថា **គុណៈ** ជាត្រកូលកស្សបៈ ដល់លទ្ធិអាក្រាតកាយ ព្រះអង្គតិបានសួរបញ្ហាចំពោះអាចារ្យគុណៈ ថា បដិបត្តិអ្វីទើបទៅកើតក្នុងសុគតិបាន អាចារ្យគុណឆ្លើយថា ការធ្វើកុសលក្ដី អកុសលក្ដី ឥឡូវនេះមិនបានទទួលផលយ៉ាងណាមួយឡើយ

ការបដិបត្តិចំពោះបិតា មាតា គ្រូអាចារ្យ និងលោកដែលចម្រើនដោយគុណ ក៏មិនបានទទួលផលយ៉ាងណាដូចតែគ្នា ដូច្នេះអ្នកប្រកាន់ខ្លួនថាមានបញ្ញានោះពិតណាស់លោកជាមនុស្សល្ងង់ ពេញចិត្តសាងការបរិ- ច្ចាគ អ្នកមានបញ្ញា គឺបណ្ឌិតទាំងឡាយនោះពិតជាអ្នកទទួលទាន ផលចុងក្រោយដែលបរិច្ចាគនោះ ក៏មិនបានទទួលផលយ៉ាងច្បាស់នឹងភ្នែកឡើយ ហើយមិនចាំបាច់ត្រូវធ្វើអ្វីទេ កាលមហាកប្បគ្រប់ ៨៤ មហាកប្បហើយ ចិត្តរបស់សត្វទាំងឡាយ ក៏នឹងស្អាតបរិសុទ្ធទៅឯង នឹងនាំគ្នាចូលដល់ព្រះនិព្វាន ផុតចាកសង្សារវដ្តទាំងអស់ ។

កាលលោកអាចារ្យសម្តែងចប់ហើយ សេនាបតីអលាតៈក៏គាំទ្រឡើងភ្លាមថា ដែលលោកអាចារ្យពោលដូច្នេះ ជាការត្រឹមត្រូវណាស់ ព្រោះខ្លួននោះឯងកាលភពមុនខ្ញុំម្ចាស់បានកើតជាអ្នកសម្លាប់គោ តែកាលខ្ញុំម្ចាស់ស្លាប់ក៏ធ្លាក់កាន់អបាយហើយត្រឡប់បានមកកើតជាមនុស្សក្នុងជាតិនេះ បានទទួលសុខសប្បាយមានដំណែងជាសេនា- បតីដូច្នេះ ទើបសម្តែងឱ្យឃើញថា អកុសលក៏មិនធ្វើឱ្យបានទទួលផលយ៉ាងណា សមដូចពាក្យពោលរបស់លោកអាចារ្យ ។

សេនាបតីអលាតៈជាអ្នករលឹកជាតិបាន តែរលឹកបានត្រឹមតែមួយជាតិប៉ុណ្ណោះ ដូច្នេះទើបមិនអាចដឹងដល់ការប្រព្រឹត្តក្នុងជាតិទី ៣ បាន គឺបានយកផ្កាឈើទៅបូជាព្រះចេតិយដែលតម្កល់ព្រះសារីរិក-ធាតុរបស់ព្រះសម្មាសម្ពុទ្ធ តែពេលជិតស្លាប់ក្នុងជាតិនោះ កុសលដែលបូជាព្រះសារីរិកធាតុមិនមានឱកាសឱ្យផល កុសលដទៃៗ ដែលជាកុសលទាបជាង មានឱកាសឱ្យផលមុន ដូច្នេះទើបឱ្យផលបានមកកើតជាមនុស្សជាន់ខ្ពស់ ជាសេនាបតីមានសេចក្ដីសុខក្នុងបច្ចុ-ប្បន្នជាតិនេះ តែសេនាបតីអលាតៈមិនអាចដឹងដល់រឿងរ៉ាវក្នុងជាតិទី ៣ នោះបាន ទើបយល់ចូលចិត្តថា អកុសលដែលខ្លួនធ្វើទុកក្នុងជាតិទី ២ នោះមិនបានឱ្យផលណាឡើយ ជីវិតរបស់ខ្លួនដែលចំរើនរុងរឿង ក្នុងបច្ចុប្បន្នជាតិនេះ ជាវត្ថុដែលកើតឡើងឯងមិនមែនជាផលរបស់ វត្ថុណាមួយឡើយ ។

ក្នុងខណៈនោះមានបុរសម្នាក់ជាទាសៈ ឈ្មោះ ពីជកៈ ជាអ្នកបដិបត្តិក្នុងសីលជានិច្ច បានអង្គុយស្ដាប់ក្នុងទីនោះផង កាលបានឮលោកអាចារ្យសម្ដែងធមិ ហើយសេនាបតីអលាតៈពោលសសើរព្រមទាំងសម្ដែងរឿងរ៉ាវរបស់ខ្លួនឱ្យស្ដាប់ដូច្នេះហើយ ទាសពីជកៈ ក៏បានស្រែកយំឡើងមួយរំពេច ការសម្ដែងធមិរបស់លោកអាចារ្យនោះ

ត្រឹមត្រូវតែម្តង ព្រោះខ្ញុំម្ចាស់ក៏ដូចតែគ្នា កាលជាតិមុនខ្ញុំបានកើតជាក្សត្រិយ៍មានទ្រព្យ ៨០ កោដិ ហើយខ្ញុំក៏បានធ្វើបុណ្យរក្សាសីលជារឿយៗ មិនបានធ្វើទុច្ចរិតណាមួយឡើយ ដល់ពេលខ្ញុំស្លាប់ទៅ កុសលដែលខ្ញុំបានធ្វើនោះក៏មិនឃើញឱ្យផលដល់ខ្ញុំ ឱ្យខ្ញុំបានទទួលសេចក្តីសុខសេចក្តីសប្បាយណាមួយឡើយ ខ្ញុំត្រូវមកកើតជាមនុស្សជាន់ទាបជាទាសៈគេដូច្នេះ តែដូច្នោះក្តី ខ្ញុំម្ចាស់នៅឧស្សាហ៍ធ្វើបុណ្យ រក្សាសីលជានិច្ច មិនបានរលឹកដល់សេចក្តីលំបាក និងវៀរចាកការធ្វើទុច្ចរិតផ្សេងៗ ដូចគ្នា កាលខ្ញុំម្ចាស់បានស្តាប់លោកអាចារ្យ និងលោកសេនាបតីសម្តែងរឿងរ៉ាវដូច្នេះ ក៏ដឹងបានថាកុសលផ្សេងៗ ដែលខ្ញុំម្ចាស់បានធ្វើនោះ នឹងមិនបានប្រយោជន៍ទទេៗ ជាប្រាកដ ព្រោះខ្ញុំម្ចាស់បានធ្វើបុណ្យទុកក្នុងជាតិមុន ក៏មិនឃើញឱ្យផលដល់ខ្ញុំម្ចាស់ ដូច្នេះកុសលដែលខ្ញុំម្ចាស់បានធ្វើឡើងថ្មីក្នុងជាតិនេះ ក៏មិនឱ្យផលក្នុងជាតិខាងមុខដែរ ដោយហេតុនេះទើបខ្ញុំម្ចាស់ឈប់ជឿថាបុណ្យមាន។

រឿងរ៉ាវរបស់ទាសពីជកៈ ក៏ប្រព្រឹត្តទៅទំនង់ដូចគ្នា និងសេនា-បតីអលាតៈ គឺទាសពីជកៈនេះ រលឹកជាតិបានត្រឹមតែមួយជាតិមិនបានដឹងថា ក្នុងសម័យសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធអង្គនោះ ទាសពីជកៈនេះបានកើតជាអ្នកចិញ្ចឹមគោ ថ្ងៃមួយគោដែលចិញ្ចឹម

នោះបាត់ ក៏ចេញទៅរកក្នុងព្រៃ ខណៈនោះមានសមណៈ១អង្គ វង្វេងផ្លូវ មកជួបអ្នកចិញ្ចឹមគោ ទើបសួរផ្លូវនេះទៅណា អ្នកចិញ្ចឹមគោនោះក៏មិនបានចាប់អារម្មណ៍ ចំពោះពាក្យសួររបស់ព្រះថេរៈនោះ ព្រោះបំណងទៅរកគោឱ្យបានជួបប្រទះប៉ុណ្ណោះព្រះថេរៈទើបសួរបន្ថែមទៀតថា ផ្លូវនេះទៅណាជួយប្រាប់ឱ្យអាត្មាភាពដឹងផង អ្នកចិញ្ចឹមគោដឹង តែមិនពេញចិត្តប្រាប់ ទើបពោលវាចាត្រគោះបោះបោក ដូច្នេះថា ព្រះអង្គនេះមិនស្គាល់កាលៈទេសៈប្រហែលជាត្រកូលទាសាទាសីហើយ វាចាដែលពោលហើយ ក៏សម្រេចជាវចីកម្ម ប៉ុន្តែមិនទាន់ឱ្យផលបានកើតមកជាសេដ្ឋីសិន បន្ទាប់មកអកុសលវចីកម្មដែលធ្លាប់ជេរនោះទើបមានឱកាសឱ្យផល ដោយហេតុនេះស្លាប់ពីសេដ្ឋីហើយ ទើបបានមកកើតជាអ្នកមានត្រកូលទាប ហើយនឹងត្រូវជាទាសៈរបស់គេ ។

ព្រះអង្គតិ កាលស្តាប់អាចារ្យគុណ សម្តែងរឿងរ៉ាវចប់ហើយ ព្រមទាំងបានស្តាប់ប្រវត្តិរបស់សេនាបតីអលាតៈ និងទាសពីជកៈហើយ ក៏ពេញព្រះទ័យ នឹងការមិនឃើញប្រយោជន៍ក្នុងការធ្វើល្អ និងមិនឃើញទោសរបស់ការធ្វើអាក្រក់ ក្នុងពេលនោះទិដ្ឋិគឺការយល់ខុសកើតឡើងដល់ព្រះអង្គតិ ហើយកាលត្រឡប់មកដល់ព្រះរាជវាំងក៏ឈប់ធ្វើបុណ្យទាន ហើយបញ្ជាឱ្យគេរើរោងទានចេញ កិច្ចការងារក្នុង

ស្រុកផ្សេងៗ ក៏ប្រគល់ភារៈឱ្យដល់អាមាត្យធ្វើជំនួស ចំណែកព្រះអង្គ យកចិត្តទុកដាក់ ក្នុងការសោយកាមគុណផ្សេងៗ តែប៉ុណ្ណោះ មិនថា ជាវត្ថុសុចរិត ឬទុច្ចរិតក៏ដោយ ឱ្យតែពេញព្រះទ័យហើយ ក៏នាំស្រី ក្រមុំ និងមិនក្រមុំ ក្នុងស្រុកនគររបស់ព្រះអង្គចូលមក ប្រសិនបើពេញចិត្ត ហើយ ត្រូវបង្គាប់ឱ្យមកបម្រើខ្លួនដោយប្រការផ្សេងៗ ។ធ្វើឱ្យប្រជា-ជនទាំងឡាយ បានទទួលសេចក្តីក្តៅក្រហាយយ៉ាងក្រៃលែង សូម្បី ព្រះរាជធីតាដែលជាអ្នកជ្រះថ្លាក្នុងការធ្វើកុសលរក្សាជានិច្ច បាននិយាយ ដាស់តឿនសតិរបស់ព្រះរាជបិតា សូមអង្វរឱ្យឈប់ប្រព្រឹត្តអាក្រក់ ទៀត ដោយលើកហេតុផលផ្សេងៗ មកឱ្យស្តាប់ ប៉ុន្តែព្រះអង្គតិមិន បានជឿទេ តមកព្រះពោធិសត្វដែលជាព្រហ្មមាននាមថា នារទៈបាន និមិត្តជាតាបស ចុះមកទេសនាប្រោសទូន្មានដោយប្រការ ផ្សេងៗ ទីបំផុតព្រះអង្គតិ ទើបព្រមលះបង់ទិដ្ឋុបាទាននោះបាន ។

រឿងនេះសម្តែងឱ្យឃើញថា តណ្ហាបានដល់សេចក្តីត្រេកអរក្នុង កាមគុណារម្មណ៍ជាហេតុឱ្យកើត ទិដ្ឋុបាទានបាន ។

## ៣.សម្តែងតណ្ហាជាបច្ច័យឱ្យកើតសីលព្វតុបាទាន

ការត្រូវការសេចក្តីសុខ គឺឱ្យឆ្លងផុតសេចក្តីទុក្ខក្នុងសង្សារវដ្ត ម្យ៉ាង ឬមានសេចក្តីត្រូវការសេចក្តីសុខក្នុងទេវលោកម្យ៉ាង ទាំង២

យ៉ាងនេះ បានឈ្មោះថា តណ្ហា បើតណ្ហាទាំងនេះកើតឡើងក្នុងចិត្តរបស់អ្នកណាហើយអ្នកនោះ រមែងរកផ្លូវបដិបត្តិខ្លួនដើម្បីឱ្យបានទទួលសេចក្តីសុខដូចដែលខ្លួនប្រាថ្នាក្នុងការបដិបត្តិខ្លួននេះ បើបានជួបនឹងពួកសប្បុ-រសដែលជាបណ្ឌិត ឬខ្លួនឯងមានការដឹងក្នុងខបដិបត្តិ ដែលត្រឹម-ត្រូវជាបរិយត្តិសាសនាល្អល្អមហើយ ការបដិបត្តិនោះក៏នឹងដំណើរទៅដោយល្អ មិនខុសផ្លូវដែលបណ្ឌិតទាំងឡាយប្រព្រឹត្ត ប្រសិនបើអ្នកនោះមិនបានគប់រកនឹងពួកបណ្ឌិត ឬមិនមានសេចក្តីដឹងក្នុងបរិយត្តិសាសនាការបដិបត្តិនោះក៏នឹងនាំទៅកាន់ផ្លូវខុស ដោយវង្វេងយល់ថាជាផ្លូវដែលត្រូវមាន២ ផ្លូវ គឺបដិបត្តិទៅក្នុងផ្លូវធ្វើទណ្ឌកម្មរាងកាយរបស់ខ្លួនឱ្យបានទទួលសេចក្តីលំបាកផ្សេង១ ហៅថា **អត្តកិលមថានុយោគ** ម្យ៉ាងឬបដិបត្តិទៅក្នុងផ្លូវទំនុកបម្រុងរាងកាយរបស់ខ្លួន ឱ្យបានទទួលសេចក្តីសុខផ្សេង ១ ហៅថា **កាមសុខល្លិកានុយោគ** ម្យ៉ាង ការបដិបត្តិទាំង ២ ផ្លូវនេះ ក៏សុទ្ធតែជាការបដិបត្តដែលខុសផ្លូវទាំងអស់ ដែលទទួលផលជាសុខតាមដែលខ្លួនប្រាថ្នាទុក ត្រឡប់ឱ្យផលផ្ទុយគ្នា គឺ រមែងបានទទួលសេចក្តីទុក្ខយ៉ាងក្រៃលែងឡើងថែមទៀត ។

ការបដិបត្តិក្នុងផ្លូវអត្តកិលមថានុយោគនេះ មានច្រើនវិធី ដូចជាការធ្វើទណ្ឌកម្មរាងកាយដោយអត់អាហារ មិនដេកមិនផ្លាស់ឥរិយា-បថ មិនងូតទឹក ឬដុតរាងកាយដោយដែកខ្លះ បរិភោគភ្លើងខ្លះ ត្រាំខ្លួនក្នុងទឹកខ្លះ ដេកលើដែកគោលខ្លះ ទាំងនេះជាដើមក្តី ឬ បដិបត្តិបដិបត្តិខ្លួនឱ្យដូចសត្វគោ សត្វឆ្កែក្តី ទាំងនេះហៅថា **អត្តកិលមថា -នុយោគ** ទាំងអស់។

ក្នុងទីនេះ ដែលឈ្មោះថា **សីលព្វតុបាទាន** នោះ បានដល់ការបដិបត្តិខ្លួនក្នុងផ្លូវអត្តកិលមថានុយោគ ដោយវិធីប្រព្រឹត្តខ្លួនឱ្យដូចគោ ដូចឆ្កែ ការបដិបត្តិខ្លួនប្រភេទនេះ ក៏ជាផលដែលទាក់ទងមកពីតណ្ហាជាហេតុនោះឯង។

ក្នុងរឿងដែលលើកឡើងសម្តែងទុកក្នុង **កុក្កុរោវាទសូត្រ** នៃមជ្ឈិមបណ្ណាសក ព្រះបាលីថា មានបរិព្វាជក ២ នាក់ ម្នាក់ឈ្មោះ **បុណ្ណៈ** ហើយម្នាក់ទៀតឈ្មោះ **សេនីយៈ** ទាំងពីរនាក់នេះត្រូវការសេចក្តីសុខក្នុងទេវលោក ចង់បានជាទេវតាដែលមានអំណាច ទើបនាំគ្នាបដិបត្តិខ្លួនដូចសត្វគោ សត្វសុនខ ដោយយល់ថា ប្រព្រឹត្តដូច្នេះហើយនឹងធ្វើឱ្យកិលេសផ្សេងៗមិនកើត និងអកុសលធម៌ចាស់ក៏បាត់ទៅបាន បុណ្ណបរិព្វាជកបដិបត្តិខ្លួនដូចឆ្កែ សេនីយបរិព្វាជក បដិបត្តិខ្លួនដូច

គោ បដិបត្តិដូច្នេះរឿយ ៗ តមកទាំង ២ នាក់នេះ កើតមានសេចក្តីសង្ស័យក្នុងខបដិបត្តិរបស់ខ្លួនថា ការបដិបត្តិ អ្នកណាល្អជាងអ្នកណា ឈ្លោះប្រកែកគ្នាមិនត្រូវគ្នា ទីបំផុតនាំគ្នាទៅគាល់ព្រះសម្មាសម្ពុទ្ធទូលរឿងនោះឱ្យព្រះអង្គទ្រង់ព្រះសណ្តាប់ ហើយទូលសួរថា ការបដិបត្តិរបស់ខ្ញុំទាំង២នេះ មានអានិសង្សយ៉ាងណាខ្លះ បដិបត្តិដូចសុនខល្អជាងបដិបត្តិដូចគោ ឬបដិបត្តិដូចគោល្អជាងបដិបត្តិដូចសុនខ ហើយខ្ញុំម្ចាស់ទាំង២ កាលស្លាប់ពីជាតិនេះទៅហើយនឹងទៅកើតទីណា កាលព្រះសម្មាសម្ពុទ្ធបានទ្រង់សណ្តាប់ហើយ ព្រះអង្គក៏ហាម បរិព្វាជកទាំង ២ ថាកុំសួរដូច្នេះឡើយ ទ្រង់ហាមដូច្នេះរហូតដល់ទៅ៣ដង តែបរិ-ព្វាជកទាំង២ ក៏មិនព្រមស្ងាត់ នៅទូលសួរដដែលទៀតជាគម្រប់ ៤ ដង ព្រះអង្គទើបត្រាស់ថា "ម្នាលបរិព្វាជក អ្នកដែលបដិបត្តិខ្លួនដូចសុនខគ្រប់យ៉ាងនោះ កាលបើស្លាប់ហើយក៏នឹងទៅកើត ជាឆ្កែពិតប្រាកដ ហើយអ្នកដែលបដិបត្តិខ្លួនដូចគោគ្រប់វត្តគ្រប់យ៉ាង នោះកាលស្លាប់ហើយ ក៏នឹងទៅកើតជាគោពិតប្រាកដដូចគ្នា ហើយប្រសិនបើថា អ្នកនោះដែលបដិបត្តិដូច្នោះមានសេចក្តីយល់ថា ការបដិ-បត្តិខ្លួននោះនឹងជាហេតុឱ្យបានទទួលផលឱ្យទៅកើតក្នុងទេវលោក ជាទេវតាដែលមានអំណាចយ៉ាងនេះ ហើយក៏ចាត់ថា ការយល់ឃើញជាមិច្ឆាទិដ្ឋិ ដូច្នោះកាលស្លាប់នឹងត្រូវទៅសោយទុក្ខក្នុងនរកជាមុន

កាលផុតពីនរកហើយ ទើបមកកើតជាសត្វតិរច្ឆានម្តងទៀត” កាលព្រះសម្មាសម្ពុទ្ធសម្តែងចប់ហើយ បរិព្វាជកទាំង ២ ក៏ស្រែកឡើងភ្លាមដោយសេចក្តីខូចចិត្ត ដែលខ្លួនបានវង្វេងប្រព្រឹត្តខុសអស់ពេលដ៏យូរ បន្ទាប់ពីនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ទេសនាឱ្យបរិព្វាជកទាំង ២ ស្តាប់ កាលទ្រង់សម្តែងចប់ហើយ បុណ្ណបរិព្វាជកពោលពាក្យដល់នូវត្រៃសរណគមន៍ជាទីពឹងទីរលឹក លះចោលនូវលទ្ធិចាស់ក៏ចូលជាពុទ្ធសាសនិកជនចាប់ពីពេលនោះមក ចំណែកសេនីយៈបរិព្វាជកនោះក៏សូមបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ហើយបានបំពេញវិបស្សនាកម្មដ្ឋានក៏បានសម្រេចជាព្រះអរហន្តក្នុងកាលតមក ។

រឿងនេះសម្តែងឱ្យឃើញថា តណ្ហាបានដល់សេចក្តីត្រូវការឱ្យបានទទួលសេចក្តីសុខក្នុងជាតិមុខ ជាហេតុឱ្យកើតសីលព្វតុបាទាន គឺបដិបត្តិខុសពីផ្លូវដូចដែលបានសម្តែងមកនេះ ។

## ៤.សម្តែងតណ្ហាជាបច្ច័យនាំឱ្យអត្តវាទុបាទានកើត

តាមធម្មតាមនុស្សយើងមានការឃើញ ការឮ ការដឹងក្លិន ការដឹងរស ការដឹងសម្ផស្ស ដូច្នោះ នឹងត្រូវប្រកបដោយហេតុ ដោយបច្ច័យតាមសមគួរ ដូចជាការឃើញ គឺចក្ខុទ្វារវិថីនឹងកើតឡើងបាននោះ ក៏ត្រូវអាស្រ័យមានហេតុមានបច្ច័យតាមសមគួរ គឺ៖

១. មានចក្ខុបសាទ គឺ មានភ្នែកល្អ

២. មានរូបារម្មណ៍ គឺ មានពណ៌ផ្សេង ៗ

៣. មានអាលោកៈ គឺ ពន្លឺ

៤. មានមនសិការ គឺ ការតាំងចិត្ត

បើគ្រប់បច្ច័យ ៤ យ៉ាងនេះហើយ ចក្ខុទ្វារវិថីក៏កើតឡើង ហើយតមកក៏ត្រូវមានមនោទ្វារវិថីចិត្តកើតឡើងទៀត ៤ វិថី គឺៈ

១. វិថីដែលទទួលអារម្មណ៍តពីចក្ខុទ្វារវិថី ឈ្មោះថា **អតីតគ្គហនវិថី**

២.វិថីដែលទទួលរូបារម្មណ៍តពីអតីតគ្គហនវិថី ឈ្មោះថា **សមូហគ្គហនវិថី**

៣ .វិថីដែលដឹងរូបរាងសណ្ឋាន របស់រូបារម្មណ៍នោះ ៗ ឈ្មោះថា **អត្ថគ្គហនវិថី**

៤. ជាវិថីដែលដឹងឈ្មោះ របស់រូបារម្មណ៍នោះៗឈ្មោះថា **នាមគ្គ-ហនវិថី**

បើមនោទ្វារវិថីចិត្តកើតឡើងគ្រប់ ៤ យ៉ាងនេះហើយ អ្នកដែលឃើញនោះក៏ដឹងភ្លាមថាជា វត្ថុនោះវត្ថុនេះ ការបានឮជាដើម ក៏ប្រព្រឹត្តទៅដូចគ្នា។

ដែលបានអធិប្បាយមកនេះ សម្តែងឱ្យឃើញថា វត្ថុគ្រប់យ៉ាងដែលប្រព្រឹត្តទៅក្នុងលោកនេះ ក្រៅពីរូបនិងនាមហើយ ក៏មិនមានអ្វីផ្សេងទៀត ហើយក្នុងការឃើញដូចពោលហើយនោះ អ្នកឃើញក៏មិនមែនផ្សេង គឺរូបនិងនាមនោះឯងជាអ្នកឃើញ គឺ :

ចក្ខុបសាទ ជាមួយ ចក្ខុទ្វារវិថី រហូតដល់ហទយៈវត្ថុ ជាមួយមនោ-ទ្វារវិថីទាំង ២ ប៉ុណ្ណោះ ជាអ្នកដឹង ជាអ្នកឃើញ ជាអ្នកឮ ជាសភាព អនត្តៈពិត១ មិនមែនជាអត្តៈ គឺមិនមែនយើងឃើញ អ្នកនោះឃើញ អ្នកនេះឃើញ។

ក្នុងឥរិយាបថផ្សេង១ ដូចជា ដេក ដើរ ឈរ អង្គុយ និង ការផ្លាស់ប្តូរក្នុងឥរិយាបថផ្សេង១ ដែលសម្រេចកិច្ចបាននោះ ក៏ត្រូវ អាស្រ័យហេតុបច្ច័យដូចគ្នា ដូចជាក្នុងការដើរដែលសម្រេច បាននោះ ត្រូវមានបច្ច័យ ៤ យ៉ាង គឺ :

១. ត្រូវមានការតាំងចិត្តដើរ

២.ត្រូវមានចិត្តជាអ្នកបញ្ជា

៣.ត្រូវមានចិត្តជួវាំយោធាតុកើតឡើង

៤.ត្រូវមានជើងល្អ

កាលបើគ្រប់ ៤ យ៉ាងនេះហើយ ការដើរក៏សម្រេចបាន ហើយ អ្នកដែលកំពុងដើរនោះ កាលបើនិយាយតាមសភាវៈ អ្នកដើរ បានដល់ ចិត្ត ចេតសិក ជាអ្នកមានការតាំងចិត្តដើរ ហើយអ្នកបញ្ជា ចិត្តជួវាំយោ ធាតុដែលនៅក្នុងរាងកាយនោះ ជាអ្នកជំរុញ បបរីធាតុ គឺរាងកាយ ជាអ្នកដើរ ហើយសន្មតិថា យើងដើរ បុគ្គល"ក"ដើរ បុគ្គល"ខ"ដើរ ដូច្នេះ ជាដើម សេចក្តីពិតនោះ យើងឬសត្វបុគ្គល ដែលអាចដើរទៅបាន នោះមិនមាន មានតែរូបជាមួយនាមប៉ុណ្ណោះ។

ក្នុងឥរិយាបថផ្សេង ៗ ក៏ប្រព្រឹត្តទៅក្នុងទំនងដូចគ្នា។

សូម្បីការឃើញ ការឮ ជាដើមទាំងនេះ នឹងប្រព្រឹត្តទៅតាមហេតុបច្ច័យ មិនមានបុគ្គលណាចាត់ចែងក៏ពិត តែធម្មតាសត្វទាំងឡាយនោះ បើមានការឃើញ ការឮ កើតឡើងហើយ បើអារម្មណ៍ដែលបានឃើញ បានឮ ជាដើមនោះ ជាអារម្មណ៍ដែលល្អ ក៏ពេញចិត្តឡើង ហៅថា លោភៈ ឬតណ្ហាកើតឡើងហើយដល់អ្នកនោះ បើអារម្មណ៍ដែលបានឃើញ បានឮ ជាដើមនោះ ជាអារម្មណ៍មិនល្អ ក៏កើតសេចក្ដីមិនចូលចិត្តឡើង ហៅថា ទោសៈកើតឡើងហើយដល់អ្នកនោះ តែអារម្មណ៍ដែលជាហេតុឱ្យទោសៈកើតឡើង មិនជាហេតុក្នុងការប្រកាន់មាំ ចិត្តរបស់សត្វទាំងឡាយ ដែលធ្វើឱ្យមានឧបាទានកើតឡើងបានទេ ចំណែកអារម្មណ៍ដែលជាហេតុឱ្យលោភៈកើតឡើងនោះ រមែងមានអំណាចចងចិត្តសត្វទាំងឡាយ ឱ្យកើតឧបាទានប្រកាន់មាំឡើងបាន ពោលគឺកាល បានឃើញ ឬបានឮអារម្មណ៍ដែលជាទីចូលចិត្តពេញចិត្តរឿយៗ ក៏ធ្វើឱ្យចិត្តអ្នកនោះ ប្រកាន់អារម្មណ៍នោះៗ ទុកមិនព្រមលែង ការប្រកាន់អារម្មណ៍ទុកមិនព្រមលែងដូច្នេះ ហៅថាជាឧបាទាន ហើយក្នុងវេលា ជាមួយគ្នានោះ អ្នកដែលយល់ខុសក្នុងខន្ធ ៥ ដែលកើតឡើង ក្នុងខណៈឃើញ ខណៈបានឮជាដើមនោះថា យើងឃើញ យើងឮ យើងគិត យើងនិយាយ យើងបរិភោគ

យើងអង្គុយ យើងដេក យើងដើរ ដូច្នេះជាដើម ចាត់ជាអត្តវាទុបាទាន កើតឡើង ក៏ព្រោះអាស្រ័យតណ្ហាជាហេតុ ដូចមានរឿងដែលជាឧទាហរណ៍ថា

ក្នុងក្រុងវេសាលី មាននិគ្រន្ថម្នាក់ឈ្មោះថាសច្ចកៈអគ្គិវេសនគោត្រ និគ្រន្ថម្នាក់នេះ បានយកផែនដែកមកចងព័ទ្ធត្រង់ពោះជានិច្ច ព្រោះ មានការយល់ឃើញថា ខ្លួនជាអ្នកមានបញ្ញាច្រើន បើមិនយកផែនដែកមកចង ដើម្បីរក្សាបញ្ញាទុកទេ ពោះរបស់ខ្លួននឹងត្រូវបែកជាចំណែក សច្ចកៈនិគ្រន្ថម្នាក់នេះប្រកាសខ្លួនថា "មិនថាអ្នកណាម្នាក់ អាចារ្យណាម្នាក់ក៏ដោយ បើមកពោលវាទៈជាមួយយើងហើយ អ្នកនោះ នឹងត្រូវមានអាការៈតក់ស្លុតញ័រខ្លួនញាក់សាច់ កុំថាតែមនុស្សឡើយ សូម្បីតែអ្នកតារក្សាដើមឈើ ប្រសិនបើយើងពោលវាចាហើយ អ្នកនោះនឹងត្រូវកើតអាការញ័រដូចគ្នា សច្ចកៈនិគ្រន្ថប្រកាសដូច្នេះជា-និច្ច សេចក្តីពិតក្នុងវេលានោះ អ្នកដែលតាំងខ្លួនជា អាចារ្យផ្សេងៗ ក៏មិនអាចនឹងតបតវាទៈជាមួយសច្ចកៈនិគ្រន្ថបានទេ ដោយហេតុនេះ ទើបធ្វើឱ្យសច្ចកៈនិគ្រន្ថ មានសេចក្តីតម្កើងខ្លួន ខ្លាំងឡើង។

តមកថ្ងៃមួយ សច្ចកៈនិគ្រន្ថបានឮថា ព្រះសមណគោតមសម្មា-សម្ពុទ្ធទ្រង់ទេសនាថា សត្វទាំងឡាយនេះសុទ្ធតែមានខន្ធ ៥ ទាំងអស់ ហើយមានសេចក្តីកើតរលត់ជានិច្ច ព្រោះហេតុនោះ ទើបជាអនិច្ចៈ

មិនទៀង ជាទុក្ខ មិនតាំងនៅបានជាអនត្តាពិត១ រកតួខ្លួនជាម្ចាស់របស់មិនមាន ដូច្នោះ សត្វទាំងឡាយកុំយល់ខុសក្នុងរាងកាយរបស់ខ្លួនថាជាយើង ជាគេ ជាស្រី ជាប្រុស សច្ចកៈនិគ្រន្ថបានឮដំណើងដូច្នេះហើយ ក៏នឹកចង់ទៅគាល់នឹងលើកវាទៈជាមួយព្រះសម្មាសម្ពុទ្ធ ទើបបបួលពួកក្សត្រលិច្ឆវី ៥០០ អង្គឱ្យទៅជាមួយផងហើយនិយាយអួតចំពោះក្សត្រលិច្ឆវីទាំងនោះថា សូមឱ្យពួកលោកចាំមើល យើងនឹងធ្វើឱ្យព្រះសមណគោតមស្លុតខ្លាចចំពោះវាទៈរបស់យើង ឱ្យដូចពពែដែលចាប់ត្រង់កដូច្នោះ ហើយសច្ចកៈនិគ្រន្ថព្រមទាំងក្សត្រលិច្ឆវី ៥០០ អង្គ ក៏នាំគ្នាទៅគាល់ព្រះសម្មាសម្ពុទ្ធ ទូលសូមអនុញ្ញាតហើយ សច្ចកៈ-និគ្រន្ថទូលសួរឡើងថា "បពិត្រព្រះសមណគោតមដ៏ចម្រើន លោកអប់រំសាវ័ក របស់លោកដោយធម៌យ៉ាងណា" ទើបព្រះអង្គទ្រង់តបថា "យើងអប់រំសាវ័ក របស់យើងដោយធម៌ គឺខន្ធ ៥ ដែលប្រាកដជាសត្វទាំងឡាយនោះ សុទ្ធតែជាអនិច្ចំ ទុក្ខំ អនត្តា គឺមិនទៀង ជាទុក្ខ មិនបាននៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណា មិនមែនតួខ្លួន យើង គេ ដូច្នេះ" ។

សច្ចកៈនិគ្រន្ថនិយាយឡើងថា "បពិត្រព្រះសមណគោតមដ៏ចម្រើន ធម្មតាពូជផ្លែឈើផ្សេង១ ដែលនឹងចម្រើនលូតលាស់ឡើងបាន ក៏ត្រូវអាស្រ័យផែនដីយ៉ាងណា សត្វទាំងឡាយអាស្រ័យខន្ធ ៥

ហើយ ក៏រមែងបានសោយសេចក្តីសុខខ្លះ ទុក្ខខ្លះ ធ្វើកុសលខ្លះ អកុសលខ្លះ ស្វែងរកសេចក្តីសុខក្នុងមគ្គខ្លះ ផលខ្លះ ហើយក្នុងចន្លោះដែលនៅមានជីវិតនោះ អត្តាតួខ្លួនក៏នៅមាន ព្រោះហេតុនោះក្នុងការដែលព្រះសមណគោតមសម្តែងថា **សព្វេ ធម្មា អនត្តា** នោះត្រូវយ៉ាងណា"។

ទើបព្រះពុទ្ធទ្រង់ត្រាស់តបថា "ក្នុងការដែលអ្នកពោលដូច្នេះមានន័យថា លោកមានសេចក្តីយល់ឃើញថា ខន្ធ ៥ នោះ ជាតួខ្លួនរបស់យើង ដូច្នេះមិនមែនឬ?" សច្ចកៈទូលតបថា "ការយល់ឃើញបែបនេះមិនមែនតែខ្ញុំព្រះអង្គម្នាក់នោះទេ សូម្បីពួកអ្នកដែលអង្គុយនៅទីនេះ ក៏មានការយល់ឃើញដូច្នេះដែរ" ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "អ្នកមិនត្រូវលើកយកអ្នកផ្សេងចូលមកអាងទេ តថាគតចង់ដឹង ការយល់ឃើញរបស់អ្នកតែម្នាក់ប៉ុណ្ណោះ" សច្ចកៈនិគ្រន្ថទូលថា "ពិត ខ្ញុំព្រះអង្គមានការយល់ឃើញដូច្នោះ" ទើបព្រះអង្គត្រាស់ថា "បើអ្នកមានសេចក្តីយល់ឃើញដូច្នោះ តថាគតចង់សួរថា ធម្មតាអ្នកដែលជាក្សត្រនោះ មានអំណាចជាឥស្សរៈក្នុងប្រទេសរបស់ខ្លួនថា អ្នកដែលគួរតិះដៀលក៏តិះដៀល អ្នកដែលគួរសរសើរក៏សរសើរបាន អ្នកដែលគួរសម្លាប់ក៏សម្លាប់បាន អ្នកដែលគួរដេញក៏ដេញបាន ដូច្នេះឬ?" សច្ចកៈនិគ្រន្ថឆ្លើយថា "ត្រូវហើយ" ទើបព្រះអង្គត្រាស់សួរថា "បើដូច្នោះ

អ្នកអាចទទួលបានទេថា អ្នកមានឥស្សរៈក្នុងរាងកាយរបស់អ្នក អ្នកអាចបញ្ជាឱ្យរូបរាងដែលមិនស្អាត ឱ្យស្អាត ឬបង្គាប់មិនឱ្យសក់ស្កូវ ធ្មេញបាក់ ស្បែកជ្រួញ ឱ្យមានរូបរាង ដូចជាកំលោះៗ អាយុ ១៦ ដូច្នេះបានឬទេ ?"។

សច្ចកៈនិគ្រន្ថ កាលបានឮពាក្យសួររបស់ព្រះសម្មាសម្ពុទ្ធដូច្នេះ ក៏គិតក្នុងចិត្តថា "បើយើងឆ្លើយថា អាចគ្រប់គ្រងរាងកាយឱ្យប្រព្រឹត្តទៅតាមសេចក្តីពេញចិត្តរបស់យើងបាន ពួកក្សត្រលិច្ឆវីក៏នាំគ្នាស្រែកសូមឱ្យយើងបង្គាប់រាងកាយរបស់យើងដែលមិនស្អាត ឱ្យត្រឡប់ជាស្រស់ស្អាតឡើង យើងនឹងធ្លាក់ឋានៈដែលលំបាកៗ តែបើយើងឆ្លើយថា មិនអាចនឹងបង្គាប់បញ្ជាឱ្យរាងកាយរបស់យើង ប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នាបានដូច្នេះហើយ ក៏ត្រូវទទួលការរ៉ាប់រងពាក្យរបស់ព្រះសម-ណគោតមដែលថា "**សព្វេ ធម្មា អនត្តា**" ហើយព្រះសមណគោតមនឹងឈ្នះយើងពិតប្រាកដ សច្ចកៈគិតទៅគិតមកហើយ ក៏និយាយមិនចេញ ទើបនៅស្ងៀមព្រងើយ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ដាស់តឿនថា "ហេតុអ្វីអ្នកនៅស្ងៀម សូមដោះស្រាយវាទៈរបស់តថាគត" សច្ចកៈក៏នៅស្ងៀមនិយាយមិនចេញ។

ក្នុងវេលានោះសក្កទេវរាជក៏និមិត្តកាយជាយក្ស មានដៃកាន់ដំបងដែកចូលមកកន្លែងសច្ចកៈ លើកដំបងឡើងបំរុងនឹងវាយ ហើយពោល

ថា "សច្ចកៈ ព្រះតថាគតសួរអ្នក ហេតុអ្វីអ្នកនៅស្ងៀមមិនឆ្លើយ បើអ្នកមិនឆ្លើយ យើងនឹងវាយអ្នកដោយដំបងនេះ ឱ្យក្បាលរបស់អ្នកបែកជា ៧ ចំណែក ឥឡូវនេះ" វេលាដែលព្រះឥន្ទនិមិត្តជាយក្សចូលមកនិយាយជាមួយសច្ចកៈនោះ អ្នកផ្សេងៗ នៅឯទីនោះមិនមានអ្នកណាមើលឃើញ មានតែព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងសច្ចកៈប៉ុណ្ណោះ ដែលមើលឃើញ កាលសច្ចកៈឃើញដូច្នោះហើយ ក៏មិនអាចនៅស្ងៀមបានក៏ឆ្លើយថា "ខ្ញុំម្ចាស់នឹងដោះស្រាយវាទៈរបស់ព្រះតថាគតឥឡូវនេះ" ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គសួរទៀតថា "សច្ចកៈ រូបរបស់អ្នកដែលអ្នកមានឥស្សរៈនោះមិនស្អាត មិនស្រស់ អ្នកនឹងបង្គាប់បញ្ជាឱ្យស្រស់ស្អាតដូចរូបរបស់ពួកក្សត្រលិច្ឆវីនោះ ឱ្យប្រព្រឹត្តទៅបានឬ?" សច្ចកៈបានទូលឆ្លើយថា "បង្គាប់បញ្ជាឱ្យប្រព្រឹត្តទៅដូច្នោះមិនបានទេ" ព្រះសម្មាសម្ពុទ្ធត្រាស់ថា "សច្ចកៈអ្នកចូលប្រយ័ត្នពាក្យដោះស្រាយរបស់អ្នកឱ្យល្អ ពាក្យនិយាយរបស់អ្នកខាងដើម និងខាងចុងផ្ទុយគ្នា" ហើយព្រះអង្គសួរទៀតថា "រូបរាងរបស់អ្នក ដែលជាឥស្សរៈនោះអ្នកនឹងបង្គាប់ឱ្យប្តូរផ្លាស់ទៅតាមសេចក្តីប្រាថ្នារបស់អ្នកបានឬទេ?"។ សច្ចកៈបានទូលថា "រូបរាងរបស់ខ្ញុំព្រះអង្គមិនអាចបង្គាប់ឱ្យប្រព្រឹត្តតាមសេចក្តីពេញចិត្តបានទេ" ព្រះសម្មាសម្ពុទ្ធទ្រង់សួរទៀតថា "មាន

មនុស្សម្នាក់កំពុងបានទទួលសេចក្តីលំបាកកាយ លំបាកចិត្តតែអ្នកនោះ ឃើញថា សេចក្តីលំបាកនេះជាតួខ្លួន ជាយើង កាលយល់ឃើញយ៉ាង នេះហើយ សេចក្តីលំបាកនោះនឹងបាត់ទៅបានឬទេ" សច្ចកៈទូលឆ្លើយ ថា "មិនបាត់ទេ" ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សួរទៀតថា "ខន្ធ ៥ ដែលជា ទុក្ខនោះ អ្នកកំពុងប្រកាន់យកថា ជាខ្លួន ជាយើង ជាគេ ដូច្នេះមិនមែន ឬ?" សច្ចកៈទូលឆ្លើយថា "មែនហើយ ខ្ញុំព្រះអង្គប្រកាន់ដូច្នោះ" ព្រះសម្មាសម្ពុទ្ធទ្រង់សួរទៀតថា "បុគ្គលដែលស្វែងរកខ្លឹមឈើ តែទៅ កាត់ដើមចេកបកចេញដើម្បីរកខ្លឹម រកយ៉ាងណាក៏មិនជួបព្រោះដើម ចេកនោះ ជាដើមឈើដែលរកប្រយោជន៍មិនបាន ហើយទីបំផុតក៏ មិនបានអ្វីជាខ្លឹមសារ ចំណុចនេះយ៉ាងណា វាទៈរបស់អ្នកក៏ដូច្នោះដែរ ។ ពេលដែលអ្នកពោលប្រកាន់មាំថាខន្ធ ៥ នេះ មានតួខ្លួនជាខ្លឹមសារ តែកាលបើអ្នក(សច្ចកៈ)បានដឹងក្នុងខន្ធ៥ល្មមប្រមាណ មានតថាគត ជាដើម សួរទៅសួរមកហើយ ក៏ឃើញបានថាវាទៈរបស់អ្នកមិនមាន អ្វីជាខ្លឹមជាសារៈបានឡើយ ហើយតាមដែលអ្នកធ្លាប់បានពោលថា មិនថាអ្នកណាក៏ដោយ ដែលយើងបាននឹងលើកវាទៈជាមួយអ្នកនោះ នឹងត្រូវមានអាការៈតក់ស្លុត ភិតភ័យ បែកញើសហូរចេញមក ឥឡូវ នេះ តថាគតជាអ្នកលើកវាទៈជាមួយអ្នក តែតថាគតក៏មិនឃើញមាន

ញើសហូរមក អ្នកឯងត្រឡប់ជាអ្នកមានញើសហូរមក” សច្ចកៈក៏មិនអាចលើកបញ្ហាក់យ៉ាងណាបាន អង្គុយឱនមុខចុះស្ងៀម ក្នុងទីនោះ! ក្នុងទីបំផុតសច្ចកៈនិគ្រន្ថ ក៏បានទូលអារាធនាព្រះសម្មាសម្ពុទ្ធ ព្រមដោយសាវ័ក ឱ្យទៅទទួលចង្ហាន់នៅសំណាក់ របស់ខ្លួននៅថ្ងៃស្អែក។

រឿងនេះសម្តែងឱ្យឃើញថា តណ្ហាជាហេតុឱ្យអត្តវាទុបាទានកើត ដូចសច្ចកៈនិគ្រន្ថអ្នកមានការពេញចិត្តក្នុងខន្ធ៥ របស់ខ្លួនជាហេតុឱ្យកើតសេចក្តីយល់ឃើញខុសក្នុងខន្ធ ៥ របស់ខ្លួន ជាអត្តវាទុ-បាទាន ដូចដែលបានសម្តែងមកនេះ។

## លក្ខណាទិចតុក្កៈរបស់ ឧបាទាន

**១.គហណលក្ខណំ** មានការប្រកាន់មាំជាលក្ខណៈ

**២.អមុញ្ចនរសំ** មានការមិនលែងជាកិច្ច

**៣.តណ្ហាទឡ្ហត្តទិដ្ឋិបច្ចុប្បដ្ឋានំ** មានតណ្ហាដែលមានកម្លាំងយ៉ាងមាំ និងមានសេចក្តីយល់ខុស ជាអាការប្រាកដ

**៤.តណ្ហាបទដ្ឋានំ** មានតណ្ហាជាហេតុជិត

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា
## តណ្ហាប្បច្ចយា ឧបាទានំ

១.តណ្ហាដែលកើតមុនៗ ជាបច្ច័យជួយឧបការៈដល់កាមុបាទាន ដែលកើតក្រោយៗនោះ បានដោយអំណាចបច្ច័យ ១ គឺ បកតូបនិស្សយបច្ច័យ ។

២.តណ្ហាដែលកើតមុនៗ ជាបច្ច័យជួយឧបការៈដល់ទិដ្ឋុប្បាទាន សីលព្វតុបាទាន អត្តវាទុបាទាន ដែលកើតព្រមគ្នាជាមួយខ្លួននោះបានដោយអំណាចបច្ច័យ ៧ គឺ :

១.ហេតុប្បច្ច័យ ២.សហជាតប្បច្ច័យ ៣.អញ្ញមញ្ញប្បច្ច័យ ៤.សហជាតនិស្សយប្បច្ច័យ ៥. សម្បយុត្តប្បច្ច័យ ៦.សហជាតត្ថិប្បច្ច័យ ៧.សហជាតអវិគតប្បច្ច័យ ។

៣.តណ្ហាដែលកើតមុនៗ ជាបច្ច័យជួយឧបការៈដល់ឧបាទាន ៣ (វៀរកាមុបាទាន) ដែលកើតក្រោយៗនោះ បានដោយអំណាចបច្ច័យ ១ គឺ បកតូបនិស្សយប្បច្ច័យ ។

**ចប់ តណ្ហាប្បច្ចយា ឧបាទានំ**

## ៩-ឧបាទានប្បច្ចយា ភវោ សម្ភវតិ

ភព រមែងប្រាកដកើតឡើងព្រោះអាស្រ័យ ឧបាទាន ជាហេតុ ឧបាទាន ដែលជាហេតុឱ្យកើតភព បានដល់ ឧបាទាន ៤ មាន កាមុបាទាន ជាដើមដូចដែលបានសម្ដែងហើយនោះឯង ។

## ភវៈ មាន ២ យ៉ាង

**១.កម្មភវៈ** ការតាក់តែងដែលធ្វើឱ្យផលកើតឡើង បានដល់ អកុសលចេតនា ១២ លោកិយកុសលចេតនា ១៧ រួមចេតនា ២៩ ។

**២.ឧបត្តិភវៈ** ផលដែលកើតឡើងក្នុងភពនោះៗ ដោយអាស្រ័យ កម្មភវៈ បានដល់ លោកិយវិបាកចិត្ត ៣២ ចេតសិក ៣៥ កម្មជរូប ២០ ។

កាលបើពោលដោយបុគ្គលាធិដ្ឋាន កម្មភវៈ បានដល់ការធ្វើដោយ កាយ វាចា ចិត្ត ក្នុងវត្ថុដែលល្អ និងមិនល្អរបស់បុគ្គលទូទៅ (វៀរព្រះអរហន្ត) ។

**ឧប្បត្តិភវៈ** បានដល់ សត្វទាំងឡាយដែលនៅក្នុងភូមិ ៣១ ព្រមទាំងការឃើញ ការឮ ការដឹងក្លិន ការដឹងរស ជាដើម ។

## វចនត្ថៈរបស់ពាក្យថា ភវៈ

**១.ភវតិ ឯតស្មាតិ = ភវោ** ផលរមែងកើតឡើងដោយអាស្រ័យ កម្មនោះ ព្រោះហេតុនោះ កម្មដែលជាហេតុរបស់ផលនោះ ទើបឈ្មោះ ថា **កម្មភវៈ** ។

**២.កម្មមេវ ភវោ = កម្មភវោ** កម្មនោះឯងជាហេតុឱ្យកើតផល ព្រោះហេតុនោះ ទើបឈ្មោះថា កម្មភវ បានដល់ អកុសលចេតនា ១២ លោកិយកុសលចេតនា ១៧ ។

**៣.ឧបជ្ជតីតិ = ឧប្បត្តិ** ធម្មជាតិណាវមែងចូលទៅកើតក្នុងភពថ្មី ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **ឧប្បត្តិ** ។

**៤.ភវតីតិ = ភវោ** ធម្មជាតិណាបានកើតឡើងព្រោះអាស្រ័យកម្ម ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថា **ភវៈ** ។

**៥.ឧប្បត្តិ ច សា ភវោ ចាតិ = ឧប្បត្តិភវោ** ធម្មជាតិណាចូលទៅកើតក្នុងភពថ្មីផងបានកើតឡើងព្រោះអាស្រ័យកម្មផង ព្រោះហេតុនោះធម្មជាតិនោះទើបឈ្មោះថា **ឧប្បត្តិ** បានដល់ លោកិយវិបាកចិត្ត ៣២ ចេតសិក ៣៥ និងកម្មជរូប ២០ ។

## ចែកកម្មភវៈដោយទ្វារ

កម្មភវៈនេះ បើចែកដោយទ្វារមាន ៣ គឺៈ

១.កម្មភវៈដែលកើតផ្លូវកាយ ឈ្មោះថាកាយកម្ម បានដល់ អកុសលកម្ម ១២ និងមហាកុសលកម្ម ៨ ។

២.កម្មភវៈដែលកើតតាមផ្លូវវាចា ឈ្មោះថា វចីកម្ម បានដល់ អកុសលកម្ម ១២ និងមហាកុសលកម្ម ៨ ។

៣.កម្មភវៈដែលកើតផ្លូវចិត្ត ឈ្មោះថា មនោកម្ម បានដល់ អកុសលកម្ម ១២ មហាកុសលកម្ម ៨ និងមហគ្គតកុសលកម្ម ៩ ។

ឧប្បត្តិភវៈ មាន ៩ គឺៈ

## ពោលដោយភូមិ

១.កាមភវៈ បានដល់ កាមវិបាកចិត្ត ២៣ ចេតសិក ៣៣ កម្មជរូប ២០

២.រូបភវៈ បានដល់ រូបវិបាកចិត្ត ៥ ចក្ខុវិញ្ញាណ ២ សោតវិញ្ញាណ ២ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ចេតសិក ៣៥ កម្មជរូប ១៥ ។

៣.អរូបភវៈ បានដល់ អរូបវិបាកចិត្ត ៤ ចេតសិក ៣០ ។

## ពោលដោយចិត្ត

៤.សញ្ញីភវៈ បានដល់ លោកិយវិបាកចិត្ត ៣១( វៀរនេវសញ្ញា-នាសញ្ញាយតនវិបាក ) ចេតសិក ៣៥ កម្មជរូប ២០ ។

៥.អសញ្ញីភវៈ បានដល់ ជីវិតនវកកលាបៈ( មិនមានចិត្ត) ។

៦.នេវសញ្ញីនាសញ្ញីភវៈ បានដល់ នេវសញ្ញានាសញ្ញាយតន វិបាកចិត្ត ១ ចេតសិក ៣០ ។

## ពោលដោយខន្ធ

៧.ឯកវោការភវៈ បានដល់ ជីវិតនវកលាប ។

៨.ចតុវោការភវៈ បានដល់ អរូបវិបាកចិត្ត ៤ ចេតសិក ៣០ ។

៩.បញ្ចវោការភវៈ បានដល់ កាមវិបាកចិត្ត ២៣ រូបវិបាកចិត្ត ៥ ចេតសិក ៣៥ កម្មជរូប ២០ ។

ឬន័យម្យ៉ាងទៀត ឧប្បត្តិភវៈមាន ៩ គឺៈ

**១.នានត្តកាយនានត្តសញ្ញីភវៈ** បានដល់ សត្វដែលកើតនៅក្នុងកាមសុគតិភូមិ ៧ ។

**២.នានត្តកាយឯកត្តសញ្ញីភវៈ** បានដល់ សត្វដែលកើតនៅក្នុងអបាយភូមិ ៤ និងបឋមជ្ឈានភូមិ៣ ។

**៣.ឯកត្តកាយនានត្តសញ្ញីភវៈ** បានដល់ សត្វដែលកើតនៅក្នុងទុតិយជ្ឈានភូមិ ៣ ។

**៤.ឯកត្តកាយឯកត្តសញ្ញីភវៈ** បានដល់ សត្វដែលកើតនៅក្នុងតតិយជ្ឈានភូមិ ៣ និងចតុត្ថជ្ឈាន ។

**៥.អសញ្ញីភវៈ** បានដល់ សត្វដែលកើតនៅក្នុងអសញ្ញីសត្តាភូមិ ។

**៦.អាកាសានញ្ចាយតនភវៈ** បានដល់សត្វដែលកើតនៅក្នុងអាកា-សាណញ្ចាយតនភូមិ ។

**៧.វិញ្ញាណញ្ចាយតនភវៈ** បានដល់សត្វដែលកើតនៅក្នុងវិញ្ញាណ-ញ្ចាយតនភូមិ ។

**៨.អាកិញ្ចញ្ញាយតនភវៈ** បានដល់ សត្វដែលកើតនៅក្នុង អាកិញ្ច-ញ្ញាយតនភូមិ ។

**៩.នេវសញ្ញានាសញ្ញាយតនភវៈ** បានដល់ សត្វដែលកើតនៅក្នុង នេវសញ្ញានាសញ្ញាយតនភូមិ ។

## សម្តែងឧប្បត្តិភវៈ ៩ ដោយបុគ្គលាធិដ្ឋាន

**១.កាមភវៈ** បានដល់ អបាយសត្វមានតិរច្ឆាន មនុស្ស ទេវតា ជាដើម ។

**២.រូបភព** បានដល់ រូបព្រហ្មទាំងឡាយ ។

**៣.អរូបភព** បានដល់ អរូបព្រហ្មទាំងឡាយ ។

**៤.សញ្ញីភព** បានដល់ អបាយសត្វ មនុស្ស ទេវតា រូបព្រហ្ម អរូបព្រហ្ម ( វៀរនេវសញ្ញានាសញ្ញាយតនព្រហ្ម) ។

**៥.អសញ្ញីភព** បានដល់ អសញ្ញសត្តព្រហ្ម ។

**៦.នេវសញ្ញីនាសញ្ញីភវៈ** បានដល់ នេវសញ្ញានាសញ្ញាយតនព្រហ្ម ។

**៧.ឯកវោការភព** បានដល់ អសញ្ញសត្តព្រហ្ម ។

**៨.ចតុវោការភព** បានដល់ អរូបព្រហ្ម ។

**៩.បញ្ចវោការភព** បានដល់ អបាយសត្វ មនុស្ស ទេវតា រូបព្រហ្ម ។

ឧប្បត្តិភវៈទាំង ៩ ដូចដែលបានសម្ដែងមកហើយនេះបើសង្ខេប បាន ៣ គឺ ១.កាមភព ២.រូបភព ៣.អរូបភព ។

កម្មភវៈនិងឧប្បត្តិភវៈទាំង ២ ដែលពោលហើយនេះ ប្រាកដកើតឡើងបានព្រោះអាស្រ័យឧបាទានទាំង ៤ ជាហេតុ និងភវៈទាំង ២ នេះ ក៏ជាហេតុជាផលដល់គ្នានិងគ្នាបាន ពោលគឺៈ

ប្រសិនបើពោលដល់កាលដែលជាអនាគត កម្មភវៈជាហេតុ ឧប្បត្តិភវៈជាផល មានន័យថា សត្វទាំងឡាយដែលជាឧប្បត្តិភវៈនោះប្រាកដឡើងបានព្រោះអាស្រ័យការប្រព្រឹត្តផ្សេងៗ ដោយកាយ វាចា ចិត្ត ដែលជាអកុសលកម្មភវៈ និងលោកិយកុសលកម្មភវៈជាហេតុ នេះចាត់ជាជនកៈហេតុដូចដែលអដ្ឋកថាចារ្យសម្ដែងទុកក្នុង សម្មោហវិនោទនីថា :

**តត្រស្ស ឧប្បត្តិហេតុ ភូតំ កម្មំ កម្មភវោ កម្មនិព្វត្តា ខន្ធា ឧប្បត្តិភវោ** ក្នុងភវៈទាំង ២ យ៉ាងនោះ អកុសលកម្ម និងលោកិយកុសលកម្មចេតនា ដែលជាហេតុនៃការកើតឡើងរបស់សត្វទាំងឡាយនោះ ឈ្មោះថា កម្មភវៈ ខន្ធ ៥ ដែលកើតឡើងដោយអាស្រ័យកម្មភវៈនោះ ឈ្មោះថា ឧប្បត្តិភវៈ ។

ប្រសិនបើ ពោលដល់កាលដែលជាបច្ចុប្បន្ន ឧប្បត្តិភវៈជាហេតុ កម្មភវៈជាផលព្រោះការងារទាំងឡាយដែលទាក់ទងដោយកាយ វាចា

ចិត្ត ប្រាកដឡើងបានក៏ព្រោះអាស្រ័យសត្វទាំងឡាយដែលជាឧប្បត្តិភវៈ ជាហេតុ ដោយហេតុនេះ បណ្ឌិតទាំងឡាយបានឱ្យពាក្យណែនាំថា

**អមតំ មិយ្យមានេន ជរមានេន និជ្ជរំ**

**និព្វុតំ តបមានេន និមេយ្យ ពោន្ទិនា សិវំ**

អ្នកឆ្លាត គួរព្យាយាមយករាងកាយដែលមានសេចក្ដីស្លាប់ មិនមានទីបំផុតនោះដូរជាមួយព្រះនិព្វានដែលមានសន្តិ មិនមានការ ស្លាប់ ប្រៀបដូចអ្នកជំនួញយកទំនិញធម្មតាទៅប្ដូរយកមាស ។

បុគ្គលឆ្លាត គួរព្យាយាមយករាងកាយដែលមានការចាស់មិនមានទីបំផុតនោះដូរជាមួយព្រះនិព្វានដែលមានសន្តិមិនមានការចាស់ ប្រៀបដូចអ្នកជំនួញយកទំនិញធម្មតាទៅប្ដូរយកមាស ។

បុគ្គលឆ្លាត គួរព្យាយាមយករាងកាយដែលមានការក្ដៅក្រហាយដោយកិលេសជានិច្ចនោះ ដូរជាមួយព្រះនិព្វានដែលមានសន្តិ មិនមានការក្ដៅក្រហាយដោយកិលេសជានិច្ច ប្រៀបដូចអ្នកជំនួញយកទំនិញធម្មតាទៅប្ដូរយកមាស ។

## ការកើតឡើងរបស់កម្មភវៈនិងឧប្បត្តិភវៈ ដោយអាស្រ័យភាវុបាទាន

តាមធម្មតាចិត្តរបស់បុថុជ្ជនទាំងឡាយនោះ រមែងចូលចិត្តប្រកាន់ទុកក្នុងការឃើញរបស់ខ្លួនជាធំ មិនចាំបាច់មានការពិចារណាដល់

ហេតុផលដែលសមគួរ ដូចការប្រព្រឹត្តរបស់មនុស្សអត់សតិ សមដូចដែលពោលទុកថា **បុថុជ្ជនោ ឧម្មត្តកោ វិយ** ការរស់នៅរបស់បុថុជ្ជននោះប្រៀបដូចមនុស្សឆ្កួតដូច្នោះ ក្នុងការប្រព្រឹត្តផ្សេងៗ របស់ជនទាំងឡាយដែលមានសេចក្តីសង្ឃឹមដល់សេចក្តីសុខ សេចក្តីសប្បាយក្នុងមនុស្សនិងទេវតា ដោយអំណាចនៃកាមុបាទាននោះ ពួកខ្លះជឿកាន់យកក្នុងពាក្យណែនាំប្រៀនប្រដៅរបស់អាចារ្យដែលជាមិច្ឆាទិដ្ឋិ អ្នកមិនធ្លាប់សិក្សាក្នុងព្រះវិន័យ ព្រះសូត្រ និង ព្រះអភិធម្ម រមែងប្រព្រឹត្តការងារដែលទាក់ទងជាមួយនឹងទុច្ចរិត មានការសម្លាប់សត្វលួចទ្រព្យ សេពសុរាជាដើម ហើយធ្វើគ្រឿងបូជាបួងសួងពីវត្ថុស័ក្តិសិទ្ធផ្សេងៗ ការប្រព្រឹត្តដូច្នេះជាអកុសលកម្មភវៈដែលកើតឡើងដោយអាស្រ័យកាមុបាទានជាហេតុ បុគ្គលពួកនេះបើលះចាកពីលោកនេះហើយ រមែងទៅកើតក្នុងអបាយភូមិ ៤ ដែលជាឧប្បត្តិភវៈមយ៉ាង ។

បុគ្គលពួកខ្លះ ក៏កាន់ជឿតាមពាក្យប្រៀនប្រដៅរបស់គ្រូអាចារ្យដែលមានការយល់ឃើញត្រូវ ក៏បដិបត្តិក្នុងការងារដែលទាក់ទងជាមួយទាន សីល ភាវនាដែលជាកុសលកម្មភវៈអាស្រ័យកាមុបាទានជាហេតុ ។

បុគ្គលពួកនេះ កាលបើលះចាកពីលោកនេះហើយ រមែងទៅកើតក្នុងសុគតិភូមិ ជាមនុស្សទេវតា ដែលជាឧប្បត្តិភវៈមយ៉ាង ។

បុគ្គលពួកខ្លះក៏បានទទួលការអប់រំណែនាំថា ការធ្វើសមថៈ រហូតបាន ឈានដោះ អាចធ្វើឱ្យទៅកើតជារូបព្រហ្ម អរូបព្រហ្មបាន ទទួល សេចក្ដីសុខកាយ សុខចិត្ត ពិសេសជាងសេចក្ដីសុខក្នុងមនុស្ស និងទេវតា កាលបើបានទទួលការណែនាំដូច្នេះហើយ ក៏ព្យាយាមចម្រើនសមថ កម្មដ្ឋាន រហូតបានដល់រូបឈានខ្លះ អរូបឈានខ្លះ ដែលជាកុសល កម្មភវៈអាស្រ័យកាមុបាទានជាហេតុ បុគ្គលពួកនេះកាលបើ លះលោក នេះហើយ រមែងទៅកើតក្នុងរូបភូមិ អរូបភូមិ ដែលជាឧប្បត្តិ ភវៈម្យ៉ាង ។

## ការកើតឡើងរបស់កម្មភវៈនិងឧប្បត្តិភវៈ ដោយអាស្រ័យទិដ្ឋុបាទាន

អ្នកដែលមានការយល់ឃើញខុស ជានិយតមិច្ឆាទិដ្ឋិយ៉ាងណាមួយ គឺៈ

**១.នត្ថិកទិដ្ឋិ** មានការយល់ឃើញថា ធ្វើអ្វីក៏ដោយ ផលដែលបាន ទទួលខាងមុខនោះមិនមាន ដូចជា ក្នុងអន្តគ្គាហិកទិដ្ឋិ ១០ ជាដើម និង អ្នកដែលមាននត្ថិកទិដ្ឋិនេះ នឹងត្រូវមានឧច្ឆេទទិដ្ឋិផងគឺឃើញថា សត្វ ទាំងឡាយស្លាប់ហើយត្រូវសូន្យ ។

**២.អហេតុកទិដ្ឋិ** មានការយល់ឃើញថា សត្វទាំងឡាយ ដែល កំពុងបានទទួលសេចក្ដីលំបាក ឬសប្បាយក៏ដោយ មិនមានអាស្រ័យអ្វី ជាហេតុឱ្យកើតឡើងលំបាក ឬសប្បាយទាំងនេះកើតឡើងដោយឯង ។

**៣.អកិរិយទិដ្ឋិ** មានការយល់ឃើញថា សត្វទាំងឡាយ ធ្វើល្អក៏ដោយ ធ្វើអាក្រក់ក៏ដោយ មិនជាហេតុធ្វើឱ្យផលកើតខាងមុខ ផលដែលបានទទួលខាងមុខមិនមាន សូម្បីធ្វើល្អឬមិនល្អយ៉ាងណាក៏មិនហៅថា ធ្វើល្អ ធ្វើអាក្រក់ អ្នកដែលធ្វើខ្លួនឯងក្តី ប្រើឱ្យគេធ្វើក្តីក៏មិនហៅថាធ្វើដូចគ្នា។

អ្នកដែលមានការយល់ឃើញខុសដូចដែលពោលមកនេះ ឈ្មោះថាទិដ្ឋុបាទាន ។ បុគ្គលពួកនេះ រមែងប្រព្រឹត្តទៅតាមការពេញចិត្តរបស់ខ្លួន ចូលចិត្តប្រព្រឹត្តតាមផ្លូវអកុសលជាចំណែកច្រើន សមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា **បាបស្មឹ រមតី មនោ** តាមធម្មតាចិត្តរបស់ជនទាំងឡាយនោះ រមែងត្រេកអរក្នុងការងារជាអកុសលជានិច្ច ហើយអ្នកដែលមានទិដ្ឋុបាទាននេះរមែងហ៊ានធ្វើក្នុងវត្ថុដែលជាទុច្ចរិត មុខរបរអាក្រក់ផ្សេងៗ ដែលជាអកុសលកម្មភវៈដោយអាស្រ័យទិដ្ឋុបាទានជាហេតុ សូម្បីថាបុគ្គលពួកនេះធ្វើកុសលខ្លះក៏ប្រព្រឹត្តទៅបានព្រោះអាស្រ័យកាមុបាទានជាហេតុ គឺសង្ឃឹមចង់បានកិត្តិយស កេរ្តិ៍ឈ្មោះ និងសង្ឃឹមផលតបស្នងដែលជាប្រយោជន៍បច្ចុប្បន្នប៉ុណ្ណោះ ។

កុសលកម្មភវៈដែលកើតឡើងដោយអាស្រ័យទិដ្ឋុបាទានជាហេតុនោះ កើតឡើងបានតែចំពោះពួកដែលមានឧច្ឆេទទិដ្ឋិប៉ុណ្ណោះ។ ព្រោះ

បុគ្គលពួកនេះយល់ឃើញថា ខ្លួនស្លាប់ទៅហើយនឹងសួន្យក្នុងទេវភូមិ ឬ ព្រហ្មភូមិបានជាការល្អណាស់ បើឃើញដូច្នេះហើយ ក៏ធ្វើកុសល មាន ទាន សីល សមថៈ ភាវនា ឱ្យកើតឡើងដើម្បីសង្ឃឹមនូវការសួន្យអស់ ក្នុងភូមិដែលខ្លួនត្រូវការ ប្រសិនបើការធ្វើកុសលនោះ ប្រព្រឹត្តទៅ ដោយត្រឹមត្រូវបរិបូរណ៍ហើយ ក៏បានទៅកើតក្នុងទេវភូមិ ឬ រូបភូមិ អរូបភូមិ ដែលជាឧប្បត្តិភវៈបាន ប៉ុន្តែប្រសិនបើការធ្វើកុសលនោះ មិនបានដោយបរិបូណ៍ ក៏មិនអាចទៅកើតក្នុងរូបភូមិ អរូបភូមិបានទេ តែក៏គង់បានទៅកើតជាមនុស្ស ឬទេវតាដែលជាឧប្បត្តិភវៈប៉ុណ្ណោះ សម្រាប់កុសលកម្មភវៈនោះ កើតឡើងដោយអាស្រ័យ ទិដ្ឋុបាទាន បានទាំងអស់ ។

## ការកើតឡើងរបស់កម្មភវៈ និងឧប្បត្តិភវៈ ដោយអាស្រ័យសីលព្វតុបាទាន

អ្នកដែលកំពុងបដិបត្តិ ដូចជាសត្វគោ សត្វឆ្កែនោះដោយ ច្រើនមានសេចក្តីយល់ឃើញថា ដែលខ្លួនកំពុងបដិបត្តិយ៉ាងនេះ ជា ការដើរនូវក្នុងជួរផ្លូវរបស់សប្បុរស ដែលជាវត្ថុធ្វើបានដោយលំបាក នឹង មានការជឿស៊ប់ថា ការបដិបត្តិរបស់ខ្លួននេះនឹងផ្តល់ផលឱ្យខ្លួនទៅកើត ក្នុងទេវភូមិ ព្រហ្មភូមិ យ៉ាងពិតប្រាកដ ហើយមើលឃើញការ បដិបត្តិរបស់ជនដទៃ មានទាន សីល ភាវនាទាំងនោះ ថាជាការមិនត្រឹម

ត្រូវ ហើយបុគ្គលទាំងនោះ ក៏មិនអាចនឹងប្រព្រឹត្តបដិបត្តិដូចខ្លួនបាន ដោយហេតុនេះ បុគ្គលទាំងឡាយនេះទើបមិនអាចទៅកើតក្នុងទេវភូមិ និងព្រហ្មភូមិតាមសេចក្ដីប្រាថ្នាបាន ។

ការគិតឃើញរបស់បុគ្គលដែលប្រព្រឹត្តខុសផ្លូវដូច្នេះ រមែងជាមិច្ឆាធិមោក្ខគឺតួទិដ្ឋិដែលមានការសម្រេចចិត្តខុស និងជាទោសដែលមានការមើលងាយដល់ការបដិបត្តិរបស់អ្នកផ្សេង ការយល់ឃើញរបស់បុគ្គលនេះជាអកុសលកម្មភវៈដែលកើតឡើង ដោយអាស្រ័យសីលព្វតុបាទានជាហេតុ ។ បុគ្គលពួកនេះកាលនិងលះអំពីលោកនេះទៅហើយ រមែងទៅកើតក្នុងអបាយសត្វជាឧប្បត្តិភវៈម្យ៉ាង ។

បុគ្គលពួកខ្លះក៏មានការយល់ឃើញថា ការបដិបត្តិ ដូចគោ ឬដូចឆ្កែប៉ុណ្ណោះ ដែលអាចទម្លាយកិលេសដោយត្រង់ នឹងឱ្យសម្រេចបានការបដិបត្តិយ៉ាងដទៃ មានទាន សីល ភាវនា ទាំងនោះត្រឹមតែឱ្យបានទៅកើតក្នុងទេវភូមិ ព្រហ្មភូមិប៉ុណ្ណោះ តែការបដិបត្តិដូចនេះបដិបត្តិក្នុងមនុស្សភូមិ ទើបមានការសម្រេចបានដោយលំបាក ព្រោះមិនងាយស្រួល ប្រសិនបើបានបដិបត្តិ ក្នុងទេវភូមិ ឬ ព្រហ្មភូមិហើយនឹងសម្រេចជាព្រះអរហន្តបានងាយ កាលបើមានការយល់ឃើញដូច្នេះហើយ ក៏ព្យាយាមបំពេញទាន សីល ភាវនា ដែលជាកុសលកម្មភវៈ ដើម្បីឱ្យកើតក្នុងទេវភូមិ ព្រហ្មភូមិ អ្នកខ្លះបាន

បដិបត្តិដល់ឈាន អ្នកខ្លះក៏មិនបានដល់ឈាន អ្នកបដិបត្តិបានដល់ឈាននោះ កាលស្លាប់ហើយក៏បានទៅកើតជាព្រហ្ម អ្នកដែលមិនបានឈាននោះ កាលស្លាប់ហើយ ក៏ទៅកើតជាមនុស្ស ទេវតា ដែលជាឧប្បត្តិភវៈ ។

## ការកើតឡើងរបស់កម្មភវៈនិងឧប្បត្តិភវៈ ដោយអាស្រ័យអត្តវាទុបាទាន

អត្តវាទុបាទាននេះ កើតឡើងបានទូទៅដល់បុថុជ្ជនទាំងឡាយ ព្រោះបុគ្គលជំពូកនេះ មើលមិនឃើញការប្រព្រឹត្តទៅរបស់ខន្ធ ៥ ដែលជាសភាពអនត្តា ទៅថាជាតួខ្លួនយើង គេ សត្វ បុគ្គល ប្រុស ស្រី ពោលគឺមិនមានការដឹងក្នុងការឃើញ ការឮជាដើមថាក្នុងខណៈ ឃើញ ការឃើញនោះឯងជាយើង យើងជាអ្នកឃើញ ក្នុងខណៈឮ ការបានឮនោះឯងជាយើង យើងជាអ្នកឮ ក្នុងខណៈគិត ការគិតនោះឯងជាយើង យើងជាអ្នកគិត ក្នុងខណៈ ដេក ដើរ ឈរ អង្គុយ ការដេក ដើរ ឈរ អង្គុយនោះឯងជាយើង យើងជាអ្នកដេក ដើរ ឈរ អង្គុយ ការដឹង ការឃើញដូចពោលមកនេះ កើតឡើងពីអត្តវាទុបាទានទាំងអស់ ដោយហេតុនេះ ទើបឃើញបានថា ក្នុងការធ្វើកុសលនិងអកុសល ដែលមនុស្សទាំងឡាយធ្វើរាល់ថ្ងៃនេះ ក៏ព្រោះអាស្រ័យអត្តវាទុបាទាននោះជាហេតុ ដោយមានការនឹកគិតថា ខ្លួនយើងនេះមានសេចក្ដីសុខ

សេចក្ដីសប្បាយតិច ឬមានទ្រព្យសម្បត្តិមាសប្រាក់ កិត្តិយសកេរ្តិ៍-ឈ្មោះនៅតិច ត្រូវព្យាយាមឱ្យបានវត្ថុទាំងនេះមកឱ្យច្រើនឡើង ហើយក៏ធ្វើកុសលខ្លះ អកុសលខ្លះ តាមអធ្យាស្រ័យរបស់ខ្លួន ឬស្រេចតែការបានទទួលការអប់រំពីបិតា មាតា គ្រូអាចារ្យ ប្រសិនបើអ្នកណាមានអធ្យាស្រ័យមិនល្អ ឬមិនបានទទួលការអប់រំល្អ អ្នកនោះរមែងស្វែងរកវត្ថុដែលខ្លួនត្រូវការក្នុងផ្លូវមិនល្អ ជាទុច្ចរិត មិច្ឆាជីវៈ ដែលចាត់ជាអកុសលកម្មភវៈ ហើយបើអ្នកណាមានអធ្យាស្រ័យល្អ ឬបានទទួលការអប់រំល្អ អ្នកនោះរមែងរកវត្ថុដែលខ្លួនត្រូវការក្នុងផ្លូវល្អជាសុចរិត និងសម្មាជីវៈ មានការសាងទាន រក្សាសីល ចម្រើនសមថកម្មដ្ឋាន ដែលចាត់ជាកុសលកម្មភវៈ កាលលះលោកនេះហើយ រមែងបានទៅកើតជាមនុស្សខ្លះ ទេវតាខ្លះ រូបព្រហ្មខ្លះ អរូបព្រហ្មខ្លះ ដែលជាឧបត្តិភវៈ ។

## សភាពផ្សេងគ្នារវាងសង្ខារ និងកម្មភវៈ

សង្ខារដែលជាផលរបស់អវិជ្ជា (**អវិជ្ជាបច្ចយា សង្ខារា**) និងកម្មភវៈដែលជាផលរបស់ឧបាទាន (**ឧបាទានប្បច្ចយា ភវោ**) ទាំង ២ នេះកាលពោលដោយអង្គធម៌ហើយ បានដល់ចេតនា ២៩ ដែលក្នុងអកុសលចិត្ត ១២ និងលោកិយកុសលចិត្ត ១៧ ដូចគ្នា តែដែលផ្សេងគ្នានោះគឺ :

ក្នុងន័យអទ្ធា ៣ ចេតនា ២៩ ដែលកើតឡើងក្នុងអតីតភព ដែលជាហេតុឱ្យឧបាទានក្ខន្ធកើតឡើងក្នុងភពនេះ ឈ្មោះថា សង្ខារ ដូច មានបាលីសំដែងថា **អវិជ្ជា សង្ខារា អតីតោ អទ្ធា ។**

ចេតនា ២៩ ដែលកើតឡើងក្នុងបច្ចុប្បន្នភព ដែលជាហេតុឱ្យ ឧបាទានក្ខន្ធ កើតឡើងក្នុងភពខាងមុខ ឈ្មោះថា កម្មភវៈ ដូចមាន បាលីសំដែងថា **មជ្ឈេ អដ្ឋ បច្ចុប្បន្នោ អទ្ធា ។**

សម្រាប់ការសំដែងក្នុងអាការ ២០ គឺ ប្រភេទ២០នោះ ការ ប្រព្រឹត្តទៅរបស់សង្ខារនិងកម្មភវៈទាំង២ នេះមិនមានការផ្សេងគ្នាទេ ដោយ**កាល** ពោលគឺៈ ក្នុងអតីតហេតុ ៥ នោះ សង្ខារនិងកម្មភវៈ ក៏ចូលរួមនៅក្នុងធម៌ ដែលជាអតីតហេតុផងដូចគ្នា ដោយហេតុនេះ ទើបដឹងបានថា ការផ្សេងគ្នារវាងសង្ខារនិងកម្មភវៈ ដែលពោលដោយ កាលទើបមិនមានក្នុងទីនេះ តែសេចក្តីផ្សេងគ្នានោះមានដូចនេះគឺៈ

**បុព្វចេតនា** ដែលកើតមុនការធ្វើកុសល អកុសល ឈ្មោះថា **សង្ខារ**។

**មុញ្ចនចេតនា** ដែលកើតឡើងក្នុងខណៈកំពុងធ្វើកុសល អកុសល ឈ្មោះថា **កម្មភវៈ**។

ឬន័យម្យ៉ាងទៀត ក្នុងកុសល អកុសលជវនៈ ៧ ខណៈនោះ កុសល អកុសល ចេតនា ដែលកើតឡើងក្នុងជវនៈដួងទី ១ ដល់ដួងទី ៦ ឈ្មោះថា **សង្ខារ** ។

កុសល អកុសល ចេតនា ដែលកើតឡើងក្នុងជវនៈដួងទី ៧ ឈ្មោះថា **កម្មភវៈ** ។

## ន័យម្យ៉ាងទៀត

ចិត្ត ចេតសិក ដែលកើតព្រមគ្នាជាមួយ កុសល អកុសល ចេតនា ឈ្មោះថា **សង្ខារ** ។

កុសល អកុសល ចេតនាចេតសិក ឈ្មោះថា **កម្មភវៈ** ។ ដូចមានបាលីសម្ដែងថា

**សង្ខារា បុរចេតនា ភវោ តុ មុញ្ចសត្តមា**
**សព្វា វា ចេតនា ភវោ សង្ខារា សម្បយុត្តកា ។**

បុព្វចេតនាក្ដី ចេតនាដែលប្រកបជាមួយជវនៈមុន១ ៦ ខណៈក្ដី ឈ្មោះថា **សង្ខារ** ។

មុញ្ចនចេតនាក្ដី ចេតនាដែលប្រកបជាមួយវិញ្ញាណ នាមរូប សឡាយតនៈ ឈ្មោះថា **កម្មភវៈ** ។

ឬ អកុសល និងលោកិយកុសលចេតនាទាំងអស់ ឈ្មោះថា **កម្មភវៈ**

ចិត្ត ចេតសិក ដែលប្រកបជាមួយកុសល អកុសល ចេតនាទាំងនេះ ឈ្មោះថា **សង្ខារ** ។

## ឬន័យមួយទៀត

**សង្ខារ** បានដល់ កុសល អកុសល ចេតនាចេតសិក ។

**កម្មភវៈ** បានដល់ កុសល អកុសល ចេតនា ព្រមដោយនាមខន្ធ ៤ ដែលនៅសល់ ។

## ន័យមួយទៀត

**សង្ខារ** បានដល់ កុសល អកុសល ចេតនា ២៩ ដែលជាហេតុរបស់លោកិយវិបាកវិញ្ញាណដែលជាបដិសន្ធិ និងបវត្តិ ។

**កម្មភវៈ** បានដល់ កុសល អកុសល ចេតនា ២៩ ដែលជាហេតុរបស់លោកិយវិបាកវិញ្ញាណដែលជាបដិសន្ធិបវត្តិ និងអសញ្ញីភព ។

## លក្ខណាទិចតុក្កៈរបស់កម្មភវៈ

**១.កម្មលក្ខណោ** មានភាពជាកម្មជាលក្ខណៈ ។

**២.ភាវនរសោ** មានការធ្វើឱ្យកើតជាកិច្ច ។

**៣.កុសលាកុសលបច្ចុប្បដ្ឋានោ** មានភាពជាកុសល អកុសល ជាអាការប្រាកដ ។

**៤.ឧបាទានាបទដ្ឋានោ** មានឧបាទានជាបទដ្ឋាន ។

## លក្ខណាទិចតុក្កៈ របស់ឧប្បត្តិភវៈ

**១.កម្មផលលក្ខណោ** មានភាពជាផលរបស់កម្មជាលក្ខណៈ ។

**២.ភវនរសោ** មានការកើតឡើងជាកិច្ច ។

**៣.អព្យាកតបច្ចុប្បដ្ឋានោ** មានភាពជាអព្យាកតធម៌ ជាអាការប្រាកដ

**៤.ឧបាទានបទដ្ឋានោ** មានឧបាទានជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទ ឧបាទានប្បច្ចយា ភវោ

**១.កាមុបាទាន** ជាបច្ច័យជួយឧបការៈដល់កម្មភវៈ ដែលប្រកបជាមួយខ្លួននោះបានដោយអំណាចបច្ច័យ ៧ គឺៈ
១-ហេតុប្បច្ច័យ ២-សហជាតប្បច្ច័យ ៣-អញ្ញមញ្ញប្បច្ច័យ ៤-សហជាតនិស្សយប្បច្ច័យ ៥-សម្បយុត្តប្បច្ច័យ ៦-សហជាតត្ថិប្បច្ច័យ ៧-សហជាតអវិគតប្បច្ច័យ ។

**២. ទិដ្ឋុបាទាន** សីលព្វតុបាទាន អត្តវាទុបាទាន ទាំង ៣ នេះជាបច្ច័យជួយឧបការៈដល់កម្មភវៈ ដែលប្រកបជាមួយខ្លួននោះ បានដោយអំណាចបច្ច័យ ៧ គឺៈ

១-សហជាតប្បច្ច័យ ២-អញ្ញមញ្ញប្បច្ច័យ ៣-សហជាត-និស្សយប្បច្ច័យ ៤-មគ្គប្បច្ច័យ ៥-សម្បយុត្តប្បច្ច័យ ៦-សហ-ជាតប្បច្ច័យ ៧- សហជាតអវិគតប្បច្ច័យ ។

**៣.ឧបាទាន** ទាំង ៤ ជាបច្ច័យជួយឧបការៈដល់កម្មភវៈ ដែលកើតឡើងជាប់បន្តគ្នាជាមួយខ្លួនដោយមិនមានចន្លោះនោះ បានដោយអំណាចបច្ច័យ ៦ គឺៈ

១-អនន្តរប្បច្ច័យ ២-សមនន្តរប្បច្ច័យ ៣-អនន្តរូនិស្សយប្បច្ច័យ
៤-អាសេវនប្បច្ច័យ ៥-នត្ថិប្បច្ច័យ ៦-វិគតប្បច្ច័យ

**៤.ឧបាទាន** ទាំង ៤ ជាបច្ច័យជួយឧបការៈដល់កម្មភវៈនិងឧប្បត្តិភវៈ ដែលមិនបានកើតព្រមគ្នាជាមួយខ្លួន មានន័យថា តាមធម្មតា

អ្នកដែលមិនមានឧបាទានហើយនោះ ការប្រព្រឹត្តរបស់បុគ្គលនោះមិនជា កុសលអកុសលកម្មភវៈ កាលបើស្លាប់ពីលោកនេះហើយ ឧប្បត្តិភវៈគឺការ កើតជាសត្វតូចធំក៏រមែងមិនមាន តែការប្រព្រឹត្តរបស់សត្វទាំងឡាយ ដែលសម្រេចជាកុសលអកុសលកម្មភវៈក្តី កាលស្លាប់អំពីលោកនេះហើយ ទៅកើតជាសត្វតូចធំដែលជាឧប្បត្តិភវៈក្តី ទាំងនេះរមែងប្រព្រឹត្តទៅដោយ អំណាចនៃឧបាទានណាមួយ ដែលមានហើយក្នុងសន្តានរបស់សត្វនោះឯង ជាបច្ច័យ ដូច្នោះ ក្នុងការជួយឧបការរបស់ ឧបាទានទាំង ៤ ដល់ ភវៈទាំង ២ នេះ រមែងបានអំណាចបកតូបនិស្សយបច្ច័យតែម្យ៉ាង។

**៥.**ក្នុងខណៈដែលកុសលអកុសលកម្មភវៈ កើតឡើងដោយមាន ឧបាទានណាមួយ ជាអារម្មណ៍យ៉ាងសាមញ្ញ ខណៈនោះឧបាទានទាំង ៤ ណាមួយ ជាបច្ច័យជួយឧបការៈដល់កុសលអកុសលកម្មភវៈនោះបាន ដោយអំណាចបច្ច័យ ១ គឺ អារម្មណបច្ច័យ។

**៦.**ក្នុងខណៈដែលកុសលអកុសលកម្មភវៈ កើតឡើងដោយមាន ឧបាទានណាមួយ ជាអារម្មណ៍ពិសេស ខណៈដែលឧបាទានទាំង ៤ ណា មួយជាបច្ច័យជួយឧបការៈ កុសលអកុសលកម្មភវៈនោះ បានដោយ អំណាចបច្ច័យ ៣ គឺៈ

១-អារម្មណបច្ច័យ ២-អារម្មណាធិបច្ច័យ ៣-អារម្មណូបនិស្សយបច្ច័យ

**ចប់ ឧបាទានបច្ចយា ភវោ**

## ១០.ភវប្បច្ចយា ជាតិ សម្ភវតិ

ការកើតឡើងនៃលោកិយវិបាកចិត្ត ចេតសិក និងកម្មជរូប ប្រាកដកើតឡើងព្រោះអាស្រ័យកម្មភវៈជាហេតុ ។

ភវៈដែលជាបច្ច័យរបស់ជាតិដែលយកតែកម្មភវៈ ក៏ព្រោះការកើតឡើងនៃវិបាក និងកម្មជរូបដែលជាតួជាតិនោះ កើតឡើងបានដោយអាស្រ័យអកុសលកម្មនិងលោកិយកុសលកម្មប៉ុណ្ណោះ ដោយហេតុនេះ ភវៈក្នុងបទ **ភវប្បច្ចយា ជាតិ** ទើបបានដល់កម្មភវៈតែម្យ៉ាង។

**ជាតិ** គឺការកើតឡើងគ្រាដំបូងនៃលោកិយវិបាក និងកម្មជរូបដែលជាឧប្បត្តិភវៈ ក្នុងភូមិ ៣១ ដោយមានខន្ធ ១ ខ្លះ ខន្ធ ៤ ខ្លះ ខន្ធ ៥ ខ្លះ ។

ដូចមានវចនត្ថៈថា

**ជននំ = ជាតិ** ការកើតឡើងនៃខន្ធ ៥ ឈ្មោះថា ជាតិ

ន័យម្យ៉ាងទៀត

**ជាយន្តិ បាតុភវន្តិ ធម្មា ឯតាយាតិ = ជាតិ**

សង្ខារធម៌ទាំងឡាយ រមែងប្រាកដកើតឡើងដោយអាស្រ័យធម្មជាតិនោះ ឈ្មោះថា ជាតិ។

**ជាតិ** បើពោលដោយធម្មាធិដ្ឋាន មាន ២ យ៉ាងគឺៈ

១.**នាមជាតិ** ការកើតឡើងនៃវិបាកនាមក្ខន្ធ ៤

២.**រូបជាតិ** ការកើតឡើងនៃកម្មជរូប

បើពោលដោយកាល មាន ៣ គឺៈ

១.បដិសន្ធិកាល

២.សន្តតិកាល

៣.ខណិកកាល

ក្នុងកាល ៣ យ៉ាងនោះ ការកើតឡើងគ្រាដំបូង ក្នុងភពថ្មី របស់សត្វទាំងឡាយ ដែលស្លាប់ពីភពចាស់ ឈ្មោះថា **បដិសន្ធិកាល** បើពោលដោយ ធម្មាធិដ្ឋាន បានដល់ បដិសន្ធិចិត្ត ១៩ ចេតសិក ៣៥ កម្មជកលាបៈ ៣-៧-៤ ដែលកើតឡើងក្នុងបដិសន្ធិកាល ។

បន្ទាប់ពីបដិន្ធិកាលហើយ នាមធម៌និងរូបធម៌ដែលកើតថ្មីៗ ជាប់បន្តគ្នាមិនដាច់ខ្សែ អស់ថ្ងៃ អស់ខែ អស់ឆ្នាំ រហូតអស់ជីវិត ឈ្មោះថា **សន្តតិកាល** អង្គធម៌ បានដល់ ការជាប់បន្តគ្នានៃចិត្ត ចេតសិក រូបទាំងអស់ ។

ការកើតឡើង ១ ខណៈៗ របស់ចិត្តនីមួយៗ និង ការកើតឡើងមួយខណៈៗរបស់រូបកលាបនីមួយៗ ឈ្មោះថា **ខណិកកាល** បានដល់ ការកើតឡើងមួយខណៈៗរបស់ចិត្ត ចេតសិក រូប ទាំងអស់ ។

ពាក្យថា **ជាតិ** ក្នុងបទថា ***ភវប្បច្ចយា ជាតិ*** នេះ សំដៅយកបដិសន្ធិជាតិប៉ុណ្ណោះ។

**បដិសន្ធិជាតិ** នេះ បើពោលដោយកំណើតមាន ៤ គឺៈ

**១.ជលាពុជកំណើត** ការកើតឡើងក្នុងស្បូន

**២.អណ្ឌជកំណើត** ការកើតឡើងក្នុងស៊ុត

**៣.សំសេទជកំណើត** កំណើតដែលកើតក្នុងញើសក្អែល ឬក្នុងទីស្មោកគ្រោក អាប់អួ។

**៤.ឱបបាតិកកំណើត** ការកើតឡើងធំឯង ភ្លាមៗ

ពោលដោយខន្ធមាន ៣ គឺៈ

**១-បញ្ចវោការជាតិ** ការកើតឡើងនៃខន្ធ ៥

**២-ចតុវោការជាតិ** ការកើតឡើងនៃខន្ធ ៤

**៣-ឯកវោការជាតិ** ការកើតឡើងនៃរូបក្ខន្ធ ១

**ជាតិ** គឺការកើតឡើងរបស់សត្វទាំងឡាយក្នុងភូមិ ៣១ ដោយប្រការផ្សេងៗមានពួកអបាយសត្វ មនុស្ស ទេវតា ព្រហ្ម ទាំងនេះ ក៏ដោយសារតែជាប់កម្មភវៈ គឺការប្រព្រឹត្តដោយកាយ វាចា ចិត្ត ដែលជាកុសលខ្លះ អកុសលខ្លះ នោះឯង ព្រោះហេតុនោះ ទើបឃើញបានថា សត្វទាំងឡាយក្នុងលោកនេះ មិនមានអ្នកណាជាអ្នកបង្កើត ក្រៅអំពី កុសលកម្ម និង អកុសលកម្មទេ។

សមដូចដែលព្រះដ៏មានព្រះភាគសម្តែងថា

**កម្មំ សត្តេ វិភជ្ជតិ យទិទំ ហីនប្បណីតតាយ**

កម្មរមែងចែកសត្វទាំងឡាយឱ្យមានភាពថោកទាបនិងប្រណីត ។

ហើយព្រះមហាពុទ្ធឃោសាចារ្យ បានសម្តែងទុកថា

**តុល្យោបិ ពហិ ហេតុម្ហិ យមកានំ បយតុល្យតា**

**ន ចាញ្ញោ កម្មតោ តស្មា ញេយ្យោ សោ ជាតិបច្ចយោ។**

សូម្បីមានខ្សែលោហិតនិងអាហារ ដែលជាហេតុតែមួយ ដូចគ្នាតែទារកភ្លោះនោះក៏នៅមានវត្ថុផ្សេងគ្នាឱ្យឃើញបានពោលគឺ មនុស្សម្នាក់ជាប្រុស មនុស្សម្នាក់ជាស្រីក៏មាន បញ្ញាផ្សេងគ្នាក៏មាន ចំណុចនេះសម្តែងឱ្យឃើញថា ក្រៅអំពីកុសល និង អកុសលកម្មភវៈ ហើយក៏មិនមានហេតុផ្សេងណាទៀតដែលចាត់ចែងក្នុងការកើតរបស់សត្វទាំងឡាយ ព្រោះហេតុដូច្នោះ បណ្ឌិតទាំងឡាយគប្បីជ្រាប់កម្មភវៈនេះជាបច្ច័យរបស់ជាតិ ។

## លក្ខណាទិចតុក្កៈ របស់ជាតិ

**១.តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិលក្ខណា** មានការកើតឡើងជាគ្រាដំបូងក្នុងភពនោះៗជាលក្ខណៈ ។

**២.និយ្យាតនរសា** មានការប្រគល់ឱ្យនូវខន្ធ ៥ ជាកិច្ច

**៣.អតីតភវតោ ឥធ ឧម្មុជ្ជនបច្ចុបដ្ឋានា (វា) ទុក្ខវិចិត្តតាបច្ចុប-ដ្ឋានា** មានការកើតឡើងក្នុងភពនេះតអំពីភពមុន(ឬ) មានសភាពដែលពេញទៅដោយទុក្ខ ជាផល ។

**៤.ឧបចិតនាមរូបបទដ្ឋានា** មានការសន្សំនាមរូបជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា ភវប្បច្ចយា ជាតិ

កម្មភវៈ ជាបច្ច័យជួយឧបការៈដល់ជាតិនោះ បានដោយអំណាចបច្ច័យ ២ គឺៈ

១.បកតូបនិស្សយប្បច្ច័យ ២.នានក្ខណិកកម្មប្បច្ច័យ

<u>ចំណាំ</u> ក្នុងបទ **ភវប្បច្ចយា ជាតិ** នេះ ព្រះមូលដីកា យកកម្មភវៈ និង ឧប្បត្តិភវៈទាំង ២ ដោយលើកហេតុផលថា ជាតិនោះក៏គឺការកើតឡើងរបស់លោកិយវិបាក និងកម្មជរូបដែលជាឧប្បត្តិភវៈ នឹងមានក៏ដោយអាស្រ័យកម្មភវៈ ប្រសិនបើបាត់កម្មភវៈហើយ ឧប្បត្តិភវៈក៏មិនមាន ហើយប្រសិនបើឧប្បត្តិភវៈមិនមាន ជាតិក៏មិនមានដូចគ្នា ព្រោះហេតុដូច្នោះ ភវៈដែលជាបច្ច័យរបស់ជាតិទើបយកទាំងកម្មភវៈ និង ឧប្បត្តិភវៈ ។

តែសម្រាប់ព្រះអដ្ឋកថាចារ្យនោះ មិនយកឧប្បត្តិភវៈទេ ។

**១១.ជាតិប្បច្ចយាជរាមរណំ សោកបរិទេវទុក្ខទោមនស្សុ-បាយស្សា សម្ភវន្តិ.**

ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយស្សៈ ទាំង ៧ នេះ ប្រាកដកើតឡើងព្រោះអាស្រ័យជាតិជាហេតុ។

**ជរា** ដែលជាផលរបស់ជាតិនេះ បានដល់ ភពចាស់របស់លោកិយវិបាក និងកម្មជរូប គឺ បើវិបាកនិងកម្មជរូបកើតឡើងជាជាតិហើយ រមែងមានខណៈតាំងនៅ ដែលហៅថា ឋិតិ និង ឋិតិខណៈ របស់លោកិយវិបាកនិងកម្មជរូបនេះឯងឈ្មោះថា **ជរា** មានវចនត្ថៈថា

**ជរណំ = ជរា**

ការចាស់របស់វិបាកនាមក្ខន្ធ ៤ និង និប្ផន្នរូប ឈ្មោះថា **ជរា**

**មរណៈ** ដែលជាផលរបស់ជាតិនេះ បានដល់ អាការៈដែលកំពុងរលត់របស់លោកិយវិបាក និង កម្មជរូប ដែលហៅថា **ភង្គខណៈ ដូចមានវចនត្ថៈថា**

**មរីយតេ = មរណំ**

ការស្លាប់ គឺអាការៈដែលកំពុងរលត់របស់លោកិយវិបាក និងកម្មជរូប ឈ្មោះថា **មរណៈ**។

អង្គធម៌របស់ជរានិងមរណៈដែលបានពោលមកនេះ ដូចគ្នាជាមួយ អង្គធម៌របស់ជាតិដែរ ដូច្នេះក៏ព្រោះ ជាតិ ជរា មរណៈ ទាំង ៣ នេះ សង្គ្រោះចូលក្នុងវិបាកវដ្ដ ដូចក្នុងបាលីដែលសម្ដែងទុកខាងដើមថា **ឧប្បត្តិភវសង្ខាតោ ភវេកទេសោ អវសេសា ច វិបាកវដ្ដំ** ប្រែថា ភវៈមួយចំណែក គឺឧប្បត្តិភវៈ និង វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជរាមរណៈដែលនៅសល់ ទាំងនេះជាវិបាកវដ្ដៈ ។

សម្រាប់ក្នុងបដិច្ចសមុប្បាទ ដែលសម្ដែងតាមសុត្តន្តភាជនីយន័យ នោះ សម្ដែងទុកថាៈ **តត្ថ កតមា ជរា? យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា,**

**តត្ថ កតមំ មរណំ? យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាល-កិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ,**

ប្រែថា ក្នុងជរានិងមរណៈ ២ យ៉ាងនោះ ជរាតើដូម្ដេច? ការ ចាស់ សេចក្ដីគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញ ការអន់ថយនៃ

អាយុ ការថយទៅនៃឥន្ទ្រិយ៍ មានចក្ខុជាដើមក្នុងពួកសត្វនោះៗ របស់សត្វនោះៗ យ៉ាងនេះ ហៅថា **ជរា**។

ក្នុងជរានិងមរណៈទាំង ២ យ៉ាងនោះ មរណៈតើដូម្ដេច ? ការចុតិ ការរសាត់ទៅ ការបែកធ្លាយ ការបាត់ទៅ មរណៈ សេចក្ដីស្លាប់ ការធ្វើកាល ការបែកធ្លាយនៃខន្ធ ការបោះបង់ចោលសាកសព ការបាត់ទៅនៃជីវិតនោះៗ ហៅថា **មរណៈ**។

ព្រោះហេតុនោះ ពាក្យថា ជរានិងមរណៈ ក្នុងបដិច្ចសមុប្បាទនេះ សំដៅយកការចាស់និងការស្លាប់របស់សត្វទាំងឡាយ ដែលសម្មតិគ្នានៅក្នុងលោកនេះ គឺបន្ទាប់ពីជាតិការកើតឡើងជាដើមមករហូតដល់ស្លាប់ ហៅថា **ជរា** បានដល់ ការចាស់នៃលោកិយវិបាក កម្មជរូប ចិត្តជរូប ឧតុជរូប និង អាហារជរូប ។

**ដូចមានវចនត្ថៈថា**

**ជីរន្តិ ជិណ្ណភាវំ គច្ឆន្តិ ឯតាយាតិ = ជរា**

សង្ខារទាំងឡាយរមែងចូលដល់សភាពចាស់ ដោយអាស្រ័យធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិដែលជាហេតុនៃការចូលដល់សភាពចាស់នៃសង្ខារធម៌ទាំងឡាយនោះ ឈ្មោះថា **ជរា** ។

**មរន្តិ សត្តា ឯតេនាតិ = មរណំ**

សត្វទាំងឡាយរមែងស្លាប់ដោយអាស្រ័យធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិដែលជាហេតុនៃការស្លាប់របស់សត្វទាំងឡាយនោះ ឈ្មោះថា **មរណៈ** ។

## ជរា ៩ យ៉ាង

១.វយោវុទធិជរា ២.សន្តតិជរា ៣.ខណិកជរា

៤.បាកដជរា ៥.បដិច្ឆន្នជរា ៦.អវីចិជរា

៧.សវីចិជរា ៨.បរមត្ថជរា ៩.បញ្ញត្តិជរា ។

**១.វយោវុទធិជរា** បានដល់ ភាពជរាដែលកើតឡើងតាមលំដាប់ដោយមានអាការៈប្រាកដផ្សេងៗ ដូចជា ធ្មេញបាក់ សក់ ស្កូវ ស្បែកជ្រួញ ខ្នងកោង ជាដើម ។

**២.សន្តតិជរា** បានដល់សភាពចាស់នៃនាមរូបដែលកើតឡើង ជាប់បន្តគ្នារឿយៗ មិនដាច់ខ្សែ រហូតដល់ស្លាប់ ។

**៣.ខណិកជរា** បានដល់ ឋិតិខណៈរបស់រូបនឹងដែលប្រាកដកើតឡើងបន្តគ្នាដោយអាការៈដែលកើតឡើង តាំងនៅ រលត់ទៅ ដែលជាខណៈតូច ។

**៤.ខាកដជរា** គឺភាពជរាដែលប្រាកដច្បាស់ បានដល់ វយោវុទ្ធិជរានោះឯង។

**៥.បដិច្ឆន្នជរា** គឺភាពជរាដែលប្រក្រតីមិនអាចមើលឃើញបាន បានដល់ ភាពជរារបស់នាមធម៌។

**៦.អវីចិជរា** គឺភាពជរាដែលមិនមានស្នាមឱ្យដឹងបាន បានដល់ ការថយចុះរបស់កែវ ថ្ម ព្រះអាទិត្យ ព្រះចន្ទ ក្មេង ស្រីក្រមុំ ប្រុសកំលោះជាដើម។

**៧.សវីចិជរា** គឺសភាពចាស់ដែលមានស្នាមឱ្យដឹងបាន បានដល់ការអន់ថយរបស់រថ ផ្ទះ ស្ថានទីផ្សេងៗ វត្ថុផ្សេងៗ និងមនុស្សចាស់ សត្វចាស់ ដើមឈើចាស់ ជាដើម។

**៨.បរមត្ថជរា** បានដល់ ឋិតិខណៈរបស់នាមនិងរូប ដូចខណិកៈជរាដែរ។

**៩.បញ្ញត្តិជរា** បានដល់ ភាពជរាផ្សេងៗ ដែលក្រៅពីខណិកៈជរា។

ក្នុងបណ្ដាលជរាផ្សេងៗនោះ **វយោវុទធិជរា** បើពោលដោយវ័យមាន ៣ ឬ ១០។

## វ័យ ៣ យ៉ាង

**១.បឋមវ័យ** ក្នុងសម័យដែលកំណត់អាយុ ៧៥ ឆ្នាំដែលជាអាយុក្ខ័យនោះ រាប់ចាប់តាំងពីកើតមក រហូតដល់អាយុ ២៥ ឆ្នាំ ចាត់នៅក្នុងបឋមវ័យ។

២.ទុតិយវ័យ រាប់តាំងពីអាយុ ២៥ រហូតដល់ ៥០ ឆ្នាំ ចាត់ជាទុតិយវ័យ ។

៣.តតិយវ័យ រាប់តាំងពីអាយុ ៥០ ដល់ ៧៥ ឆ្នាំ ចាត់ជាតតិយវ័យ ។

**មាន ១០ នោះ គឺ:**

**១.មន្ទទសកវ័យ** វ័យទន់ខ្សោយ រាប់តាំងពីអាយុ ១ ដល់ ១០ ឆ្នាំ

**២.ខិឌ្ឌាទសកវ័យ** វ័យសប្បាយ រាប់តាំងពីអាយុ ១០ ដល់ ២០ ឆ្នាំ

**៣.វណ្ណទសកវ័យ** វ័យស្រស់ស្អាត រាប់តាំងពីអាយុ ២០ ដល់ ៣០ ឆ្នាំ

**៤.ពលទសកវ័យ** វ័យមានកម្លាំង រាប់តាំងពីអាយុ ៣០ ដល់ ៤០ ឆ្នាំ

**៥.បញ្ញាទសកវ័យ** វ័យមានបញ្ញា រាប់តាំងពីអាយុ ៤០ ដល់ ៥០ ឆ្នាំ

**៦.ហានិទសកវ័យ** វ័យអន់ថយ រាប់តាំងពីអាយុ ៥០ ដល់ ៦០ ឆ្នាំ

**៧.បព្ភារទសកវ័យ** វ័យដែលរាងកាយចាប់ផ្ដើមកោងងតិចៗ រាប់តាំងពីអាយុ ៦០ ដល់ ៧០ ឆ្នាំ

**៨.វង្កទសកវ័យ** វ័យដែលរាងកាយកោងងខ្លាំង រាប់តាំងពីអាយុ ៧០ ដល់ ៨០ ឆ្នាំ

**៩.មោមូហទសកវ័យ** វ័យវង្វេង រាប់តាំងពីអាយុ ៨០ ដល់ ៩០ ឆ្នាំ

**១០.សយនទសកវ័យ** វ័យដេកមិនក្រោកឡើង រាប់តាំងពីអាយុ៩០ ដល់ ១០០ ឆ្នាំ

វ័យទាំង ១០ ដែលពោលមកនេះ ជាការសំដែងតាមវ័យដែលកំណត់

អាយុ ១០០ឆ្នាំ ជាអាយុក្ខ័យ ប្រសិនបើសម័យដែលអាយុ-

ក្ខ័យ ចុះ វ័យទាំង ១០ នេះក៏ថយចុះតាមលំដាប់ ។

ក្នុងបដិច្ចសមុប្បាទនេះ ពាក្យថាជរា សំដៅយករបោរុទធិជរា និង បាកដជរា ។ ហើយជរាទាំង ២ នេះ ជាជរាដែលទាក់ទងជាមួយរូបធម៌ ប៉ុណ្ណោះ ក្នុងនាមធម៌មិនមានជរាប្រភេទនេះទេ ។

ធម្មតាអាយុរបស់រូបធម៌មួយរូបៗនោះ មានអាយុស្មើនិង អាយុរបស់ចិត្ត ១៧ ខណៈ ព្រោះហេតុដូច្នោះ បើពោលដោយ សភាវបរមត្ថហើយ រូបនោះចាស់ រូបទន់ខ្សោយ មិនមានឡើយ តែយើងឃើញថា សក់ស្កូវ ធ្មេញបាក់ ស្បែកជ្រួញជាដើម ក៏ជារឿង ដែលយើងសម្មតិគ្នាថា **ចាស់** នោះឯង ដោយហេតុនេះ បើវៀរ ខណិកជរា បដិច្ឆន្នជរា និងបរមត្ថជរាចេញហើយ ជរាក្រៅពីនោះ ក៏ជាបញ្ញត្តិជរាទាំងអស់ ។

ម្យ៉ាងទៀតជរា នេះជាវត្ថុដែលឃើញមិនបាន ព្រោះជាធម្មា-រម្មណ៍. ដែលឃើញថាសក់ស្កូវ ធ្មេញបាក់ជាដើមនោះ ក៏មិនមែនជាតួ ខ្លួនយើង ជាផលដែលកើតពីអំណាចនៃជរាម្យ៉ាងទៀត តែបុគ្គលទាំង-ឡាយបានឃើញសក់ស្កូវ ធ្មេញបាក់ជាដើមហើយក៏ដឹងថា អ្នកនេះ អ្នក នោះជរាហើយ ។

ប្រសិនបើសួរថា ហេតុអ្វីជរា មានសក់ស្កូវ ធ្មេញបាក់ជាដើមទើបប្រាកដដល់មនុស្សដែលមានអាយុច្រើនៗហើយ ចំណែកក្មេងៗនិងកំលោះក្រមុំនោះមិនប្រាកដ ដូចជាថា ភាពជរានេះមានចំពោះតែមនុស្សចាស់ប៉ុណ្ណោះ ក្មេងៗកំលោះក្រមុំមិនមាន ដូច្នេះព្រោះហេតុអ្វី? ចំណុចនេះឆ្លើយថា ធម្មតាជរានោះ រមែងមានដល់សត្វទាំង-ឡាយទូទៅ មិនថាជាមនុស្សចាស់ ក្មេង ឬកំលោះក្រមុំក៏ដោយ ហើយជរានេះមាននាទីធ្វើឱ្យរូបធម៌ ចូលដល់សភាពចាស់ដូចគ្នាទាំងអស់។ ក្មេងៗតូចៗដែលទើបធំរហូតដល់កំលោះក្រមុំនោះ ក៏ដោយអំណាចនៃជរា មនុស្សកំលោះក្រមុំដែលចម្រើនវ័យរហូតដល់ចាស់នោះ ដោយអំ-ណាចជរាដូចគ្នាព្រោះសភាពចាស់នេះចែកចេញជា ២ ប្រភេទគឺ ចាស់ឡើង ហៅថា **អភិកកាមជរា** ម្យ៉ាង ចាស់ចុះ ហៅថា **បដិកកម្មជរា** ម្យ៉ាង សម្រាប់ជរាដែលមាននៅក្នុងក្មេង តាំងពីវ័យមន្ទទសកៈ រហូតដល់ ពលទសកៈនោះ ជាភិកកម្មជរា គឺជរាដែលចាស់ឡើង ដោយហេតុនេះឯង ក្មេងៗតូចទើបធំឡើងតាមលំដាប់ រហូតដល់ទីបំផុតនៃអភិកកម្មជរាបន្ទាប់ពីនោះក៏ចាស់សន្សឹមៗជាលំដាប់ ប្រាកដអាការៈ ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញ ភ្នែកព្រិលជាដើម រហូតដល់ស្លាប់ ហៅថា បដិកកម្មជរា ដែលជាដូច្នេះព្រោះអំណាចនៃ ជិរណតេជោ ដែលដុតបំផ្លាញរូបធម៌ឱ្យមានអាការអន់ថយជាលំដាប់នោះឯង ។

ម្យ៉ាងទៀត អាការដែល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញ ភ្នែកងងឹតជាដើម ដែលជាវយោវុទធិជរា ទាំងនេះ រមែងមិនមានដល់ពួកទេវតានិងព្រហ្មទាំងឡាយនេះ ក៏ព្រោះពួកទេវតានិងព្រហ្មទាំង-ឡាយនោះមានកម្មជរូប ជាមូលដ្ឋានណែនជាងឧតុជរូប និងអាហារជរូប ចំណែកពួកមនុស្ស និងសត្វតិរច្ឆានទាំងឡាយ មានកម្មជរូបកើតតិចជាង ឧតុជរូប និងអាហារជរូប ព្រោះហេតុដូច្នោះ ទើបមានវយោវុទធិជរាកើតឡើងប្រាកដច្រើន ។

## មរណៈ ៩ យ៉ាង

**១.សម្មតិមរណៈ** បានដល់ ការស្លាប់របស់សត្វដែលសម្មតិហៅថា បុគ្គល "ក" ស្លាប់ បុគ្គល "ខ" ស្លាប់ ដើមឈើងាប់ជាដើម ។

**២.សន្តតិមរណៈ** បានដល់ ការរលត់ជាប់បន្តគ្នារបស់នាមរូប ដែលមានការផ្លាស់ប្តូរជារយៈៗ មិនតាំងគង់នៅកន្លែង ដូចរូបដែលកើតឡើងក្នុងវេលាមិនសប្បាយ នឹងកាលធូរស្រាលហើយ រូបមិនសប្បាយនោះក៏រលត់ទៅ រូបសប្បាយកើតឡើងថ្មី ហើយបើមានសេចក្តីខូចចិត្តពិបាក ចិត្តកើតឡើងតមកមានការសប្បាយចិត្តកើតឡើង សេចក្តីខូចចិត្ត និង ពិបាកចិត្តនោះក៏បាត់ទៅដូច្នេះជាដើម ។

**៣.ខណិកមរណៈ** បានដល់ សភាពរលត់ទៅរបស់នាមនិងរូបគ្រប់ៗ ភង្គខណៈ ។

**៤.សមុច្ឆេទមរណៈ** បានដល់ បរិនិព្វានរបស់ព្រះអរហន្តទាំងឡាយ ដែលមិនមានការកើតបន្តទៀត ។

**៥.ជាតិក្ខយមរណៈ** បានដល់ ការស្លាប់រលត់ក្នុងជាតិមួយ ៗ ។

**៦.ឧបក្កមមរណៈ** បានដល់ អាយុក៏នៅមិនទាន់អស់ កម្មក៏នៅមិនទាន់អស់ ប៉ុន្តែដល់នូវសេចក្តីស្លាប់ ដោយអាស្រ័យសេចក្តីព្យាយាមរបស់ខ្លួនឯង ឬអ្នកដទៃ ។

**៧.សរសមរណៈ** បានដល់ ការស្លាប់ដែលអស់អាយុនិងកម្ម ។

**៨.អាយុក្ខយមរណៈ** បានដល់ ការស្លាប់ដែលអស់អាយុ ប៉ុន្តែមិនទាន់អស់កម្ម ។

**៩.បុញ្ញក្ខយមរណៈ** បានដល់ ការស្លាប់ដែលអស់បុណ្យ សូម្បីនៅមិនទាន់អស់អាយុក៏ដោយ ។

ក្នុងបដិច្ចសមុប្បាទនេះ ពាក្យថា **មរណៈ** សំដៅយកសម្មតិមរណៈ ជាតិក្ខយមរណៈ ឧបក្កមមរណៈ សរសមរណៈ អាយុក្ខ-យមរណៈ បុញ្ញក្ខយមរណៈ ប៉ុណ្ណោះ ហើយតាំងពី ជាតិក្ខយមរណៈ រហូតដល់ បុញ្ញក្ខយមរណៈ ទាំង ៥ នេះបើពិចារណាមើលហើយក៏ចូលក្នុងសម្មតិមរណៈ នោះឯង ។

ជរានិងមរណៈ ដូចពោលមកនេះជាសភាវដែលជាអនិដ្ឋៈ ជាវត្ថុដែលគួរខ្លាចមិនគួរប្រាថ្នា តែមនុស្សគ្រប់ៗគ្នាមិនអាចលើកលែងបាន

ត្រូវជួបដូចគ្នាទាំងអស់ មិនមានផ្លូវដែលនិងអាចគេចចេញឱ្យផុតបានឡើយក្នុងភពនេះ ដូច្នេះក៏ព្រោះមានជាតិ គឺការកើតនោះឯង ជាដើមហេតុ បើអ្នកណាមានការសេចក្តីខ្លាច ជរា មរណៈ អ្នកនោះក៏ចាំបាច់ត្រូវរកផ្លូវទម្លាយជាតិចេញ ទើបផុតបាន ហើយវិធីដែលទម្លាយជាតិនេះ មានតែនៅក្នុងសាសនាព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ បានដល់ ការទម្លាយកម្មភវៈឱ្យអស់ ព្យាយាមធ្វើឱ្យកាយ វាចា ចិត្ត របស់ខ្លួនឱ្យចូលដល់ភាពជាកិរិយា គឺភាពជាព្រះអរហន្តនោះឯង ហើយការប្រព្រឹត្តដែលឱ្យសម្រេចជាកិរិយានោះ ក៏ត្រូវនៅក្នុងចន្លោះពេលដែលព្រះពុទ្ធសាសនាតាំងនៅ បើវៀរចាកព្រះពុទ្ធសាសនាហើយ ក៏គ្មានផ្លូវនឹងអាចរួចចាកទុក្ខឡើយ ប៉ុន្តែអកុសលកម្ម និងលោកិយកុសលកម្មដែលជាការប្រព្រឹត្តដែលឱ្យសម្រេចជាកុសលនោះធ្វើបានងាយ និងមានឱកាសច្រើន គឺធ្វើបានទាំងក្នុងវេលាដែល ព្រះពុទ្ធសាសនានៅមាន និងក្នុងវេលាដែលវៀរចាកព្រះពុទ្ធសាសនា ប៉ុន្តែការប្រព្រឹត្តដែលឱ្យកុសលអស់រលីងទៅនោះធ្វើបានលំបាក និងមានកំណត់ពេលវេលាគឺធ្វើបានចំពោះក្នុងវេលាដែលព្រះពុទ្ធសាសនា នៅមានតែប៉ុណ្ណោះ លោកឧបមាប្រៀបធៀបការសាងកុសលនេះ ដូចជាមនុស្សគ្រុនក្តៅលេបថ្នាំល្វីង ដែលតាមប្រក្រតីថ្នាំល្វីងមិនមានអ្នកណាចង់លេប ប៉ុន្តែអ្នកគ្រុនក្តៅត្រូវ ព្យាយាមលេបថ្នាំនោះ ក៏ព្រោះត្រូវការឱ្យជារោគ

ចំណុចនេះយ៉ាងណា លោកិយកុសលទាំងនេះក៏ប្រៀបដូចថ្នាំលាបដែរ អ្នកដែលត្រូវការរួចចាកពីកិលេស ត្រូវព្យាយាមសាងលោកិយកុសលឱ្យកើតឡើង ដើម្បីចាប់ផ្ដើមទម្លាយកិលេសជាលំដាប់ទៅ រហូតដល់បានសម្រេចជាព្រះអរហន្ត ការទម្លាយកិលេសអស់ ប្រៀបដូចមនុស្ស-គ្រុនដែលត្រូវការជាពីរោគ ព្យាយាមលេបថ្នាំនោះរឿយៗរហូតជារោគ បើរោគផ្សេងៗ ជាហើយ ក៏មិនចាំបាច់លេបថ្នាំតទៅទៀតឡើយ ដូចជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ របស់យើងពោលជាមួយទេវបុត្តមារ ក្នុងខណៈដែលព្រះអង្គកំពុងបដិបត្តិទុក្ករកិរិយា ដោយមានទេវបុត្តមារបានមកទូលថា សូមព្រះអង្គចូលព្យាយាមធ្វើខ្លួនឱ្យជាអ្នកមានអាយុវែង និងមានពេលវេលាកសាងកុសល មានការរក្សាសីល បូជាភ្លើងជាដើម ប្រសិនបើមកនៅក្នុងព្រៃ ហើយបដិបត្តិដូច្នេះក៏គ្មានប្រយោជន៍អ្វីឡើយ ទើបព្រះអង្គទ្រង់ត្រាស់តបជាមួយនឹងមារថា

**អនុមត្តោបិ បុញ្ញេន អត្ថោ មយ្ហំ ន វិជ្ជតិ**

**យេសញ្ច អត្ថោ បុញ្ញេន តេ មារោ វត្តុមរហតិ។**

ម្នាលមារ សេចក្ដីពេញចិត្តក្នុងសភាវៈដែលជាកុសល មិនមានដល់យើងសូម្បីតែបន្តិច អ្នកដែលមានបញ្ញាតិចប៉ុណ្ណោះដែលមានសេចក្ដីពេញចិត្តក្នុងភាពជាកុសល ព្រោះហេតុនោះ អ្នកគួរនិយាយពាក្យនេះជាមួយបុគ្គលដែលមានសេចក្ដីត្រេកអរក្នុងកុសលចុះ។

ម្យ៉ាងទៀត ក្នុងសច្ចវិភង្គអដ្ឋកថា ព្រះមហាពុទ្ធឃោសាចារ្យ សម្តែងឧបមាប្រៀបធៀបជាតិ ជរា មរណៈ ទាំង ៣ នេះដូចជាបុរស ៣ នាក់ ដែលរួមដៃគ្នាធ្វើការបោកបញ្ឆោទសត្រូវទៅសម្លាប់ បុរសទី ១ ទទួលនាទីដឹកនាំសត្រូវឱ្យចូលទៅក្នុងព្រៃ ដោយការពោលសរសើរភាពស្រស់ស្អាតតាមធម្មជាតិរបស់ព្រៃនោះឱ្យស្តាប់ សរសើររហូតធ្វើឱ្យចង់ទៅ ហើយក៏រំមែងទៅជាមួយបុរសម្នាក់នោះ កាលបើចូលបរិវេណព្រៃនោះហើយ បុរសទី ២ ក៏ធ្វើនាទីបៀតបៀនសត្រូវនោះ ឱ្យត្រូវរបួសអស់កម្លាំង ហើយបុរសទី ៣ ក៏ធ្វើនាទីប្រហារដោយយកកាំបិតអារកសត្រូវរហូតដល់ស្លាប់ ចំណុចនេះយ៉ាណា បុរសទី ១ ប្រៀបដូចជាតិ បុរសទី ២ ប្រៀបដូចជរា គឺបៀតបៀនខន្ធ ៥ របស់សត្វទាំងឡាយរឿយៗតាមលំដាប់ ដូចជាត្រូវសត្រូវប្រទូសឱ្យអស់កម្លាំង បុរសទី៣ប្រៀបដូចមរណៈ ដែលធ្វើឱ្យខន្ធ ៥ របស់សត្វទាំងឡាយបែករលត់ក្នុងភពនីមួយៗ ដូចគ្នាជាមួយនឹងសត្រូវយកកាំបិតមកប្រហារ ឱ្យស្លាប់ដូច្នេះ។

## លក្ខណាទិចតុក្កៈរបស់ ជរា

**១.ខន្ធបរិបាកលក្ខណា** មានការចាស់គ្រាំគ្រានៃខន្ធ ជាលក្ខណៈ។

**២.មរណូបនយនរសា** មានការបង្អោនទៅជិតសេចក្តីស្លាប់ជាកិច្ច។

**៣.យោព្វនវិនាសបច្ចុប្បដ្ឋានា** មានការទម្លាយនូវវ័យក្មេង ជាផល ។

**៤.បរិបច្ចនាមរូបបទដ្ឋានា** មានរូបដែលកំពុងចាស់ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់ មរណៈ

**១.ចុតិលក្ខណំ** មានការឃ្លាតចាកភព ជាលក្ខណៈ ។

**២.វិយោគរសំ** មានការព្រាត់ប្រាស់ ជាកិច្ច ។

**៣.គតិវិប្បវាសបច្ចុប្បដ្ឋានំ** មានការប្រាស់ចាកគតិជាផល ។

**៤.បរិភិជ្ជមាននាមរូបបទដ្ឋាន** មាននាមរូបដែលកំពុងរលត់ ជាហេតុជិត ។

## សង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា ជាតិប្បច្ចយា ជរា មរណំ

ជរា មរណៈ ដែលសម្ដែងតាមអភិធម្មភាជនីយន័យនោះ មិនមានបច្ច័យសង្គ្រោះទេ ព្រោះជរាក៏បានដល់ឋិតិខណៈរបស់រូបនិងនាម ហើយមរណៈក៏បានដល់ភង្គខណៈរបស់រូបនិងនាមដូចគ្នា ចំណែកជរា មរណៈដែលសម្ដែងតាមសុត្តន្តភាជនីយន័យនោះ មានបច្ច័យសង្គ្រោះបាន គឺ ជាតិជាបច្ច័យជួយឧបការដល់ ជរា មរណៈ នោះ បានដោយអំណាច ដោយបច្ច័យ ១ គឺ បកតូបនិស្សយប្បច្ច័យ ។

វចនត្ថៈរបស់ **សោកៈ**

**១.សោចនំ=សោកោ**

សេចក្តីសោកសៅ ឈ្មោះថា **សោកៈ** បានដល់ ទោមនស្សវេទនាដែលប្រកបជាមួយទោសមូលចិត្ត ២ ដួង ដែលកើតពីព្យសនៈ ៥ យ៉ាង ។

**ន័យម្យ៉ាងទៀត**

**សោចន្តិ ចិត្តបរិឡាហំ គច្ឆតិ ឯតេនាតិ = សោកោ**

សត្វទាំងឡាយរមែងមានសេចក្តីសោកសៅសេចក្តីក្តៅក្រហាយដោយអាស្រ័យធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិដែលជាហេតុនៃសេចក្តីសោកសៅ របស់សត្វទាំងឡាយនោះ ឈ្មោះថា សោកៈ បានដល់ ទោមនស្សវេទនាដែលប្រកបជាមួយទោសមូលចិត្ត ២ដួង ។

តាមធម្មតាសត្វទាំងឡាយដែលមានសេចក្តីសោកសៅ ខូចចិត្តកើតឡើង ក៏បានដល់សភាពរបស់សោកៈនោះឯង ហើយសោកៈកើតឡើងបាន ក៏ត្រូវអាស្រ័យមានហេតុដែលត្រូវឱ្យកើត ហេតុនោះក៏គឺព្យសនៈ ៥ យ៉ាង ។

**លក្ខណាទិចតុក្កៈរបស់ សោកៈ**

**១.អន្តោនិជ្ឈាយនលក្ខណោ** មានការដុតបំផ្លាញសភាពខាងក្នុងខ្លួនជាលក្ខណៈ ។

**២.ចេតសោ បរនិជ្ឈាយនរសោ** ធ្វើឱ្យចិត្តក្ដៅក្រហាយ ជាកិច្ច ។

**៣.អនុសោចនបច្ចុប្បដ្ឋានោ** មានសេចក្ដីសោកសៅរឿយៗជាផល ។

**៤.ទោសចិត្តុប្បាទបទដ្ឋានោ** មានទោសចិត្តុប្បាទ ជាហេតុជិត ។

វចនត្ថៈរបស់ **បរិទេវៈ**

**បរិទេវនំ = បរទេវោ** ការខ្សឹកខ្សួល ឈ្មោះថា **បរិទេវៈ**

ន័យម្យ៉ាងទៀត

**តំ តំ បវត្តឹ បរិកិត្តេត្វា ទេវន្តិ កន្ទន្តិ ឯតេនាតិ = បរិទេវោ**

សត្វទាំងឡាយរំពឹងដល់រឿងរ៉ាវផ្សេងៗហើយខ្សឹកខ្សួល ដោយអាស្រ័យធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិដែលជាហេតុនៃការខ្សឹកខ្សួលរបស់សត្វទាំងឡាយ ឈ្មោះថា បរិទេវៈ បានដល់ ចិត្តជ្ជ-រូបវិបល្លាសសទ្ទៈដែលកើតឡើង ដោយមានការខ្សឹកខ្សួល ព្រោះអាស្រ័យព្យសនៈ ៥ យ៉ាង ណានីមួយ ជាហេតុ ។

## លក្ខណាទិចតុក្កៈរបស់ បរិទេវៈ

**១.លាលប្បនលក្ខណោ** មានការខ្សឹកខ្សួល ជាលក្ខណៈ ។

**២.គុណទោសបរិកិត្តនរសោ** មានការពណ៌នាដល់គុណ និង ទោស ជាកិច្ច ។

**៣.សម្ភមបច្ចុប្បដ្ឋានោ** មានការក្រវល់ក្រវាយចិត្ត ជាផល ។

**៤.ទោសចិត្តមហាភូតបទដ្ឋានោ** មានមហាភូតរូបដែលកើតពីទោសចិត្តជាហេតុជិត ។

## វចនត្ថៈរបស់ ទុក្ខ

**ទុកុច្ឆិតំ ហុត្វា កាយិកសុខំ ខណតីតិ = ទុក្ខំ (វ៉ា) ទុក្ខមន្តិ=ទុក្ខំ**

ធម្មជាតិណាដែលជាទីគួរខ្ពើមនិងទម្លាយសេចក្តីសុខកាយព្រោះហេតុនោះធម្មជាតិនោះឈ្មោះថាទុក្ខ(ឬ)សត្វទាំងឡាយរមែងអត់ធន់បានដោយលំបាកពីវេទនាណា ដូច្នោះ វេទនានោះ ឈ្មោះ ថា **ទុក្ខ** ។

ន័យម្យ៉ាងទៀត **ខមិតុំ ទុក្ករន្តំ = ទុក្ខំ**

វេទនា ដែលអត់ធន់ដោយលំបាក ដូច្នោះ ឈ្មោះថា ទុក្ខ បានដល់ កាយិកទុក្ខវេទនា។

## សេចក្តីទុក្ខ ៩ យ៉ាង

**១.ទុក្ខទុក្ខ** សេចក្តីទុក្ខមានសភាពជាទុក្ខពិត។ បានដល់កាយិក - ទុក្ខវេទនា និង ចេតសិកទុក្ខវេទនា។

**២.វិបរិណាមទុក្ខ** បានដល់ កាយិកសុខវេទនា និង ចេតសិកសុខវេទនា ព្រោះសុខទាំង ២ នេះ ជាហេតុឱ្យកាយិកទុក្ខ និងចេតសិកទុក្ខកើតឡើងដោយ អាស្រ័យមានសេចក្តីវិបរិតប្រែប្រួល។

**៣.សង្ខារទុក្ខ** បានដល់ ឧបេក្ខាវេទនា និងចិត្ត ចេតសិក រូបដែលវៀរចាកទុក្ខទុក្ខ និងវិបរិណាមទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើតរលត់ជារឿយ ៗ ។

**៤.បដិច្ឆន្នទុក្ខ ឬ អបាកដទុក្ខ** បានដល់ ឈឺធ្មេញ ឈឺត្រចៀក ឈឺក្បាល ឈឺពោះជាដើមនិងការមិនសប្បាយចិត្ត ដែលកើតឡើងព្រោះអំណាច រាគៈ ទោសៈ ជាដើម ព្រោះទុក្ខប្រភេទនេះ នឹងដឹងបានក៏ត្រូវអាស្រ័យការសាកសួរ និងអាការដែលបៀតបៀននោះ ក៏មិនប្រាកដ ។

**៥.អប្បដិច្ឆន្នទុក្ខ ឬ បាកដទុក្ខ** បានដល់ ការឈឺដែលកើតអំពីមុខរបួសផ្សេងៗ និងសេចក្ដីទុក្ខកាយ ដែលបណ្ដាលមកពីការធ្វើកម្មករ ៣២ យ៉ាង ព្រោះទុក្ខប្រភេទនេះដឹងបានដោយមិនត្រូវមានការសាកសួរ និងអាការដែលបៀតបៀននោះក៏ប្រាកដជាក់ច្បាស់ ។

**៦.បរិយាយទុក្ខ** បានដល់ វិបរិណាមទុក្ខ សង្ខារទុក្ខ ព្រោះទុក្ខប្រភេទនេះមិនមែនជាតួទុក្ខដោយត្រង់ ជាទីកើតនៃទុក្ខផ្សេងៗ ។

**៧.និប្បរិយាយទុក្ខ** បានដល់ ទុក្ខ ទោមនស្សៈ ឧបាយាសៈ ដែលហៅថា ទុក្ខទុក្ខនោះឯង ។

**៨.កាយិកទុក្ខ** បានដល់ សេចក្ដីទុក្ខដែលកើតតាមផ្លូវកាយ មានឈឺធ្មេញ ឈឺពោះ ឈឺក្បាល និងរបួសផ្សេង ៧ ជាដើម ។

៩.ចេតសិកទុក្ខ បានដល់សេចក្តីទុក្ខដែលកើតតាមផ្លូវចិត្ត មានការខូចចិត្ត ព្រួយចិត្ត ខ្លាច ក្រោធជាដើម ។

ក្នុងបដិច្ចសមុប្បាទនេះ ពាក្យថា **ទុក្ខ** បានដល់ **កាយិកទុក្ខ**

**ការធ្វើកម្មករ ៣២ យ៉ាង ដែលឱ្យកើតសេចក្តីទុក្ខកាយ**

១.វាយដោយរំពាត់

២.វាយដោយរំពាត់ផ្តៅ

៣.វាយដោយដំបង

៤.កាត់ដៃ

៥.កាត់ជើង

៦.កាត់ទាំងដៃ ទាំងជើង

៧.កាត់ត្រចៀក

៨.កាត់ច្រមុះ

៩.កាត់ទាំងត្រចៀក ទាំងច្រមុះ

១០.ឱ្យធ្វើពិលង្គថាលិកកម្ម (យកក្បាលធ្វើជាឆ្នាំង)

១១.ឱ្យធ្វើសង្ខមុណ្ឌិកកម្ម ( ធ្វើក្បាលឱ្យរលីងដូចជាស័ង្ខ)

១២.ឱ្យធ្វើរាហុមុខកម្ម ( អំពើធ្វើមាត់ឱ្យដូចជាមាត់រាហុ)

១៣.ឱ្យធ្វើជោតិមាលិកកម្ម( អំពើធ្វើខ្លួនឱ្យដូចផ្កាភ្លើង)

១៤ ឱ្យធ្វើហត្ថប្បជោតិកកម្ម( អំពើយកភ្លើងដុតដៃ)

១៥. អំពើដូចជាការពន្ធាត់ស្បែកពពៃ

១៦.អំពើឱ្យដូចជាការស្លៀកសំពត់សំបកឈើ

១៧.អំពើដែលគេធ្វើឱ្យដូចជាសត្វទា

១៨.អំពើដែលគេផ្ដក់ដោយសន្ទូច

១៩.អំពើដែលគេធ្វើឱ្យខូចសរីរៈប៉ុន ១កហាបណៈ

២០.អំពើដែលគេយកទឹកផ្សាស្រោច

២១.អំពើដែលគេបង្វិលឱ្យដូចសសរគោល

២២.អំពើដែលគេធ្វើឱ្យដូចកណ្ដាប់ចំបើង

២៣.អំពើដែលគេស្រោចប្រេងដ៏ក្ដៅ

២៤.អំពើដែលគេប្រើឱ្យឆ្កែខាំ

២៥.យកដែកចាក់តាំងអំពីក្បាលទំលុះទ្វារ

២៦.ប្រើដាវកាត់ក្បាល

២៧.យកដែកគោលដុតភ្លើងដំត្រង់ដៃខាងស្ដាំ

២៨.យកដែកគោលដុតភ្លើងដំត្រង់ដៃខាងឆ្វេង

២៩.យកដែកគោលដុតភ្លើងដំត្រង់ជើងខាងស្ដាំ

៣០.យកដែកគោលដុតភ្លើងដំត្រង់ជើងខាងឆ្វេង

៣១.យកដែកគោលដុតភ្លើងដំត្រង់ដើមទ្រូង

៣២.អំពើដែលគេយកដាវកាត់ក្បាល ។

## លក្ខណាទិចតុក្កៈរបស់ ទុក្ខ

១. **កាយបីឡនលក្ខណំ** មានការបៀតបៀនរាងកាយជាលក្ខណៈ

២. **ទុប្បញ្ញានំ ទោមនស្សករណរសំ** មានការធ្វើទោមនស្ស ដល់អ្នកមានបញ្ញាតិច ជាកិច្ច ។

៣. **កាយិកាពាធបច្ចុប្បដ្ឋានំ** មានសេចក្តីឈឺផ្លូវកាយ ជាផល ។

៤. **កាយបសាទបទដ្ឋានំ** មានកាយបសាទជាហេតុជិត ។

សេចក្តីទុក្ខកាយនេះ ជាសេចក្តីទុក្ខពិសេស ព្រោះបៀតបៀនរាងកាយហើយបៀតបៀនផ្លូវចិត្តទៀតផង គឺ កាលបើរាងកាយមិនសប្បាយហើយ ភាពមិនសប្បាយនេះរមែងធ្វើឱ្យអ្នកនោះកើតសេចក្តីខូចចិត្ត និង ទោមនស្ស ព្រោះហេតុនោះ ព្រះមហាពុទ្ធឃោសាចារ្យទើបសម្តែងទុកក្នុងសច្ចៈវិភង្គអដ្ឋកថា និង វិសុទ្ធិមគ្គអដ្ឋកថាថា :

**បីលេតិ កាយិកមិទំ ទុក្ខញ្ច មានសំ ភិយ្យោ**

**ជនយតិ យស្មា តស្មា ទុក្ខន្តិ វិសេសតោ វុត្តំ។**

កាយិកទុក្ខ រមែងបៀតបៀនអ្នកដែលកំពុងបានទទួលសេចក្តីទុក្ខនេះ នឹងអាចធ្វើឱ្យទុក្ខចិត្តកើតឡើងបានច្រើន ដោយហេតុណាហេតុនោះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថាជាទុក្ខពិសេស ។

**វចនត្ថៈ ទោមនស្ស ទុមនស្ស ភាវោ = ទោមនស្សំ**

សភាពដែលជាហេតុឱ្យជាអ្នកមានចិត្តមិនល្អ ឈ្មោះថា ទោ-មនស្ស បានដល់ ចេតសិកទុក្ខគឺទុក្ខចិត្ត ។

សេចក្តីទោមនស្ស កាលបើកើតមានឡើងនឹងអ្នកណាហើយធ្វើឱ្យចិត្តអ្នកនោះក្តៅក្រហាយ មានកិរិយាអាការវិបរិតទាំងកាយនិងវាចា ហើយសេចក្តីទោមនស្សនេះរមែងជាហេតុ ឱ្យកាយិកទុក្ខកើតឡើងដល់ខ្លួនឯងនិងអ្នកដទៃបាន ដូចជា កាលបើទោមនស្សកើតឡើងហើយ បុគ្គលខ្លះក៏សម្តែងកិរិយាគក់ទ្រូងកញ្ជ្រោលចិត្តខ្លះ បោចសក់ខ្លះបុគ្គលខ្លះក៏ដល់នូវការសម្លាប់ខ្លួនដោយវិធីផ្សេងៗ ហើយបុគ្គលខ្លះ ក៏ប្រទូសរ៉ាយដល់អ្នកដទៃឱ្យបានទទួលសេចក្តីទុក្ខកាយ ឬដល់ជីវិតបានទៀតផង ។

ហេតុដែលធ្វើឱ្យកើតសេចក្តីទោមនស្សបាននោះ មានច្រើនប្រការ តែដោយចំពោះ ទាក់ទងមកពីការព្រាត់ប្រាសចាកវត្ថុដែលខ្លួនស្រឡាញ់ម្យ៉ាង ការបានជួបនិងវត្ថុដែលខ្លួនមិនពេញចិត្តម្យ៉ាងទាំង ២

យ៉ាងនេះ ធ្វើឱ្យកើតសេចក្ដីទោមនស្សបានជាចំណែកច្រើន ដោយហេតុនេះព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់បានត្រាស់សម្ដែងដាស់តឿនសតិរបស់ពុទ្ធសាសនិកទាំងឡាយ ទាក់ទងនិងរឿងទុក្ខចិត្តនេះទុកក្នុងសំយុត្តព្រះបាលីថា

**មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ**
**បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ**

សូមកុំនៅរួមជាមួយអ្នកដែលយើងស្រឡាញ់ ហើយកុំនៅរួមជាមួយអ្នកដែលមិនស្រឡាញ់ (ព្រោះ) ការដែលមិនបានឃើញអ្នកដែលយើងស្រឡាញ់ក្ដី ការដែលបានឃើញអ្នកដែលយើងមិនស្រឡាញ់ក្ដី សុទ្ធតែជាទុក្ខទាំងអស់។

## លក្ខណាទិចតុក្កៈរបស់ ទោមនស្ស

**១.ចិត្តបីលនលក្ខណំ** មានអាការបៀតបៀនចិត្តជាលក្ខណៈ។

**២.មនោវិឃាតនរសំ** មានការធ្វើបាបជាកិច្ច។

**៣.មានសព្យាធិបច្ចុប្បដ្ឋានំ** មានសេចក្ដីមិនសប្បាយចិត្តជាផល។

**៤.ហទយវត្ថុបទដ្ឋានំ** មានហទយវត្ថុជាហេតុជិត។

**វចនត្ថៈ ឧបាយាស ភុសោ អាយាសនំ = ឧបាយាសោ**

សេចក្ដីលំបាកចិត្តយ៉ាងខ្លាំង ឈ្មោះថា ឧបាយាសៈ បានដល់ទោសចេតសិកដែលកើតឡើងដោយអាស្រ័យព្យសនៈណានីមួយ ។

ពាក្យថា **ឧបាយាសៈ** នេះមកពី **ឧប** + **អាយាស** **ឧប** = យ៉ាងជិត **អាយាស** = សេចក្ដីលំបាក កាលបើរួមគ្នាហៅថា **ឧបាយាស** ប្រែថា សេចក្ដីលំបាកចិត្តយ៉ាងខ្លាំង ។

សភាពរបស់ឧបាយាសក៏គឺ សេចក្ដីសៅហ្មងខូចចិត្តយ៉ាងធំដែលជាប់ទាក់ទងមកពីសោកៈ កាលបើសោកៈមានកម្លាំងច្រើនឡើងឈានដល់បរិទេវៈ បន្ទាប់ពីបរិទេវៈឈានដល់ឧបាយាសៈដែលជាទីបំផុតនៃសេចក្ដីសោកសៅ ធ្វើឱ្យអ្នកដែលបានទទួលនោះមានចិត្តក្រៀមក្រំភ្លាម មិនអាចនឹងទប់ទល់ចំពោះសេចក្ដីដឹងប្រភេទនេះមានអាការអង្គុយស្ងៀមនិយាយមិនចេញ យំមិនចេញពេលខ្លះរហូតដល់វិសញ្ញី ឬក្លាយជាអ្នកខូចសតិ ឬអាចទម្លាយជីវិតខ្លួនឯងបាន ដោយច្រើនតែងតែកើតជាមួយអ្នកដែលបានជួបនឹងព្យសនៈទាំង ៥ ណានីមួយដោយមិនបាននឹកស្មាន ដូចជាមាតាបិតា ស្វាមីភរិយា បុត្រដែលបានស្លាប់ក្នុងបច្ចុប្បន្ន ឬទ្រព្យសម្បត្តិត្រូវសូន្យបាត់ទៅដោយខ្យល់ ដោយអគ្គីភ័យចោរភ័យ ឧទកភ័យជាដើមឬជារោគភ័យដែលអស់ផ្លូវនឹងរក្សាបានទាំងនេះជាដើម ធ្វើឱ្យអ្នកនោះបានទទួលសេចក្ដីប៉ះខ្ទប់ដល់ចិត្តយ៉ាង

ធ្ងន់ធ្ងរ សភាពដូច្នេះឯងឈ្មោះថា **ឧបាយាស** ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកក្នុងមហានិទ្ទេសព្រះបាលីថា

**តស្ស ចេ កាមយានស្ស ឆន្ទជាតស្ស ជន្តុនោ**
**តេ កាមា បរិហាយន្តិ សល្លវិទ្ធោវ រុប្បតិ**

បុគ្គលដែលជិះយាន គឺ កាមគុណអារម្មណ៍យ៉ាងសុខស្រួលភ្លើតភ្លើន និងមានសេចក្តីពេញចិត្ត ស្រលាញ់ជាប់ជំពាក់កាមគុណអារម្មណ៍ទាំងនោះ បើវត្ថុអារម្មណ៍កាមគុណនោះ សាបសូន្យទៅហើយ កាលបើដូច្នេះ អ្នកដែលវង្វេងភ្លើតភ្លើននោះ រមែងបានទទួលសេចក្តីក្រៀមក្រំចិត្ត ដោយសភាពនៃសោកៈ បរិទេវៈ ឧបាយាសៈ ។

សេចក្តីផ្សេងគ្នារវាង សោកៈ បរិទេវៈ ឧបាយាសៈ

**សោកៈ** សេចក្តីសោក បានដល់ ទោមនស្សវេទនា បរិទេវៈ សេចក្តីខ្សឹកខ្សួល បានដល់ ចិត្តវិបល្លាសសទ្ទដែលកើតអំពីទោសមូលចិត្តុប្បាទ និង ឧបាយាសៈ សេចក្តីតូចចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្ត បានដល់ តួទោសចេតសិក ទាំង ៣ យ៉ាងនេះបើនិយាយដោយន័យប្រៀបធៀប ហើយក៏ប្រៀបដូចជាទឹកនៅក្នុងខ្ទះដាក់លើភ្លើងកាលបើដុតភ្លើង ទឹកក៏ផ្តើមក្តៅឡើងជាលំដាប់ ភាពក្តៅនោះក៏ឡើងរហូតដល់ការពុះ ហើយទឹកក៏ពុះកបញ្ជ្រោលឡើង កាលបើពុះយូរទៅៗ

ភាពក្តៅក៏ច្រើនឡើងៗរហូតក្តៅដល់ទីបំផុត ហើយក៏មានផ្សែងប្រាកដឡើង បន្ទាប់ពីនោះមកទឹកក៏ចាប់ផ្តើមរីងបន្តិចម្តងៗរហូតដល់រីងស្ងួតទៅ សេចក្តីនេះយ៉ាងណា សោកៈ ក៏ប្រៀបបានដូចភាពក្តៅរបស់ទឹកដែលផ្តើមក្តៅឡើង បរិទេវៈ ប្រៀបដូចទឹកកំពុងពុះ ឧបាយាសៈ ប្រៀបដូចទឹកដែលក្តៅបំផុតហើយក៏ផ្តើមរីងស្ងួតបន្តិចម្តងៗ សមដូចព្រះពុទ្ធឃោសាចារ្យសម្តែងទុកក្នុងវិសុទ្ធិមគ្គថា **ភាជនន្តោ តេលបាកោ ឧត្តរិត្វា ច និក្ខមោ សេសស្ស ខយបាកោតិ ឥមេហេតេ តយោសមា** សោកៈ បរិទេវៈ ឧបាយសៈ ទាំង ៣ នេះដូចគ្នានឹងសេចក្តីប្រព្រឹត្តទៅរបស់ប្រេងទាំង ៣ ចំណុច គឺប្រេងដែលក្តៅឡើងក្នុងភាជនៈជាចំណុចទី ១ ប្រេងដែលកំពុងពុះជាចំណុចទី ២ ប្រេងដែលក្តៅខ្លាំងហើយរីងស្ងួតទៅជាចំណុចទី ៣ ។

## លក្ខណាទិចតុក្កៈរបស់ ឧបាយាសៈ

**១.ចិត្តបរិទហនលក្ខណោ** មានការដុតចិត្តក្តៅខ្លាំងជាលក្ខណៈ ។

**២.និត្ថុននរសោ** មានការដកថយចិត្តជាកិច្ច ។

**៣.វិសាទបច្ចុប្បដ្ឋានោ** មានការសៅហ្មងចិត្តជាផល ។

**៤.ទហយវត្ថុបទដ្ឋានោ** មានហទយវត្ថុជាហេតុជិត ។

## ការសង្គ្រោះបច្ច័យ ២៤ ចូលក្នុងបទថា ជាតិប្បច្ចយា- សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ

ជាតិជាបច្ច័យដល់ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈទាំងនេះបានដោយអំណាចបច្ច័យ ១ គឺបកតូបនិស្សយប្បច្ច័យ ។

ការនៅរបស់សត្វទាំងឡាយ ដែលមានការវិលវល់ស្លាប់ កើតនៅក្នុងលោកនេះក៏បានដល់ការវិលវល់របស់គ្រឿងចក្ក គឺ បដិច្ចសមុប្បាទធម៌ មានអវិជ្ជាជាដើមនោះឯង តែសត្វទាំងឡាយមានចំនួនច្រើនរកមិនឃើញដល់ការប្រព្រឹត្តទៅនៃជីវិតនេះបានទេ ដឹងបានត្រឹមសម្មតិសច្ចៈប៉ុណ្ណោះ គឺ អ្នកនោះស្លាប់ អ្នកនេះកើត យើងឃើញយើងឮ ជាដើម កាលបើពោលដោយសភាវៈដែលពិតហើយអ្នកនោះអ្នកនេះ យើង គេ ប្រុស ស្រី ជាដើមនេះមិនមានឡើយ មានតែធម៌ដែលជាហេតុ ជាផល កើតឡើងជាប់តគ្នាមិនដាច់ ធម៌ទាំងនេះក៏សុទ្ធតែជាកងទុក្ខទាំងអស់ និងសេចក្តីកើតឡើងនៃកងទុក្ខទាំងពួង ដែលសម្មតិថា អ្នកនោះ អ្នកនេះ យើង គេ ប្រុស ស្រី ក៏មិនមានអ្នកណាសាងឱ្យកើតឡើងឡើយ ការកើតឡើងរបស់ធម៌ទាំងនេះ ក៏ព្រោះអាស្រ័យបច្ច័យផ្សេងៗ មានអវិជ្ជាជាដើម ដូច្នោះទើបព្រះមានព្រះភាគត្រាស់ថា **ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** មានសេចក្តីថា ការកើតឡើងនៃកងទុក្ខទាំងពួង នេះព្រោះអាស្រ័យបច្ច័យផ្សេង ៗ មានអវិជ្ជាជាដើមដូចដែលបានពោលមកហើយ ។

ការពិចារណាតាមបដិច្ចសមុប្បាទធម៌ហើយ ក៏ឃើញបានថា បណ្ដាវត្ថុដែលមានជីវិតទាំងឡាយ មានមនុស្ស ទេវតា ព្រហ្ម ទាំងនេះ ប្រាកដកើតឡើងបាន ក៏ព្រោះមានអវិជ្ជាជាតួហេតុ ចំណែកសង្ខារជាដើមនោះ កើតមកពីអវិជ្ជាតែម្យ៉ាងប៉ុណ្ណោះ ដែលជាតួហេតុ បើអវិជ្ជានៅមាន ការកើត ស្លាប់ របស់សត្វទាំងឡាយ ក៏រមែងមិនមានទីបំផុត កាលណាបានទម្លាយអវិជ្ជាឱ្យអស់ហើយ សង្ខារជាដើមក៏អស់ទៅផងដែរ សេចក្ដីថា ការកើត ចាស់ ឈឺ ស្លាប់ របស់សត្វ-ទាំងឡាយក៏រលត់ទៅ ដោយហេតុនេះ ព្រះដ៏មានជោគ ទើបត្រាស់សម្ដែងបដិច្ចសមុប្បាទដោយបដិលោម **អវិជ្ជាយត្វេវ អសេសវិរាគ-និរោធា សង្ខារនិរោធោ** កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ដោយអរិយមគ្គ ឥតមានសេសសល់ នៃអវិជ្ជាមែនពិត ។

**សង្ខារនិរោធា វិញ្ញាណនិរោធោ** កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ ។

**វិញ្ញាណនិរោធា នាមរូបនិរោធោ** កិរិយារលត់នៃនាម និងរូប ព្រោះរលត់នៃវិញ្ញាណ ។

**នាមរូបនិរោធា សឡាយតននិរោធោ** កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាម និងរូប ។

**សឡាយតននិរោធា ផស្សនិរោធោ** កិរិយារលត់នៃ សម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦ ។

**ផស្សនិរោធា វេទនានិរោធោ** កិរិយារលត់នៃ វេទនា ព្រោះរលត់នៃ សម្ផស្ស ។

**វេទនានិរោធា តណ្ហានិរោធោ** កិរិយារលត់នៃ តណ្ហា ព្រោះរលត់នៃ វេទនា ។

**តណ្ហានិរោធា ឧបាទាននិរោធោ** កិរិយារលត់នៃ ឧបាទាន ព្រោះរលត់នៃ តណ្ហា ។

**ឧបាទាននិរោធា ភវនិរោធោ** កិរិយារលត់នៃ ភព ព្រោះកិរិយារលត់នៃ ឧបាទាន ។

**ភវនិរោធា ជាតិនិរោធោ** កិរិយារលត់នៃ ជាតិ ព្រោះកិរិយារលត់នៃ ភព ។

**ជាតិនិរោធា ជរា មរណំ** ជរា និង មរណៈ (រលត់) ព្រោះកិរិយារលត់នៃ ជាតិ ។

**សោកបរិទេវទុក្ខទោមនស្សុបាយាស និរុជ្ឈន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់ទៅ នៃជាតិដែរ) ។

**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នោះ មានដោយប្រការដូច្នេះ ។

ក្នុងបដិច្ចសមុប្បាទដោយបដិលោមទេសនានេះ ចំណុចសំខាន់គឺសេចក្ដីរលត់សាបសូន្យអស់របស់អវិជ្ជានោះឯង ចំណែកសេចក្ដីរលត់របស់សង្ខារជាដើមនោះ កាលអវិជ្ជារលត់ទៅហើយ សង្ខារជាដើមទាំងនេះ ក៏រមែងរលត់ព្រមគ្នា មិនមែនរលត់ទៅភ្លាម១ តាមលំដាប់ដែលផ្សេងជាមួយក្នុងអនុលោមទេសនា ឧបមាដូចគ្រាប់ពូជព្រោះហើយ ផលគឺដើមក៏ប្រាកដបាន កាលមានដើមហើយ មែកក៏ប្រាកដឡើងបាន កាលបើមានមែកហើយ ធាងក៏ប្រាកដឡើងបាន កាលបើមានធាង និងស្លឹកមានហើយ ផ្កាក៏ប្រាកដឡើងបាន កាលបើមានផ្កាហើយ ផ្លែក៏ប្រាកដឡើងបាន កាលបើមានផ្លែហើយ គ្រាប់ពូជក៏ប្រាកដឡើងបាន កាលបើមានគ្រាប់ពូជហើយ ដើមក៏ប្រាកដឡើងបាន កាលបើមានដើមហើយ មែកក៏ប្រាកដឡើងបាន ជាហេតុនិងផលដោយចំពោះ វិលវល់ជារឿយ១ ទៅមិនដាច់ដូចគ្នានឹងការសម្ដែងបដិច្ចសមុប្បាទ ដោយអនុលោមទេសនាមាន **អវិជ្ជាបច្ចយា សង្ខារា** ជាដើម ។

តែបើថាគ្រាប់ពូជនោះដុតទម្លាយចេញហើយ ដើមក៏ប្រាកដឡើងមិនបាន កាលបើដើមដុះមិនបានហើយ មែកក៏កើតមិនបាន កាលបើមែកកើតមិនបានហើយ ធាង ស្លឹក ក៏កើតមិនបាន កាលបើធាងស្លឹក

កើតមិនបានហើយ ផ្កាក៏កើតមិនបាន កាលបើផ្កាកើតមិនបានហើយ ផ្លែក៏កើតមិនបាន កាលបើផ្លែកើតមិនបានហើយ គ្រាប់ពូជក៏កើតមិនបាន កាលបើគ្រាប់ពូជកើតមិនបានហើយ ដើមក៏កើតមិនបាន ក្នុងការសំដែងហេតុផល ចំណែកការកើតមិនបាន ដែលពោលទៅតាមលំដាប់ដូចនេះ ក៏ត្រឹមតែការសម្ដែងដោយវោហារប៉ុណ្ណោះ ដែលពិតនោះកាលបានទម្លាយ នូវគ្រាប់ពូជ អស់ទៅហើយ ដើម មែក ធាង ស្លឹក ផ្កា ផ្លែ គ្រាប់ពូជ ទាំងនេះក៏កើតមិនបានដែរ ដូចគ្នានឹងការសម្ដែងបដិច្ចសមុប្បាទ ដោយបដិលោមទេសនា មាន **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ជាដើម ។

ដែលពោលថា ការរលត់ទៅនៃអវិជ្ជាមិនមានសេសសល់ ក៏បានដល់ព្រះនិព្វាននោះឯង តែជាសឧបាទិសេសនិព្វាន គឺនិព្វានអស់កិលេស នូវមានខន្ធ ៥ ហើយនឹងចូលដល់អនុបាទិសេសនិព្វាន គឺរលត់ទាំងកិលេស រលត់ទាំងខន្ធ ៥ ដូច្នោះអ្នកមានសេចក្ដីចូលចិត្តក្នុងព្រះនិព្វាន ដោយត្រូវត្រង់នោះ ជាទូទៅដោយច្រើនចូលចិត្តថាអ្នកដែលបានសោយសេចក្ដីសុខ ក្នុងអនុបាទិសេសនិព្វាននោះ នូវមានខ្លួនអ្នកសោយតែអ្នកនោះក៏មិនមានការកើត ចាស់ ឈឺ ស្លាប់ ផុតអំពីទុក្ខទាំងពួងសេចក្ដីពិតនោះអនុបាទិសេសនិព្វាននេះមិនមានតួខ្លួនយើង គេ យ៉ាង

ណា បានដល់ការរំលត់ការកើតឡើងនៃខន្ធ ៥ និងមិនមានការកើតឡើងទៀត ឧបមាដូចពន្លឺភ្លើងដែលរលត់ទៅ មិនទៅតាំងទីណាទៀតឡើយ យ៉ាងណាព្រះអរហន្តទាំងឡាយ ដែលចូលកាន់អនុបាទិសេសនិព្វាន ក៏យ៉ាងនោះដែរ ។

ក្នុងរឿងព្រះនិព្វាននេះ ស្តេចមហាព្រហ្មមាននាមថា **ពកៈព្រហ្ម** កាលបានឮ សេចក្តីប្រព្រឹត្តទៅនៃព្រះនិព្វាន ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងហើយ អត់ធន់នៅយ៉ាងស្ងៀមមិនបាន ក៏និយាយឡើងថា **តុច្ឆកញ្ចេវ អហោសិ រិត្តកញ្ចេវ អហោសិ និរត្ថកញ្ចេវ អហោសិ** ។

បពិត្រព្រះគោតមដ៏ចម្រើន និព្វានរបស់ព្រះអង្គជារបស់ទទេៗ ទំនេរទាំងមិនមានអ្វីឡើយ រកប្រយោជន៍មិនបាន " រឿងនេះអ្នកសម្តែងក៏ជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ អ្នកស្តាប់ក៏មិនមែនជាសាមញ្ញជន ជាស្តេចមហាព្រហ្ម តែដល់សេចក្តីនោះ ក៏មិនចូលចិត្តក្នុងសេចក្តីសុខរបស់ព្រះនិព្វាន តែមិនទាក់ទិនជាមួយនឹងខន្ធ ៥ យ៉ាងណាដោយហេតុនេះ គ្រូ អាចារ្យ និងធម្មកថិកខ្លះ លោកអ្នកមិនមានសេចក្តីចូលចិត្តល្អក្នុងរឿងសេចក្តីសុខរបស់ព្រះនិព្វាន ទើបមានសេចក្តីយល់ឃើញថា អ្នកដែលបានដល់ព្រះនិព្វាននោះ សូម្បីថាមិនមាន ខន្ធ ៥ តែក៏

នៅមានភាពពិសេស ដែលក្រៅអំពីខន្ធ ៥ ជាអ្នកសោយ នឹងសភាពពិសេសនេះ មិនមានការកើត ចាស់ ឈឺ ស្លាប់ផុតចាកសេចក្តីទុក្ខទាំងពួង ជាសេចក្តីសុខពិសេស កាលបើមានសេចក្តីយល់ឃើញដូចច្នេះ ទើបព្យាមយាមចង្អុលណែនាំ ដល់បណ្តាសិស្សរបស់ខ្លួន រហូតដល់សិស្សនោះ ពេញចិត្តក្នុងធម៌ទាំងឡាយ ឱ្យចូលដល់ព្រះនិព្វានដែលខ្លួនបានសាងឡើង បុគ្គលទាំងនោះបានស្តាប់ហើយក៏យល់ថា នេះជាសេចក្តីពិត ក៏នាំគ្នាជឿចូលចិត្តខុស ទៅតាមគ្នា ។

ការពោលដល់អធ្យាស្រ័យចិត្តរបស់បុគ្គល ២ ពួកគឺៈ បុគ្គលប្រកបទៅដោយនេក្ខម្មធាតុ ១ និង បុគ្គលដែលប្រកបដោយតណ្ហា១ រមែងមានសេចក្តីផ្សេងគ្នា ពោលគឺអ្នកប្រកបដោយនេក្ខម្មធាតុ រមែងមានសេចក្តីចូលចិត្តក្នុងសេចក្តីស្ងប់ ប្រាសចាកកិលេសផ្សេងៗ ចំណែកអ្នកប្រកបដោយតណ្ហា រមែងមានសេចក្តីពេញចិត្តភ្លើតភ្លើន ដែលជាកិលេសទាំងអស់ និងលើកតួយ៉ាងមកសំដែងឱ្យឃើញសេចក្តីផ្សេងគ្នានៃចិត្តរបស់បុគ្គលពីរពួកនេះ ដូចព្រះអនាគាមី និងព្រះអរហន្តទាំងឡាយ កាលបានឮអ្នកដទៃពោលថា ក្នុងព្រៃនោះ រូងភ្នំនោះ ជាទីដែលស្ងប់អំពីពួកមនុស្ស មានដើមឈើម្លប់សាខា កំពង់ទឹកបរិបូណ៌បានឮហើយក៏មានសេចក្តីចូលចិត្តត្រូវការទៅក្នុងស្ថានទីនោះ កាលបានទៅដល់ហើយ មិនមានប្រាថ្នាចង់ត្រឡប់មកច្រឬកច្របល់ដោយពួក

ខណៈទៀត ចំណែកពួកបុគ្គលពាលទាំងឡាយ កាលបានឮដូច្នេះមិនមានសេចក្ដីចូលចិត្តចង់ទៅ ហើយគិតថាស្ថានទីនោះនឹងមានសេចក្ដីសុខដូចម្ដេច? មានតែសេចក្ដីគួរឱ្យខ្លាច គួរឱ្យធុញទ្រាន់ តែបើមានអ្នកណាមកប្រាប់ថាស្ថានទីឯណោះមានភាពរីករាយច្រើន មានរោងមហោស្រពគគ្រឹកគគ្រេង មានរោងសុរាអាហារបរិបូណ៌ ដូច្នេះហើយបុគ្គលពាលទាំងឡាយកាលបានឮ មានសេចក្ដីប្រាថ្នាចង់ទៅទីនោះ ដោយភាពរហ័សជាទីបំផុត និងកាលបានទៅដល់ទីនោះហើយ មានសេចក្ដីភ្លើតភ្លើន និងមិនចង់ត្រឡប់មកវិញ ចំណែកព្រះអនាគាមី និងព្រះអរហន្តទាំងឡាយ កាលបានឮដូច្នេះហើយក៏មានសេចក្ដីសង្វេគក្នុងចិត្ត មិនកើតសេចក្ដីត្រេកអរសូម្បីតិចតួច ព្រោះក្នុងសន្ដានចិត្តរបស់លោកមាននេក្ខម្មធាតុគ្រប់គ្រង កាលស្ដាប់ដល់រឿងសេចក្ដីសុខហើយ ក៏ស្ដាប់ដោយនេក្ខម្មធាតុ បើសេចក្ដីសុខនោះមិនប្រកបដោយតណ្ហា ជាសេចក្ដីសុខស្ងប់ បានស្ដាប់ដោយពេញចិត្ត បើប្រកបដោយតណ្ហា ហើយក៏មិនត្រេកអរនឹងស្ដាប់ មានសេចក្ដីធុញទ្រាន់និងឃើញទោស ចំណែកបុគ្គលពាលទាំងឡាយ ចូលចិត្តស្ដាប់រឿងសេចក្ដីសុខ ដែលប្រកបដោយតណ្ហាប៉ុណ្ណោះ បើសេចក្ដីសុខប្រាសចាកតណ្ហាហើយ បុគ្គលពាលទាំងឡាយរមែងមិនចង់ស្ដាប់រឿងនោះទេ។

ចំណែកព្រះនិព្វាននោះជាសុញ្ញតធាតុ ស្ងប់អំពីខន្ធ ៥ ដូច្នោះ អ្នកដែលស្ដាប់ព្រះនិព្វានត្រូវស្ដាប់ដោយនេក្ខម្មធាតុ ទើបនឹងឃើញសេចក្ដីសុខពិតបើស្ដាប់ដោយតណ្ហារមែងមិនឃើញសេចក្ដីសុខ ត្រឡប់ជាឃើញថាជាវត្ថុដែលរកសារៈមិនមានដូចគ្នា នឹងសេចក្ដីឃើញរបស់ពកៈព្រហ្មដូច្នោះ ។

## អត្ថរបស់ការទេសនា

ការសម្ដែងបដិច្ចសមុប្បាទ របស់ព្រះសម្មាសម្ពុទ្ធក្នុងសំយុត្ត-និកាយនោះ មានប្រភេទនៃការសំដែងជា ៤ ន័យ

**១.សម្ដែងពីដើមដល់ចុង**គឺតាំងពីអវិជ្ជាទៅតាមលំដាប់រហូតដល់ជរាមរណជាទីបំផុតហៅថា **អាទិបរិយោសានអនុលោមទេសនា**

**២.សម្ដែងពីកណ្ដាលទៅដល់ចុង** គឺតាំងពីវេទនាទៅតាមលំដាប់រហូតដល់ជរាមរណជាទីបំផុត ហៅថា **មជ្ឈិមបរិយោសាន-អនុលោមទេសនា។**

**៣.សម្ដែងពីចុងទៅដល់ដើម** គឺតាំងពីជរាមរណថយក្រោយទៅតាមលំដាប់រហូតដល់អវិជ្ជាជាទីបំផុត ហៅថា **បរិយោសានអាទិ-បដិលោមទេសនា ដូចជា ជាតិប្បច្ចយា ជរាមរណំ ភវប្បច្ចយា ជាតិ ។ល។ អវិជ្ជាបច្ចយា សង្ខារា។**

**៤.សម្តែងពីកណ្តាលទៅដល់ដើម** គឺតាំងពីតណ្ហាថយក្រោយតាមលំដាប់រហូតដល់អវិជ្ជាជាទីបំផុត ហៅថា **មជ្ឈិមអាទិបដិ-លោមទេសនា ដូចជា ឥមេ ច ភិក្ខវេ ចត្តារោ អាហារា កឹនិទានា កឹសមុទយា កឹបភវា? ឥមេ ចត្តារោ អាហារា តណ្ហានិទានា តណ្ហាសមុទយា តណ្ហាជាតិកា តណ្ហាបភវា, តណ្ហា កឹនិទានា កឹសមុទយា កឹជាតិកា កឹភវា? វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវា ។ល។ សង្ខារា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា? អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជាបភវា ។**

ម្នាលភិក្ខុទាំងឡាយ អាហារ ៤ ទាំងនេះមានអ្វីជាមូល មានអ្វីជាហេតុឱ្យកើត មានអ្វីជាដើមហេតុ?

ឆ្លើយថា អាហារ ៤ ទាំងនេះ មានតណ្ហាជាមូល មានតណ្ហាជាសមុទយៈ មានតណ្ហាជាហេតុឱ្យកើត មានតណ្ហាជាដើមហេតុ ។

តណ្ហានេះ មានអ្វីជាមូល មានអ្វីជាសមុទយៈ មានអ្វីជាហេតុឱ្យកើត មានអ្វីជាដើមហេតុ ?

ឆ្លើយថា តណ្ហានេះមានវេទនាជាមូល មានវេទនាជាសមុទយៈ មានវេទនាជាហេតុឱ្យកើត មានវេទនាជាដើមហេតុ ។

។ល។

សង្ខារនេះ មានអ្វីជាមូល មានអ្វីជាសមុទយៈ មានអ្វីជាហេតុឱ្យកើត មានអ្វីជាដើមហេតុ ?

ឆ្លើយថា សង្ខារនេះមានអវិជ្ជាជាមូល មានអវិជ្ជាជាសមុទយៈ មានអវិជ្ជាជាហេតុឱ្យកើត មានអវិជ្ជាជាដើមហេតុ ដូច្នេះហៅថា មជ្ឈអទិបដិលោមទេសនា ។

## ប្រយោជន៍ដែលបានទទួលពីការសម្តែងដោយន័យទាំង ៤

១.ការសម្តែងដោយ **អាទិបរិយោសានអនុលោមទេសនា** ក៏ដើម្បីឱ្យជាប្រយោជន៍ក្នុងការជាក់ច្បាស់ ឱ្យដល់ជនទាំងឡាយដែលមិនដឹង មិនយល់ក្នុងការកើតឡើងរបស់សត្វទាំងឡាយ កាលមិនបានពិចារណាផ្សេងៗ កាត់សេចក្តីមិនបានថា អ្វីជាហេតុឱ្យកើត នឹងបានដឹងថាការកើតរបស់សត្វទាំងឡាយនោះ រមែងអាស្រ័យហេតុដោយតែម្យ៉ាង ហើយដើម្បីឱ្យដឹងការកើតរបស់ ហេតុទាំងនេះថា កាលប្រព្រឹត្តទៅតាមលំដាប់ ។

២.ការសម្តែងដោយ **មជ្ឈបរិយោសានអនុលោមទេសនា** ក៏ដើម្បីឱ្យជាប្រយោជន៍ដល់បុគ្គលពួក ខ្លះដែលមិនជឿថាកាល បើសត្វទាំងឡាយស្លាប់ហើយ នឹងកើតក្នុងភពខាងមុខទៀត ទាំងនេះនឹងបានឃើញដល់ បច្ចុប្បន្នហេតុ ៥ គឺ តណ្ហា ឧបាទាន កម្មភវៈ អវិជ្ជា សង្ខារ ជាអ្នកបង្កើតឱ្យដល់ខ្លួន និងកាលមានបច្ចុប្បន្នហេតុហើយ

ផលក្នុងអនាគតក៏នឹងត្រូវមានពិតប្រាកដ ហើយផលនោះក៏គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ដែលហៅថា សត្វទាំង-ឡាយនោះឯង ។

៣.ការសម្តែងដោយ **បរិយោសានអាទិបដិលោមទេសនា** ក៏ដើម្បីប្រយោជន៍ឱ្យបុគ្គលទាំងឡាយ បានឃើញធម៌ដែលជាហេតុនៃសេចក្តីទុក្ខតាមលំដាប់ តាំងពីជាតិជាដើមរហូតដល់អវិជ្ជា គឺឱ្យដឹងថា សេចក្តីទុក្ខមាន ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ដែលសត្វទាំងឡាយ កំពុងបានទទួលរៀងរាល់ថ្ងៃនេះ ប្រាកដកើតឡើងបានក៏ដោយអាស្រ័យជាតិជាហេតុ កាលបើមិនមានជាតិហើយ ទុក្ខទាំងនេះក៏កើតឡើងមិនបាន បើឃើញមានជាតិហើយ ក៏ឱ្យឃើញហេតុដែលធ្វើឱ្យជាតិកើត គឺកម្មភវៈ បើឃើញកម្មភវៈហើយ ក៏ឱ្យឃើញហេតុដែលធ្វើឱ្យកម្មភវៈកើត គឺឧបាទាន ឱ្យឃើញហេតុជាប់បន្តគ្នាតាមលំដាប់ទៅរហូតដល់អវិជ្ជា បើឃើញអវិជ្ជាហើយ ក៏នឹងបានដឹងថា អវិជ្ជានេះឯងជាប្រធាន នៃហេតុទាំងពួង ។

៤.ការសម្តែងដោយ **មជ្ឈអាទិបដិលោមទេសនា** ក៏ដើម្បីប្រយោជន៍ឱ្យដឹងដល់ហេតុផលតាមលំដាប់ ដែលជាសមុដ្ឋានរបស់អាហារទាំង៤ ដែលជាអ្នកនាំសត្វទាំងឡាយ តាំងពីអតីតភព រហូតដល់ បច្ចុប្បន្នភព គឺ រាងកាយរបស់សត្វទាំងឡាយតាំងនៅបានចម្រើនបាន ក៏ដោយអាស្រ័យអាហារផ្សេងៗ ជាអ្នកនាំមុខ្យាង ។

សត្វទាំងឡាយដែលមានសេចក្ដីដឹងសុខ ព្រងើយៗបាន ក៏ដោយអាស្រ័យផស្សៈ គឺ ការប៉ះខ្ទប់រវាងភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយចិត្ត និងអារម្មណ៍ទាំង ៦ ។

សត្វទាំងឡាយដែលធ្វើការងារផ្សេងៗ បានទាំងផ្លូវល្អនិងមិនល្អក៏ដោយអាស្រ័យចេតនា ជាប្រធាន។

ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ បេះដូង ភេទស្រី ភេទប្រុស និងការប៉ះខ្ទប់អារម្មណ៍ ការសោយអារម្មណ៍ ការចាំអារម្មណ៍ ជាដើមទាំងនេះ កើតឡើងបានក៏ដោយអាស្រ័យបដិសន្ធិវិញ្ញាណជាប្រធាន សម្រាប់ក្នុងបវត្តិកាលនោះ សេចក្ដីលោភ សេចក្ដីក្រោធ សេចក្ដី វង្វេង សេចក្ដីប្រកាន់ខ្លួន សេចក្ដីយល់ខុស សេចក្ដីច្រណែន ជាដើមក្ដី សេចក្ដីជ្រះថ្លា សេចក្ដីដឹង សេចក្ដីអាណិត សេចក្ដីរលឹកបាន ជាដើមក្ដី កើតឡើងបានក៏ដោយអាស្រ័យបវត្តិវិញ្ញាណជាប្រធាន។

អាហារទាំង៤ ដែលជាអ្នកនាំសត្វទាំងឡាយឱ្យកើតឡើង និងតាំងនៅបាន ធ្វើការងារផ្សេងៗ រហូតអស់ជីវិតនោះ នឹងកើតឡើងបានក៏ដោយអាស្រ័យតណ្ហាជាហេតុឱ្យកើត តណ្ហានឹងកើតឡើងបាន ក៏ដោយអាស្រ័យវេទនាជាហេតុ វេទនានឹងកើតឡើងបាន ក៏ដោយអាស្រ័យផស្សៈជាហេតុ ផស្សៈនឹងកើតឡើងបានក៏ដោយអាស្រ័យសឡាយតនៈជាហេតុ សឡាយតនៈកើតឡើងបានក៏ដោយអាស្រ័យ

នាមរូបជាហេតុ នាមរូបនឹងកើតឡើងបានក៏ដោយអាស្រ័យវិញ្ញាណជាហេតុ វិញ្ញាណនឹងកើតឡើងបានក៏ដោយអាស្រ័យសង្ខារជាហេតុ សង្ខារនឹងកើតឡើងបាន ក៏ដោយអាស្រ័យអវិជ្ជាជាហេតុ ឱ្យសម្លឹងឃើញហេតុផល ដែលប្រព្រឹត្តទៅតាមលំដាប់ ដោយការកំណត់ពិចារណា អាហារ ៤ ជាគោល ។

សរុបសេចក្តីថាបដិច្ចសមុប្បាទនេះជាសមន្តភទ្ទកធម៌ គឺជាធម៌ដែលមានសេចក្តីល្អយ៉ាងច្រើន ព្រោះមិនបានសម្តែងដោយន័យយ៉ាងណាក៏ដោយ អ្នកស្តាប់ហើយក៏រមែងបានសម្រេចប្រយោជន៍ គឺបានកំណត់ដឹងនូវទុក្ខសច្ចៈ បានលះនូវសមុទយសច្ចៈ ឃើញច្បាស់នូវនិរោធសច្ចៈ ចម្រើននូវមគ្គសច្ចៈ ហើយចូលដល់ព្រះនិព្វាន ដោយប្រការម្យ៉ាង និង ប្រការម្យ៉ាងទៀត ព្រះតថាគតជាអ្នកសំដែងទេសនាវិសាសៈបត្តបុគ្គល គឺជាអ្នកមានសេចក្តីទទួលការឧបត្ថម្ភសំដែងនោះ ឱ្យងាយស្រួលស្តាប់ ។

អធិប្បាយក្នុងបាលីចំណុចទី ៤ ដែលថា **តត្ថ តយោ អទ្ធា** ជាដើមរហូតដល់ **ទ្វេ មូលានិ ច វេទិតព្វានិ** ។

ក្នុងបាលីចំណុចនេះមានបំណង ដើម្បីឱ្យអ្នកសិក្សាទាំងឡាយបានដឹងដល់វត្ថុដែលគួរដឹង ក្នុងបដិច្ចសមុប្បាទធម៌ បានដល់ អទ្ធា គឺកាល ៣ អង្គ ១២ អាការៈគឺប្រភេទ ២០ សន្ធិគឺការតភ្ជា ៣ សង្ខេបគឺពួក ៤ វដ្តៈ គឺការវិលវល់ ៣ មូលគឺដើមហេតុ ២ ។

អធិប្បាយក្នុងបាលីចំណុចទី ៥ ដែលថា **កថំ ។ល។ អវិជ្ជា សង្ខារា អតីតោ អទ្ធា** ជាដើម រហូតដល់ **តយោ អទ្ធា។**

បាលីចំណុចនេះពន្យល់សេចក្តីនៃពាក្យថា **តយោ អទ្ធា** ដែលមាននៅក្នុងបាលីចំណុចទី ៤ ។

ពាក្យថា **កថំ** នេះ ជាពាក្យបុច្ឆា **កថេតុកម្យតាបុច្ឆា** គឺតាំងបញ្ហាឡើងដើម្បីប្រាថ្នានឹងឆ្លើយដោយខ្លួនឯង មិនមែនឱ្យអ្នកដទៃឆ្លើយ ។

## ពាក្យបុច្ឆា ៥ យ៉ាង

១. **អទិដ្ឋជោតនាបុច្ឆា** សួរដើម្បីឱ្យដឹងក្នុងរឿងដែលខ្លួនមិនទាន់បានដឹងបានយល់ ។

២. **ទិដ្ឋិសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបនឹងវត្ថុដែលខ្លួនបានដឹង ។

៣. **វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់សេចក្តីសង្ស័យ ។

៤. **អនុមតិបុច្ឆា** ត្រឹមត្រូវហើយប៉ុន្តែសួរដើម្បីឱ្យអ្នកឆ្លើយៗតាមការយល់ស្របរបស់ខ្លួន ។

៥. **កថេតុកម្យតាបុច្ឆា** សួរដើម្បីនឹងឆ្លើយដោយខ្លួនឯង ។

ក្នុងពាក្យសួរ ៥ យ៉ាងនេះ ពាក្យបុច្ឆា ២ ប្រភេទគឺ អនុមតិបុច្ឆា និងកថេតុកម្យតាបុច្ឆា សម្រាប់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ។ ព្រោះ

ព្រះអង្គជាអ្នកមានសេចក្ដីដឹងមិនមានទីបំផុតស្រាប់ហើយដូច្នោះ ទើបមិនមានពាក្យសួរប្រភេទទី១។ នឹងដើម្បីប្រៀបធៀបសេចក្ដីដឹង រវាងព្រះសម្មាសម្ពុទ្ធ ជាមួយមនុស្ស ទេវតា ព្រហ្ម នោះក៏មិនសមគួរ ព្រោះហេតុនោះ ពាក្យសួរប្រភេទ ទី ២នេះទើបមិនមានដល់ព្រះអង្គ។ ប្រការមួយទៀត ព្រះសម្មាសម្ពុទ្ធជាអ្នកដឹងធម៌ទាំងអស់ ដោយមិនមានសេសសល់ ប្រាសចាកសេចក្ដីសង្ស័យ ក្នុងរឿងរ៉ាវទាំងពួង ព្រោះហេតុនោះ ពាក្យសួរប្រភេទ ទី ៣ ក៏មិនមាន ដល់ ព្រះអង្គដូចគ្នា ចំណែកបុគ្គលផ្សេងៗ មានព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវ័កជាដើម រហូតដល់បុថុជ្ជនទាំងឡាយនោះ រមែងមានពាក្យ បុច្ឆាបានទាំង ៥ យ៉ាង។

## អធិប្បាយក្នុងការចែកអង្គនៃបដិច្ចសមុប្បាទ ១២ ដោយកាលទាំង ៣

ពាក្យថា **អទ្ធា** ប្រែថា កាល ជាបញ្ញត្តិមិនមានអង្គធម៌បរមត្ថ តែក្នុងទីនេះពាក្យថា **អតីតអទ្ធា អនាគតអទ្ធា បច្ចុប្បន្នអទ្ធា** នោះសំដៅយកធម៌ដែលកើតក្នុងកាលទាំង ៣ មានអង្គធម៌បរមត្ថ គឺ អវិជ្ជា សង្ខារ ជាអតីតកាល ជាតិ ជរាមរណៈ ជាអនាគតកាល វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន កម្មភវៈ ជាបច្ចុប្បន្នកាល ព្រោះហេតុនោះ អវិជ្ជា សង្ខារ ដែលឈ្មោះថា ជាអតីត-

កាលជាដើមនេះ ជាការហៅឈ្មោះដោយ ឋានូបចារន័យ គឺ លើកយក ឈ្មោះរបស់កាលទាំង ៣ មកតាំងទុកក្នុងធម៌ ហើយហៅអវិជ្ជា សង្ខារ ជាដើមនេះ ថាជា អតីតកាល អនាគតកាល បច្ចុប្បន្នកាល ។

អធិប្បាយថា តាមធម្មតាក្នុងចិត្តសន្តាន របស់មនុស្សទាំងឡាយ ដែលក្រៅពីព្រះអរហន្តហើយ រមែងមានមោហៈអ្នកគ្រប់គ្រងជាប្រចាំ ដោយហេតុនេះទើបធ្វើឱ្យបុគ្គលទាំងឡាយ មើលមិនឃើញទោសក្នុង ការធ្វើអកុសល និងមិនឃើញវដ្តទុក្ខក្នុងការធ្វើកុសលរបស់ខ្លួន មោហៈ នេះ បានឈ្មោះថា អវិជ្ជា ហើយក្នុងការធ្វើកុសល អកុសលទាំងនេះ ក៏ត្រូវមានចេតនាជាអ្នកជំរុញ ចាត់ចែងជាមុន ការធ្វើនោះៗ ទើបនឹងកើតឡើងបាន ចេតនាដែលជាអ្នកជំរុញឱ្យដៃធ្វើការងារដែល ហៅថា បុព្វចេតនានេះឯង បានឈ្មោះថា សង្ខារ ព្រោះហេតុនោះ អវិជ្ជា និងសង្ខារទាំង ២ នេះទើបជាអតីតកាល ។

បើមានអវិជ្ជាជាអ្នកគ្រប់គ្រង មានសង្ខារជាអ្នកជំរុញចាត់ចែង ហើយ អ្នកទាំងឡាយក៏ធ្វើការងារដែលជាកុសលខ្លះ អកុសលខ្លះ រាង កាយ ចិត្ត ហើយការប្រព្រឹត្តរបស់បុគ្គលទាំងនោះ បើពោលដោយ ធម្មាធិដ្ឋាន ក៏បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន កម្មភវៈ ព្រោះហេតុនោះ វិញ្ញាណ នាមរូប ជាដើម ទាំង ៨ យ៉ាង ទើបចាត់ជាបច្ចុប្បន្នកាល ។

បើមនុស្សទាំងឡាយ បានប្រព្រឹត្តការងារដែលជាកុសល អកុសល សម្រេចហើយដោយអំណាច នៃការធ្វើប្រព្រឹត្តកុសលអកុសល ដែលហៅថា កម្មភវៈនោះឯង រមែងឱ្យផលទៅកើតឡើងក្នុងអនាគតកាល ដោយបុគ្គលទាំងឡាយ បើស្លាប់ពីភពនេះហើយ ក៏រមែងទៅកើតថ្មីទៀតក្នុងភពមុខ តែការធ្វើរបស់ខ្លួន គឺ ប្រសិនបើធ្វើអកុសលធម៌ ក៏កើតជាអបាយសត្វ បើធ្វើកុសលកម្ម ក៏បានទៅកើតជាមនុស្ស ទេវតា ព្រហ្ម តាមសមគួរដល់កុសលនោះៗ ការបានទៅកើតជាមនុស្សទេវតាជាដើមទាំងនេះហើយឈ្មោះថា ជាតិ ឬហៅថា ឧប្បត្តិភវៈក៏បាន កាលបើមានជាតិប្រាកដកើតឡើងហើយ ជរាមរណៈក៏ត្រូវកើតឡើងជាប់តាមមកជាធម្មតា ព្រោះហេតុនោះ ជាតិ ជរាមរណៈទាំងនេះទើបចាត់ជា អនាគតកាល ។

ម្យ៉ាងទៀត អវិជ្ជា សង្ខារ ដែលចាត់ជាអតីតកាលនោះ ជាអតីតកាលក្នុងភពមុនក៏មាន ជាអតីតកាលក្នុងភពនេះក៏មាន កាលបើពោលដល់ផលក្នុងបច្ចុប្បន្នដែលបានដល់ វិញ្ញាណ នាមរូប សឡាយ-តនៈ ផស្សៈ វេទនា ( អវិជ្ជា សង្ខារ ក៏ជាអតីតកាលក្នុងភពនេះ) ។

អធិប្បាយក្នុងបាលីចំណុចទី ៦ ដែលថា **អវិជ្ជា សង្ខារា** ជាដើមរហូតដល់ **ទ្វាទសង្គានិ** បាលីចំណុចនេះអធិប្បាយសេចក្ដីនៃពាក្យថា **ទ្វាទសង្គានិ** ដែលនៅក្នុងបាលីចំណុចទី ៤ ។

ពាក្យថា **អង្គ** មានន័យថា ជាគ្រឿងប្រកបរបស់បដិច្ចសមុប្បាទ ដែលអាចធ្វើឱ្យវិលវល់ទៅមក មិនមានទីបំផុតបាន ដូចនឹងគ្រឿងប្រកបរបស់កង់ដែលជួយឱ្យកង់នោះវិលទៅបាន ព្រោះហេតុនោះ អង្គនេះទើបជាអង្គសំខាន់ក្នុងការវិលវល់ស្លាប់កើត របស់សត្វទាំងឡាយ ដែលហៅថា **ចក្កបដិច្ចសមុប្បាទ**។

សម្រាប់អង្គបដិច្ចសមុប្បាទ ១២ ឱ្យយល់តាមពាក្យប្រែដែលសំដែងទុកហើយក្នុងផ្នែកខាងដើមនោះ ។

អធិប្បាយក្នុងចំណុចដែលថា សោកៈ បរិទេវៈ ជាដើម មិនចាត់ជាអង្គបដិច្ចសមុប្បាទដោយចំពោះទេ ។

បដិច្ចសមុប្បាទធម៌ ដែលព្រះសម្មាសម្ពុទ្ធអង្គទ្រង់ទេសនានោះ បន្ទាប់អំពីជរាមរណៈហើយ មានការញ៉ាំងផលធម៌ ៥ យ៉ាង ទៀត គឺៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ប៉ុន្តែផលធម៌ ទាំង ៥ នេះ មិនបានរាប់ចូលជាអង្គដោយចំពោះទេ ទាំងនេះក៏ព្រោះថា កើតឡើងដល់បុគ្គលមិនទូទៅដូចជា ពួកព្រហ្ម ទេវតាថ្នាក់ខ្ពស់ ២ ពួកនេះទោះបីជាថា អវិជ្ជា ជាដើមរហូតដល់មរណៈ កើតឡើងបានក៏ដោយ តែសោកៈ ជាដើមរមែងមិនកើត មនុស្សដែលជាព្រះអនាគាមី និងឈានលាភីបុគ្គលទាំងនេះ អវិជ្ជា ជាដើម រហូតដល់

ជរាមរណៈកើតបាន ប៉ុន្តែសោកៈ បរិទេវៈ ទោមនស្សៈ ឧបាយាសៈ ទាំង ៤ នេះកើតមិនបាន កើតបានតែ ទុក្ខៈប៉ុណ្ណោះ អ្នកដែលបាន ទទួលការអប់រំក្នុងធម៌ជាន់ខ្ពស់ និងព្រះសោតាបន្ន ព្រះសកទាគាមី ទាំងនេះ ឧបាយាសៈក៏កើតមិនបាន បដិច្ចសមុប្បាទធម៌ក្រៅពីនោះកើត បាន ដោយហេតុនេះទើបមិនរាប់ជាអង្គដោយចំពោះ តែជាផលធម៌ ដែលកើតអំពីជាតិជាហេតុដូចគ្នា ផ្សេងគ្នាត្រង់ថា សោកៈ បរិទេវៈ ជាដើមទាំងនេះ ជាផលដែលកើតអំពីជាតិមិនប្រាកដដូចជាមួយ ជរា មរណៈ ហៅថា **និស្សន្ទផល** គឺជាផលចំណែកចុង ចំណែកជរា មរណៈ ហៅថា **វិបាកផល** គឺជាផលដោយត្រង់របស់ជាតិ ។

អធិប្បាយក្នុងបាលីចំណុចទី ៨ ដែលថា **អវិជ្ជា សង្ខារគ្គហេ-ណេន** ជាដើមរហូតដល់ **ចតុសង្ខេបា ច ភវន្តិ** ។

បាលីនេះពន្យល់សេចក្តីពាក្យថា **វីសតាការា តិសន្ធិ ចតុសង្ខេ-បា** ដែលនៅក្នុងបាលីខទី ៤ ។

**វីសតាការា**( អាការៈ ២០)ក្នុងការសំដែងអង្គក្នុងបដិច្ចសមុប្បាទ ទាំង ១២ ដោយការដែលសំដែងទៅហើយនោះ ជាការសំដែង ក្នុងអង្គបដិច្ចសមុប្បាទ ១២ ដោយចំពោះ ព្រោះហេតុនោះធម៌ដែល ជាអតីតកាល បច្ចុប្បន្នកាល អនាគតកាល ទើបមានកំណត់ តែបើ

សំដែងដល់សភាពនៃការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ ដោយហេតុផលក្នុងអតីតជាមួយបច្ចុប្បន្ន បច្ចុប្បន្នជាមួយអនាគតហើយ មានប្រភេទដល់ទៅ ២០ គឺ អតីតហេតុ ៥ បច្ចុប្បន្នផល ៥ បច្ចុប្បន្នហេតុ ៥ និងអនាគតផល ៥ ដូច្នេះព្រោះថា អវិជ្ជា សង្ខារ តណ្ហា ឧបាទាន កម្មភវៈ ទាំង ៥ នេះបើកើតឡើងហើយរមែងវៀរចេញពីគ្នាមិនបាន គឺ អវិជ្ជា សង្ខារ បើកើតឡើងដល់អ្នកណាហើយ ដែលមិនមានតណ្ហា ឧបាទាន កម្មភវៈ កើតឡើងជាមួយគ្នានោះ រមែងមិនមាន តណ្ហា ឧបាទាន កម្មភវៈបើកើតឡើងដល់អ្នកណា អវិជ្ជា មិនកើតជាមួយនោះ ក៏រមែងមិនមានដូចគ្នា ហើយជាតិ ជរា មរណៈ នោះក៏បានដល់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា នោះឯងដែលជាតួកើត ចាស់ ស្លាប់ មិនមានអង្គធម៌ដោយចំពោះ ព្រោះហេតុនោះ ក្នុងការសំដែងហេតុក្នុងអតីតនោះទើបសង្គ្រោះយក តណ្ហា ឧបាទាន កម្មភវៈ ទាំង ៣ នេះចូលរួមជាមួយអវិជ្ជា សង្ខារ ផង ព្រោះកាលបើពោលដោយវដ្តៈ ៣ អវិជ្ជា តណ្ហា ឧបាទាន ក៏ជាពួកកិលេសវដ្តៈដូចគ្នា សង្ខារ និងកម្មភវៈ ក៏ជាពួកកម្មវដ្តៈដូចគ្នា ។

ក្នុងអង្គបដិច្ចសមុប្បាទ ៨ ដែលជាបច្ចុប្បន្នកាលនោះ ចែកចេញជា ២ ពួក គឺផល ១ ពួក ហេតុ ១ ពួក ផលនោះបានដល់ វិញ្ញាណ នាមរូប

សឡាយតនៈ ផស្សៈ និងវេទនា, ហេតុនោះ បានដល់ តណ្ហា ឧបាទាន កម្មភវៈ ក្នុងបច្ចុប្បន្នផល ៥ ដែលមិនរាប់យកជាតិ ជរាមរណៈ ចូលមកផងនោះក៏ព្រោះ ជាតិ ជរាមរណៈ ទាំង ៣ នេះមិនមានអង្គធម៌ដោយចំពោះ ត្រឹមតែជាអាការប្រព្រឹត្តទៅរបស់ វិញ្ញាណ នាមរូប ជាដើម ដូចដែលពោលមកហើយ ចំណែកក្នុងបច្ចុប្បន្នហេតុ ៥ នោះ បានរាប់យក អវិជ្ជា សង្ខារ ចូលរួមជាមួយ តណ្ហា ឧបាទាន កម្មភវៈ ផង ក៏ព្រោះធម៌ទាំង ៥ ពួកនេះ ត្រូវកើតឡើងជាមួយគ្នាជានិច្ចដូចដែលបានពោលហើយ សម្រាប់អង្គបដិច្ចសមុប្បាទ ២ គឺ ជាតិ ជរាមរណៈ ដែលជាអនាគតកាលនោះ បើពោលដោយវដ្តៈ ៣ ហើយ ជាវិបាកវដ្តៈ និងតួ ជាតិ ជរាមរណៈ ក៏បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា នោះឯង ព្រោះហេតុនោះ ក្នុងអនាគតផល ៥ ទើបបានយក វិញ្ញាណ នាមរូប ជាដើមទាំងនេះ លើកឡើងសំដែងជំនួស ជាតិ ជរា មរណៈ ។

ពាក្យអធិប្បាយដូចពោលមកនេះ ជាការអធិប្បាយក្នុងប្រភេទនៃអាការៈ ២០ ។

## តិសន្ធិ (សន្ធិ ៣ )

ពាក្យថា **សន្ធិ** ប្រែថា ការត សំដែងវចនត្ថថា

**សន្ធិយតេ=សន្ធិ** ការបន្តរវាងហេតុនិងផល ផល និងហេតុ ឈ្មោះថា សន្ធិ ន័យម្យ៉ាងទៀត **សន្ធិយន្តិ ហេតុផលធម្មា ឯថាតិ=សន្ធិ** ធម៌ដែលជាហេតុ និងផល គប្បីតគ្នាក្នុងទីនោះ ព្រោះហេតុនោះ ឈ្មោះថា **សន្ធិ** ។

បើចែកអង្គបដិច្ចសមុប្បាទ ១២ ដោយការបន្តគ្នាមាន ៣ គឺ

១.ក្នុងចន្លោះ សង្ខារ និងវិញ្ញាណ ដែលជាអតីតហេតុ និងបច្ចុប្បន្នផល តគ្នាជាសន្ធិ ១

២.ក្នុងចន្លោះ វេទនា និងតណ្ហា ដែលជាបច្ចុប្បន្នផល និងបច្ចុប្បន្នហេតុ តគ្នាជាសន្ធិ ១

៣.ក្នុងចន្លោះ កម្មភវៈ និងជាតិ ដែលជាបច្ចុប្បន្នហេតុ និងអនាគតផល តគ្នាជាសន្ធិ ១

## ចតុសង្ខេបា (សង្ខេប ៤ )

ពាក្យថា **សង្ខេប** ប្រែថា ការរួបរួមទុកជាពួក១ សម្តែងវចនត្ថៈថា

**សង្ខិបីយន្តិ សង្គយ្ហន្តិ បធានធម្មា ឯត្ថាតិ=សង្ខេបោ**

ការរួបរួមធម៌ដែលជាប្រធានទុកជាពួក១ ក្នុងទីនោះ ព្រោះហេតុនោះ ការរួបរួមធម៌ទាំងនោះ ទើបឈ្មោះថា សង្ខេប ។

**បើចែកអង្គបដិច្ចសមុប្បាទ ១២ ដោយពួកមាន ៤ គឺៈ**

១.អវិជ្ជា សង្ខារ ដែលជាអតីតហេតុ ១ ពួក

២.វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ដែលជា បច្ចុប្បន្នផល ១ ពួក

៣.តណ្ហា ឧបាទាន កម្មភវៈ ដែលជាបច្ចុប្បន្នហេតុ ១ពួក

៤.ជាតិ ជរា មរណៈ ដែលជាអនាគតផល ១ ពួក

សម្រាប់ សោកៈ បរិទេវៈ ទុក្ខ ទោមនស្សៈ ឧបាយាសៈ ទាំង ៥ នេះ សង្គ្រោះចូលពួកទី ៤ ។

អធិប្បាយចំណុចទី ៩ ដែលថា **អវិជ្ជា តណ្ហុបាទានា ច កិលេសវដ្តំ** ជាដើម រហូតដល់ **តីនិវដ្តានិ** ។

បាលីចំណុចនេះអធិប្បាយសេចក្តីនៃពាក្យថា **តីនិវដ្តានិ** ដែលនៅក្នុងបាលីចំណុចទី ៤ ។

**តីណិវដ្តានិ** (**វដ្តៈ ៣** )

ពាក្យថា **វដ្ត** ប្រែថា ការវិលវល់ ដូចជាការវិលវល់របស់កង់

សំដែងវចនត្ថថា **វដ្តន្តិ បុនប្បុនំ អាវដ្តន្តីតិ =វដ្តំ**

ធម៌ទាំងឡាយណារមែងវិលវល់រឿយ១ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះឈ្មោះថា **វដ្តៈ** ។

# ការវិលវល់ ៣ យ៉ាង

**១.កិលេសវដ្ត** បានដល់ អវិជ្ជា តណ្ហា ឧបាទាន

**២.កម្មវដ្ត** បានដល់ កម្មភវៈ សង្ខារ

**៣.វិបាកវដ្ត** បានដល់ ឧបត្តិភវៈ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាតិ ជរា មរណៈ ។

អធិប្បាយថា ក្នុងរាងកាយនិងចិត្តរបស់មនុស្សទាំងឡាយ វៀរព្រះអរហន្តចេញហើយ វដ្តទាំង៣ រមែងមានបរិបូណ៌គឺរាងកាយនិងចិត្តរបស់មនុស្សទាំងឡាយនេះឯងជាវិបាកវដ្ត ការវង្វេង ការចង់បាន ការយល់ខុសដែលកើតនៅខាងក្នុងចិត្តសន្តានជាកិលេសវដ្តៈ ការធ្វើល្អមិនល្អដោយកាយ វាចា ចិត្ត ដែលមនុស្សយើងធ្វើរាល់ៗថ្ងៃនេះជាកម្មវដ្ត សភាពទាំង ៣ យ៉ាងនេះរមែងវិលវល់ផ្លាស់ប្តូរគ្នា ជាហេតុជាផលគ្រប់ភពគ្រប់ជាតិ មិនមានទីបំផុតពោលគឺបើមនុស្សយើងមានសេចក្តីវង្វេង សេចក្តីចង់បាន សេចក្តីយល់ខុស ដែលជាកិលេសវដ្ត ប្រចាំក្នុងចិត្តសន្តានហើយ ដោយអំណាចនៃកិលេសវដ្តនេះរមែងធ្វើឱ្យអ្នកនោះ មានការប្រព្រឹត្តផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ ផ្លូវចិត្តខ្លះ ល្អខ្លះ អាក្រក់ខ្លះ ដែលជាកម្មវដ្តកើតឡើង ការធ្វើផ្សេងៗ ទាំងនេះឯងនិងឱ្យផលប្រាកដឡើងក្នុងកាលខាងមុខ កាលអ្នកស្លាប់នោះ ចាកភពនេះទៅហើយក៏បានទៅកើតថ្មីមានក្នុងភូមិ ៣១ តាមសមគួរ ដល់អំពើ របស់ខ្លួន

ការកើតថ្មីរបស់ខន្ធ ៥ ដែលហៅថាសត្វទាំងឡាយនេះឯង ជាវិបាក-វដ្ត បើមានវិបាកវដ្តកើតឡើងហើយ កិលេសវដ្តក៏រមែងកើតឡើង ដោយអាស្រ័យវិបាកវដ្ត ជាហេតុវិលវល់ទៅដូច្នេះមិន មានទីបំផុត រហូតនឹងបានចូលដល់ព្រះនិព្វាន ការវិលវល់របស់វដ្ត ទាំង៣ ដូច ពោលនេះឯង បើពោលដោយវោហារដែលប្រើនៅក្នុង លោកនេះ ក៏បានដល់ ស្លាប់ហើយកើត កើតហើយក៏សាងកម្មថ្មី ហើយ ក៏ស្លាប់ ស្លាប់ហើយក៏កើតថ្មីទៀត កើតហើយក៏សាងកម្មថ្មីទៀត ហើយ ក៏ស្លាប់ទៀត វិលវល់យ៉ាងនេះ ឧបមាដូចជាការប្រព្រឹត្តទៅរបស់ ដើមឈើដែលបន្តគ្នារឿយៗ គឺដើមឈើកើតឡើងក៏ព្រោះអាស្រ័យគ្រាប់ពូជ គ្រាប់ពូជកើតឡើងក៏ព្រោះអាស្រ័យជ័រក្នុងដើម ជ័រកើតឡើង ក៏ព្រោះអាស្រ័យដើម បើប្រៀបធៀបជាមួយវដ្តទាំង៣ វិបាកវដ្ត ប្រៀបដូចដើម កិលេសវដ្តប្រៀបដូចជ័រ កម្មវដ្តប្រៀបដូចគ្រាប់ពូជ ។

កាលពិចារណាក្នុងវដ្តទាំង៣ នេះហើយ នឹងឃើញបានថាកិលេសវដ្តជាតួសំខាន់ជាទីបំផុត ព្រោះហេតុនោះ ក្នុងការទម្លាយវដ្ត ដើម្បីមិនឱ្យវិលវល់តទៅទៀត ទើបត្រូវទម្លាយកិលេសវដ្ត បើកិលេសវដ្តត្រូវទម្លាយហើយ កម្មវដ្តនិងវិបាកវដ្តទាំង ២ នេះក៏ត្រូវទម្លាយតាមទៅផង ។

## ទ្វេទមូលានិ (មូល ២)

ពាក្យថា **មូល** ប្រែថា ជាទីតាំង ឬជាដើមហេតុរបស់វដ្តទុក្ខទាំង-ពួងដូចសម្តែងវចនត្ថៈថា

**"មូលយន្តិ សព្វេបិ វដ្តធម្មា តិដ្ឋន្តិ ឯត្ថាតិ = មូលានិ"**

(វា) **"មូលយន្តិ បតិដ្ឋហន្តិ វដ្តធម្មា ឯតេហីតិ = មូលានិ"**

វដ្តធម៌ទាំងពួងរមែងតាំងនៅក្នុងទីនោះ ព្រោះហេតុនោះ ធម៌ដែលជាទីតាំងរបស់វដ្តធម៌ទាំងនោះ ឈ្មោះថា **មូល**។

(ឬ) វដ្តធម៌រមែងតាំងនៅបានដោយអាស្រ័យធម៌ទាំងឡាយ ព្រោះហេតុនោះ ធម៌ដែលជាហេតុឱ្យវដ្តធម៌តាំងនៅបាន ទាំងនោះ ឈ្មោះថា **មូល** បានដល់ អវិជ្ជា និង តណ្ហា ។

បដិច្ចសមុប្បាទធម៌បើចែកចេញជាភវចក្រមាន ២ គឺ តាំងពីអតីតហេតុ ជាដើម រហូតដល់បច្ចុប្បន្នផល ជាភវចក្រមួយ ឈ្មោះថា បុព្វន្ត-ភវចក្រ ជាភវចក្រដំបូង។

តាំងពីបច្ចុប្បន្នហេតុជាដើមរហូតដល់អនាគតផល ជាភវចក្រមួយ ឈ្មោះថា អបរន្តភវចក្រ ជាភវចក្រក្រោយ។ ក្នុងបុព្វន្តភវចក្រ មានអង្គបដិច្ចសមុប្បាទ ៧ គឺ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ក្នុងអង្គទាំង ៧ យ៉ាងនេះ អវិជ្ជា ជាដើមហេតុឬ ជាទីតាំងនាំឱ្យដល់វេទនា ។

ក្នុងអបរន្តភវចក្រ មានអង្គ ៥ គឺ តណ្ហា ឧបាទាន កម្មភវៈ ជាតិ ជរាមរណៈ ក្នុងអង្គ ៥ ពួកនេះ តណ្ហា ជាដើមហេតុ ឬ ជាទីតាំងនាំឱ្យដល់ ជរាមរណៈ ។

ក្នុងបុព្វន្តភវចក្រ ដែលមានអង្គ ៧ នោះ សំដៅដល់ចំពោះអង្គដែលប្រាកដចេញមុខ តែក្នុងខណៈដែលអង្គ ៧ វិលវល់មុននោះ តណ្ហា ឧបាទាន កម្មភវៈ ជាតិ ជរា មរណៈ ៥ យ៉ាងនេះ វិលទៅតាម ផងដែរ មានន័យថា ចំពោះសត្វទាំងឡាយដែលកើតនៅក្នុងបច្ចុប្បន្នភពនេះ រមែងកើតឡើងដោយអំណាចនៃអវិជ្ជាជាប្រធាន មានសង្ខារ ជាអ្នកចាត់ចែងនៅក្នុងភពមុន ដូច្នោះ អវិជ្ជា ទើបហៅថា បុព្វន្តមូល កាលមានអវិជ្ជាអ្នកនាំ មានសង្ខារជាអ្នកចាត់ចែង ក្នុងភពនោះក៏ត្រូវមាន តណ្ហា ឧបាទាន កម្មភវៈ កើតឡើងព្រោះអវិជ្ជា ជាអ្នកបិទបាំងមិនឱ្យឃើញទោសនិងសភាពជាសេចក្តីពិត ទើបធ្វើឱ្យអ្នកនោះកើតសេចក្តីត្រេកអរ សេចក្តីត្រូវការ សេចក្តីឃើញខុស សេចក្តីប្រកាន់ខ្ជាប់ខ្លាំងឡើង និងរមែងធ្វើការផ្សេងៗ ដោយកាយ វាចា ចិត្ត ជាកុសលខ្លះ អកុសលខ្លះតាមសេចក្តីប៉ងប្រាថ្នារបស់តណ្ហា ឧបាទាន ឱ្យសម្រេច ដោយមានសង្ខារជាអ្នកចាត់ចែង ឱ្យធ្វើរាងកាយរបស់សត្វទាំងឡាយដែលកើតនៅក្នុងបច្ចុប្បន្នភពនេះ ក៏បានដល់ វិញ្ញាណ នាមរូប

សឡាយតនៈ ផស្សៈ វេទនា នោះឯងនិងក្នុងរាងដែលមានជីវិតនេះ រាងកាយរបស់សត្វទាំងឡាយនោះក៏ត្រូវមានការ ប្រែប្រួលទៅតាម ធម្មជាតិ គឺ ពីក្មេងឡើងមកជាកំលោះក្រមុំ ពីកំលោះក្រមុំ មកជាមនុស្សធំ បន្ទាប់អំពីមនុស្សធំមកជាមនុស្សចាស់ មានអាការៈ សក់ស្កូវ ធ្មេញបាក់ ស្បែកជ្រួញ ភ្នែកងងឹត ការចងចាំជាដើម ចុះថយទៅតាមលំដាប់ និងទីបំផុតក៏ដល់វារៈនៃជីវិត បានដល់ ជរាមរណៈ សម្រាប់ជាតិនោះកាលខណៈដែលវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ចាប់ផ្ដើមកើតឡើងក្នុងភពថ្មី ជាតិ ក៏សង្គ្រោះនៅក្នុងទីនោះហើយ ដោយហេតុនេះទើបពោលទុកថា កាល អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា អង្គទាំង ៧ នេះ វិលវល់នៅក្នុងបុព្វន្តភវចក្រ តណ្ហា ឧបាទាន កម្មភវៈ ជាតិ ជរាមរណៈ អង្គទាំង ៥ នេះ ក៏រមែងវិលវល់តាមផងដែរ ។

ក្នុងអបរន្តភវចក្រដែលមានអង្គ ៥ សំដៅយកតែអង្គដែល ប្រាកដចេញមុខដូចគ្នា ក្នុងខណៈដែលអង្គទាំង ៥ វិលវល់នោះ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា អង្គទាំង ៧ នេះក៏ វិលទៅតាមផងដែរ មានន័យថា សត្វទាំងឡាយនឹងកើតភពខាងមុខ នោះ រមែងទៅកើតដោយអំណាចនៃតណ្ហាជាប្រធាន និងមានឧបាទាន កម្មភវៈជួយឧបត្ថម្ភ ដូច្នោះ តណ្ហាទើបឈ្មោះថា អបរន្តមូល និង

សត្វទាំងឡាយដែលប្រាកដនៅក្នុងលោកនេះ វៀរតែព្រះអរហន្ត ហើយ ក្រៅពីនោះរមែងមានការធ្វើផ្សេងៗ ដោយកាយ វាចា ចិត្ត ដែលប្រព្រឹត្តទៅតាមសេចក្តីពេញចិត្ត ការប្រកាន់មាំ មានមិច្ឆាទិដ្ឋិ ដែលនៅប្រចាំក្នុងខ្លួនហៅថា តណ្ហាឧបាទាន កម្មភព និងសេចក្តីពេញចិត្ត ការប្រកាន់មាំ មានមិច្ឆាទិដ្ឋិក្នុងវត្ថុផ្សេងៗ កើតឡើងបាន ព្រោះអ្នកនោះមិនឃើញទោស ឬមិនឃើញសេចក្តីតាមសភាវៈពិត ដែលហៅថាអវិជ្ជា ជាគ្រឿងបិទបាំងទុក និង មានសង្ខារ តាក់តែង ឱ្យធ្វើកម្មផ្សេងៗឱ្យបានសម្រេចតាមសេចក្តីប្រាថ្នារបស់អ្នកនោះ ដូច្នោះ តណ្ហា ឧបាទាន កម្មភព ដែលខ្លួនសម្គាល់ក្នុងអបរន្តចក្ក ទើបមាន អវិជ្ជា សង្ខារ វិលទៅតាមផង សម្រាប់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា វិលវល់តាម ជាតិ ជរាមរណៈផងនោះ គឺបុគ្គលទាំងឡាយដែលធ្វើកម្មផ្សេងៗ ដោលកាយ វាចា ចិត្ត ជាកុសលខ្លះ ជាអកុលសខ្លះ តាមអំណាចរបស់តណ្ហា ឧបាទាន ជាប្រចាំនោះ កាលបើស្លាប់អំពីលោកនេះទៅ នឹងកើតក្នុងភពថ្មីទៀត កាលបើកើតឡើងហើយ ការចាស់ ការស្លាប់ ប្រាកដឡើងតាមលំដាប់ ការកើត ចាស់ ឈឺ ស្លាប់ ដែលហៅថា ជាតិ ជរាមរណៈ ទាំង ៣ នេះ បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាអ្នកកើត ចាស់ ឈឺ ស្លាប់ ដោយហេតុនេះទើបពោលថា កាលបើតណ្ហា ឧបាទាន កម្មភព ជាតិ ជរាមរណៈ អង្គទាំង៥នេះ វិលនៅក្នុងអបរន្តភវចក្ក

អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតន ផស្ស វេទនា អង្គ៧ នេះវិលតាមផង ។

ការពិចារណាអង្គរបស់បដិច្ចសមុប្បាទក្នុងបុព្វន្តភវចក្ក និង អបរ-ន្តភវចក្ក ទាំង ២ ចំណែកនេះក៏ជ្រាបបានថា អវិជ្ជា សង្ខារ និងតណ្ហា ឧបាទាន កម្មភព ដែលកើតនៅក្នុងភពមុន នោះសង្គ្រោះចូលក្នុង បុព្វន្តភវចក្ក តណ្ហា ឧបាទាន កម្មភព និងអវិជ្ជា សង្ខារ ដែលកើតក្នុងភពនេះសង្គ្រោះចូលក្នុងអបរន្តភវចក្ក សម្រាប់វិញ្ញាណ នាមរូប សឡាយតនះ ផស្សះ វេទនា និង ជាតិ ជរាមរណះ បានដល់សត្វទាំងឡាយ ចាប់ផ្តើមកើតមក រហូតដល់ស្លាប់ក្នុងបច្ចុប្បន្ន ភពនេះ សង្គ្រោះចូលក្នុងបុព្វន្តភវចក្ក ជាតិ ជរាមរណះ និងវិញ្ញាណ នាមរូប សឡាយតនះ ផស្សះ វេទនា ដែលកើតក្នុងភពខាង មុខគឺសត្វទាំងឡាយ ចាប់ផ្តើមកើតឡើងរហូតដល់ស្លាប់ក្នុងភពថ្មីនោះ សង្គ្រោះចូលក្នុង អប្បរន្តភវចក្ក ។

ដែលថាអង្គរបស់បដិច្ចសមុប្បាទវិលវល់នោះ មានន័យថា កើតឡើងជាប់តគ្នា រវាងភពនេះនឹងភពមុខ និង ភពមុខជាមួយ នឹងភពខាងមុខទៀត ។

ការដឹងដែលបានទទួលអំពីការសម្តែង ប្រព្រឹត្តទៅរបស់ ភវចក្កទាំង ២ ។

ការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ ដូចដែលបានពោលមក ហើយនេះ ចង្អុលឱ្យឃើញថា កាលបើបច្ចុប្បន្នភពមានក៏ត្រូវមាន អតីតភព និងអនាគតតទៅទៀត ពោលគឺសត្វទាំងឡាយដែល កើតក្នុងភពនេះ ក៏ធ្លាប់កើតស្លាប់មកហើយរាប់មិនអស់ និង ត្រូវកើត ស្លាប់ទៅខាងមុខទៀត រាប់ក៏រាប់មិនអស់ដូចគ្នា ក្នុងការរកសមុដ្ឋាន ដែលធ្វើឱ្យសត្វទាំងឡាយកើតជារឿយៗ មិនចាំបាច់ត្រូវការទៅរក ឯណាទៀត គឺមាននៅក្នុងខ្លួនរបស់យើង ដែលបានដល់ការធ្វើកម្ម ផ្សេងៗ ដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ ដែលមានអវិជ្ជា តណ្ហា ជាហេតុនោះឯង ដូច្នោះ ព្រះអដ្ឋកថាចារ្យ ទើបពោលទុក ក្នុងសម្មោហវិនោទនីថា អ្នកដែលធ្វើទុច្ចរិតដែលនាំ ឱ្យទៅកាន់ទុគ្គតិ ភូមិនោះ ព្រោះមាន អវិជ្ជា ជាហេតុពិសេស និងតណ្ហាជាហេតុសាមញ្ញ អ្នកដែលធ្វើ សុច្ចរិតដែលនាំទៅកាន់ សុគតិភូមិនោះ ព្រោះអាស្រ័យ តណ្ហាជា ហេតុពិសេស និងមានអវិជ្ជា ជាហេតុសាមញ្ញ ។

**អធិប្បាយថា** អ្នកដែលធ្វើទុច្ចរិតផ្សេងៗ នោះ ក៏មកអំពីថា អ្នកនោះ មិនឃើញទោសរបស់ទុច្ចរិត គឺធ្វើទុច្ចរិតផ្សេងៗ នេះ មិនបាននាំសេចក្តីត្រេកអរមកកាន់ខ្លួន មិនមានប្រយោជន៍មានតែ សាបសូន្យប្រយោជន៍ និងនាំផលអន្តរាយមកឱ្យតែប៉ុណ្ណោះ ការមិន ឃើញ ទោសផ្សេងៗ នេះ ក៏ដោយអំណាចអវិជ្ជា ជាគ្រឿងបិទបាំង

និងតណ្ហាជាអ្នកពេញចិត្តឱ្យធ្វើឧបមាដូចគោ ដែលត្រូវគេទូន្មានដោយការយកភ្លើងដុត ហើយនិងវាយដោយដំបង គោនោះរមែងមានអាការៈបំរាស់នន្ទៀលនិងមានការស្រេចទឹកជាកម្លាំង កាលបើជួបទឹកក្តៅដែលគេនាំមកឱ្យផឹក ក៏ប្រញាប់ផឹក កាលបើផឹកចូលទៅហើយក៏ទទួលសេចក្តីទុក្ខក្រៃលែងឡើងទៀត ព្រោះទឹកក្តៅបានចូលដល់មាត់និងក តែគោនោះក៏ត្រូវព្យាយាមផឹក ដោយអំណាចនៃសេចក្តីក្តៅក្រហាយអន្ទះអន្ទែង ដោយទឹកនោះឯង សេចក្តីនេះយ៉ាងណា អ្នកព្យាយាមធ្វើទុច្ចរិត ដែលជាហេតុនាំឱ្យទៅកើតអបាយភូមិ ដោយអំណាចអវិជ្ជា និងតណ្ហា ។ ចំណែកអ្នកធ្វើសុចរិតផ្សេងៗ ក៏មកអំពីថាអ្នកនោះ ខ្លាចសេចក្តីទុក្ខលំបាក ដែលបានទទួល ក្នុងទុគ្គតិភូមិ និងប្រាថ្នាឱ្យបានទទួលសេចក្តីសុខ ជាមនុស្ស ទេវតា និង ព្រហ្ម តទៅទើបបានព្យាយាមធ្វើកុសលផ្សេងៗ មានទាន សីល ភាវនា ដែលជាកម្មគួរត្រេកអរ នាំសេចក្តីជ្រះថ្លាមកដល់ខ្លួន ដែលជាវត្ថុមានប្រយោជន៍ នាំផលល្អមកឱ្យ តែអ្នកនោះមិនឃើញទោសក្នុងវដ្តទុក្ខ ដែលធ្វើឱ្យវិលវល់កើត ចាស់ ឈឺ ស្លាប់គេចមិនផុត ឧបមាដូចជាគោ ដែលគេទូន្មានដោយប្រការផ្សេងៗ ដូចដែលបានពោលមកហើយ កាលបើស្រេចទឹក ជួបទឹកត្រជាក់ដែលគេនាំឱ្យផឹកក៏ប្រញាប់ផឹក កាលបើបានផឹកទឹកត្រជាក់ហើយ ក៏ដឹងថា បំបាត់ភាពក្តៅក្រហាយបាន សេចក្តីនេះយ៉ាងណា អ្នកដែលព្យាយាមធ្វើសុចរិតផ្សេងៗ នាំទៅកាន់សុគ្គតិភូមិ ដោយអំណាចតណ្ហា និងអវិជ្ជាក៏ដូច្នោះឯង ។

ការប្រព្រឹត្តទៅរបស់ភវចក្ក ដែលមានជាប្រធានដឹកនាំខាងមុខ និងខាងក្រោយ បានដល់ អវិជ្ជា និងតណ្ហា ដែលនាំសត្វទាំងឡាយវិលវល់ក្នុងភពតូច និងភពធំ មិនមានទីបំផុត ប្រៀបដូចរថភ្លើងដែលមានក្បាលពីរ ទាំងខាងមុខ និងខាងក្រោយ ដែលនាំរថភ្លើងនោះទៅមកបាន ដូចដីកាចារ្យ សំដែងការប្រព្រឹត្តទៅនៃវដ្តមូលទាំង ២ ប្រៀបដូចជារថភ្លើងដែលមានក្បាលពីរដូច្នេះថា :

**ឱគ្គច្ឆន្តោវ ចុគ្គច្ឆំ ទុស្សីសោ អគ្គគោ រថោ**

**ឯវំភវរថោយាតិ ភវរថោ យាតិ ចិរំសង្សារអញ្ឆសេ ។**

រថភ្លើងដែលមានក្បាលពីរ គឺអវិជ្ជា និងតណ្ហា ដែលវិលទៅមកឡើងចុះបានក្នុងសង្សារវដ្ត គឺទៅកាន់ទុគ្គតិខ្លះ ឡើងទៅកាន់សុគតិខ្លះ អស់កាលជាយូរ ដូចជារថភ្លើងដែលមានក្បាលពីរ វិលចុះខ្លះឡើងខ្លះ ដូច្នោះឯង ម្យ៉ាងទៀត សង្សារវដ្តនេះ គឺជាការកើតឡើងជាប់តគ្នារបស់សត្វលោកទាំងឡាយ ដែលជាការកើតឡើងជាប់តគ្នារបស់ខន្ធ អាយតនៈធាតុ បានដល់បដិច្ចសមុប្បាទ ដូចព្រះពុទ្ធ-ឃោសាចារ្យសំដែងទុកក្នុងអដ្ឋសាលិនីថា

**ខន្ធានញ្ច បដិបាតិ ធាតុអាយតនាន ច**

**អព្វោច្ឆិន្នំ វដ្តមានា សង្សារោតិ បវុច្ចតិ។**

ការកើតឡើងប្រព្រឹត្ត ទៅជាប់តគ្នាមិនដាច់របស់ខន្ធ ធាតុអាយតនៈ ហៅថា សង្សារវដ្ត ។

អធិប្បាយក្នុងគាថាបាលីចំណុចលេខ ១០ ដែលសំដែងអំពីការដាច់ចុះនៃវដ្តទាំង ៣ និងសមុដ្ឋានរបស់អវិជ្ជា ។

ហេតុនាំឱ្យវដ្តទាំង៣ដាច់ចុះ តាមធម្មតាដើមឈើរមែងចម្រើនបានក៏ត្រូវអាស្រ័យដី និងឬសកែវ កាលបើឬសត្រូវដាច់ចេញហើយ ដើមឈើនោះក៏មិនអាចកើតតទៅទៀតបាន និងផលចុងក្រោយ គឺស្លាប់ សេចក្តីនេះយ៉ាងណា នាមរូបគឺសត្វទាំងឡាយ ចម្រើនក្នុងសង្សារវដ្ត ដោយមិនមានទីបំផុតនោះ ក៏ព្រោះដោយអវិជ្ជា និងតណ្ហា កាលណា អវិជ្ជា និង តណ្ហាទាំង ២ នេះត្រូវទម្លាយចេញដោយអំណាចនៃអរហត្តមគ្គហើយ សេចក្តីចម្រើនរបស់នាមរូបបានដល់ ការវិលវល់របស់សត្វទាំងឡាយនោះ ក៏ដល់ទីបញ្ចប់ ដូចព្រះអនុរុទ្ធាចារ្យសម្តែងថា **តេសមេវ ច មូលានំ និរោធេន និរុជ្ឈតិ** កាលបើវដ្តមូលទាំង ២ នេះ រលត់អស់មិនមានសេសសល់ ដោយអំណាចនៃអរហត្តមគ្គហើយ ការវិលវល់នៃបដិច្ចសមុប្បាទ គឺ វដ្តទាំង ៣ ក៏ត្រូវរលត់ ដែលត្រូវគ្នាជាមួយព្រះពុទ្ធដីកា សម្តែងទុកក្នុងបដិច្ចសមុប្បាទថា **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ជាដើម និងសម្តែងទុកក្នុងសំយុត្តនិកាយថា

**យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនទេវ រុហត្តិឯវំបិ តណ្ហានុស្សយេ អនុហតេ និព្វត្តិ ទុក្ខមិទំ បុនប្បុនំ**
ឬសកែវគឺ តណ្ហានុស្ស័យ បើនូវមិនទាន់ទម្លាយឱ្យអស់ វដ្តទុក្ខ គឺជាតិ ជរា ព្យាធិ មរណៈ ជាដើម ក៏រមែងកើតឡើងជាញយៗ (បើបានប្រហារតណ្ហានុស្ស័យឱ្យអស់ហើយវដ្តទុក្ខទាំងពួងក៏ត្រូវរលត់) ដូចឬសកែវដែលមានឬសតូចៗ ជាបរិវារ បើតាំងនៅមាំមិនទម្លាយហើយសូម្បីនឹងកាត់ដើមចេញហើយ ដើមឈើនោះរមែងចម្រើនឡើង បានទៀត (កាលបើ ឬសកែវ ដាច់ចេញហើយ ដើមឈើក៏រមែងចម្រើនទៅមិនបាន)ដូច្នោះ ។

## សមុដ្ឋានរបស់ អវិជ្ជា

បើមានពាក្យសួរឡើងថា សង្ខារ ទាំង ៣ ដែលជាបុណ្យជាបាបកើតឡើង ដោយអាស្រ័យអវិជ្ជា ជាហេតុ រហូតដល់ជរា មរណៈ សោកបរិទេវ ទុក្ខ ទោមនស្ស ឧបាយាសៈ កើតឡើងអាស្រ័យជាតិជាហេតុ ។

អ្វីជាហេតុ នាំឱ្យអវិជ្ជាកើត ? ដូចនេះកាលបើពោលដល់សមុដ្ឋានរបស់អវិជ្ជា ព្រះអនុរុទ្ធាចារ្យសម្ដែងថា

**ជរាមរណមុច្ឆាយ     បីឡិតាន មភិណ្ហសោ**
**អាសវានំ សមុប្បាទា អវិជ្ជាច បវត្តតិ ។**

អវិជ្ជាកើតឡើងបានក៏ព្រោះអាស្រ័យការកើតឡើងនៃអាសវៈធម៌ ដែលនៅក្នុងសន្ដានរបស់សត្វទាំងឡាយ អ្នកដែលត្រូវបៀតបៀនដោយការចាស់ ការស្លាប់ និងធម៌ជាហេតុនៃសេចក្ដីវង្វេង គឺសោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ជារឿយៗ នោះឯង ។

ពាក្យថា មុច្ឆា ប្រែថា វង្វេង ក្នុងទីនេះសំដៅយកធម៌ជាហេតុឱ្យធ្លាក់ចុះ ក្នុងសោក ៈបរិទេវៈ ជាដើម ។

អធិប្បាយថា សមុដ្ឋានរបស់អវិជ្ជា បានដល់អាសវៈទាំង ៤ មាន កាមាសវៈ ជាដើម មានន័យថា ក្នុងបដិច្ចសមុប្បាទបាលីនេះ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈទាំង ៥ នេះ ទ្រង់សំដែងទុកខាងចុង កាលបើដោយអង្គធម៌ហើយ សោកៈ ទោមនស្ស ឧបាយាសៈ ទាំង ៣ នេះជាទោមនស្ស និងទោសចេតសិក កាលបើអ្នកមានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីតូចចិត្ត កើតឡើងហើយ មោហៈ ក៏រមែងកើតរួមផងដែរ និងបរិទេវៈ សេចក្ដីព្រួយក៏កើតមកអំពីទោសចិត្ត ដូច្នោះ កាលខណៈសេចក្ដីព្រួយកើត មោហៈក៏រួមជាមួយផងដែរ ចំណែកទុក្ខកាយជាហេតុនាំឱ្យមិនសប្បាយចិត្តកើតឡើងបាន ក្នុងខណៈដែលមិនសប្បាយចិត្តកើតឡើង មោហៈក៏កើតរួមជាមួយក្នុងខណៈនោះឯង មោហៈកើតព្រមជាមួយនិងសោកៈ បរិទេវ ទោមនស្ស ឧបាយាសៈ និង កើតខាងក្រោយអំពីទុក្ខកាយ

នោះឯង ហៅថា អវិជ្ជា ដូចព្រះពុទ្ធឃោសាចារ្យ សំដែងទុកក្នុងបដិច្ចសមុប្បាទអដ្ឋកថាថា **ឯត្ថ ហិ សោក ទុក្ខ ទោមនស្សុបាយាសា អវិជ្ជាយ អវិយោគិនោ បរិទេវោ ច នាមូឡ្ហមូឡ្ហស្សាតិ ទេសុ តាវ សិទ្ធេសុ ហោតិ អវិជ្ជា** ប្រែថា ក្នុងការប្រព្រឹត្តរបស់ភវចក្ក សោកៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ ទាំងនេះ រមែងប្រកបជាមួយអវិជ្ជា បែកពីគ្នាមិនបាន ចំណែកបរិទេវៈ ក៏រមែងកើតដល់អ្នកដែលមានសេចក្តីវង្វេងដូច្នេះ កាលសោកៈ ជាដើមកើតឡើងស្រេចហើយ អវិជ្ជា ក៏កើតបានដែរ សមុដ្ឋានរបស់សោកៈ ជាដើមក៏ជាសមុដ្ឋានរបស់ អវិជ្ជា ។

ក្នុងបដិច្ចសមុប្បាទសម្តែងទុកថា ជាតិប្បច្ចយា សោកៈបរិទេវៈ **ទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងកើតមានព្រោះជាតិជាបច្ច័យពិត ប៉ុន្តែ ជាតិមិនមែនជាហេតុជិតរបស់សោកៈ បរិទេវៈ ជាដើម តែជាហេតុឆ្ងាយ និងជាមូលហេតុ គឺសេចក្តីសោក ជាដើម កើតឡើងបាននោះនឹងវៀរជាតិហើយ កើតឡើងមិនបាន ចំណែកធម៌ដែលជាហេតុជិតនោះគឺអាសវៈធម៌ទាំង៤ដូចសត្វ-ទាំងឡាយដែលកើតមកហើយ ក៏ត្រូវអាស្រ័យហេតុ ២ ប្រការ គឺហេតុជិត និងហេតុឆ្ងាយ ឬហៅថា មូលហេតុ និងមូលីហេតុ ក៏បាន ហេតុ

ឆ្ងាយនោះបានដល់អកុសលកម្ម និងលោកិយកុសលកម្ម ដែលធ្វើមកក្នុងភពមុន ហេតុជិត បានដល់ មាតា បិតា ដូច្នោះជាតិជាហេតុឆ្ងាយ អាសវៈ ជាហេតុជិត របស់សោកៈ បរិទេវៈ ជាដើម សមដូចព្រះពុទ្ធឃោសាចារ្យសំដែងទុកក្នុង បដិច្ចសមុប្បាទវិភង្គថា **អាសវសមុទយា ចេតេ សោកាទយោ ហោន្តិ** សេចក្ដីសោកជាដើមកើតឡើង ព្រោះការកើតឡើងរបស់អាសវៈ សមដូចព្រះមានព្រះភាគសំដែងទុកថា **អាសវសមុ ទយា អវិជ្ជាសមុទយោ** ការកើតឡើងរបស់អវិជ្ជានោះ ក៏ព្រោះ អាស្រ័យការកើតឡើងរបស់អាសវៈជាហេតុ ។ ដូច្នោះ តាមដែលព្រះពុទ្ធឃោសាចារ្យសំដែងទុកក្នុងវិសុទ្ធិមគ្គអដ្ឋកថាថា **ឥតិ យស្មា អាសវសមុទយា ឯតេ ធម្មា ហោន្តិ តស្មា ឯតេ សិជ្ឈមានា អវិជ្ជាយ ហេតុភូតេ អាសវេ សាធេន្តិ អាសវេសុ ច សទ្ធេសុ បច្ចយភាវេ ភាវតោ សិទ្ធា ហោតិ ។** សោកៈ ជាដើម រមែងកើតឡើង ព្រោះការកើតឡើងរបស់អាសវៈ ដោយន័យដូចដែលបានពោលមកហើយ សោកៈជាដើមនេះ កើតឡើងហើយ ក៏រមែងធ្វើឱ្យដឹងដល់អាសវៈ ដែលជាហេតុនៃអវិជ្ជាក៏សម្រេចបាន ហើយកាលអាសវៈទាំងឡាយ កើតឡើងស្រេចហើយ អវិជ្ជាក៏រមែងកើតបានដែរ ព្រោះមានហេតុគឺ

អាសវៈកើតឡើងហើយ ផលគឺអវិជ្ជា ក៏កើតផងដែរ ការកើតឡើងរបស់សោកៈ ជាដើមដោយអាស្រ័យអាសវៈទាំង ៤ ។

**១.សោកៈ** ជាដើមកើតឡើងព្រោះអាស្រ័យកាមាសវៈជាហេតុគឺ កាល មនុស្សយើងស្រលាញ់នរណាម្នាក់ មានមាតា បិតា ភរិយា ស្វាមី កូន ចៅ ហើយក៏ស្លាប់ទៅ យើងរមែងកើតសេចក្តីសោក ខ្សឹកខ្សួល ជាដើម ព្រោះមានអ្នកជាទីស្រលាញ់បាត់បង់ជីវិត សមដូចព្រះមាន-ព្រះភាគ សំដែងទុកថា **កាមតោ ជាយតេ សោកោ** ជាដើម សេចក្តីសោកកើត ព្រោះសេចក្តីស្រលាញ់ សេចក្តីសោកជាដើមនេះ កើតឡើងព្រោះកាមាសវៈ ជាហេតុដូច្នេះ ។

**២.សោកៈ** ជាដើមកើតឡើងព្រោះអាស្រ័យភវាសវៈ ជាហេតុគឺ ពួក ទេវតាទាំងឡាយ មានសេចក្តីត្រេកអរក្នុងឋានរបស់ខ្លួន គឺអ្នក មាន អាយុវែង មានពណ៌សម្បុរល្អ មានសេចក្តីសុខក្នុងវិមានរបស់ខ្លួនអស់កាលដ៏យូរ ដោយអំណាចភវាសវៈ បើមានឱកាសស្តាប់ធម៌ ទាក់ទង់ រឿង អនិច្ចំ ទុក្ខំ អនត្តា បណ្តាលវត្ថុមានជីវិតនិងមិនមានជីវិត ទាំងឡាយក្នុងលោកនេះសុទ្ធតែមិនទៀងជាទុក្ខ និងមិននៅក្នុងបង្គាប់ បញ្ជារបស់អ្នកណា ដូច្នេះ សម្បុរល្អក្តី សេចក្តីសុខសប្បាយផ្សេងៗក្តី អាយុក្តី ទាំងនេះ ក៏មិនតាំងនៅបាន រមែងប្រែប្រួលជាធម្មតា

បើពួកទេវតាបានស្តាប់ហើយ មានសេចក្តីភ័យខ្លាច កើតសេចក្តីសោកឡើង នឹកដល់សម្បត្តិ សេចក្តីសុខ អំណាច មានអាយុយឺនយូររបស់ខ្លួន ដែលកំពុងទទួលនោះ និងមិនឋិតនៅ ដូចព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា **យេបិ តេ ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា ឧច្ចេសុ វិមានេសុ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ តេបិ តថាគតស្ស ធម្មទេសនំ សុត្វា ភយំ សន្តានំ សង្វេគមាបជ្ជន្តិ** ទេវតាទាំងឡាយមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន អស់កាលជាយូរក្នុងវិមានដ៏ប្រណីត ទេវតានោះ កាលបានស្តាប់ធម៌ទេសនារបស់តថាគតហើយ រមែងដល់នូវសេចក្តីភ័យតក់ស្លុត មិនសប្បាយចិត្ត នេះជាសោកៈ ជាដើម កើតព្រោះ អាស្រ័យភវាសវៈជាហេតុ ។

៣.**សោកៈ** ជាដើមកើតព្រោះអាស្រ័យទិដ្ឋាសវៈជាហេតុគឺៈ អ្នកមានសេចក្តីប្រកាន់មាំថា ខ្លួនជាយើង ខ្លួនជារបស់យើង ហើយក៏ផ្ទាក់ផ្តួមខ្លួនជានិច្ច ក្នុងកាលតមកខ្លួននោះឯង កើតអាការៈបៀតបៀនដោយធម្មជាតិ ឬកើតការបៀតបៀនដោយរោគភ័យ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា **អហំ រូបំ មម រូបន្តិ បរិយុដ្ឋដ្ឋាយិនោ រូបវិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវ**

**ទុក្ខទោមនស្សុបាយាសា** សត្វទាំងឡាយមានសេចក្តីឃើញខុស ជាប្រក្រតីថា កាយនេះជាយើង ឬយើងគឺកាយ កាយនេះជារបស់យើង ដូច្នេះហើយ រាងកាយនោះប្រែប្រួលវិបរិត ទៅតាមសភាវៈ សេចក្តីសោក ជាដើមរមែងកើតដល់អ្នកនោះ សោកៈ ជាដើម កើតឡើង ព្រោះអាស្រ័យទិដ្ឋាសវៈ ជាហេតុ ។

៤.**សោកៈ** ជាដើមកើតឡើងព្រោះអវិជ្ជាសវៈ ជាហេតុគឺៈ អ្នកគ្មានបញ្ញា មានសេចក្តីដឹងតិច ជាមនុស្សល្ងង់ ជាមនុស្សអន្ធពាល អ្នកមានវ័យក្មេងឬអ្នកដែលបានទទួលការសិក្សាច្រើន តែគ្មានបញ្ញា បុគ្គលនោះឯង រមែងធ្វើក្នុងវត្ថុដែលមិនគួរធ្វើ និងមិនធ្វើក្នុង វត្ថុដែលគួធ្វើ ដោយអំណាចអវិជ្ជាសវៈ គឺ មោហៈ ជាអ្នកបិទបាំង មិនឱ្យឃើញទោស និងប្រយោជន៍ ដូច្នោះ ទើបធ្វើក្នុងវត្ថុដែលមិនគួរធ្វើ ព្រោះមិនឃើញទោស និងមិនធ្វើក្នុងវត្ថុដែលគួរធ្វើព្រោះមិនឃើញប្រយោជន៍ បុគ្គលជំពូកនេះ រមែងជួបសេចក្តីទុក្ខកាយ ទុក្ខចិត្ត ជាហេតុឱ្យសេចក្តីសោកកើតឡើង ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **សខោ សោភិក្ខវេ ពាលោ ទិដ្ឋេវ ធម្មេ តិវិធំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកដែលមិនមានបញ្ញាត្រូវប្រសព្វ ជាមួយសេចក្តី លំបាក ៣ យ៉ាងគឺ សោកៈ បរិទេវៈ ទុក្ខកាយ និងទុក្ខចិត្ត ក្នុងភពនោះឯង សោកៈ ជាដើមកើតព្រោះ អវិជ្ជាសវៈ ជាហេតុ ។

## សមុដ្ឋានរបស់ អាសវៈ

មានពាក្យសួរថា អាសវៈ ទាំងនេះជាហេតុរបស់ អវិជ្ជា ហើយចុះអ្វីជាហេតុរបស់អាសវៈ ?

ឆ្លើយថា អាសវៈ ទាំងនេះសង្គ្រោះចូលក្នុង តណ្ហា ឧបាទាន កម្មភព តាមសមគួរ ដូច្នោះ ធម៌ដែលជាហេតុឱ្យតណ្ហា ឧបាទាន កុសល អកុសល កម្មភវៈ កើតឡើងនោះ រមែងពោលបានថា ជាហេតុរបស់អាសវៈ ។

សម្តែងហេតុដែលលើកយក អវិជ្ជា មកតាំងទុកដំបូងក្នុងបដិច្ចសមុប្បាទ កាល អវិជ្ជា កើតឡើងព្រោះអាស្រ័យការកើតឡើងនៃអាសវៈ ដូចម្តេចទើបលើកយកអវិជ្ជា មកដាក់ខាងដើម ?

កាលប្រព្រឹត្តទៅរបស់នាមរូប ដែលវិលវល់ក្នុងសង្សារវដ្ត មាន អវិជ្ជា ជាតួសំខាន់ឈ្មោះថា វដ្តសីសៈ ដែលដូចគ្នានិងសីសៈរបស់មនុស្សទាំងឡាយ ដូច្នោះ ព្រះពុទ្ធអង្គទើបត្រាស់អវិជ្ជា ជាហេតុដំបូង ។

អធិប្បាយថា ក្នុងបដិច្ចសមុប្បាទធម៌ អវិជ្ជា និងតណ្ហា ទាំង ២ នេះ ដូចជាសីសៈរបស់មនុស្សទាំងឡាយ និងក្នុងកាលសាងសង្ខារ

ផ្សេងៗ មានបុញ្ញាភិសង្ខារ ជាដើម សម្រេចបាននោះ ព្រោះអាស្រ័យសេចក្ដីត្រេកអរក្នុងអារម្មណ៍ផ្សេងៗ គឺតណ្ហា ជាហេតុ តណ្ហា គឺសេចក្ដីត្រេកអរក្នុងអារម្មណ៍កើតឡើងបាន ក៏ត្រូវអវិជ្ជាជាអ្នកបិទបាំង មិន-ឱ្យឃើញសភាវៈតាមសេចក្ដីពិត បើមិនមានអវិជ្ជា ជាអ្នកបិទបាំងហើយ តណ្ហា ក៏កើតឡើងមិនបាន កាលបើតណ្ហាកើតឡើងមិនបានហើយ ការធ្វើកម្មផ្សេងៗ របស់មនុស្សទាំងឡាយ ក៏មិនសម្រេចជាសង្ខារ ដូច្នេះ អវិជ្ជា និងតណ្ហា ទាំង ២ នេះ អវិជ្ជា ជាប្រធានតណ្ហា ដោយហេតុនេះ ព្រះពុទ្ធទើបទ្រង់លើកយកអវិជ្ជា ជាហេតុដំបូងក្នុងបដិច្ចសមុប្បាទ ។ ក្នុងការសម្ដែង គាថា ចុងក្រោយថា **វដ្ដមាពន្ធមិច្ចេវំ** ជាដើម រហូតដល់ **បថបេសិ មហាមុនិ** គាថាបទនេះ មានន័យថា ការរស់នៅរបស់សត្វទាំងឡាយ ដែលវិលវល់ជាប់តគ្នា គឺការកើតហើយត្រូវស្លាប់ កាលបើស្លាប់ហើយក៏កើតឡើង ដូច្នេះហៅថា តគ្នាមិនដាច់ បើថាដោយធម្មាធិដ្ឋានសុទ្ធតែជាការកើតឡើងរបស់បដិច្ចសមុប្បាទ ធមិទាំងអស់ពោលគឺមានអវិជ្ជាហើយ ជាហេតុឱ្យសង្ខារកើតឡើង ដោយចំពោះ រកសត្វបុគ្គល តួខ្លួន ជាដើមមិនមែនជាអ្នកកើត។ ហើយនឹងមានជាតិជាហេតុឱ្យជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ កើតឡើង រកសត្វ បុគ្គល តួខ្លួន ជាដើម មិនមែនជាអ្នកកើត

សេចក្តីប្រព្រឹត្តទៅដូចនេះ ឈ្មោះថា វដ្តសង្សារ ព្រោះមានសេចក្តីជាប់តគ្នាមិនដាច់ ម្យ៉ាងទៀត រមែងប្រព្រឹត្តទៅក្នុងភូមិទាំង ៣ និងរកខាងដើម ខាងចុងមិនបាន សមដូចព្រះមហាមុនី ត្រាស់ថា បដិច្ចសមុប្បាទ ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងកណ្តាលភិក្ខុទាំងឡាយថា

**អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វកោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសារតំ។**

ម្នាលភិក្ខុទាំងឡាយ សង្សារវដ្តនេះ រមែងរកខាងដើមមិនបាន និងខាងចុងរមែងមិនប្រាកដ សត្វទាំងឡាយមានអវិជ្ជានីវរណៈ និងតណ្ហាសញ្ញោជនៈ ទាំងនេះ ទើបវិលវល់ទៅក្នុងសង្សារវដ្ត ។

ចំណែកអង្គរបស់បដិច្ចសមុប្បាទ ដោយសច្ចៈតាមអភិធម្មភាជនីយន័យ

អវិជ្ជា សង្ខារ ចាត់ជាសមុទយសច្ចៈ

វិញ្ញាណ នាមរូប សឡាយតនៈ ផស្ស វេទនា ចាត់ជាទុក្ខសច្ចៈ

តណ្ហា ឧបាទាន កម្មភព ចាត់ជាសមុទយសច្ចៈ

ឧប្បត្តិភព ជាតិ ជរាមរណៈ ចាត់ជាទុក្ខសច្ចៈ

## ការសម្តែងប្រៀបធៀបអង្គបដិច្ចសមុប្បាទតាមន័យ សម្មោហវិនោទនីអដ្ឋកថា

**អវិជ្ជា** ប្រៀបដូចជាមនុស្សខ្វាក់ភ្នែក

**សង្ខារ** ប្រៀបដូចជាមនុស្សខ្វាក់ភ្នែកដើរជំពប់

**វិញ្ញាណ** ប្រៀបដូចជាមនុស្សខ្វាក់ភ្នែកដើរជំពប់ដួល

**នាមរូប** ប្រៀបដូចជាមនុស្សខ្វាក់ភ្នែកដើរដួលមានរបួស

**សឡាយតនៈ** ប្រៀបធៀបដូចដំបៅមានពងថ្មីជាប់នឹងដំបៅចាស់

**ផស្សៈ** ប្រៀបដូចជាដំបៅចាស់និងពងថ្មីប៉ះនិងវត្ថុណាមួយ

**វេទនា** ប្រៀបដូចជាមនុស្សឈឺមុខរបួស

**តណ្ហា** ប្រៀបដូចជា អ្នកត្រូវការថ្នាំព្យាបាលដំបៅនោះ

**ឧបាទាន** ប្រៀបដូចជាបានថ្នាំមិនត្រូវនឹងជំងឺ

**ភវ** ប្រៀបដូចជាបានថ្នាំនោះមកលាប

**ជាតិ** ប្រៀបដូចជាដំបៅរាលដាលឡើងព្រោះថ្នាំមិនត្រូវ

**ជរាមរណៈ** ប្រៀបធៀបដូចដំបៅបែកខ្ទុះពេញខ្លួន ។

## ការពិចារណាបដិច្ចសមុប្បាទដោយន័យទាំង ៤ ដើម្បីលះទិដ្ឋិ៧

ការពិចារណាបដិច្ចសមុប្បាទដើម្បីឱ្យលះទិដ្ឋិ ៧យ៉ាង បាននោះ មាន ៤ ន័យ គឺ :

១.ឯកត្តន័យ ២.នានត្តន័យ ៣.អព្យាបារន័យ ៤.ឯវំធម្មតាន័យ

១.កាលបើពិចារណាហើយដឹងថា ខន្ធ ៥ របស់សត្វទាំងឡាយនោះ មានការកើតការរលត់ជាប់បន្តគ្នាមិនដាច់ខ្សែក្នុងភពនេះទៅក្នុងភពត១ ទៅទៀត ការពិចារណាដឹងយ៉ាងនេះហៅថា **ឯកត្តន័យ** ។

២.កាលបើពិចារណាហើយដឹងថា ការជាប់បន្តគ្នារបស់ ខន្ធ ៥ នេះ សូម្បីនឹងប្រព្រឹត្តទៅដោយមិនដាច់ក៏ពិត តែសភាវៈរបស់បដិច្ចសមុប្បាទធម៌ទាំងនេះ មានសភាពផ្សេងគ្នា មានហេតុផលផ្សេងគ្នា ការពិចារណាដឹងយ៉ាងនេះហៅថា **នានត្តន័យ** ។

៣.កាលបើពិចារណាយ៉ាងនេះហើយដឹងថា ហេតុផ្សេង១ មានអវិជ្ជាជាដើមឱ្យផលផ្សេង១មានសង្ខារជាដើម កើតនោះមិនមានការខ្វល់ខ្វាយព្យាយាមដែលនឹងឱ្យផលកើតឡើង ធម៌ដែលជាហេតុ និងជាផលនោះ ក៏កើតឡើងប្រព្រឹត្តទៅតាមសភាវៈប៉ុណ្ណោះ មិនមានវត្ថុណាមួយ មកចាត់ចែងឱ្យប្រព្រឹត្តទៅ បានការពិចារណាដឹងយ៉ាងនេះហៅថា **អព្យាបារន័យ** ។

៤.កាលបើពិចារណាហើយដឹងថា ការកើតឡើងរបស់ផលធម៌ផ្សេង១ នោះមានហេតុរបស់ខ្លួន ១ ដោយចំពោះដូចគ្នានឹង សង្ខារ

កើតឡើងក៏មានអវិជ្ជាជាហេតុ ក្រៅពីអវិជ្ជា ធម៌ផ្សេងៗ នឹងជាហេតុឱ្យសង្ខារកើតឡើងមិនបានទេ ការពិចារណាដឹងយ៉ាងនេះហៅថា**ឯវំ-ធម្មត្តាន័យ** ។

ការពិចារណាដោយឯកត្តន័យ អាចលះឧច្ឆេទទិដ្ឋិ និងនត្ថិកទិដ្ឋិបាន ព្រោះមើលឃើញសន្តតិជាប់បន្តគ្នាមិនដាច់ គឺកើតហើយស្លាប់ៗហើយកើត មិនមែនសូន្យបាត់ទៅ។

ការពិចារណាដោយនានត្តន័យ អាចលះសស្សតទិដ្ឋិបាន ព្រោះឃើញសភាពរបស់ហេតុ និងសភាពរបស់ផលនោះមិនដូចគ្នា ហើយធម៌ដែលជាហេតុជាផលក៏កើតឡើងថ្មីជានិច្ច មិនមែនកើតឡើងហើយក៏តាំងនៅបានរហូត ដូចជាវេទនា ជាមួយតណ្ហា ដែលជាហេតុ និងជាផលមួយគូនេះ កាលបើកើតហើយក៏រលត់ទៅហើយក៏កើតថ្មីទៀត មិនមានជារបស់ចាស់តាំងនៅ មានសេចក្តីប្រែប្រួលៗ ដូច្នោះ ការយល់ឃើញ ថាទៀងគឺ សស្សតទិដ្ឋិទើបបាត់ទៅ។

ការពិចារណាដោយអព្យាបារន័យ អាចលះឥស្សរនិម្មានវាទ-ទិដ្ឋិ និងអត្តទិដ្ឋិបាន ព្រោះឥស្សរនិម្មានវាទទិដ្ឋិនោះមានការយល់ឃើញថា វត្ថុផ្សេងៗ ដែលប្រាកដបានក្នុងលោកនេះមានព្រះជាអ្នកសាងប្រសិនបើមិនមានព្រះជាអ្នកសាងឡើងទេ វត្ថុផ្សេង ៗ ក៏មិនអាចកើតឡើងបាន។

ចំណែកអត្តទិដ្ឋិនោះ មានការយល់ឃើញថា ក្នុងសន្តានរបស់សត្វទាំងឡាយមានតួខ្លួន ហើយតួខ្លួននោះឯងជាអ្នកចាត់ចែងឱ្យ ធ្វើការផ្សេងៗ ទៅតាមការពេញចិត្តរបស់ខ្លួននោះ ព្រោះហេតុនោះកាលបើពិចារណាឃើញថា ហេតុផ្សេងៗ និងផលផ្សេងៗ កើតឡើងនោះ រមែងប្រព្រឹត្តទៅតាមសភាវធម៌របស់ខ្លួន ធម៌ដែលជាហេតុក៏មិនមានការកង្វល់ខ្វល់ខ្វាយណា ដើម្បីនឹងឱ្យផលរបស់ខ្លួនកើតបានឡើយ ជាអនត្តាពិតៗ កាលឃើញយ៉ាងនេះទើបទម្លាយទិដ្ឋិទាំង ២ ដូចដែលពោលហើយនេះ ។

ការពិចារណាដោយឯវំធម្មតាន័យ អាចលះអហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិបាន ព្រោះអហេតុកទិដ្ឋិនោះ មានការយល់ឃើញថា វត្ថុផ្សេងៗ ដែលកើតឡើង មិនបានកើតព្រោះអាស្រ័យហេតុកុសលកម្ម អកុសលកម្មណាមួយ សត្វទាំងឡាយដែលមានសេចក្ដីសុខ សេចក្ដីទុក្ខនោះ កើតឡើងឯងៗ តាមធម្មតា មិនបានកើតពីកុសលកម្ម អកុសល កម្មជាហេតុ ។

ចំណែកអកិរិយទិដ្ឋិនោះមានសេចក្ដីយល់ឃើញថា ការប្រព្រឹត្តល្អក៏ដោយមិនល្អក៏ដោយ មិនហៅថាជាកុសល អកុសលទេ ចេះតែធ្វើទៅ ព្រោះហេតុនោះអ្នកដែលពិចារណាតាមឯវំធម្មតាន័យនេះ រមែង

ឃើញថា ធម៌ដែលជាហេតុផលនោះរមែងកើតឡើង មិនបានដាច់ចេញពីគ្នា ព្រោះហេតុនោះ ទើបអាចទម្លាយទិដ្ឋិទាំង ២ ដូចដែលបានពោលហើយ ។

## គាថាពោលណែនាំក្នុងការពិចារណាបដិច្ចសមុប្បាទ

**អនាទិទំ ភវចក្កំ វីតការកវេទកំ**

**និច្ចសុខ សុភត្តេហិ សុញ្ញំ បស្សេ បុនប្បុនំ។**

ភវចក្រដែលសុទ្ធតែជាកងទុក្ខដែលវិលវល់វែងឆ្ងាយ រាប់ភពរាប់ជាតិមិនបាននេះ រមែងរកចំណុចខាងដើមនៃការវិលវល់នោះមិនបានប្រាសចាកតួខ្លួន គឺ អ្នកសាងនិងអ្នកសោយជាអនត្តាមិនមានសភាពដែលជា និច្ចៈ សុខៈ សុភៈ តែយ៉ាងណាអ្នកមានបញ្ញាគួរពិចារណាជា-និច្ច ដូចពោលមកនេះ ។

អ្នកដែលកាន់ព្រះពុទ្ធសាសនា និងចូលចិត្តពិចារណា ដល់រឿងរ៉ាវផ្សេងៗ ជានិច្ចនោះសូម្បីឈ្មោះថាលោកដែលយើងនៅនេះ រមែងមិនតាំងនៅបានរហូត ត្រូវមានការរលត់ និងកាលបើរលត់ ហើយក៏កើតឡើងថ្មីទៀត ចំណែកការប្រព្រឹត្តទៅរបស់សត្វទាំងឡាយនោះក៏ជឿតាមបដិច្ចសមុប្បាទដែលពោលថា ព្រោះអវិជ្ជាជាហេតុ ទើបនាំឱ្យកើតសង្ខារ ព្រោះសង្ខារជាហេតុទើបកើតវិញ្ញាណ ដូច្នេះជាដើម

តែក៏នៅគិតសង្ស័យឡើងថា ការកើតឡើងរបស់លោកនិងសត្វទាំងឡាយនោះ ចាប់ផ្ដើមកើតឡើងដំបូងនោះ ក្នុងវេលាណាកាលបើព្យាយាមពិចារណាទៅមកហើយក៏កាត់សេចក្ដីមិនបាន បុគ្គលដែលពិចារណាកាត់សេចក្ដីមិនបានទាំងនេះ ក៏កើតសេចក្ដីយល់ដោយខ្លួនឯង គឺបុគ្គលខ្លះក៏យល់ថា លោកនិងសត្វទាំងឡាយនេះ រមែងប្រាកដឡើងដោយប្រាសចាកហេតុដែលធ្វើឱ្យកើតឡើងក្នុងគ្រាដំបូង សម្រាប់ការដែលលោកត្រូវរលត់ និងដែលលោកកើតឡើងថ្មីក្ដី ឬអវិជ្ជាជាហេតុសង្ខារជាផល សង្ខារជាហេតុវិញ្ញាណជាផលជាដើមក្ដី ទាំងនេះក៏ជាហេតុដែលកើតឡើងខាងក្រោយ ដែលមានសត្វនិងលោកទាំងឡាយប្រាកដហើយប៉ុណ្ណោះ តែជាហេតុក្រោយមិនមែនជាហេតុចមុននោះទេ ព្រោះហេតុនោះអ្នកដែលមានសេចក្ដីយល់ដោយខ្លួនឯងយ៉ាងនេះ ទើបក្លាយ ជាអ្នកដែលមានអហេតុកទិដ្ឋិកើតឡើងដោយមិនដឹងខ្លួន បុគ្គលមួយពួកទៀតយល់ថា លោកនិងសត្វទាំងឡាយដែលកើតឡើងដោយអាស្រ័យហេតុផលដូចពោលហើយនោះ ជាហេតុផលដែលកើតឡើងតាមធម្មតា ក្រោយពីលោកនិងសត្វប្រាកដឡើងហើយប៉ុណ្ណោះ ចំណែកដើមហេតុដំបូងនោះត្រូវមានអ្នកជាធំគឺព្រះអ្នកសាងឡើង បើមិនមានព្រះជាអ្នកសាងឡើងទេវត្ថុផ្សេង ៗ ទាំងនេះក៏មិនអាចកើតឡើងបានព្រោះហេតុនោះដែលមានសេចក្ដីយល់ឃើញខ្លួនឯងយ៉ាងនេះ ទើបក្លាយជា ពួកឥស្សរនិម្មានវាទទិដ្ឋិ ដោយមិនដឹងខ្លួនដូចគ្នា ។

បុគ្គលទាំង២ពួកដូចពោលមកនេះ ស្រេចតែមានការគិតដែលធ្វើឱ្យខូចប្រយោជន៍ គឺវត្ថុដែលមិនគួរគិតក៏យកមកគិត រហូតធ្វើខ្លួនឱ្យក្លាយ ជាពួកមិច្ឆាទិដ្ឋិ ដោយហេតុនេះព្រះដ៏មានព្រះភាគទើបសម្តែងដាស់តឿនពួកភិក្ខុទាំងឡាយថា

ចត្តារិមានិ ភិក្ខវេ អចិន្តេយ្យានិ ន ចត្តេតព្វានិ យានិ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស កតមានិ ចត្តារិ ? ពុទ្ធានំ ភិក្ខវេ ពុទ្ធាវិសយោ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស ឈាយិស្ស ភិក្ខវេ ឈានវិសយោ អចិន្តេយោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស កម្មវិបាកោ ភិក្ខវេ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស លោកចិន្តា ភិក្ខវេ អចិន្តេយ្យោ ន ចិន្តេតព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស ឥមានិ ខោ ភិក្ខវេ ចត្តារិ អចិន្តេយ្យានិ ន ចិន្តេតព្វានិ យានិ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស អស្សាតិ។

ម្នាលភិក្ខុទាំងឡាយវត្ថុដែលមិនគួរគិតដែលឈ្មោះថា អចិន្តេ-យ្យធម៌ មាន ៤ ប្រការ បើអ្នកណាយកមកគិតហើយ អ្នកនោះក៏គប្បី

ជាអ្នកមានចំណែកនៃការឆ្កួត មានសេចក្ដីលំបាកចិត្ត ។ វត្ថុដែលមិនគួរគិតទាំង ៤ យ៉ាងនោះតើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ **ពុទ្ធវិស័យ** គឺរឿងដែលទាក់ទងជាមួយនឹងការប្រព្រឹត្តទៅ ជាមួយសព្វញ្ញុតញ្ញាណ និងអានុភាពរបស់ព្រះសម្មាសម្ពុទ្ធក៏ជាវត្ថុដែលមិនគួរគិតម្យ៉ាង **ឈានវិស័យ** គឺឈានអភិញ្ញានៃលោកអ្នកដែលទ្រទ្រង់ឥទ្ធិឫទ្ធិ ក៏ជាវត្ថុដែលមិនគួរគិតម្យ៉ាង **កម្មវិបាក** គឺផលនៃកម្មទាំងឡាយ មានទិដ្ឋធម្មវេទនីយកម្មជាដើមក៏ជាវត្ថុដែលមិនគួរគិតម្យ៉ាង **លោកចិន្តា** គឺការប្រព្រឹត្តទៅរបស់លោក គឺលោកដែលជាទីអាស្រ័យរបស់សត្វទាំងឡាយ ផែនដី ភ្នំ ទន្លេ ស្ទឹង ដើមឈើ ជាដើមទាំងនេះក៏ជាវត្ថុដែលមិនគួរគិតម្យ៉ាង ម្នាលភិក្ខុទាំងឡាយ វត្ថុដែលមិនគួរគិត ៤ យ៉ាងដូចដែលបានពោលមកនេះ បើអ្នកណាគិត អ្នកនោះនឹងគប្បីជាអ្នកមានចំណែកនៃសេចក្ដីឆ្កួត មានសេចក្ដីលំបាកចិត្តជាពិតប្រាកដ ។

ដោយហេតុដូចដែលពោលមកហើយនេះ ពុទ្ធសាសនិកជនទាំងឡាយគួរពិចារណាការវិលវល់ នៃបដិច្ចសមុប្បាទដោយន័យទាំង ៤ មានឯកត្តន័យជាដើម ដូចដែលបានសំដែងមកហើយនោះ និងកាលបានពិចារណាហើយ ក៏កើតការយល់ដឹងឡើងខ្លួនឯងថា ការប្រព្រឹត្តទៅរបស់លោកនិងសត្វទាំងឡាយនោះរមែងរកខាងដើមមិនបាន ។

ចំណែកអ្នកដែលមានត្រឹមការដឹងក្នុងការប្រព្រឹត្តទៅ នៃបដិ-សមុប្បាទឱ្យផុតអំពីសង្សារវដ្តបាននោះមិនមានឡើយ ព្រោះហេតុនោះពុទ្ធសាសនិកជនអ្នកប្រាថ្នាឆ្លងផុតចាកកងទុក្ខទាំងឡាយ គួរព្យាយាមដឹងនូវសេចក្តីប្រព្រឹត្តទៅនៃសេចក្តីវិលវល់ របស់ភវចក្រ ដែលហៅថាបដិច្ចសមុប្បាទនោះឯង ។

## ការពិចារណាបដិច្ចសមុប្បាទរបស់ព្រះអានន្ទត្ថេរ និង ព្រះឱវាទរបស់ព្រះសម្មាសម្ពុទ្ធ

សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់គង់ប្រថាប់នៅសទ្ធម្មនិគម ក្នុងដែនកុរុ ព្រះអានន្ទត្ថេរបានទៅបិណ្ឌបាតក្នុងស្រុកនោះគ្រប់ ៧ ផ្ទះ ដើម្បីអនុគ្រោះឧបាសក ឧបាសិកាទាំងឡាយ ថ្ងៃមួយកាលព្រះថេរៈទៅបិណ្ឌបាតត្រឡប់មកឆាន់ស្រេចហើយ ក៏បានទៅបដិបត្តិព្រះដ៏មានព្រះភាគតាមតួនាទីរបស់ខ្លួន កាលដល់ថ្ងៃត្រង់ព្រះដ៏មានព្រះភាគ ស្តេចយាងទៅកាន់ គន្ធកុដិ ដើម្បីសម្រាក ហើយព្រះអានន្ទក៏ត្រឡប់ទៅកុដិរបស់ខ្លួនវិញ បានធ្វើការអប់រំសទ្ធិវិហារិករបស់លោកស្រេចហើយ ក៏បានទៅរកទីស្ងប់អង្គុយសោយវិមុត្តិសុខ គឺចូលផលសមាបត្តិនៅទីនោះ កាលចេញចាកផលសមាបត្តិហើយ ក៏បានពិចារណាបដិច្ច-សមុប្បាទដោយអនុលោម បដិលោម ច្រាសត្រឡប់ ហើយពិចារណាពី

ដើមទៅរកកណ្តាលដោយអនុលោម បដិលោម ពីចុងទៅរកកណ្តាល ដោយន័យដែលពិចារណាថា "សង្ខារប៉ុណ្ណោះដែលអាស្រ័យអវិជ្ជាជាហេតុ រកតួខ្លួនយើង គេ ស្រី ប្រុសមិនមានកើតឡើងដោយអាស្រ័យអវិជ្ជា ហើយអវិជ្ជាក៏ជាផលធម៌ដែលកើតឡើងដោយអាស្រ័យហេតុតាមសមគួរ វិញ្ញាណប៉ុណ្ណោះដែលអាស្រ័យសង្ខារជាហេតុ រកតួខ្លួនយើង គេ ស្រី ប្រុសមិនមាន កើតឡើងដោយអាស្រ័យសង្ខារ ហើយសង្ខារក៏ជាផលធម៌ដែលកើតឡើង ដោយអាស្រ័យហេតុតាមសមគួរ លោកពិចារណាដោយន័យនេះរឿយៗ រហូតដល់ ជរាមរណៈ ប៉ុណ្ណោះដែលកើតឡើងដោយអាស្រ័យជាតិជាហេតុមិនមែនតួខ្លួន យើង គេ ស្រី ប្រុស កើតឡើងដោយអាស្រ័យជាតិ លោកពិចារណា ៣ ដង គឺ ពីដើមទៅរកចុងពីចុងទៅរកដើមម្តង ពីដើមទៅរកកណ្តាលៗទៅរកដើមម្តង ពីចុងទៅរកកណ្តាលៗ ទៅរកចុងម្តង ក្នុងចន្លោះដែលពិចារណានោះកាលប្រព្រឹត្តទៅរបស់ បដិច្ចសមុប្បាទធម៌ដែលមានការសម្តែងដោយហេតុនិងផល ទាំងអង្គ ១២ ក៏ប្រាកដច្បាស់ឡើងក្នុងបញ្ញារបស់លោក ទើបលោកគិតថា ព្រះដ៏មានព្រះភាគជាម្ចាស់ទាំងឡាយ បានសម្តែងថា បដិច្ចសមុប្បាទធម៌នេះមានសភាពជ្រាលជ្រៅ និងអាការៈដែលប្រព្រឹត្តទៅក៏សម្តែងឱ្យឃើញថា យើងខ្លួនឯងក៏ត្រឹមជាសាវ័កដែលមានបញ្ញាមួយចំណែកប៉ុណ្ណោះ តែក៏មានសេចក្តីភ្លឺច្បាស់ក្នុងការប្រព្រឹត្តរបស់

បដិច្ចសមុប្បាទធម៌នេះយ៉ាងល្អ ព្រះសាវ័កអង្គផ្សេងៗ និងមានការដឹងដូចយើងទេហ្ន៎! ដល់វេលាល្ងាច ព្រះអានន្ទត្ថេរក៏ទៅគាល់ ព្រះសម្មា-សម្ពុទ្ធ ហើយទូលសួរថា **អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវគម្ភីរោ ចាយំ ភន្តេ បដិ- ច្ចសមុប្បាទោ គម្ភីរាវភាសោ ច អថ ច បន មេ ឧត្តានកុត្តានកោ វិយ ខាយតិ** បពិត្រព្រះអង្គដ៏ចម្រើន វត្ថុដែលគួរអស្ចារ្យយ៉ាងក្រៃលែង ជាវត្ថុពិសេស ដែលមិនធ្លាប់ប្រាក-ដមកពីមុនឡើយ បពិត្រព្រះអង្គដ៏ចំរើន បដិច្ចសមុប្បាទធម៌នេះប្រាកដជាក់ច្បាស់ដល់ខ្ញុំព្រះអង្គ ដូចជាធម៌នេះរាក់សម្រាប់ខ្ញុំព្រះអង្គ។

កាលព្រះដ៏មានព្រះភាគទ្រង់បានព្រះសណ្ដាប់ហើយ ក៏ទ្រង់ព្រះតម្រិះក្នុងព្រះទ័យថា អានន្ទប្អូននេះពោលដល់រឿងជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយថា បដិច្ចសមុប្បាទធម៌នេះ ប្រាកដច្បាស់ដល់ខ្លួន កាលដែលព្រះអានន្ទពោលដូច្នេះក៏ដូចជាថា ព្យាយាមឈោងដៃចាប់ភវគ្គភូមិ ព្យាយាមបំបែកភ្នំសិនេរុឱ្យបែក ដើម្បីនិងយកកែវដែលនៅក្នុងភ្នំនោះ ព្យាយាមនឹងឆ្លងមហាសមុទ្រដោយមិនអា-ស្រ័យទូក ព្យាយាមនឹងផ្កាប់ផែនដីដើម្បីយកឱជាដែលនៅក្នុងផែនដីនោះ បើដូច្នេះយើងចាំបាច់ហាមពាក្យដូច្នេះ ហើយត្រូវសម្ដែងឱ្យដឹងដល់សេចក្ដីដឹងជ្រាលជ្រៅរបស់បដិច្ចសមុប្បាទធម៌ឱ្យយល់ កាលព្រះអង្គទ្រង់ព្រះតម្រាស់ដូច្នេះហើយ ក៏ត្រាស់ដល់ព្រះអានន្ទថា " **មាហេវំ**

**អានន្ទ មា ហេវំ អានន្ទ គម្ភីរោ ចាយំ អានន្ទ បដិច្ចសមុប្បាទោ គម្ភីរាវភាសោ** ” ម្នាលអានន្ទកុំនិយាយយ៉ាងនេះៗ អានន្ទបដិច្ចសមុប្បាទធម៌នេះ មានសភាពជ្រៅយ៉ាងក្រៃលែង ហើយអាការៈដែលប្រព្រឹត្តទៅក៏សម្តែងឱ្យឃើញថាជ្រៅ ។

បដិច្ចសមុប្បាទធម៌ ជាធម៌មានសភាពជ្រៅ ហើយអាការៈដែលប្រព្រឹត្តទៅក៏សម្តែងឱ្យឃើញថាជ្រៅនោះ ឧបមាដូចទឹក ក្នុងមហាសមុទ្រដែលនៅជិតភ្នំសិនេរុដូច្នោះ ។

## ការប្រព្រឹត្តទៅរបស់ទឹក ៤ យ៉ាង

១.ទឹកកន្លែងខ្លះ បើសម្លឹងមើលយល់ថាជ្រៅ តែសេចក្តីពិតនោះត្រឹមតែ ២ ឬ ៣ ហត្ថប៉ុណ្ណោះ ដូចជាទឹកក្នុងស្រះ ឬក្នុងអណ្តូងដែលមានឈូកធ្វើឱ្យទឹកនោះប្រាកដមានពណ៌ខៀវ អ្នកដែលឃើញនិងយល់ថា ទឹកក្នុងស្រះឬអណ្តូងនោះជ្រៅណាស់ តែបើមើលហើយក៏ប្រាកដថារាក់ ។

២.ទឹកកន្លែងខ្លះ បើមើលយល់ថារាក់ តែសេចក្តីពិតនោះជ្រៅណាស់ ដូចជាទឹកក្នុងស្រះ ឬបឹង មានសភាពថ្លាឃើញវត្ថុផ្សេងៗដែលនៅខាងក្រោមបានជាក់ច្បាស់ ធ្វើឱ្យអ្នកឃើញយល់ថា រាក់ តែបើចុះទៅមើលប្រាកដជាជ្រៅណាស់ ។

៣.ទឹកកន្លែងខ្លះ បើមើលទៅក៏ដឹងថារាក់ ហើយទឹកក្នុងទីនោះក៏មានសភាពរាក់ពិត១ ដូចជាទឹកក្នុងធុង ទឹកក្នុងឆ្នាំង ជាដើម ។

៤.ទឹកកន្លែងខ្លះ កាលមើលទៅឃើញថាជ្រៅ ហើយទឹកក្នុងទីនោះក៏មានសភាពជ្រៅពិត១ ដូចជាទឹកក្នុងមហាសមុទ្រធំ១។

សភាពជ្រៅរបស់បដិច្ចសមុប្បាទនេះ នៅក្នុងពួកទឹកប្រភេទទី ៤ តែម្យ៉ាង បុគ្គលធម្មតានឹងយល់បានយ៉ាងជាក់ច្បាស់ដោយហេតុនេះ ទើបព្រះសម្មាសម្ពុទ្ធត្រាស់ហាមព្រះអានន្ទមិនឱ្យនិយាយថា បដិច្ចស-មុប្បាទធម៌នេះ ដូចជាធម៌រាក់ណាស់ ។

បណ្ដាសាវ័កទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធនោះ វៀរអគ្គសាវ័ក ២ អង្គចេញហើយ សាវ័កអង្គផ្សេង១ នោះ ដែលមានការយល់ក្នុងបដិច្ចសមុប្បាទបានជាក់ច្បាស់ដូចព្រះអានន្ទនោះមិនមាន ហើយក្នុងការដែលព្រះអានន្ទមានបញ្ញាដឹងបានជាក់ច្បាស់ ដូច្នេះដោយអាស្រ័យហេតុ ៤ យ៉ាង គឺៈ

**១.ឧបដ្ឋាកអធិករោ** ជាអ្នកដែលធ្លាប់សាងទាន សីល ភាវនា ហើយប្រាថ្នាជាពុទ្ធុបដ្ឋាក។

**២.អន្តេវាសិកោ** បានជាអ្នកជិតដិតជាមួយព្រះបរមសាស្ដា។

**៣.សោតាបន្នោ** បានសម្រេចព្រះសោតាបន្ន។

**៤.ពហុស្សុតធរោ** ជាពហុស្សូតអ្នកចេះដឹងច្រើនបំផុត។

## ការសម្ដែងបដិច្ចសមុប្បាទធម៌ ដោយអភិធម្មភាជនីយន័យ

ការសម្ដែងបដិច្ចសមុប្បាទធម៌របស់ព្រះសម្មាសម្ពុទ្ធនេះ មាន ២ន័យគឺសុត្តន្តភាជនីយន័យ និងអភិធម្មភាជនីយន័យដែលព្រះអនុរុទ្ធាចារ្យបាននាំមកសម្ដែងក្នុងបរិច្ឆេទទី ៨ នេះ ជាការសម្ដែងដោយសុត្តន្តភាជនីយន័យ ដែលសម្ដែងដល់ការប្រព្រឹត្តទៅនៃបដិច្ចសមុប្បាទក្នុងចិត្តច្រើនៗដួង ឈ្មោះថា "**នានាចិត្តក្ខណិកបដិច្ចសមុប្បាទ**" ហើយតទៅនេះនឹងបានសម្ដែងដោយអភិធម្មភាជនីយន័យ ដែលសម្ដែងដល់ការប្រព្រឹត្តទៅនៃបដិច្ចសមុប្បាទក្នុងចិត្តមួយដួងៗឈ្មោះថា "**ឯកចិត្តក្ខណិកបដិច្ចសមុប្បាទ**"។

### ក្នុងការសម្ដែងដោយអភិធម្មភាជនីយន័យនេះ

### បានចែកចេញជា ៣ ពួក គឺៈ

១.អកុសលបទ ២.កុសលបទ ៣.អព្យាកតបទ

### ១.អកុសលបទ

ក្នុងអកុសលបទនេះ នឹងសម្ដែងការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ ចំពោះក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ប៉ុណ្ណោះ ។

អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមំ នាមបច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនបច្ចយា

**ផស្សោ ផស្សប្បច្ចយា វេទនា វេទនាប្បច្ចយា តណ្ហា តណ្ហាប្បច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ។**

ព្រោះអវិជ្ជាជាហេតុ អបុញ្ញាភិសង្ខារ គឺ ទិដ្ឋិគតសម្បយុត្ត អកុសលចេតនា ដែលប្រព្រឹត្តទៅព្រមដោយអវិជ្ជានោះ ទើបកើតឡើង។

ព្រោះអបុញ្ញាភិសង្ខារ គឺ ទិដ្ឋិគតសម្បយុត្តអកុសលចេតនាជាហេតុ ទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ ចេតសិកខន្ធ៣ ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្តនោះៗ ទើបកើតឡើង។

ព្រោះចេតសិក្ខន្ធ៣ ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ មនាយតនៈគឺ ទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះមនាយតនៈ គឺទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ មនោសម្ផស្ស ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះមនោសម្ផស្ស ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ វេទនាដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះវេទនា ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ តណ្ហាដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះតណ្ហា ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្តជាហេតុ ឧបាទាន ៣ (វៀរកាមុបាទាន) ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្ត ទើបកើតឡើង ។

ព្រោះឧបាទាន ៣ ដែលប្រកបជាមួយទិដ្ឋិគតសម្បយុត្តចិត្ត ជាហេតុ ភវៈ គឺ ទិដ្ឋិគតសម្បយុត្តចិត្តុប្បាទ (វៀរ ទិដ្ឋិ) ទើបកើតឡើង ។

ព្រោះភវៈ គឺ ទិដ្ឋិគតសម្បយុត្តចិត្តុប្បាទ (វៀរទិដ្ឋិ) ជាហេតុ នាមជាតិ គឺ អាការដែលកើតឡើងរបស់ទិដ្ឋិគតសម្បយុត្តចិត្តុប្បាទនោះ ទើបកើតឡើង ។

ព្រោះនាមជាតិ គឺ អាការដែលកើតឡើងរបស់ទិដ្ឋិគតសម្បយុត្តចិត្តុប្បាទជាហេតុ នាមជរា នាមមរណៈ គឺខណៈតាំងពីរលត់របស់ទិដ្ឋិគត-សម្បយុត្តចិត្តុប្បាទ ទើបកើតឡើង ។

ការកើតឡើងនៃកងទុក្ខទាំងពួងនេះ ព្រោះអាស្រ័យបច្ច័យផ្សេងៗ មានអវិជ្ជាជាដើម ដូចដែលបានពោលមកហើយនេះ ។

# អធិប្បាយពិសេស

ក្នុងទីនេះសម្ដែងថា "**វិញ្ញាណប្បច្ចយា នាមំ**" មិនសម្ដែងថា "**វិញ្ញាណប្បច្ចយា នាមរូបំ**" នោះ ក៏ព្រោះថាត្រូវការសម្ដែងធម៌ដែលប្រកបជាមួយចិត្តមួយដួង១ នឹងត្រូវការសម្ដែងឱ្យប្រព្រឹត្តទៅបានក្នុងភូមិដែលចិត្តកើតបានទូទៅ ព្រោះហេតុនោះ ទើបមិនប្រើពាក្យថា "**នាមរូបំ**"

ដែលសម្ដែងថា "**នាមប្បច្ចយា ឆដ្ឋាយតនំ**" មិនសម្ដែងថា "**នាមប្បច្ចយា សឡាយតនំ**" នោះ ក៏ព្រោះថាធម៌ដែលជាហេតុនោះជានាម គឺចេតសិកដូចគ្នាមិនមានរូប ព្រោះហេតុនោះធម៌ដែលជាផលគឺអាយតនៈទី ៦ ដែលបានដល់ចិត្តតែម្យ៉ាង ។

អង្គធម៌របស់ **វិញ្ញាណំ** ក្នុងបទថា **សង្ខារប្បច្ចយា វិញ្ញាណំ** និងអង្គធម៌របស់ **ឆដ្ឋាយតនំ** ក្នុងបទថា **នាមប្បច្ចយា ឆដ្ឋាយតនំ** ទាំង ២ នេះ បានដល់ ទិដ្ឋិគតសម្បយុត្តចិត្តដូចគ្នា តែពិសេសនោះ ក៏គឺក្នុងបទថា "**សង្ខារប្បច្ចយា វិញ្ញាណំ** " នោះ ចេតនាជាហេតុពិសេសរបស់វិញ្ញាណ ចេតសិកខន្ធ ៣ ជាផលសាមញ្ញរបស់វិញ្ញាណ ។

ក្នុងបទថា "**នាមប្បច្ចយា ឆដ្ឋាយតនំ**" នោះ ចេតសិកខន្ធ ៣ ជាហេតុសាមញ្ញ របស់ឆដ្ឋាយតនៈ ផស្សៈចេតសិកជាផលពិសេសរបស់ឆដ្ឋាយតនៈ ។

ក្នុងអភិធម្មភាជនីយន័យនេះ ព្រះអង្គទ្រង់មិនបានសម្ដែង សោកៈ បរិទេវៈ ជាដើម ដែលជាផលរបស់ជាតិ ទ្រង់សម្ដែងតែ "**ជាតិប្បច្ចយា ជរាមរណំ**" តែប៉ុណ្ណោះ ទាំងនេះក៏ព្រោះថា ក្នុងចិត្តខណៈ មួយដួងៗនោះ សោកៈ បរិទេវៈ ជាដើមទាំងនេះ រមែងកើតឡើងមិនបាន ហើយប្រការមួយទៀត សោកៈ បរិទេវៈ ជាដើមទាំងនេះក៏មិនបានកើតក្នុងភូមិទូទៅ ដូចជាក្នុងរូបភូមិ អរូបភូមិ ដោយហេតុនេះ ទើបព្រះអង្គទ្រង់សម្ដែង សោកៈ បរិទេវៈ ជាដើម ឱ្យជាផលរបស់ជាតិមិនទូទៅ។

ការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលពិសេសដូច្នេះ "**វេទនាប្បច្ចយា តណ្ហា តណ្ហាប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ**"។

ការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទក្នុងទោសមូលចិត្ត ដែលពិសេសដូច្នេះ "**វេទនាប្បច្ចយា បដិឃំ បដិឃប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ**"

ក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ដែលពិសេសដូច្នេះ "**វេទនាប្បច្ចយា វិចិកិច្ឆា វិចិកិច្ឆប្បច្ចយា ភវោ**"

ក្នុងឧទ្ធច្ចសម្បយុត្តចិត្ត ដែលពិសេសដូច្នេះ "វេទនាប្បច្ចយា ឧទ្ធច្ចំ ឧទ្ធច្ចប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ"។

## ២.កុសលបទ

ក្នុងកុសលបទនេះ នឹងសម្ដែងការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ ចំពោះក្នុងមហាកុសលញាណសម្បយុត្ត ៤ ប៉ុណ្ណោះ។

**កុសលមូលប្បច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយោ នាមំ នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាប្បច្ចយា បសាទោ បសាទប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ។**

ព្រោះកុសលមូល ៣ ជាហេតុ បុញ្ញាភិសង្ខារ គឺមហាកុសលញាណសម្បយុត្តចេតនាដែលប្រព្រឹត្តព្រមដោយកុសលមូល ៣ ទើបកើតឡើង។

ព្រោះបុញ្ញាភិសង្ខារ គឺ មហាកុសលញាណសម្បយុត្តចេតនាជាហេតុ មហាកុសលញាណសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះមហាកុសលញ្ញាណសម្បយុត្តចិត្តជាហេតុ ចេតសិកខន្ធ ៣ ដែលប្រកបជាមួយមហាកុសលញ្ញាណសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះចេតសិកខន្ធ ៣ ដែលប្រកបជាមួយមហាកុសលញ្ញាណ-សម្បយុត្តចិត្តជាហេតុ មនាយតនៈ គឺ មហាកុសលញ្ញាណសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះមនាយតនៈ គឺ មហាកុសលញ្ញាណសម្បយុត្តចិត្តជាហេតុ មនោសម្ផស្សៈ ដែលប្រកបជាមួយមហាកុសលញ្ញាណសម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះមនោសម្ផស្សៈ ដែលប្រកបជាមួយមហាកុសលញ្ញាណ សម្បយុត្តចិត្តជាហេតុ វេទនាដែលប្រកបជាមួយមហាកុសលញ្ញាសម្ប-យុត្តចិត្ត ទើបកើតឡើង។

ព្រោះវេទនា ដែលប្រកបជាមួយមហាកុសលញ្ញាណសម្បយុត្ត ចិត្តជាហេតុ បសាទៈ គឺ សទ្ធាដែលប្រកបជាមួយមហាកុសលញ្ញាណ សម្បយុត្ត ទើបកើតឡើង។

ព្រោះបសាទៈ គឺ សទ្ធាដែលប្រកបជាមួយមហាកុសលញ្ញាណ-សម្បយុត្តចិត្តជាហេតុ អធិមោក្ខដែលប្រកបជាមួយមហាកុសលញ្ញាណ សម្បយុត្តចិត្ត ទើបកើតឡើង។

ព្រោះអធិមោក្ខ គឺ ដែលប្រកបជាមួយមហាកុសលញ្ញាណ-សម្បយុត្តចិត្តជាហេតុ ភវៈគឺ មហាកុសលញ្ញាណសម្បយុត្តចិត្តុប្បាទ (វៀរ អធិមោក្ខ) ទើបកើតឡើង។

ព្រោះភវៈ គឺ មហាកុសលញ្ញាណសម្បយុត្តចិត្តុប្បាទ (វៀរ អធិមោក្ខ) ជាហេតុ នាមជាតិ គឺ ការកើតឡើងរបស់មហាកុសលញ្ញា-សម្បយុត្តចិត្តុប្បាទ ទើបកើតឡើង។

ព្រោះនាមជាតិ គឺ អាការកើតឡើងមហាកុសលញ្ញាណសម្ប-យុត្តចិត្តុប្បាទជាហេតុ នាមជរា នាមមរណៈ គឺ ខណៈតាំងនៅ និងខណៈរលត់របស់មហាកុសលញ្ញាណសម្បយុត្តចិត្តុប្បាទ ទើបកើតឡើង។

ការកើតឡើងនៃកងទុក្ខពិត១ ទាំងពួងនេះ ព្រោះអាស្រ័យបច្ច័យផ្សេង១ មានកុសលមូលជាដើម ដូចដែលបានពោលមកហើយនេះ។

## អធិប្បាយពិសេស

ការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទក្នុងកុសលបទនេះ មិនបានសម្តែងថា **"វេទនាប្បច្ចយា តណ្ហា តណ្ហាប្បច្ចយា ឧបាទានំ"**

តែសម្ដែង ថា "**វេទនាប្បច្ចយា បសាទោ បសាទប្បច្ចយា អធិមោក្ខោ**" នោះ ក៏ព្រោះតណ្ហា ឧបាទាន នេះប្រកបជាមួយលោភមូលចិត្តប៉ុណ្ណោះ មិនបានប្រកបជាមួយចិត្តផ្សេងៗ ព្រោះហេតុនោះ ទើបសម្ដែងសទ្ធាជំនួស តណ្ហា អធិមោក្ខ ជំនួសឧបាទាន ដូចដែលសម្ដែងថា "**វេទនាប្បច្ចយា បសាទោ បសាទប្បច្ចយា អធិមោក្ខោ** ដែលប្រៀបធៀបសភាពការប្រព្រឹត្តទៅ ហើយតណ្ហាមានសភាពត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ សទ្ធាក៏មាន សភាពត្រេកអរពេញចិត្តក្នុងអារម្មណ៍ដូចគ្នា ហើយឧបាទាន មានសភាពចូលទៅប្រកាន់មាំក្នុងអារម្មណ៍ អធិមោក្ខក៏មានសភាពចូល ទៅប្រកាន់មាំ ក្នុងអារម្មណ៍ដូចគ្នា ព្រោះហេតុនោះទើបបានលើកយក សទ្ធា និងអិធិមោក្ខ ឡើងសម្ដែងជំនួសតណ្ហា ឧបាទាន ។

ការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទក្នុងកុសលចិត្តផ្សេង ៗ ក៏ដូចគ្នាតែសម្រាប់ក្នុងបទចុងក្រោយ ដែលសម្ដែងជាមួយលោកុត្តរចិត្តនោះសម្ដែងថា "**ឯវមេតេសំ ធម្មានំ សមុទយោ ហោតិ**" ប្រែថា ការ កើតឡើងរបស់លោកុត្តរកុសលធមិ រមែងប្រព្រឹត្តទៅដូច្នេះ ។

## ៣.អព្យាកតបទ

ក្នុងអព្យាកតបទនេះ នឹងសម្ដែងការប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ ចំពោះក្នុងទ្វិបញ្ចវិញ្ញាណ ១០ ប៉ុណ្ណោះ។

**សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាប្ប ច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ។**

ព្រោះបុញ្ញាភិសង្ខា អបុញ្ញាភិសង្ខារ គឺមហាកុសលចេតនា ៨ អកុសលចេតនា ១២ ជាហេតុ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទើបកើតឡើង

ព្រោះទ្វិបញ្ចវិញ្ញាណចិត្ត ១០ ជាហេតុ ចេសិកខន្ធ ៣ ដែលប្រកបជាមួយទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទើបកើតឡើង។

ព្រោះចេតសិកខន្ធ ៣ ដែលប្រកបជាមួយទ្វិបញ្ចវិញ្ញាណចិត្ត ១០ ជាហេតុ មនាយតនៈ គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទើបកើតឡើង។

ព្រោះមនាយតនៈ គឺទ្វិបញ្ចវិញ្ញាណចិត្ត ១០ ជាហេតុ ផស្សៈ ៥ មានចក្ខុសម្ផស្សៈជាដើម ដែលប្រកបជាមួយទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទើបកើតឡើង។

ព្រោះផស្សៈ ៥ មានចក្ខុសម្ផស្សជាដើមដែលប្រកបជាមួយទ្វិបញ្ចវិញ្ញាណចិត្ត ១០ជាហេតុ វេទនាដែលប្រកបជាមួយទ្វិបញ្ច-វិញ្ញាណចិត្ត ១០ ទើបកើតឡើង។

ព្រោះវេទនា ដែលប្រកបជាមួយទ្វិបញ្ចវិញ្ញាណចិត្ត ១០ ជាហេតុ ភវៈ គឺ ទ្វិបញ្ចវិញ្ញាណចិត្តុប្បាទ (វៀរវេទនា) ទើបកើតឡើង។

ព្រោះភវៈ គឺ ទ្វិបញ្ចវិញ្ញាណចិត្តុប្បាទ (វៀរ វេទនា) ជាហេតុនាមជាតិ គឺ អាការៈដែលកើតឡើងរបស់ទ្វិបញ្ចវិញ្ញាណចិត្តុប្បាទ ទើបកើតឡើង។

ព្រោះនាមជាតិ គឺអាការដែលកើតឡើងរបស់ទ្វិបញ្ចវិញ្ញាណចិត្តុប្បាទជាហេតុ នាមជរា នាមមរណៈ គឺខណៈតាំងនៅ និងខណៈរលត់របស់ទ្វិញ្ចបវិញ្ញាណចិត្តុប្បាទ ទើបកើតឡើង។

ការកើតឡើងរបស់ទុក្ខពិត៧ទាំងពួងនេះ ព្រោះអាស្រ័យបច្ច័យផ្សេងៗ មានបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារជាដើម ដូចដែលបានពោលមកហើយ។

✍ <u>ចំណាំ</u> ការសម្តែងបដិច្ចសមុប្បាទក្នុងអហេតុកវិបាកចិត្ត ដែលនៅសល់ និងអាវជ្ជនចិត្ត ២ នោះ មានសម្តែងពិសេសត្រង់ដែលថា "វេទនាប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ" ប៉ុណ្ណោះ ហើយក្នុងសហេតុកវិបាកចិត្តសម្តែងថា "**វេទនាប្បច្ចយា បសាទោ បសាទប្បច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ**" បទក្រៅនោះសម្តែងដូចគ្នា។

ក្នុងបទទីបំផុតដែលសំដែងជាមួយលោកុត្តរវិបាកចិត្តនោះ មិនបានសម្តែងថា "**ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ**" ផ្លាស់ជាសម្តែងថា "**ឯវមេតេសំ ធម្មានំ សមុទយោ ហោតិ**" ប្រែថា ការកើតឡើងរបស់លោកុត្តរវិបាកធម៌ រមែងប្រព្រឹត្តទៅដូច្នេះ។

✍ <u>ចំណាំ</u> ក្នុងគម្ពីរវិភង្គបានសម្តែងបដិច្ចសមុប្បាទ ដោយអភិធម្មភាជនីយន័យ ចែកចេញជានិទ្ទេសមាន ៦ គឺ:

១.អកុសលនិទ្ទេស

២.កុសលនិទ្ទេស

៣.អព្យាកតនិទ្ទេស

និទ្ទេសទាំង ៣ នេះ ដូចគ្នាជាមួយអកុសលបទ កុសលបទ អព្យាកតបទក្នុងគោលព្រះសូត្រនោះឯង ។

៤.អវិជ្ជាមូលកុសលនិទ្ទេស បានដល់ និទ្ទេសរបស់កុសលចិត្ត ២១ ដែលមានអវិជ្ជាជាមូល ក្នុងនិទ្ទេសនេះមានអង្គបដិច្ចសមុប្បាទ ១២ គឺ អវិជ្ជា សង្ខារ វិញ្ញាណ នាម ឆដ្ឋាយតនៈ ផស្សៈ វេទនា បសាទៈ អធិមោក្ខ ភវៈ ជាតិ ជរាមរណៈ ។

៥.កុសលមូលវិបាកនិទ្ទេស បានដល់ និទ្ទេសរបស់កុសល ២៩ដែលមានកុសលជាមូលក្នុងនិទ្ទេសនេះ បញ្ចវិញ្ញាណកុសលវិបាកចិត្ត ៥ មានអង្គបដិច្ចសមុប្បាទ ១០ គឺ កុសលមូល សង្ខារ វិញ្ញាណ នាម ឆដ្ឋាយតនៈ ផស្សៈ វេទនា ភវៈ ជាតិ ជរាមរណៈ ។

អហេតុកវិបាកចិត្តដែលនៅសល់ ៣ មានអង្គបដិច្ចសមុប្បាទ ១១ គឺ បន្ថែមអធិមោក្ខក្នុងចន្លោះ វេទនា និងភវៈជា វេទនា អធិមោក្ខៈ ភវៈ អង្គដែលនៅសល់ដូចគ្នាជាមួយ បញ្ចវិញ្ញាណ ដែលជាកុសលវិបាកចិត្ត ។

៦.អកុសលមូលវិបាកនិទ្ទេស បានដល់ និទ្ទេសរបស់អកុសលវិបាកចិត្ត ៧ ដែលមានអកុសលជាមូល ក្នុងនិទ្ទេសនេះ បញ្ចវិញ្ញាណដែលជាអកុសលវិបាកចិត្ត ៥ មានអង្គបដិច្ចសមុប្បាទ ១០ គឺ អកុសល

មូល សង្ខារ អង្គដែលនៅសល់ដូចគ្នាជាមួយបញ្ចវិញ្ញាណដែលជាកុសលវិបាកចិត្ត។

អកុសលវិបាកចិត្តដែលនៅសល់ ២ មានអង្គបដិច្ចសមុប្បាទ ១១ គឺ បន្ថែម អធិមោក្ខ ក្នុងរវាង វេទនា និងភវៈ ជា វេទនា អធិមោក្ខ ភវៈ ប៉ុណ្ណោះ។

ចប់ បដិច្ចសមុប្បាទន័យ

## បច្ច័យ ២៤ ដោយសង្ខេប

## សម្តែងបាលី និងសេចក្តីប្រែតាមអភិធម្មត្ថសង្គហៈ

១.ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អានន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញ-មញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាត-តប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ច-យោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្ប-ច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ អយមេត្ថ-

**បដ្ឋាននយោ** ។ ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អានន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ រួមជាបច្ច័យមាន ២៤ ដូច្នេះ ក្នុងបច្ច័យសង្គហៈ ។

## គាថាសង្គហៈ សម្ដែងបច្ច័យ ៦ ពួក

២.ឆធា នាមន្តុ នាមស្ស បញ្ចធា នាមរូបិនំ ឯកធា បុន រូបស្ស រូបំ នាមស្ស ចេកធា បញ្ញត្តិ នាមរូបានិ នាមស្ស ទុវិធា ទ្វយំ ទ្វយស្ស នវធា ចេតិ ឆព្វិនា បច្ចយា កថំ ។

### ចំណែកបច្ច័យ ២៤ ចែកជាពួក៦ គឺ

**នាម** ជាបច្ច័យដល់ **នាម** មាន ៦ បច្ច័យ

**នាម** ជាបច្ច័យដល់ **រូប** មាន ៥ បច្ច័យ

**នាម** ជាបច្ច័យដល់ **រូប** ផ្សេងទៀត មាន ១ បច្ច័យ

**រូប** ជាបច្ច័យដល់ **នាម** មាន ១ បច្ច័យ

**បញ្ញត្តិនាមរូប** ទាំង ៣ ជាបច្ច័យដល់**នាម** មាន ២ បច្ច័យ **នាមរូប** ទាំង ២ ជាបច្ច័យដល់ **នាមរូប** មាន ៩ បច្ច័យ

បច្ច័យធម៌ទាំងឡាយ ចែកចេញជា ៦ ពួកដូច្នេះ ។

ការបែងចែកបច្ច័យជា ៦ ពួក យ៉ាងណានោះ និងសំដែងដូចត ទៅនេះ :

**៣.អនន្តរនិរុទ្ធា ចិត្តចេតសិកា ធម្មា បដុប្បន្នានំ ចត្តចេត- សិកានំ ធម្មានំ អនន្តរ សមនន្តរនត្ថិវិគតវសេន, បុរិមា ជវនានិ បច្ឆិមានំ ជវនានំ អសេវនវសេន, សហជាតា ចិត្តចេតសិកា ធម្មា អញ្ញមញ្ញំ សម្បយុត្តវសេនេតិ ច ឆធា នាមំ នាមស្ស បច្ចយោ ហោតិ** ។ ចិត្ត និង ចេតសិកធម៌ កើតឡើង និងរលត់ទៅមិនមាន រវាងចន្លោះ ជាបច្ច័យ ជួយឧបការដល់ចិត្ត និងចេតសិកធម៌ ដែលកើត ថ្មីជាប់តគ្នា ដោយអំណាចបច្ច័យគឺ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ ។

ជវនដែលកើតមុនៗ ជាបច្ច័យ ដល់ជវនដែលកើតខាងក្រោយ ដោយអំណាចបច្ច័យ គឺ អាសេវនប្បច្ច័យ

ចិត្ត និងចេតសិកធម៌ ដែលកើតព្រមគ្នានោះ ជាបច្ច័យដល់គ្នា ដោយអំណាចបច្ច័យគឺ សម្បយុត្តប្បច្ច័យ ។

**៤.ហេតុឈានង្គមគ្គង្គានិ សហជាតានំ នាមរូបានំ ហេតាទិវសេន, សហជាតា ចេតនា សហជាតានំ នាមរូបានំ នានក្ខណិកា ចេតនា កម្មាភិនិព្វត្តានំ នាមរូបានំ កម្មវសេន វិបា- កក្ខន្ធា អញ្ញមញ្ញំ សហជាតានំ រូបានំ វិបាកវសេនេតិ ច បញ្ចធា នាមំ នាមរូបានំ បច្ចយោ ហោតិ ។** នាមជាបច្ច័យជួយឧបការៈ ដល់នាមរូប មានបច្ច័យ ៥ គឺ ហេតុ ៦ អង្គឈាន ៥ អង្គមគ្គ ៩ ជាបច្ច័យដល់នាមរូប ដែលកើតព្រមជាមួយនិងខ្លួន ដោយអំណាចបច្ច័យគឺ ហេ- តុប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ ។

ចេតនា ដែលកើតព្រមគ្នា ជាបច្ច័យជួយឧបការដល់ នាមរូប ដែលកើតព្រមគ្នា ឬនឹងចេតនា ដែលកើតផ្សេងខណៈគ្នា ក៏រលត់ទៅហើយ ជាបច្ច័យដល់នាមរូប ដែលកើតឡើងអាស្រ័យកម្ម ដែលរលត់ទៅ បានដោយអំណាចបច្ច័យ គឺ កម្មប្បច្ច័យ សហជាតកម្មប្បច្ច័យ និង នានក្ខណិកកម្មប្បច្ច័យ ។

វិបាកនាមខន្ធ ៤ ជាបច្ច័យដល់គ្នានិងគ្នា ហើយជួយឧបការដល់រូប ដែលកើតព្រមគ្នានោះ ដោយអំណាចបច្ច័យគឺវិបាកប្បច្ច័យ ។

**៥.បច្ឆាជាតា ចិត្តចេតសិកា ធម្មា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតវសេនេតិ ឯកធាវ នាមំ រូបស្ស បច្ចយោ ហោតិ ។**

នាមជាបច្ច័យជួយឧបការដល់ រូប មាន ១ បច្ច័យគឺៈ

ចិត្ត និងចេតសិក ដែលកើតខាងក្រោយជាបច្ច័យដល់រូប ដែលកើតមុនដោយអំណាចបច្ច័យគឺ បច្ឆាជាតប្បច្ច័យ ។

**៦.ឆ វត្ថូនិ បវត្តិយំ សត្តន្នំ វិញ្ញាណធាតូនំ បញ្ចារម្មណានិ ច បញ្ចវិញ្ញាណវិថិយា បុរេជាតវសេនេតិ ឯកភាវ រូបំ នាមស្ស បច្ចយោ ហោតិ ។**

**រូបជាបច្ច័យដល់នាម ១ បច្ច័យគឺៈ**

វត្ថុទាំង ៦ ជាបច្ច័យដល់វិញ្ញាណធាតុទាំង ៧ ក្នុងបវត្តិកាល និងអារម្មណ៍ទាំង ៥ ជាបច្ច័យដល់បញ្ចវិញ្ញាណវិថី ដោយអំណាចបច្ច័យគឺ បុរេជាតប្បច្ច័យ បានដល់វត្ថុបុរេជាតប្បច្ច័យ និងអារម្មណប្បុរេជា-តប្បច្ច័យ ។

**៧.អារម្មណវសេន ឧបនិស្សយវសេនេតិ ច ទុវិធា បញ្ញត្តិនាមរូបានិ នាមស្ស បច្ចយោ ហោតិ ។** បញ្ញត្តិនាមរូប ទាំង ៣ ជាបច្ច័យដល់ នាម មាន ២ បច្ច័យគឺ ដោយអំណាច អារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

**៨.តត្ថ រូបាទិវសេន ឆព្វិធំ ហោតិ អារម្មណំ ។** ក្នុងបច្ច័យទាំង ២ យ៉ាងនោះ អារម្មណប្បច្ច័យមាន ៦ យ៉ាង ។

**៩.ឧបនិស្សយោ បន តិវិធោ ហោតិ អារម្មណូបនិស្ស-យោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ចេតិ ។** ចំណែកឧបនិ-ស្សយប្បច្ច័យមាន ៣ យ៉ាងគឺ អារម្មណូបនិស្សយប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ បកតូបនិស្សយប្បច្ច័យ ។

**១០.តត្ថ អារម្មណមេវ គរុកតំ អារម្មណូបនិស្សយោ ។** ក្នុងឧបនិស្សយប្បច្ច័យទាំង ៣ នោះ អារម្មណ៍ដែលគប្បីធ្វើឱ្យពេញចិត្តជាពិសេសឈ្មោះថា អារម្មណូបនិស្សយប្បច្ច័យ ។

**១១.អនន្តរនិរុទ្ធា ចិត្តចេតសិកា ធម្មា អនន្តរូបនិស្សយោ។** ចិត្ត និងចេតសិកធម៌ ដែលកើតឡើង និងរលត់ទៅមិនមានចន្លោះឈ្មោះថា អនន្តរូបនិស្សយប្បច្ច័យ ។

**១២.រាគាទយោ បន ធម្មា សទ្ធាទយោ ច សុខំ ទុក្ខំ បុគ្គលោ ភោជនំ ឧតុ សេនាសនញ្ច យថារហំ អជ្ឈត្តញ្ច បហិទ្ធា ច កុសលាទិធម្មានំ កម្មំ វិបាកានន្តិ ច ពហុធា ហោតិ បកតូបនិ-ស្សយោ ។** ចំណែកអកុសលធម៌ មានរាគៈជាដើម កុសលធម៌មានសទ្ធា ជាដើម សេចក្ដីសុខកាយ ទុក្ខកាយ បុគ្គល អាហារ អាកាស ទាំងនេះ ជាបច្ច័យ ដល់ធម៌ទាំងឡាយ មានកុសលជាដើម ដែលកើតទាំងខាងក្នុង និងខាងក្រៅ តាមសមគួរក្ដី និងកម្ម ដែលមានកម្លាំងខ្លាំងក្លា ជាបច្ច័យដល់វិបាកនាមក្ខន្ធក្ដីឈ្មោះថា បកតូបនិស្សយប្បច្ច័យ ។

១៣.អធិបតិ សហជាត អញ្ញមញ្ញ និស្សយ អាហារ ឥន្ទ្រិ-យ វិប្បយុត្ត អត្ថិ អវិគតវសេនេតិ យថារហំ នវធា នាមរូបានិ នាមរូបំ បច្ចយា ភវន្តិ ។ នាមរូបជាបច្ច័យដល់ នាមរូប មាន ៩ គឺ

ដោយប្រភេទនៃអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និស្សយប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ តាមសមគួរ ។

១៤.តត្ថ គរុកតមារម្មណំ អារម្មណាធិបតិវសេន នាមានំ សហជាតាធិបតិ ចតុព្វិធោបិ សហជាតវសេន សហជាតានំ នាមរូបានន្តិ ចទុវិធោ ហោតិ អធិបតិប្បច្ចយោ ។ បណ្តាបច្ច័យទាំង ៩ នោះ អធិប្បច្ច័យមាន ២ គឺ :

អារម្មណ៍ដែលធ្វើឱ្យពេញចិត្តជាពិសេស ជាបច្ច័យដល់នាមរូប ដែលកើតព្រមគ្នាដោយអំណាច អារម្មណាធិបតិប្បច្ច័យ ។

អង្គអធិបតីទាំង ៤ មានឆន្ទៈ ជាដើមកើតព្រមគ្នាជាបច្ច័យដល់ នាមរូប ដែលកើតព្រមគ្នា ដោយអំណាច សហជាតាធិបតិប្បច្ច័យ ។

១៥.ចិត្តចេតសិកា ធម្មា អញ្ញមញ្ញំ សហជាតរូបានញ្ច មហាភូតា អញ្ញមញ្ញំ ឧបាទារូបានញ្ច បដិសន្ធិខណេ វត្ថុវិបាកា អញ្ញមញ្ញន្តិ ច តិវិធោ ហោតិ សហជាតប្បច្ចយោ ។

# សហជាតប្បច្ច័យ ៣ យ៉ាង

ចិត្ត និងចេតសិកជាបច្ច័យដល់គ្នា និងគ្នា នឹងជួយឧបការដល់រូបដែលកើតព្រមគ្នានោះ ។

មហាភូតរូបទាំង ៤ ជាបច្ច័យដល់គ្នា និងគ្នា នឹងជួយឧបការដល់ឧបាទាយរូប ។

ក្នុងបដិសន្ធិខណៈ ហទយវត្ថុ និងវិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នា និងគ្នា ។

**១៦.ចិត្តចេតសិកា ធម្មា អញ្ញមញ្ញំ មហាភូតា អញ្ញមញ្ញំ បដិសន្ធិខណេ វត្ថុវិបាកា អញ្ញមញ្ញន្តិ ច តិវិធោ ហោតិ អញ្ញមញ្ញបច្ចយោ ។** អញ្ញមញ្ញប្បច្ច័យមាន ៣ យ៉ាងគឺ :

ចិត្ត និងចេតសិក ជាបច្ច័យដល់គ្នា និងគ្នា តែម្យ៉ាង ។

មហាភូតរូបទាំង ៤ ជាបច្ច័យដល់គ្នា និងគ្នាតែម្យ៉ាង ។

ក្នុងខណៈបដិសន្ធិ ហទយវត្ថុ និងវិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នា និងគ្នា ។

**១៧.ចិត្តចេតសិកា ធម្មា អញ្ញមញ្ញំ សហជាតរូបានញ្ច មហាភូតា អញ្ញមញ្ញំ ឧបាទារូបានញ្ច, ឆវត្ថូនិ សត្តន្នំ វិញ្ញាណធា-តូនន្តិ ច តិវិធោ ហោតិ និស្សយបច្ចយោ ។**

## និស្សយមាន ៣ យ៉ាង

ចិត្ត និងចេតសិក ជាបច្ច័យដល់គ្នា និងគ្នា និងជួយឧបការដល់រូបដែលកើតព្រមគ្នានោះ ។

មហាភូតរូបទាំង ៤ ជាបច្ច័យដល់គ្នា និងគ្នា និងជួយឧបការដល់ឧបាទាយរូប តែម្យ៉ាង ។

វត្ថុរូប ៦ ជាបច្ច័យដល់វិញ្ញាណធាតុទាំង ៧ ។

**១៨.កវលិង្ការោ អាហារោ ឥមស្ស កាយស្ស អរូបិនោ អាហារា សហជាតានំ នាមរូបានន្តិ ច ទុវិធោ ហោតិ អាហារោ។**

## អាហារប្បច្ច័យមាន ២ យ៉ាង គឺៈ

អាហារជាបច្ច័យជួយឧបការដល់រាងកាយ ។

នាមអាហារទាំង ៣ មានផស្សៈ ជាដើម ជាបច្ច័យដល់នាមរូប ដែលកើតព្រមគ្នា ។

**១៩.បញ្ចបសាទា បញ្ចន្នំ វិញ្ញាណានំ រូបជីវិតិន្ទ្រិយំ ឧបាទិន្នរូបានំ អរូបិនោ ឥន្ទ្រិយា នាមរូបានន្តិ ច តិវិធោ ហោតិ ឥន្ទ្រិយប្បច្ចយោ ។**

## ឥន្ទ្រិយប្បច្ច័យ ៣ យ៉ាង

បសាទរូប ៥ ជាបច្ច័យដល់បញ្ចវិញ្ញាណ ។

រូបជីវិតិន្ទ្រិយ៍ ជាបច្ច័យដល់ ឧបាទិន្នករូប ។

នាមឥន្ទ្រិយ៍ ទាំង៨ ជាបច្ច័យដល់នាមរូប ដែលកើតព្រមគ្នា។

២០.ឱក្កន្តិក្ខណេ វត្ថុ វិបាកានំ ចិត្តចេតសិកា ធម្មា សហជាតរូបានំ សហជាតវសេន, បច្ឆាជាតា ចិត្តចេតសិកា ធម្មា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតវសេន, ន វត្ថុនិ បវត្តិយំ សត្តន្នំ វិញ្ញាណធាតូនំ បុរេជាតវសេនេតិ ច តិវិធោ ហោតិ វិប្បយុត្តប្បច្ចយោ ។

## វិប្បយុត្តប្បច្ច័យ ៣ យ៉ាង

ក្នុងបដិសន្ធិខណៈ ហទយវត្ថុជាបច្ច័យដល់វិបាកនាមក្ខន្ធ៤ និងចេតសិក ដែលជួយឧបការជួយដល់រូបដែលកើតព្រមគ្នា ដោយវិប្បយុត្តប្បច្ច័យ ។

ចិត្ត និងចេតសិក ដែលកើតខាងក្រោយជាបច្ច័យដល់ រូបដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

ក្នុងបវត្តិកាល វត្ថុ៦ ជាបច្ច័យដល់វិញ្ញាណធាតុ៧ ដោយបុរេជាតវិប្បយុត្តប្បច្ច័យ បានដល់ វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ និងវត្ថារម្មណវិប្បយុត្តប្បច្ច័យ ។

**២១.សហជាតានំ បុរេជាតំ បច្ឆាជាតញ្ច សព្វថា កពឡីការោ អាហារោ រូបជីវិតមិច្ចយន្តិ បញ្ចវិធោ ហោតិ អត្ថិប្បច្ចយោ អវិគតប្បច្ចយោ ។**

## អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ៥ យ៉ាង

ជាសហជាតជាតិ ១ ជាបុរេជាតជាតិ ១ ជាបច្ឆាជាតជាតិ ១ ជាកវឡិង្ការាហា ១ ជារូបជីវិតិន្ទ្រិយ ១ ។

**២២.អារម្មណូបនិស្សយកម្មត្ថិបច្ចយេសុ ច សព្វេបិបច្ចយា សមោធានំ គច្ឆន្តិ ។**

កាលបើសម្តែងបច្ច័យដោយសង្ខេបហើយ បច្ច័យទាំងអស់នេះរួបរួមក្នុងអារម្មណប្បច្ច័យ ឧបនិស្សយប្បច្ច័យ កម្មប្បច្ច័យ អត្ថិប្បច្ច័យទាំងអស់ ។

**២៣. សហជាតរូបន្តិ បគេន្ទេថ សព្វទា បវត្តេ ចិត្តសមុដ្ឋានំ បដិសន្ធិយំ កដត្តា រូបានញ្ច វសេន ទុវិធំ ហោតីតិ វេទិតព្វំ ។**

ក្នុងបដ្ឋានន័យនេះ ដែលជាសហជាតរូប ក្នុងសហជាតជាតិទូទៅបានទាំងអស់ បែងចែកជាពីរយ៉ាង ដោយប្រភេទនៃចិត្តជ្ជ-រូបក្នុងបវត្តិកាល និងកម្មជ្ជរូបដែលកើតក្នុងបដិសន្ធិកាល អ្នកសិក្សាគប្បីជ្រាបដូចនេះ ។

## បច្ឆិមគាថា ក្នុងបដ្ឋានន័យ

**២៤. ឥតិ កាលិកា ធម្មា កាលមុត្តា ច សម្ភវា**

**អជ្ឈត្តញ្ច បហិទា ច សង្ខតា សង្ខតា តថា ។**

**បញ្ញត្តិនាមរូបានំ វសេន តិវិធា ឋិតា**

**បច្ចយា នាម បដានេ ចតុវីសតិ សព្វថា ។**

ធម៌ទាំងឡាយកើតក្នុងកាលទាំង ៣ ដែលជាកាលវិមុត្តិ ដែលកើតខាងក្នុង និងខាងក្រៅ ដែលជាសង្ខតៈ និងអសង្ខតៈ ឬប្រភេទទាំង ៣ នៃបញ្ញត្តិនាមរូប ទាំងនេះឈ្មោះថា បច្ច័យ ២៤ ក្នុងបដ្ឋានករណី ដោយប្រការទាំងពួងតាមសមគួរ ។

( ចប់បដ្ឋានន័យ )

ចប់